ទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ខៀវ សំផន និងមេដឹកនាំខ្មែរក្រហម[illegible]
- ខៀវ [illegible]

លេខ៩ ខែកញ្ញា ឆ្នាំ២០០០

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២១ ខែកញ្ញា ឆ្នាំ២០០១


## មាតិកា


- សំបុត្រៈ អៀង សារី និងចលនាខ្មែរក្រហមសម័យថ្មី ................១

**ផ្នែកឯកសារ**

- ខៀវ សំផនៈ សំបុត្រចំហជូនបងប្អូនរួមជាតិទាំងអស់ ..................៣
- អង្គប្រជុំសន្និបាតលើកទី១ .....................................................៧
- ទូរលេខជូនមន្ទីរ៨១ ...............................................................១១
- កាលប្បវត្តិរបស់ហាណូយ .......................................................១៣
- ហួត សម្បត្តិ............................................................................ ១៦
- ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍.......................... ១៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

- សម្មេងពីមន្ទីរស-២១ .................................................. ២១
- កុមារស្លាតស្លំ បដិវត្តន៍បរាជ័យ........................................ ២៥
- ជុំវិញការលាលែងរបស់សម្ដេច សីហនុ..............................២៧

**ផ្នែកច្បាប់**

- តម្លៃនៃភស្តុតាង........................................................ ៣០
- តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍................................ ៣៤
- សុពលភាពច្បាប់............................................................ ៣៨

**វេទិកាពិភាក្សាសាធារណៈ**

- ជនកុម្មុយនិស្ត ខ្មែរក្រហម និង វៀតណាម........................ ៤០
- ការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជា................................៤៥
- អង្គការសហប្រជាជាតិខ្វះឆន្ទៈ...........................................៥២

**ទំព័រស្វែងរកគ្រួសារ**

- ខែបុណ្យភ្ជុំ ខ្ញុំយំក្នុងគុក...................................................៥៥
- បុណ្យភ្ជុំៈ សូមឧទ្ទិសដល់វិញ្ញាណក្ខន្ធ................................ ៥៩

**សិល្បៈខ្មែរក្រហម**

- រូបថតគ្រួសារកម្មាភិបាលខ្មែរក្រហម...........................គ្របក្រោយ




អៀង សារី

# រក្សាសិទ្ធិ


មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះ** គីម កែវ កន្និដ្ឋា, ហ៊ុយ វណ្ណៈ, វ៉ាន់ថាន់ ពៅដារ៉ា, សេង ធារី, ដេវីត ឆេនដល័រ, ចន ឆរឆីអារី, មិច្រី មូសយ៉ាកូវ, ភីតធ័រ ម៉ាឃៀរ, ថូម៉ាស់ ហាម៉ាប៊ឺក **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ដួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុខឃឹម **និពន្ធនាយករងទី១ៈ** ដាត កុសល **និពន្ធនាយករងទី២ៈ** ស៊ីម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្តិ

*សំបុត្រ:*

# អៀង សារី និងចលនាខ្មែរក្រហមសម័យថ្មី

អតីតយោធាខ្មែរក្រហមទាំងអស់ចាំបាច់ត្រូវតែទទួលការអប់រំអំពីច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនិងដំណើរការនៃតុលាការចម្រុះដែលនឹងបង្កើតឡើងក្នុងពេលខាងមុខ ។ ទន្ទឹមនឹងពេលនេះដែរ អតីតយោធាខ្មែរក្រហមទាំងអស់ពិតជាមានសិទ្ធិបញ្ចេញមតិជុំវិញបញ្ហាបង្កើតតុលាការ រួមទាំងជំហរការពារមេដឹកនាំរបស់ខ្លួនដូចជា អៀង សារី ជាដើម ។ ខ្ញុំចង់ប្រាប់អតីតយោធាខ្មែរក្រហមទាំងនោះថា ឥឡូវនេះប្រជាជនគ្រប់រូបមានសិទ្ធិសេរីភាពបញ្ចេញមតិរបស់ខ្លួន "ដោយឯករាជ្យម្ចាស់ការ" មិនដូចពីជំនាន់ខ្មែរក្រហមទេ ។

អគ្គលេខានៃចលនា(ខ្មែរក្រហម)បង្រួបបង្រួមជាតិប្រជាធិបតេយ្យ ឡុង ណូរិន មិនយល់សោះឡើយនូវអ្វីទៅដែលហៅថាសន្តិភាព ។ ចំពោះ ឡុង ណូរិន និងខ្មែរក្រហមក្បាលរឹងដទៃទៀត សន្តិភាពគឺមានន័យថាមិនសម្លាប់ខ្មាំងអង្គការទៀតទេ ។ យើងទាំងអស់គ្នាដែលជាជនរងគ្រោះសេសសល់ពីសេចក្តីស្លាប់ ហើយដែលខ្មែរក្រហមធ្លាប់បានចាត់ទុកថាជាខ្មាំងរបស់អង្គការនោះ ពុំដែលធ្លាប់បានចាត់ទុកនរណាម្នាក់ជាខ្មាំងរបស់យើងទេ ។ យើងមិនដែលចាត់ទុកអតីតយោធាខ្មែរក្រហមជាសត្រូវរបស់យើងឡើយ ។ ចំពោះមេដឹកនាំខ្មែរក្រហមក៏យើងគិតយ៉ាងដូច្នេះដែរ ។ ខ្មែរក្រហមបាននិងកំពុងរស់នៅជាមួយយើងទាំងអស់គ្នាអស់រយៈពេលជាង៣០ឆ្នាំមកហើយ ។ យើងបានអត់ឱនឲ្យខ្មែរក្រហម ។ យើងបានផ្តល់សិទ្ធិសេរីភាពគ្រប់យ៉ាងឲ្យខ្មែរក្រហម ហើយថែមទាំងគ្មានគំនិតចង់សងសឹកឬប្រហារជីវិតអ្នកទាំងនោះទេ ។ យើងទុកឲ្យច្បាប់ជាអ្នកធ្វើការវិនិច្ឆ័យទៅលើអំពើដែលខ្មែរក្រហមបានប្រព្រឹត្តមកលើយើងគ្រប់ៗគ្នា ។ តុលាការដែលនឹងត្រូវបង្កើតក្នុងពេលខាងមុខនេះ ក៏មិនមានទោសប្រហារជីវិតដែរសម្រាប់មេដឹកនាំខ្មែរក្រហមដែលនឹងត្រូវជាប់ពិរុទ្ធ ។

ចលនា(ខ្មែរក្រហម)បង្រួបបង្រួមជាតិប្រជាធិបតេយ្យគឺជាចលនាខ្មែរក្រហមសម័យថ្មីដែលត្រូវបានគ្រប់គ្រងយ៉ាងណែននៅក្នុងដៃរបស់ អៀង សារី ។ អៀង សារី បានដឹកនាំកម្លាំងយោធាខ្មែរក្រហមប្រមាណ៣០០០នាក់ចេញពីព្រៃគឺមិនមែនដើម្បីចូលមករួមរស់ជាមួយរាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជាដោយសុទ្ធចិត្តនោះទេ ប៉ុន្តែគឺដើម្បីរក្សាអំណាចរបស់ខ្លួនក្នុងនាមជាមេដឹកនាំខ្មែរក្រហមម្នាក់ ។ ទោះបីជាការចុះចូលបាននាំទៅដល់ការបញ្ចប់សង្គ្រាមស៊ីវិលជាផ្លូវការនៅក្នុងឆ្នាំ១៩៩៨ ហើយប្រហែលជានាំដល់ទីបញ្ចប់នៃកម្លាំងប្រដាប់អាវុធខ្មែរក្រហមយ៉ាងណាក៏ដោយ ក៏ធាតុពិតចលនា(ខ្មែរក្រហម) បង្រួបបង្រួមជាតិប្រជាធិបតេយ្យនៅតែបន្តរិះរកតួនាទីសម្រាប់មេដឹកនាំខ្មែរក្រហមនៅក្នុងអនាគតនៃសង្គមកម្ពុជា ។

អៀង សារី ដឹងថាខ្លួនពិតជាមិនអាចចៀសផុតអំពីការកាត់ទោសចំពោះការទទួលខុសត្រូវលើជីវិតមនុស្សជាងមួយលាននាក់ដែលបានស្លាប់បាត់បង់ជីវិត ។ អៀង សារី ក៏បានដឹងទៀតថា នៅក្នុងក្រសែភ្នែកប្រជាជនកម្ពុជាជាច្រើន ការលើកលែងទោសដែលប្រទានដោយព្រះមហាក្សត្រនឹងមិនអាចការពារខ្លួនឲ្យរួចពីការជម្រះទោសដោយតុលាការដែលនឹងមានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិឡើយ ។ ប៉ុន្តែ អៀង សារី នៅតែបន្តធ្វើផ្គរធ្វើភ្លៀងក្នុងចំណោម

អតីតយោធាខ្មែរក្រហមស្លូតត្រង់ ហើយលើសពីនេះទៀត ថែមទាំងបានរារាំងដោយប្រយោលមិនឲ្យធ្វើសមាហរណកម្មសាជាថ្មីនូវអតីតយោធាខ្មែរក្រហមទៅក្នុងសង្គមជាតិទៀតផង ។ កម្ពុជានឹងធ្វើការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហមទាំងអស់ ។ ការធ្វើយ៉ាងដូច្នេះ កម្ពុជានឹងថ្វាយកិត្តិយសដ៏ខ្ពង់ខ្ពស់ដល់ព្រះរាជបំណងរបស់ព្រះមហាក្សត្រ ។ ព្រះអង្គបានឡាយព្រះហស្តលេខាលើច្បាប់រៀបចំការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលរួមមានទាំង អៀង សារី ។ ច្បាប់នេះមិនបានចែងថាបុគ្គលដែលត្រូវបានលើកលែងទោសពីមុននឹងត្រូវរួចខ្លួន ។ អង្គការសហប្រជាជាតិបានបញ្ជាក់ច្បាស់ៗថាការលើកលែងទោសពីមុនគឺមិនអាចទទួលយកបានឡើយ ។ ប្រសិនបើការលើកលែងទោសចំពោះ អៀង សារី មានសុពលភាព អង្គការសហប្រជាជាតិនឹងមិនចូលរួមសហការទេ ។ អៀង សារី ពិតជាដឹងនូវបញ្ហានេះ ហើយចលនា (ខ្មែរក្រហម) បង្រួបបង្រួមជាតិប្រជាធិបតេយ្យក៏ដឹងរឿងនេះ ។

សួង ស៊ីគឿន អ្នកនាំពាក្យចលនា(ខ្មែរក្រហម) បង្រួបបង្រួមជាតិប្រជាធិបតេយ្យ គឺជាអ្នកគាំទ្រចលនាខ្មែរក្រហមអស់ពេញមួយជីវិត ហើយថែមទាំងបានអះអាងលើការចូលរួមដោយខ្លួនឯងផ្ទាល់ទៀតផង ។ ដូចនេះ សួង ស៊ីគឿន ពិតជាបានរួមសមគំនិតមួយចំណែកនៅក្នុងបដិវត្តន៍ខ្មែរក្រហម ។ សួង ស៊ីគឿន គួរតែដឹងថា យោងតាមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ "ការសមគំនិត" ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ចូលក្នុងធាតុផ្សំនៃបទឧក្រិដ្ឋមួយ (សូមអានមាត្រាទី៤នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ) ។ ជាការច្បាស់ណាស់ថា អៀង សារី មិនត្រឹមតែមានការទទួលខុសត្រូវផ្នែកសីលធម៌តែប៉ុណ្ណោះទេ ប៉ុន្តែ អៀង សារី ត្រូវតែរៀបចំខ្លួនមកបង្ហាញមុខចំពោះតុលាការថែមទៀតដើម្បីកាត់សេចក្តីលើការទទួលខុសត្រូវចំពោះការស្លាប់បាត់បង់ជីវិតរបស់ប្រជាជនកម្ពុជាជាងមួយលាននាក់ ។ ការចចេសក្រាញនទៀលមិនព្រមចូលខ្លួនមកឲ្យតុលាការកម្ពុជាធ្វើការវិនិច្ឆ័យទោស មានន័យថា មានចេតនាធ្វើឲ្យសង្គមកម្ពុជារង្គោះរង្គើគ្មានស្ថិរភាព ។

**ឆាំង យុ**



**ឡៀន ធី ឡឺយ: ម្តាយ អៀង សារី**

អតីតគណៈទាក់ទងវៀតណាមបានឲ្យដឹងថា ឡៀន ធី ឡឺយ គឺជាម្តាយរបស់ អៀង សារី ។ នៅក្នុងឆ្នាំ១៩៧៥ អៀង សារី បានសុំឲ្យគណៈទាក់ទងវៀតណាមចុះទៅសួរសុខទុក្ខម្តាយរបស់ខ្លួននៅភូមិក្រឡាក់ ឃុំសាងហ៊្វា ស្រុកថូវថាន់ ខេត្តត្រាវិញ ។ រូបថតភ្ជាប់មកជាមួយនេះ (ឡៀន ធី ឡឺយ) ត្រូវបានថតទុកសម្រាប់ប្រគល់ឲ្យ អៀង សារី ។ ប៉ុន្តែសភាពការណ៍នយោបាយនៅពេលនោះមានការប្រែប្រួលហើយ ទំនាក់ទំនងរវាងខ្មែរក្រហមនិងវៀតណាមត្រូវបានកាត់ផ្តាច់ ។ រូបថតនេះត្រូវបានកប់ទុកនៅប្រទេសវៀតណាមរហូតដល់ត្រូវបានក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្រាវជ្រាវរកឃើញ ។ ខ្ញុំសូមផ្ញើរូបថតនេះតាមរយៈទស្សនាវដ្តីស្វែងរកការពិត ជូនដល់ អៀង សារី និងក្រុមគ្រួសារក្នុងឱកាសបុណ្យភ្ជុំឆ្នាំ២០០១នេះ ។ **ឆាំង យុ**

(ចម្លងចេញពីសំណៅដើមទាំងស្រុង) ប៉ៃលិន ថ្ងៃទី១៦ សីហា ឆ្នាំ២០០១

# សំបុត្រចំហជូនបងប្អូនរួមជាតិទាំងអស់


ខៀវ សំផន

ក្នុងរយៈជាង២ឆ្នាំកន្លងមកនេះ បងប្អូនរួមជាតិយើងជាច្រើនបានមកសម្តែងសមាណចិត្តចំពោះខ្ញុំ ។

បងប្អូនបានជ្រាបហើយថា ជាធម្មជាតិរបស់ខ្ញុំ ខ្ញុំមិនអាចទៅនឹកគិតប្រព្រឹត្តអំពើវៀចវេរអ្វីសោះឡើយ កុំថាឡើយដល់ទៅប្រព្រឹត្តឧក្រិតកម្មនោះ ។ បងប្អូនក៏បានជ្រាបដែរថា នៅក្នុងរបប"កម្ពុជាប្រជាធិបតេយ្យ" ខ្ញុំគ្មានសិទ្ធិអំណាចអ្វីទាំងអស់ដើម្បីបញ្ជាអោយអ្នកណាទៅសម្លាប់អ្នកណា ឬចាប់ចងអ្នកណាសូម្បីតែម្នាក់ក៏គ្មានទេ ។ មានតែបញ្ហាមួយទេដែលបងប្អូនរួមជាតិយើងខ្លះនៅមានការងឿងឆ្ងល់ គឺហេតុអ្វីបានជាមនុស្សស្លូតត្រង់ដូចជារូបខ្ញុំនេះសុខចិត្តទទួលនាទីដែលមានតែឈ្មោះថាជា"ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ" ។ ប៉ុន្តែខ្ញុំខិតខំចៀសវាងនូវអ្វីៗទាំងអស់ដែលអាចជាការឆ្កឹះដំបៅចាស់ ហើយខ្ញុំជៀសវាងមិននិយាយពន្យល់អ្វីវែងឆ្ងាយឡើយចំពោះការងឿងឆ្ងល់របស់បងប្អូននេះ ។ នៅពេលនេះ សង្គ្រាមដែលបានហែកហួរប្រទេសយើងរាប់ទសវត្សមកហើយនោះបានរលត់ទៅវិញហើយ ។ ខ្ញុំមិនឃើញមានផលប្រយោជន៍អ្វីនឹងនិយាយពីរឿងចាស់ឡើងវិញនោះទេ ។ ទុកអោយចិត្តថ្មើមរបស់ម្នាក់ៗស្ងប់ទៅវិញ ដើម្បីទាំងអស់គ្នាចេះតែព្យាយាមខិតខំធ្វើការងារដូចដែលបានធ្វើមកហើយ ក្រោមការឧបត្ថម្ភនៃសហគមអន្តរជាតិ ជំរុញអោយគោលការណ៍ជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ ជំនះបានលើឧបសគ្គផ្សេងៗជាជំហាន ជាជំហានតទៅទៀតនេះប្រហែលប្រសើរជាង ដើម្បីអោយប្រទេសយើងផ្សះមុខរបួសរបស់ខ្លួន ហើយប្រឈមមុខដោះស្រាយបញ្ហាធ្ងន់ធ្ងរជាច្រើនដែលសុទ្ធសឹងជាបញ្ហាទាក់ទងដល់អាយុជីវិតជាតិយើងដែលជាប្រទេសតូចហើយធ្លាក់ចុះកាន់តែក្រ...ដោយសារតែសង្គ្រាមមិនចេះចប់នោះ ។ គឺអាស្រ័យហេតុផលដូចបានជំរាបមកខាងលើនេះផងដែរដែលខ្ញុំជៀសវាងមិនធ្វើសេចក្តីបដិសេធឬសេចក្តីកែតម្រូវអ្វីទាំងអស់ចំពោះអត្ថបទកាសែតដែលនិយាយមិនត្រឹមត្រូវពីខ្ញុំ ។ ប៉ុន្តែពេលនេះដែលកំពង់មានការរៀបចំចាត់តាំងតុលាការពិសេសមួយដើម្បីកាត់ទោសមេខ្មែរក្រហមពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ខ្ញុំពុំអាចទុកអោយនៅមានការស្រពិចស្រពិលឬការភ័ណ្ឌច្រឡំលើរូបខ្ញុំតទៅទៀតបានឡើយ ។ ហេតុដូច្នេះហើយបានជាខ្ញុំត្រូវបង្ខំចិត្តធ្វើសេចក្តីបញ្ជាក់អំពីគោលជំហរនិងសកម្មភាពនយោបាយរបស់ខ្ញុំជាបន្តបន្ទាប់ដូចតទៅ÷

១-តើកាសែត ឡុបសេវ៉ាទ័រ...មានទិសដៅអ្វី?

កាសែតនេះខិតខំផ្ទុះបញ្ចាំងនូវមតិរបស់បញ្ញាជន គ្រូបង្រៀន និងអ្នករាជការមួយចំនួនធំ ដែលគេគាំទ្រពេញទំហឹងនយោបាយអព្យាក្រិតរបស់សម្តេចព្រះ នរោត្តម សីហនុ តែព្រមជាមួយនេះក៏គេយល់ឃើញថា ចាំបាច់មានវិធានការប្រជាធិបតេយ្យមួយចំនួនសំដៅអោយមានតុល្យភាពសង្គម ដើម្បីពង្រឹកមូលដ្ឋាននយោបាយអព្យាក្រិត ។

២-ក្នុងឋានៈខ្ញុំជារដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មក្តី ជាតំណាងរាស្ត្រក្តី ក៏ខ្ញុំបានខិតខំបំពេញភារៈកិច្ចរបស់ខ្ញុំដោយអស់ពីចិត្តពីថ្លើមក្នុងស្មារតីដូចគ្នានេះដែរគឺរួមចំណែកឧបត្ថម្ភនយោបាយអព្យាក្រិត្យរបស់សម្តេចព្រះ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ ។

៣-ឯការដែលខ្ញុំរត់គេចខ្លួនចេញពីភ្នំពេញកាលពីឆ្នាំ១៩៦៧គឺមកពីខ្ញុំត្រូវបង្ខំចិត្ត ។ មិនមែនមកពីខ្ញុំសំរេចចិត្តបោះបង់ចោលសកម្មភាពរបស់ខ្ញុំនៅក្នុងក្របខ័ណ្ឌសភាទៅជ្រើសរើសផ្លូវតស៊ូបដិវត្តនោះទេ ។

រឿងរ៉ាវចាប់ផ្តើមនៅពេលដែលមានការបះបោរមួយរបស់កសិករនៅសំឡូតក្នុងខេត្តបាត់ដំបង ។ ឥឡូវនេះអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រកម្ពុជាជាច្រើនបានទទួលស្គាល់ថាការបះបោរនេះកើតមានឡើងដោយកសិករខ្លួនឯង ដោយមកពីរដ្ឋអំណាចកន្លែងនោះបានរឹបអូសយកដីធ្លីរបស់បងប្អូនយ៉ាងកំរោល ។ តែការបះបោរនេះបានត្រូវបង្ក្រាបក្នុងថ្លុកឈាមយ៉ាងកំរោលព្រៃផ្សៃ ពុំដែលមានដូច្នេះទេពីមុនមក ។

បញ្ញាជនដែលគេហៅថា “ខាងឆ្វេង” ដែលក្នុងនោះមានរូបខ្ញុំផងដែរ ក៏ត្រូវចោទថាជាអ្នកបំបះបំបោរ ហើយត្រូវឡើងទៅតុលាការសឹក ។ ជាការពិតហើយ មិនមែនទើបតែលើកនេះទេដែលមានការគំរាមកំហែងបែបនេះ ។ ប៉ុន្តែលើកនេះ ក្រោយពីសភា“ស្តាំ”មួយបានចេញមកពីការបោះឆ្នោតឆ្នាំ១៩៦៦ ហើយក្រោយពីសភានេះចាត់តាំង លន់ ណុល អោយឡើងកាន់កាប់រដ្ឋាភិបាលមក ការចោទប្រកាន់និងការគំរាមកំហែងទាំងអស់មិនអាចមើលស្រាលបានឡើយ ។

ខ្ញុំសូមគូសបញ្ជាក់ថា ចាប់ពីខ្ញុំរត់ចេញពីភ្នំពេញមក តួនាទីសកម្មរបស់ខ្ញុំលើឆាកនយោបាយក៏ត្រូវចប់តាំងពីពេលនោះមកដែរ ។ នៅជនបទ (កំពង់ស្ពឺ) ខ្ញុំអត់មានធ្វើអ្វីក្រៅពីលាក់ខ្លួនពួនអាត្មានៅក្នុងខ្ទមប្រជាជនឬនៅក្នុងគ្រង់ស្រូវនោះទេ ។ អស់រយៈពេលពីរឆ្នាំខ្ញុំអត់ហ៊ានបង្ហាញមុខចេញក្រៅទេ ពីព្រោះខ្លាចក្រែងមេឃុំ ឬជំទប ឬភ្នាក់ងារសំងាត់របស់ប៉ូលិសទាហានឃើញនិងនាំអោយមានការរាតត្បាតទៅលើប្រជាជនទូទាំងភូមិ ។ ខ្ញុំឥតបានធ្វើសកម្មភាពចាត់តាំងកម្លាំងរបស់បក្សកុម្មុយនីស្តឬចាត់តាំងកម្លាំងមហាជនចាត់តាំងកងទ័ពអ្វីទេ ។ កម្លាំងទាំងអស់នោះជាកម្លាំងដែលបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ចាត់ទុកជាកម្លាំងយុទ្ធសាស្ត្រ ។ ខ្ញុំគ្មានសិទ្ធិអ្វីចូលលាយឡំក្នុងការងារនេះទេ ។ ខ្ញុំក៏មិនបានដឹងថាមានធ្វើសន្និបាទចាត់តាំង ប.ក.ក នៅភ្នំពេញកាលពីឆ្នាំ១៩៦០នោះផងទេ ។ សូមជំរាបថាអ្នកដឹកនាំបក្សកម្ពុជាពេលនោះនៅឯរតនៈគិរី ។ ដូច្នេះពេលនោះខ្ញុំអត់បានដឹងផងទេថាអ្នកណាខ្លះជាអ្នកដឹកនាំ ប.ក.ក កុំថាឡើយដល់ទៅបានជួបមុខឬប្រជុំការងារអ្វីនោះ ។

៤-ក្រោយមកក៏មានរដ្ឋប្រហារឆ្នាំ១៩៧០ ។ ភ្លើងសង្គ្រាមវៀតណាមក៏បានឆាបឆេះយ៉ាងសន្ធោរសន្ធៅមកដល់ប្រទេសយើងភ្លាម ។ នយោបាយអព្យាក្រិត្យរបស់សម្តេចព្រះ នរោត្តម សីហនុ បញ្ចៀសអណ្តាតភ្លើងសង្គ្រាមនេះបាន១៥ឆ្នាំ ។ ដូច្នេះបានសង្គ្រោះអាយុជីវិតប្រជាជនយើងមិនតិចទេ ។ ប៉ុន្តែទោះបីព្រះអង្គខិតខំយ៉ាងណាក៏ដោយ ក៏បានត្រឹមតែពន្យាពេលគ្រោះមហន្តរាយតែប៉ុណ្ណោះ ។ ព្យុះសង្ឃរានៃសង្គ្រាមត្រជាក់និងសង្គ្រាមវៀតណាមវាខ្លាំងហួសពីកម្លាំងរបស់ព្រះអង្គនិងរបស់ជាតិយើងទាំងមូល ។ ពេលនោះមហាយក្សធំៗជាគូរសត្រូវនឹងគ្នាក្នុងសង្គ្រាមវៀតណាម ក៏ចូលមកច្បាំងគ្នានៅលើទឹកដីដ៏តូចនៃប្រទេសយើងតែម្តងគ្មានអ្នកណាទប់បានទេ ។ តើប្រទេសដ៏កំសត់របស់យើងដែលត្រូវញាំញីហែកហួយ៉ាងនេះអាចរស់គង់វង់បានទេ? នេះជាបញ្ហាដែលចោទយ៉ាងធាន់ហន់បំផុត ។ ចំពោះមុខសភាពការណ៍ប្រកបដោយគ្រោះអាសន្នយ៉ាងនេះ ខ្មែរៗស្ទើរតែទាំងអស់ ទាំងជនបទ ទាំងទីក្រុង ទាំងបញ្ញាជន ឥស្សរៈជនទាំងនិស្សិតនៅក្រៅប្រទេស បានខបត្តម្ភកម្លាំងជាតិទាំងអស់អោយរួបរួមគ្នាធ្វើការតស៊ូសង្គ្រោះជាតិ ។

ពេលនោះកម្លាំងដែលដើរតួសំខាន់មាន២គឺ÷

ទី១ បក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ដែលមានកម្លាំងអាចប្រយុទ្ធបាននៅនឹងកន្លែង ។

ទី២ សម្តេចព្រះ នរោត្តម សីហនុ ដែលមានឥទ្ធិពលទាំងនៅក្នុងប្រទេសទាំងនៅលើឆាកអន្តរជាតិ ។

កម្លាំងទាំងពីរនេះមានតែកម្លាំងណាមួយអត់កម្លាំងណាមួយមិនបានទេ ។

ប៉ុន្តែតើធ្វើយ៉ាងណាអោយកម្លាំងទាំងពីរនេះអាចរួបរួមគ្នាបាន? តើសម្តេចព្រះ នរោត្តម សីហនុ អាចរួបរួមជាមួយអ្នកដឹកនាំ ប.ក.ក បានទេ? ។ ច្បាស់ជាមិនបានទេ ។ ត្រង់នេះហើយដែលត្រូវការរូបខ្ញុំដើរតួជាស្ពាន ។ ឋានៈសង្គមរបស់ខ្ញុំនិងការដែលខ្ញុំធ្លាប់ទាក់ទងជាមួយឥស្សរៈជននយោបាយជាន់ខ្ពស់នៅក្នុងប្រទេស ចង្អុលអោយខ្ញុំដើរតួនាទីនេះ ។ ប៉ុន្តែដើម្បីខ្ញុំដើរតួនាទីជាស្ពានបាន លុះត្រាតែខ្ញុំចេញមុខជាអ្នកដឹកនាំមួយសំខាន់នៃកម្លាំងតស៊ូនៅក្នុងប្រទេសតែម្តង ។ ការពិតជាក់ស្តែង ខ្ញុំមិនមានតួនាទីជាអ្នកដឹកនាំអ្វីទាំងអស់ ។ នេះហើយដែលធ្វើអោយខ្ញុំមានការទើសទាល់ខ្លាំងណាស់ ។ តែសភាពការណ៍តម្រូវអោយកាត់ខ្មាស់កាត់អៀន សុខចិត្តធ្វើការ“លះបង់” ហើយបំពេញភារៈកិច្ចនេះដើម្បីរួមចំណែកក្នុងការតស៊ូសង្គ្រោះជាតិតាមសមត្ថភាពនិងសភាពការណ៍ជាក់ស្តែងរបស់ខ្ញុំ ។ បងប្អូនរួមជាតិបានឃើញហើយ តើកាលៈទេសៈយ៉ាងណាដែលនាំអោយខ្ញុំមានតួនាទីជានិមិត្តរូបនៃការតស៊ូនៅក្នុងប្រទេស ។ គឺក្រោយពីរដ្ឋប្រហារឆ្នាំ១៩៧០ ក្រោយពីមហាយក្សធំៗដែលជាគូរទំនាស់ក្នុងសង្គ្រាមវៀតណាមបានចូលមកច្បាំងគ្នាលើទឹកដីដ៏តូចមួយនៃប្រទេសយើង ។ ខ្ញុំសុំរំលឹកកាលៈទេសៈនេះដើម្បីជាភស្តុតាងបញ្ជាក់ថា “ខ្ញុំមិនមានចេតនាអ្វីទៅឃុបឃិតសមគំនិតជាមួយនិងអំពើកាប់សម្លាប់ដែលនិងកើតមាននៅឆ្នាំ

១៩៧៥-១៩៧៨ ដោយខ្ញុំពុំបានដឹងទាល់តែសោះផងនោះទេ ។"

ម្យ៉ាងទៀត កាលបើខ្ញុំមានឈ្មោះជាមេដឹកនាំការតស៊ូនៅក្នុងប្រទេសយ៉ាងនេះហើយ ទោះបីសង្គ្រាមបានចប់នៅឆ្នាំ១៩៧៥ក៏ដោយ ក៏ខ្ញុំពុំអាចលប់ឈ្មោះនេះវិញបានឡើយ ។ ផ្ទុយទៅវិញ ឈ្មោះជា"មេដឹកនាំ"ការតស៊ូនៅក្នុងប្រទេសនេះតម្រូវអោយខ្ញុំបន្តទទួលតួនាទីជា "ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ"បន្តទៅទៀត ទោះបីខ្ញុំគ្មានសិទ្ធអំណាចអ្វីបន្តិចបន្តួចសោះក៏ដោយ ។ បើខ្ញុំប្រកែកមិនព្រមទទួលតួនាទីនេះ តើខ្ញុំនឹងទៅជាយ៉ាងណា? ។ ខ្ញុំនឹងត្រូវមានទោសជាជនក្បត់ជាតិ ហើយនេះក៏ត្រឹមត្រូវដែរ ពីព្រោះទោះបីយ៉ាងណាក៏ដោយ កម្ពុជាប្រជាធិបតេយ្យជារដ្ឋមួយពេញលក្ខណៈច្បាប់របស់កម្ពុជា កើតចេញមកពីការតស៊ូរបស់ប្រជាជនកម្ពុជា ប្រឆាំងនិងអំពើជ្រៀតជ្រែកពីខាងក្រៅរបស់បរទេស ហើយជាសមាជិកអង្គការសហប្រជាជាតិថែមទៀតផង ។ នេះហើយជាខ្លឹមសារសំខាន់ៗដែលខ្ញុំសូមជំរាបបងប្អូនរួមជាតិ ទាក់ទងនឹងអតីតកាលរបស់ខ្ញុំ ។

គទៅនេះ ខ្ញុំសុំជំរាបជូនបងប្អូនរួមជាតិនូវសេចក្តីបំភ្លឺអំពីឋានៈនិងតួនាទីរបស់ខ្ញុំនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ។

ដូចបងប្អូនរួមជាតិជ្រាបហើយថា ឋានៈសង្គមរបស់ខ្ញុំនិងការដែលខ្ញុំធ្លាប់មានការទាក់ទងល្អបន្តួជាមួយឥស្សរៈជនជាន់ខ្ពស់នៃប្រទេសយើង បានតម្រូវអោយខ្ញុំទទួលការងារ "រណសិរ្ស" និងការងារ"បរទេស" គឺការងារទាក់ទងជាមួយស្រទាប់ខាងលើក្នុងសង្គម និងការងារលើឆាកអន្តរជាតិ ។ ដោយសារហេតុផលដដែលនេះដែរគេមិនដែលប្រគល់ការងារអ្វីសំខាន់អោយខ្ញុំទេ ទោះបីជាការងារនៅក្នុង ប.ក.ក ក្តី ការងារកសាងកម្លាំងប្រជាជនក្តី ការងារកងទ័ពក្តី ការងាររដ្ឋអំណាចក្តី ។ មានតែកម្មាភិបាលដែលចេញមកពីវណ្ណៈកសិករក្រទេ ឬកម្មាភិបាលណាដែល ប.ក.ក យល់ឃើញថាបានលត់ដំកសាងគោលជំហរវណ្ណៈបានរឹងប៉ឹងគ្រប់គ្រាន់តាមការសាកល្បងសារចុះសារឡើងហើយទេ ទើបអាចទទួលភារៈកិច្ចទាំងអស់នោះបាន ។ ឋានៈរបស់ខ្ញុំនៅក្នុង ប.ក.ក និងក្នុងកម្ពុជាប្រជាធិបតេយ្យ មិនបានស្មើនិងកម្មាភិបាលភូមិភាគ ឬតំបន់ផងទេ ហើយក៏មិនបានស្មើនិងកម្មាភិបាលសហករណ៍ទៀតផង ។

ពិតមែនហើយ ខ្ញុំបានចូលជាសមាជិកបម្រុង"ត្រៀម"នៅឆ្នាំ១៩៧១ ហើយ "ពេញសិទ្ធិ" នៅពាក់កណ្តាលឆ្នាំ១៩៧៦ ។ ប៉ុន្តែតាមគោលការណ៍ "ប្រជាធិបតេយ្យប្រមូលផ្តុំ" កិច្ចការសំខាន់ៗសុទ្ធតែបានសំរេចក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ (អ.ច.ត) ឬក្នុងការប្រជុំការងារដោយឡែករវាង អ.ច.ត និងកម្មាភិបាលទទួលខុសត្រូវតាមភូមិភាគនិងតំបន់ (ចំពោះកិច្ចការណាដែលទាក់ទងនិងភូមិភាគឬតំបន់នោះ) ។ ឯការប្រជុំមជ្ឈឹម ការពិតទៅគ្រាន់តែជាការប្រជុំអប់រំរៀនសូត្រដើម្បីកសាងទស្សនៈគោលជំហរកម្មាភិបាល សំរាប់អនុវត្តការសំរេចរបស់គណៈ អ.ច.ត អំពីមាគ៌ានយោបាយឬគោលនយោបាយផ្សេងៗ ឬដើម្បីរៀនសូត្រដកពិសោធន៍ និងធ្វើការទិទៀនស្វ័យទិតៀន ពិនិត្យការខុសនិងការត្រូវលើការងារកន្លងមកតែប៉ុណ្ណោះ ។ ដូច្នេះជាក់ស្តែង ខ្ញុំពុំមានសិទ្ធិចូលរួមក្នុងការសំរេចលើបញ្ហាសំខាន់ៗឡើយ ។ ឧទាហរណ៍ដូចជាការជំលៀសប្រជាជនចេញពីភ្នំពេញនិងទីរួមខេត្ត រហូតមកដល់ថ្ងៃនេះខ្ញុំនៅតែមិនអាចដឹងថាតើគេសំរេចពីថ្ងៃណាពេលណាផងទេ ។

ឯអំពីការកាប់សម្លាប់ក៏ខ្ញុំមិនបានដឹងរឿងអ្វីទាំងអស់ ។ នៅរវាងពាក់កណ្តាលឆ្នាំ១៩៧៨ ខ្ញុំបានដឹងឮដោយចៃដន្យអំពីករណី១នៃការចាប់ចងនិងអំពើឃោរឃៅនៅក្នុងខេត្តព្រះវិហារ ។ គឺប្រពន្ធខ្ញុំបាននិយាយប្រាប់ខ្ញុំទាំងទឹកភ្នែក អំពីបងប្អូនបង្កើតនិងសាច់ញាតិរបស់គាត់ត្រូវគេចាប់ដាក់ខ្នោះដៃខ្នោះជើងអស់រយៈពេលជាង១ឆ្នាំ ដំបៅរលេះរលួយជាមួយប្រជាជនជាច្រើនទៀត ។ ប៉ុន្តែដោយមានការដោះលែងជនរងគ្រោះ និងមានការចាប់ខ្លួនលេខាបក្សភូមិភាគនោះ ក៏នាំអោយខ្ញុំដឹងរឿងនេះជាអំពើឃោរឃៅផ្ទាល់របស់បុគ្គលតែប៉ុណ្ណោះ ។ វិន័យហាមមិនអោយខ្ញុំដើរហើរដោយគ្មានការអនុញ្ញាតិ ។ ព្រមជាមួយនេះ លក្ខការសម្ងាត់ តឹងតែង "កិច្ចការអ្នកណាអ្នកនោះដឹង កិច្ចការគេមិនដឹង មិនឮ មិនឃើញ" ហាមមិនអោយអ្នកណាហ៊ាននិយាយពីរឿងអ្វីប្រាប់ខ្ញុំទាល់តែសោះ ។ ទាំងអស់នេះហើយដែលបានរារាំងខ្ញុំមិនអោយដឹងអ្វីៗទាំងអស់ដែលបានកើតឡើងនៅក្នុងប្រទេស ។ ខ្ញុំដឹងតែអ្វីដែលអ្នកដឹកនាំ ប.ក.ក ប្រាប់អោយខ្ញុំដឹងតែប៉ុណ្ណោះ ។ លុះដល់ចលនាត្រូវរលំរលាយទៅហើយ ទើបបងប្អូនសាច់ញាតិអ្នករងគ្រោះនិងអ្នកដែលគេបានឃើញផ្ទាល់ឬដឹងឮ រៀបរាប់ប្រាប់ខ្ញុំអំពីការកាប់សម្លាប់យ៉ាងឃោរឃៅព្រៃផ្សៃស្អាប់ទៅគួរអោយព្រឺក្បាល ។

មុននិងបញ្ចប់ ខ្ញុំសុំបដិសេធយ៉ាងដាច់អហ័ងការចំណុចទី៣នៃសេចក្ដីរាយការណ៍ដែលអ្នកស្រាវជ្រាវអាមេរិកមួយក្រុមមានឈ្មោះថា "អង្គការសំរាប់យុត្តិធម៌អន្តរជាតិ" បានផ្សាយទាក់ទងមកលើរូបខ្ញុំ ។ ក្នុងផ្នែកសេចក្ដីរាយការណ៍នេះមានសរសេរថា នៅដើមឆ្នាំ១៩៧៧ ក្រោយពីប្រធានមន្ទីរ៨៧០មុនឈ្មោះ ឌឿន ត្រូវបានគេចាប់ទៅ ខ្ញុំត្រូវបានគេ"លើក"អោយធ្វើជាប្រធានមន្ទីរនេះជំនួសវិញ ។ នេះជាការមិនពិតទេ ។ ខ្ញុំមិនដែលបានធ្វើប្រធានមន្ទីរ៨៧០នេះម្ដងណាសោះឡើយ ។ ដូច្នេះ ខ្ញុំក៏មិនដែលដឹងអំពីការសំរេចរបស់គណៈអចិន្ត្រៃយ៍នៃ ប.ក.ក ចាប់ចងឬសម្លាប់អ្នកណាម្នាក់សោះទេ កុំថាឡើយដល់ទៅតាមដានការអនុវត្តសេចក្ដីសំរេចទាំងអស់នេះ ។ ដើម្បីការពិតនិងយុត្តិធម៌ ខ្ញុំសូមអោយអ្នកសរសេរសេចក្ដីរាយការណ៍នេះពិនិត្យឡើងវិញម្ដងទៀត តើគេដឹងរឿងដែលគេសរសេរអំពីខ្ញុំមកពីណា? ការពិត ខ្ញុំគ្រាន់តែជាសមាជិកសាមញ្ញមួយរូបនៃមន្ទីរនេះតែប៉ុណ្ណោះ ។ ភារកិច្ចរបស់ខ្ញុំនៅក្នុងមន្ទីរនេះមានដូចតទៅ÷

១-បន្តទាក់ទងជាមួយសម្ដេចព្រះ នរោត្តម សីហនុ និងព្រះមហេសី ដែលពេលនោះព្រះអង្គគង់នៅក្នុងព្រះបរមរាជវាំង ។

២-រៀបចំតម្លៃផលិតផលដែលសហករណ៍ផ្សេងៗបង្កើតបាន ។ ប៉ុន្តែ ខ្ញុំសំរេចភារកិច្ចនេះអត់បានទេ ពីព្រោះគ្មានការដូរស់ប្ដូរទំនិញអ្វីទាំងអស់ រវាងសហករណ៍និងសហករណ៍ក៏គ្មាន រវាងសហករណ៍និងរដ្ឋក៏គ្មាន ។

៣-អនុវត្តការសំរេចរបស់គណៈអចិន្ត្រៃក្នុងការចែកចាយសំភារៈផ្សេងៗដែលគេប្រមូលបានក្នុងទីក្រុងភ្នំពេញ ជូនទៅភូមិភាគនិងតំបន់ផ្សេងៗ ។

៤-ទាក់ទងជាមួយក្រសួងពាណិជ្ជកម្មក្រៅប្រទេសដើម្បីនាំចូលសំភារៈមួយចំនួនតាមការសំរេចរបស់គណៈអចិន្ត្រៃយ៍ ។

ខ្ញុំសុំបញ្ជាក់ថា ក្នុងឋានៈជាប្រធានមន្ទីរ ឌឿន ទទួល"កិច្ចការនយោបាយ" ។ ការងាររបស់គាត់សំងាត់បំផុត គ្មានអោយអ្នកណាផ្សេងទៀតដឹងទេ ។ ខ្ញុំមិនបានចាំថាតើមានចាត់តាំងអ្នកណាអោយជំនួស ឌឿន ទេ ។ ពេលនោះគ្មានអ្នកណានិយាយមួយម៉ាត់ពីរឿងនេះទេ ហើយក៏គ្មានអ្នកណាហ៊ានសាកសួរពីរឿងនេះដែរ ។ អ្វីដែលខ្ញុំចាំបានគឺនៅរវាងចុងឆ្នាំ១៩៧៦ ដើមឆ្នាំ១៩៧៧ ទោះបីអ្នកដឹកនាំសំខាន់ៗនៃ ប.ក.ក ខំរក្សាភាពនឹងន៎យ៉ាងណាក៏ដោយ ខ្ញុំក៏សង្កេតឃើញថាគេកំពុងតែមានការកង្វល់ក្នុងចិត្តយ៉ាងខ្លាំង ។ ខ្ញុំនឹកគិតថា សភាពការណ៍យោធានៅព្រំប្រទល់ខាងកើតប្រហែលជាមិនស្រួលហើយមើលទៅ ។ ខ្ញុំសន្និដ្ឋានយ៉ាងនេះពីព្រោះខ្ញុំឃើញមន្ទីរពេទ្យនៅភ្នំពេញហូរហៀរទៅដោយយុទ្ធជនរបួស ។ ហើយមួយថ្ងៃៗក្បួនឡានដឹកយុទ្ធជនរបួសមកពីសមរភូមិពេញៗឡានសឹងតែរាល់ថ្ងៃ ។ គឺនៅក្នុងកាលៈទេសៈនេះហើយដែលខ្ញុំបានទទួលសិទ្ធិសំរេចដោយស្វ័យភាពជាងមុនក្នុងក្របខ័ណ្ឌភារកិច្ចរបស់ខ្ញុំដូចពោលខាងលើ ពិសេសក្នុងការនាំចូលប្រដាប់ប្រដារពេទ្យខ្លះ កុំប្រេស ថ្នាំអង់ទីប៊ីយោទិច ។ល ។ ដើម្បីសេចក្ដីត្រូវការរបស់ក្រសួងសង្គមកិច្ចនិងមន្ទីរពេទ្យផ្សេងៗ ។

ខ្ញុំបានជំរាបបងប្អូនរួមជាតិសព្វគ្រប់អស់ហើយ ។ ដូចបងប្អូនរួមជាតិឃើញស្រាប់ ។ ជាហូរហែបន្តបន្ទាប់មក ខ្ញុំគ្រាន់តែជាបញ្ញាជនមួយរូបដែលគ្មានគោលបំណងអ្វីក្រៅពីបំពេញករណីយ៍កិច្ចរបស់ខ្ញុំចំពោះជាតិអោយបានត្រឹមត្រូវតែប៉ុណ្ណោះទេ ។ ក្នុងប៉ុន្មានទសវត្សរ៍ដ៏បត់បែនស្មុគស្មាញកន្លងមកនេះ ខ្ញុំស្គាល់ច្បាស់នូវចំណុចខ្សោយរបស់ខ្ញុំ តែខ្ញុំគិតថាខ្ញុំមិនអាចគេចវេសបានទេ ពេលណាករណីយ៍កិច្ចចំពោះជាតិត្រូវធ្លាក់មកលើខ្ញុំនោះ ។ ខ្ញុំមិនដែលមានមហិច្ឆិតាចង់ធ្វើជាអ្នកដឹកនាំសោះឡើយ ។ ហើយខ្ញុំក៏មិនដែលនឹកថាទៅសម្លាប់គេឯងសោះឡើយ ។

ខ្ញុំសុំឆ្លៀតឱកាសនេះលំឱនកាយវិចាចិត្តគោរពវិញ្ញាណខ័ណ្ឌបងប្អូនស្លូតត្រង់ដែលបានរងគ្រោះពីអំពើកាប់សម្លាប់និងអំពើឃោរឃៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ចំពោះបងប្អូនរួមជាតិដែលបានបាត់បង់អ្នកដែលជាទីស្រឡាញ់របស់បងប្អូននៅសម័យនោះ ខ្ញុំសុំទោស ។ កំហុសរបស់ខ្ញុំគឺមកពីខ្ញុំឆោតពេក ហើយមិនជាប់និងសភាពការណ៍ជាក់ស្ដែង ។ ខ្ញុំបានខិតខំអស់ពីចិត្តពីថ្លើមកន្លងមក ខ្ញុំនឹកថាដើម្បីជាតិយើងរស់ ហើយបានស្គាល់ការរីកចំរើនថ្មីថ្កើងនិងគេ ។ ខ្ញុំពុំបាននឹកស្មានថាវាបែជាចេញជាអំពើកាប់សម្លាប់យ៉ាងនេះសោះ ។

ដោយមនោសញ្ចេតនាគោរពស្រឡាញ់ជាទីបំផុត ។



# អង្គប្រជុំសន្និបាតលើកទី១ ក្នុងសម័យកាលទី១ របស់សភាតំណាងប្រជាជនកម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យ

ថ្ងៃ១១-១៣ មេសា ១៩៧៦

សូមគោរពមិត្តតំណាងសភាតំណាងប្រជាជនទាំងអស់ជាទីស្នេហា!

ចាប់ពីថ្ងៃទី១១ មេសា មកដល់ថ្ងៃ ១៣ មេសា ១៩៧៦ នេះ យើងបានប្រជុំពិភាក្សាគ្នាជាបន្តបន្ទាប់ ជាគណៈកម្មការផង ជាអង្គប្រជុំពេញអង្គផង ដើម្បីពិគ្រោះពិភាក្សា ពិនិត្យមើលគ្រប់ទិដ្ឋភាពទាំងអស់ និងគ្រប់លក្ខណៈសម្បត្តិទាំងអស់ លើរបៀបវារៈទាំងប៉ុន្មានរបស់អង្គប្រជុំសន្និបាតលើកទី១ក្នុងកាលសម័យទី១ របស់សភាតំណាងប្រជាជនយើង ។

ក្រោយពីបានឆ្លងកាត់នូវការពិភាក្សាជាបន្តបន្ទាប់ទាំងបីថ្ងៃនេះមក អង្គប្រជុំសន្និបាតសភាយើងបានឯកភាពគ្នាជាឯកច្ឆ័ន្ទលើខ្លឹមសារជាមូលដ្ឋាន ដើម្បីសំរេចលើបញ្ហានីមួយៗដែលចែងក្នុងរបៀបវារៈ ។

ឈរលើមូលដ្ឋាននៃឯកភាពរបស់អង្គប្រជុំសន្និបាតយើងនេះ គណៈអធិបតីនៃអង្គប្រជុំបានរៀបរៀងនូវគំរោងសេចក្តីសំរេចចិត្តមួយរបស់អង្គសន្និបាតលើកទី១ ក្នុងកាលសម័យទី១ របស់សភាតំណាងប្រជាជនយើង ។

យើងខ្ញុំសូមតាងនាមគណៈអធិបតី អានជូននូវគំរោងសេចក្តីសំរេចចិត្តនេះ ជំរាបអង្គប្រជុំសន្និបាតសភាយើង ដើម្បីអង្គប្រជុំសន្និបាតសភាយើងមានមតិវិនិច្ឆ័យនឹងអនុម័តិសំរេចជាស្ថាពរ ។ តទៅនេះ យើងខ្ញុំសូមអាននូវគំរោងសេចក្តីសំរេចចិត្តរបស់អង្គប្រជុំសន្និបាតលើកទី១ ក្នុងកាលសម័យទី១ របស់សភាតំណាងប្រជាជនកម្ពុជា ដូចតទៅ÷

### គំរោងសេចក្តីសំរេចចិត្តរបស់អង្គប្រជុំសន្និបាតលើកទី១ ក្នុងសម័យកាលទី១ របស់សភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី ១៣ មេសា ១៩៧៦

ក្រោយពីការបោះឆ្នោតជ្រើសតាំងសមាជិកសភាតំណាងប្រជាជនកម្ពុជានៅថ្ងៃទី២០ មីនា ១៩៧៦ ប្រកបដោយជោគជ័យហើយ សភាតំណាងប្រជាជនកម្ពុជាបានបើកការប្រជុំសន្និបាតពេញអង្គលើកទី១ ក្នុងសម័យកាលទី១របស់ខ្លួន ។

ការប្រជុំសន្និបាតពេញអង្គលើកទី១ ក្នុងសម័យកាលទី១ របស់សភាតំណាងប្រជាជនកម្ពុជា បានប្រព្រឹត្តទៅអស់រយៈកាល ៣ថ្ងៃ ចាប់តាំងពីព្រឹកថ្ងៃ១១ រហូតដល់ល្ងាចថ្ងៃទី១៣ មេសា ១៩៧៦ នៅរដ្ឋធានីភ្នំពេញ ក្នុងបរិយាកាសមហាសាមគ្គីកក់ក្តៅយ៉ាងក្រៃលែង ។

អង្គប្រជុំសន្និបាតលើកទី១ ក្នុងសម័យកាលទី១ របស់សភាបានលើកបញ្ហាសំខាន់ៗទាំងអស់ដែលមានចុះក្នុងរបៀបវារៈយកមកពិនិត្យពិភាក្សាយ៉ាងល្អិតល្អន់ ដោយឈរលើមូលដ្ឋាននៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ នឹងដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះបដិវត្ត ចំពោះប្រជាជាតិ ចំពោះប្រជាជនកម្មករ កសិករ ពលករផ្សេងៗ នឹងចំពោះយុទ្ធជន យុទ្ធនារី នឹងកម្មាភិបាលនៃកងទ័ពបដិវត្តកម្ពុជា ។

បន្ទាប់ពីបានពិនិត្យពិភាក្សាយ៉ាងម៉ត់ចត់សព្វគ្រប់លើបញ្ហាទាំងប៉ុន្មានដែលបានលើកឡើងក្នុងរបៀបវារៈហើយ សភាបានសំរេចជាឯកច្ឆ័ន្ទដូចតទៅៈ

**១) អំពីការពិនិត្យលទ្ធផលនៃការបោះឆ្នោតជាសកលនៅថ្ងៃ២០ មីនា ១៩៧៦**

សភាបានអនុម័តិជាឯកច្ឆ័ន្ទថាៈ កិច្ចដំណើរការបោះឆ្នោតជាសកលនៅថ្ងៃ២០ មីនា ១៩៧៦ ក្រោមការចាត់ចែងនឹងត្រួតពិនិត្យរបស់គណៈកម្មាធិការបោះឆ្នោតនឹងគណៈកម្មាធិការក្រសួងមហាផ្ទៃ បានប្រព្រឹត្តទៅយ៉ាងត្រឹមត្រូវម៉ត់ចត់តាមគោលការណ៍នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជនកម្មករ-កសិករ ពលករផ្សេងៗ យុទ្ធជន-យុទ្ធនារី នឹងកម្មាភិបាលនៃកងទ័ពបដិវត្តកម្ពុជា បានចូលរួមបោះឆ្នោតយ៉ាងសស្រាក់សស្រាំក្នុងបរិយាកាសមហាសាមគ្គី នឹងក្នុងជំនឿជឿជាក់លើ

រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ លើតំណាងជាសាច់ជាឈាមរបស់ខ្លួន និងក្នុងជំនឿជឿជាក់ចំពោះអនាគតដ៏ភ្លឺស្វាងរុងរឿងរបស់កម្ពុជាប្រជាធិបតេយ្យ មាតុភូមិជាទីស្នេហារបស់ខ្លួន ។

**៧) អំពីការរៀបចំរបៀបរបបធ្វើការរបស់សភាតំណាងប្រជាជនកម្ពុជា ការរៀបចំចាត់តាំងគណៈកម្មាធិការអចិន្ត្រៃយ៍របស់សភា និងគណៈកម្មការផ្សេងៗរបស់សភា**

សភាតំណាងប្រជាជនកម្ពុជាកើតឡើងដោយឈាមស្រស់របស់ប្រជាជនកម្មករ-កសិករយើង ដែលបានហូរជាអូរជាស្ទឹងនៅក្នុងការតស៊ូរបស់ខ្លួន តពូជពង្ស តជំនាន់ជាបន្តបន្ទាប់រាប់ពាន់ឆ្នាំមកហើយ ។

សមាជិកសភាទាំងអស់សុទ្ធតែជាសាច់ជាឈាមរបស់ប្រជាជនកម្មករ-កសិករ ពលករផ្សេងៗ និងកងទ័ពបដិវត្តកម្ពុជា ធ្លាប់រួមធ្វើការតស៊ូបដិវត្ត ទ្រាំទ្រលំបាកវេទនាជាមួយគ្នា ប្រឆាំងចក្រពត្តិនិយម អាណានិគមចាស់-ថ្មីនិងបរិវាររបស់វា ធ្លាប់រួមសុខរួមទុក្ខជាមួយគ្នារាប់សិបឆ្នាំមកហើយ ហើយឥឡូវក៏នៅជាមួយគ្នាទៀត ក្នុងឋានៈជាអ្នកធ្វើការងារពលកម្មនៅតាមរោងចក្រ នៅតាមផ្លូវដែក នៅកំពង់ផែ នៅចំការកៅស៊ូ នៅស្រែអំបិល នៅក្នុងការដ្ឋានប្រព័ន្ធភ្លឺស្រែនិងប្រឡាយ ក្នុងសហជីព នៅក្នុងសហករណ៍ និងនៅក្នុងអង្គភាពនៃកងទ័ពបដិវត្តកម្ពុជា វាយសំរុកកសាងប្រទេសនិងការពារប្រទេសយ៉ាងសស្រាក់សស្រាំជាមួយគ្នា ។

នេះជាធាតុពិតនៃតំណាងសភាយើង គ្មានអ្វីមានលក្ខណៈតំណាងជាងនេះ ហើយក៏គ្មានអ្វីមានលក្ខណៈប្រជាធិបតេយ្យជាងនេះដែរ ។ កន្លងមករហូតដល់ថ្ងៃនេះ និងចាប់ពីថ្ងៃនេះតទៅមុខទៀត សភាយើងនឹងរក្សាធាតុជាតំណាងកម្មករ-កសិករ និងកងទ័ពបដិវត្តយើងយ៉ាងនេះតទៅទៀត ។

ដោយឈរលើស្មារតីនេះ សភាបានអនុម័តិជាឯកច្ឆ័ន្ទនូវរបៀបរបបធ្វើការជាមូលដ្ឋានដូចតទៅៈ

១) សមាជិករបស់សភាតំណាងប្រជាជនកម្ពុជាមួយរូបៗត្រូវតែនៅជិតស្និទ្ធក្នុងមូលដ្ឋានរបស់ខ្លួនតទៅទៀត ត្រូវរួមសុខរួមទុក្ខជាមួយប្រជាជន ស្គាល់ចិត្តថ្លើមរបស់ប្រជាជន ស្តាប់សំណូមពររបស់ប្រជាជន ពោលគឺនៅជាប់និងសហជីពនិងរោងចក្រ នៅជាប់និងសហករណ៍ ការដ្ឋានប្រព័ន្ធភ្លឺនិងប្រឡាយទឹក នៅជាប់និងអង្គភាពរបស់ខ្លួន រួមសកម្មភាពកសាងប្រទេសនិងការពារប្រទេសជាមួយប្រជាជន កម្មករ-កសិករ ពលករផ្សេងៗ យុទ្ធជន-យុទ្ធនារី និងកម្មាភិបាលនៃកងទ័ពបដិវត្តកម្ពុជាតទៅទៀត ដើម្បីឲ្យសមស្របនិងឋានៈរបស់ខ្លួនជាតំណាងពិតប្រាកដរបស់ប្រជាជន កម្មករ-កសិករ ពលករផ្សេងៗ និងកងទ័ពបដិវត្តកម្ពុជា ។

២) សភាតំណាងប្រជាជនកម្ពុជាត្រូវបើកសន្និបាតពេញអង្គប្រចាំឆ្នាំមួយដងក្នុងមួយឆ្នាំ ដើម្បីលើកមាគ៌ានយោបាយក្នុងប្រទេសនិងក្រៅប្រទេសប្រចាំឆ្នាំ ហើយពិនិត្យតាមដានសកម្មភាពរបស់គណៈប្រធានរដ្ឋ រដ្ឋាភិបាល និងគណៈកម្មាធិការតុលាការ ពិនិត្យគុណសម្បត្តិ គុណវិបត្តិ និងតម្រែតម្រង់ទិសការងារប្រចាំឆ្នាំរបស់អង្គការរដ្ឋទាំងបីនេះ ។

៣) ក្នុងរយៈកាលពីសន្និបាតពេញអង្គមួយទៅសន្និបាតពេញអង្គមួយ របស់សភាតំណាងប្រជាជនកម្ពុជា មានអង្គការប្រចាំការមួយរបស់សភាតំណាងប្រជាជនកម្ពុជាទទួលភារកិច្ចអនុវត្តនិងតាមដានការអនុវត្តសេចក្តីសំរេចចិត្តផ្សេងៗរបស់សន្និបាតពេញអង្គរបស់សភា ។ អង្គការប្រចាំការរបស់សភានេះមាននាមថា *គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា* ។

ព្រមជាមួយគ្នានេះ សភាក៏បានជ្រើសតាំងសមាសភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា និងសមាសភាពរបស់គណៈកម្មការផ្សេងៗរបស់សភាផងដែរ ។

គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជាមានសមាសភាពដូចតទៅៈ

១) មិត្ត នួន ជា ប្រធាន

២) មិត្ត នួន កង អនុប្រធានទី១

៣) មិត្ត ពៅ ស៊ូ អនុប្រធានទី២

៤) មិត្តនារី រស់ នឹម សមាជិក

៥) មិត្ត ស ស៊ាន សមាជិក

៦) មិត្ត ម៉ី ឆាំ សមាជិក

៧) មិត្ត ខេង សុខ សមាជិក

៨) មិត្ត ម៉ាត់ លី សមាជិក

៩) មិត្ត ចន ស៊ី សមាជិក

១០) មិត្ត រស់ ព្រាប សមាជិក

**៣) អំពីការពិនិត្យវិនិច្ឆ័យនិងសំរេចលើសេចក្តីសុំចូលនិវត្តរបស់សម្តេច នរោត្តម សីហនុ តាមសេចក្តីថ្លែងការណ៍របស់សម្តេច ចុះថ្ងៃ២ មេសា ១៩៧៦ និងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាល ចុះថ្ងៃ៤ មេសា ១៩៧៦ ស្តីអំពីការសុំចូលនិវត្តរបស់សម្តេច នរោត្តម សីហនុ ដែលរដ្ឋាភិបាលបានបញ្ជូនមកសភា**

បន្ទាប់ពីបានពិនិត្យពិភាក្សាលើសេចក្តីថ្លែងការណ៍ទាំងពីរយ៉ាងម៉ត់ចត់មក សភាបានអនុមតិជាឯកច្ឆ័ន្ទៈ

◆ យល់ស្របតាមសំណូមពរសុំចូលនិវត្តរបស់សម្តេច នរោត្តម សីហនុ ។

ដោយយោលទៅតាមគុណបំណាច់របស់សម្តេច នរោត្តម សីហនុ ដែលជាអគ្គបុត្រស្នេហាជាតិមួយអង្គដែលបានរួមវិភាគទានយ៉ាងសកម្មជាមួយប្រជាជាតិនិងប្រជាជនកម្ពុជា ធ្វើការតស៊ូរំដោះជាតិ ប្រឆាំងទល់នឹងសង្គ្រាមឈ្លានពានដ៏សែនសាហាវឃោរឃៅព្រៃផ្សៃរបស់ចក្រពត្តិអាមេរិកនិងពួកអាក្បត់ លន់ណុល, សិរិមតៈ, សឺង ង៉ុកថាន់, ចេង ហេង, អ៊ិន តាំ, ឡុង បូរេត, សុស្តែន ជាបរិវារ សភាក៏បានអនុមតិជាឯកច្ឆ័ន្ទៈ

◆ យល់ស្របតាមសេចក្តីស្នើរបស់រដ្ឋាភិបាល គឺៈ

១) ថ្វាយចំពោះសម្តេច នរោត្តម សីហនុ នូវកិត្តិនាមជា "វរជនស្នេហាជាតិដ៏ខ្ពង់ខ្ពស់មួយអង្គ" ។

២) ស្ថាបនាវិមានអនុស្សាវរីយ៍មួយសំរាប់ចារឹកនូវគុណបំណាច់ខាងលើរបស់សម្តេច នរោត្តម សីហនុ។

៣) ទទួលរ៉ាប់រងនិងផ្គត់ផ្គង់ជីវភាពរបស់សម្តេច នរោត្តម សីហនុ និងគ្រួសារ សមតាមកិត្តិយសនិងឋានៈរបស់សម្តេចជាអតីតប្រមុខរដ្ឋ និងជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ព្រមទាំងថ្វាយប្រាក់និវត្តប្រចាំឆ្នាំចំនួន៨ពាន់ដុល្លាក្នុងមួយឆ្នាំដល់សម្តេច ។

**៤) អំពីការពិនិត្យវិនិច្ឆ័យនិងសំរេចលើការសុំលាលែងរបស់រដ្ឋាភិបាលចាស់**

សភាបានកត់សម្គាល់ថាៈ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលពីមុនមាននាមថា រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយដែលត្រូវបានតែងតាំងឡើងនៅថ្ងៃ៥ ឧសភា ឆ្នាំ១៩៧០ បានយកអស់ពីចិត្តពីថ្លើមបំពេញនូវភារកិច្ចរបស់ខ្លួន ដោយបានរួមជាមួយប្រជាជនកម្ពុជាយើងទាំងមូល និងកងទ័ពបដិវត្តកម្ពុជាយើងទាំងមូល ធ្វើសង្គ្រាមប្រជាជន រំដោះជាតិ រំដោះប្រជាជន ប្រឆាំងចក្រពត្តិអាមេរិកនិងពួកអាក្បត់ លន់ ណុល, សិរិមតៈ, សឺង ង៉ុកថាន់, ចេង ហេង, អ៊ិន តាំ, ឡុង បូរ៉េត, សុស្តែន ជាបរិវារ រហូតដល់បានទទួលជ័យជំនះទាំងស្រុងនិងជាស្ថាពរនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ។



អៀង សារី     នួន ជា     ប៉ុល ពត

ក្រោយពីរំដោះទូទាំងប្រទេសហើយ ហើយអនុលោមទៅតាមសេចក្តីសំរេចរបស់មហាសន្និបាតជាតិពិសេស និងសេចក្តីសំរេចរបស់មហាសន្និបាតជាតិលើកទី៣ រដ្ឋាភិបាលបានចូលរួមរៀបចំរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ប្រកាសឲ្យប្រើប្រាស់រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ហើយក៏បានដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងសភាតំណាងប្រជាជនកម្ពុជា ។ រដ្ឋាភិបាលបានបញ្ចប់បេសកកម្មចប់សព្វគ្រប់ហើយ ដោយមានគុណសម្បត្តិជាច្រើន ហើយបានសុំលាលែងនៅថ្ងៃ៦ មេសា ១៩៧៦ ។

សភាបានអនុមតិជាឯកច្ឆ័ន្ទ យល់ស្របតាមការសុំលាលែងរបស់រដ្ឋាភិបាលចាស់ ។

**៥) អំពីការជ្រើសតាំងគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ**

ក្រោយពីបានពិភាក្សាយ៉ាងម៉ត់ចត់និងល្អិតល្អន់លើលក្ខណៈសម្បត្តិផ្សេងៗគ្រប់ទិដ្ឋភាពមក សភាបានអនុមតិជ្រើសតាំងគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យដែលមានសមាសភាព

ដូចតទៅ ៈ

១) មិត្ត ខៀវ សំផន ប្រធាន

២) មិត្ត សោ ភឹម អនុប្រធានទី១

៣) មិត្ត ញឹម រស់ អនុប្រធានទី២

### ៦) អំពីការជ្រើសតាំងរដ្ឋាភិបាលថ្មីនៃកម្ពុជាប្រជាធិបតេយ្យ

ក្រោយពីបានពិភាក្សាយ៉ាងម៉ត់ចត់នឹងល្អិតល្អន់លើលក្ខណៈសម្បត្តិផ្សេងៗគ្រប់ទិដ្ឋភាពមក សភាបានអនុមតិជ្រើសតាំងរដ្ឋាភិបាលថ្មីនៃកម្ពុជាប្រជាធិបតេយ្យ ដែលមានសមាសភាពដូចតទៅ ៈ



១) មិត្ត ប៉ុល ពត រដ្ឋមន្ត្រីទី១

២) មិត្ត អៀង សារី ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកខាងកិច្ចការបរទេស

៣) មិត្ត វន វេត ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកខាងសេដ្ឋកិច្ច

៤) មិត្ត សុន សេន ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកខាងកិច្ចការការពារប្រទេស

៥) មិត្ត ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការនឹងព័ត៌មាន

៦) មិត្ត ជួន ជឿន រដ្ឋមន្ត្រីក្រសួងសុខាភិបាល

៧) មិត្តនារី អៀង ធីរិត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច

៨) មិត្ត តូច ភឿន រដ្ឋមន្ត្រីក្រសួងសាធារណៈការ

៩) មិត្តនារី យុន យ៉ាត រដ្ឋមន្ត្រីក្រសួងវប្បធម៌ អប់រំនឹងសិក្សាធិការ ។

ក្នុងក្របខណ្ឌរដ្ឋាភិបាល មានចាត់តាំងគណៈកម្មាធិការរបស់ក្រសួងទីស្តីការឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុលខាងសេដ្ឋកិច្ចមាន ៈ

១) គណៈកម្មាធិការកសិកម្ម

២) គណៈកម្មាធិការឧស្សាហកម្ម

៣) គណៈកម្មាធិការពាណិជ្ជកម្ម

៤) គណៈកម្មាធិការគមនាគមន៍

៥) គណៈកម្មាធិការថាមពល

៦) គណៈកម្មាធិការចំការកៅស៊ូ

ប្រធានគណៈកម្មាធិការនីមួយៗមានឋានៈស្មើនឹងរដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

### ៧) អំពីការជ្រើសតាំងគណៈកម្មាធិការតុលាការ

ក្រោយពីបានពិភាក្សាយ៉ាងម៉ត់ចត់នឹងល្អិតល្អន់ សភាបានសំរេចអនុមតិជ្រើសតាំងគណៈកម្មាធិការតុលាការមួយដែលមានមិត្ត កង ចាប ជាប្រធាន ។

### ៨) អំពីសេចក្តីណែនាំរបស់សភាតំណាងប្រជាជនកម្ពុជា ស្តីអំពីទិសនយោបាយក្នុងប្រទេសនឹងក្រៅប្រទេស ចំពោះគណៈប្រធានរដ្ឋនិងរដ្ឋាភិបាលថ្មីនៃកម្ពុជាប្រជាធិបតេយ្យ

សភាបានអនុមតិជាឯកច្ឆ័ន្ទនូវទិសនយោបាយក្នុងប្រទេសនឹងក្រៅប្រទេស ដើម្បីឲ្យគណៈប្រធានរដ្ឋនឹងរដ្ឋាភិបាលថ្មីនៃកម្ពុជាប្រជាធិបតេយ្យអនុវត្តតាមដូចតទៅ ៈ

១) ត្រូវអនុវត្តរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឲ្យបានល្អត្រឹមត្រូវ ពេញលេញ នឹងខ្ជាប់ខ្ជួន គ្រប់ជំពូក គ្រប់មាត្រាទាំងអស់ ។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យយើងជាព្រលឹងនៃកម្ពុជាប្រជាធិបតេយ្យ ជាមូលដ្ឋានគ្រឹះសំរាប់នយោបាយក្នុងប្រទេសនិងក្រៅប្រទេសលើគ្រប់ផ្នែកនយោបាយ យោធា សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ដែលកុលបុត្រ-កុលធីតាកម្ពុជារាប់ម៉ឺន រាប់សែន រាប់លាននាក់ បានស្ថាបនាឡើងដោយឈាមស្រស់របស់ខ្លួន តពូជ តពង្ស តជំនាន់ អស់កាលដ៏យូរលង់មកហើយ ។ ដូច្នេះត្រូវគោរពណែនាំ អនុវត្ត តាមដានអនុវត្តនឹងពិតខំអនុវត្តជាចាំបាច់ខាតឲ្យបានល្អពេញលេញនឹងខ្ជាប់ខ្ជួន ។

២) ត្រូវពង្រីកនឹងពង្រឹងកម្លាំងមហាសាមគ្គីភាពប្រជាជាតិ

នឹងប្រជាជនទាំងមូល ប្រុងប្រយ័ត្ន បដិវត្តខ្ពស់ជាប់ជានិច្ចថែមទៀត ដើម្បីការពារប្រទេស ការពារទឹកដី ការពារឯករាជ្យភាព អធិបតេយ្យភាព បូរណភាពដែនដីក្នុងព្រំដែនបច្ចុប្បន្នរបស់យើង ដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះបដិវត្ត ប្រជាជាតិ នឹងប្រជាជនកម្ពុជាយើង ។

៣) ត្រូវពង្រីងនឹងពង្រីកកម្លាំងមហាសាមគ្គីប្រជាជាតិនឹងប្រជាជនទាំងមូលថែមទៀត ដើម្បីវាយសំរុកនៅគ្រប់សមរភូមិបង្កបង្កើនផលលើគ្រប់ផ្នែកទាំងអស់ ពិសេសលើផ្នែកកសិកម្មសំដៅផលិតស្រូវឲ្យបានច្រើនជាអតិបរមា សំរាប់ដោះស្រាយនិងលើកស្ទួយជីវភាពប្រជាជនយើងឲ្យបានកាន់តែខ្ពស់នឹងឆាប់រហ័សថែមទៀត ហើយព្រមជាមួយនោះក៏សំរាប់ជំរុញការកសាងប្រទេសយើងឲ្យបានឆាប់រហ័សតាមសន្ទុះមហាលោតផ្លោះមហាអស្ចារ្យ ។

៤) ត្រូវបន្តអនុវត្តមាគ៌ានយោបាយ ឯករាជ សន្តិភាព អព្យាក្រឹត មិនចូលបក្សសម្ព័ន្ធណា របស់កម្ពុជាប្រជាធិបតេយ្យ តាមខ្លឹមសារនៃមាត្រា២១នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យតទៅទៀត ។

ត្រូវពង្រឹងនិងពង្រីកសាមគ្គីភាពនឹងមិត្តភាពជាមួយចលនាបដិវត្តទាំងអស់នៅលើសកលលោក ជាមួយប្រទេសជាមិត្តជិតឆ្ងាយទាំងអស់នៅលើសកលលោក ជាមួយប្រជាជន ឥស្សរជន នឹងយុវជនដែលស្នេហាសន្តិភាពនឹងយុត្តិធម៌នៅលើទ្វីបទាំង៥ ក្នុងនោះមានប្រជាជន ឥស្សរជននឹងយុវជនចំរើននៅសហរដ្ឋអាមេរិកផង ដើម្បីធ្វើការតស៊ូប្រឆាំងចក្រពត្តិនិយម អាណានិគមនិយមចាស់-ថ្មី នឹងកម្លាំងប្រតិកិរិយាទាំងអស់ ដើម្បីបដិវត្ត ដើម្បីឯករាជ សន្តិភាព ប្រជាធិបតេយ្យ មិត្តភាព នឹងវឌ្ឍនភាពសង្គមពិតប្រាកដនៅលើសកលលោក ។

អង្គប្រជុំមហាសន្និបាតលើកទី១ក្នុងសម័យកាលទី១របស់សភាតំណាងប្រជាជនកម្ពុជា បានចប់សព្វគ្រប់នៅវេលាល្ងាចថ្ងៃ១៣ មេសា ឆ្នាំ១៩៧៦ ដោយមហាជោគជ័យ ដោយសុទិដ្ឋិនិយមបដិវត្តក្លៀវក្លា នឹងដោយជំនឿជឿជាក់ចំពោះអនាគតដ៏ភ្លឺស្វាងរុងរឿងរបស់ប្រជាជាតិនឹងប្រជាជនកម្ពុជា ។

***(ឯកសារស្តីអំពីអង្គប្រជុំសន្និបាតលើកទី១ ក្នុងសម័យកាលទី១)***

# ជូនមន្ទីរ ៨១ ជាទីគោរព "អំពីស្ថានទូតបារាំង"

*ទូរលេខ : ១៥៧ (១១៥៥ខ្ទង់) ឯកសារលេខ D២០៦៣*

នៅព្រឹកថ្ងៃ ៨/៣ នេះ លោកមន្ត្រីទីប្រឹក្សាស្ថានទូតបារាំងនៅប៉េកាំង បានមកជួបយើងខ្ញុំនៅស្ថានទូត ហើយបានប្រគល់សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលបារាំងមួយច្បាប់ចុះថ្ងៃទី ២-១-៧៨ មកឱយយើង ។ យើងខ្ញុំជូនជាប់មកជាមួយនេះជាភាសាបារាំង ។

ទន្ទឹមនឹងនេះ លោកមន្ត្រីទីប្រឹក្សានេះបានស្នើសួរពីសភាពការណ៍ជំលួសរវាងកម្ពុជានិងវៀតណាម ការវិវត្តន៍នៃសភាពការណ៍នេះ និងអំពីគោលជំហររបស់យើងក្នុងការដោះស្រាយនេះ ។ ទី២ បានលើកឡើងអំពីការទាក់ទងមិត្តភាពរវាងប្រទេសទាំងពីរ ។ គាត់បានបញ្ជាក់ថា រដ្ឋមន្ត្រីក្រសួងការបរទេសបារាំងបានឲ្យគាត់មកជួបដើម្បីជូនសេចក្តីប្រកាសនេះ និងសួរបញ្ជាក់បញ្ហាទាំងពីរនេះ ។

យើងខ្ញុំបានជំរាបអំពីសភាពការណ៍ជំលួសនិងមូលហេតុនៃបញ្ហាដែលកើតមានរវាងប្រទេសទាំងពីរ អំពីការវិវិត្តន៍នៃសភាពការណ៍ដាក់ស្តែងសព្វថ្ងៃនៅតាមព្រំដែន និងឧបាយកលតាមផ្លូវទូតដែលយួនកំពុងដើរឧបាយកលបោកបន្លំមតិអន្តរជាតិតាមសេចក្តីប្រកាសរបស់រដ្ឋាភិបាលវាពីថ្ងៃ ៥-២-៧៨ នេះ ។ យើងបានសង្កត់បន្ថែមថា បញ្ហាជំលួសនេះពុំមែនមកពីគំនូសព្រំដែនមិនច្បាស់លាស់ដូចយួនវាលើកឡើងនោះទេ ។ បញ្ហាព្រំដែននេះមានបញ្ជាក់នៅក្នុងសេចក្តីប្រកាសរបស់រដ្ឋាភិបាលកម្ពុជានិងវៀតណាមតាំងពីឆ្នាំ១៩៦៦មកហើយ ។

ចំពោះជំហររបស់យើងក្នុងការដោះស្រាយជំលួសនេះ យើងខ្ញុំបានបញ្ជាក់ដូចជំរាបទៅលោកទូតនានាដែរ ។ ក្រៅពីនេះ លោកទីប្រឹក្សានេះបានសួរយើងអំពីថា បើសភាពការណ៍នេះ

ចេះតែពន្យារពេលទៅទៀត តើយើងយល់ព្រមឱយមានប្រទេសទីពជួយដោះស្រាយឬទេ ។ ថែមទាំងបានបញ្ជាក់ប្រាប់យើងថា ចំពោះសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលយួននៅថ្ងៃ ៥-២-៧៨ នោះ រដ្ឋាភិបាលបារាំងពុំបានយល់អាកប្បកិរិយាទេ ។ ព្រមទាំងបញ្ជាក់ទៀតថា កន្លងមក រដ្ឋមន្ត្រីក្រសួងការបរទេសបារាំងមានកម្មវិធីទៅទស្សនកិច្ចប្រទេសយួនដែរ ប៉ុន្តែឥឡូវនេះត្រូវផ្អាកទិញទៅវិញ ។

២-អំពីការទាក់ទងមិត្តភាពរវាងប្រទេសទាំងពីរ ទីប្រឹក្សានេះបានរំលឹកថា បារាំងមានការទាក់ទងគ្នាជាមិត្តភាពជាយូរលង់ណាស់មកហើយជាមួយកម្ពុជា ។ គេបានបញ្ជាក់ថា ទោះបីចាប់ពីឆ្នាំ១៩៧០ដល់៧៥ ប្រទេសបារាំងនេះមានការទាក់ទងផ្លូវទូតជាមួយរដ្ឋាភិបាល លន់ ណុល មែន ប៉ុន្តែពុំមានជិតស្និទ្ធទេ ព្រោះរដ្ឋាភិបាលនោះរណបអាមេរិកាំង ។ ឯបារាំងចង់រក្សាឱយមានរដ្ឋាភិបាលសម្តេច សីហនុ ពេលនោះ ។ នៅក្រោយកម្ពុជារំដោះ បារាំងចង់ឱយមានការទាក់ទងផ្លូវទូតតទៅទៀតដែរ ។ តែមកទល់បច្ចុប្បន្ននេះពុំមានដោះស្រាយនៅឡើយ ។ ឯស្ថានទូតកម្ពុជានៅប៉ារីសក៏ត្រូវបិទទ្វារ ។

យើងខ្ញុំបានបញ្ជាក់វិញថា ចាប់តាំងពីក្រោយកម្ពុជាបានរំដោះ រដ្ឋាភិបាលយើងខ្ញុំបានគូសបញ្ជាក់ច្បាស់អំពីនយោបាយក្រៅប្រទេសរបស់ខ្លួនដែលចង់ឱយមានមិត្តភាពល្អ និងស្វែងរកការទាក់ទងជាមិត្តភាពជាមួយប្រទេសជិតឆ្ងាយទាំងអស់ ដោយផ្អែកលើគោលការណ៍ដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន ។ យើងខ្ញុំនៅតែគោរពជានិច្ចគោលការណ៍នេះ ។ ឯជាមួយប្រទេសបារាំង ការដែលបញ្ហានេះពុំទាន់បានដោះស្រាយនោះពុំមែនមកពីខាងកម្ពុជាទេ គឺមកពីបារាំងនៅមានបញ្ហាខ្លះដែលពុំបានសំដែងឱយឃើញថាបារាំងចង់ឱយមានការទាក់ទងល្អជាមួយកម្ពុជានៅឡើយ ។ យើងខ្ញុំបានយកឧទាហរណ៍មួយមកបញ្ជាក់ ដូចជាការការពារពួកខ្មែរក្បត់ ហើយឱយពួកនេះធ្វើសកម្មភាពមួលបង្កាច់សព្វបែបយ៉ាងដែលប៉ះពាល់ដល់នយោបាយនិងកិត្តិយសជាតិកម្ពុជា ។ ហើយការនេះដែលមានតែនាំឱយមានការទាក់ទងមិនល្អរវាងប្រទេសទាំងពីរតែប៉ុណ្ណោះ ។ លោកទីប្រឹក្សានេះបានបញ្ជាក់ថា ចំពោះខ្មែរទាំងនេះ បារាំងពុំអនុញ្ញាតឲ្យធ្វើសកម្មភាពដែលប៉ះពាល់ដល់ផលប្រយោជន៍បារាំងទេ ។ គេបានបញ្ជាក់ទៀតថា “ដូចជាល្អក៏ទូតជ្រាបហើយ” នៅប្រទេសបារាំង អង្គការកាសែតនិងអង្គការនយោបាយនានាក៏មានច្រើន ខាងម៉ាក្សស៊ីសឡេនីនិសក៏មាន ខាងកាសែតសេរីផ្សេងៗទៀតក៏មាន ហើយពួកនេះផ្សាយល្អក៏មាន ផ្សាយមិនល្អក៏មាន ។ ពួកទាំងនេះពុំមានការចាត់តាំងនិងត្រួតពិនិត្យពីរដ្ឋាភិបាលទេ ។

ទីបំផុត លោកទីប្រឹក្សានេះបញ្ជាក់ថា គាត់មុខជានឹងជួបពិភាក្សារបៀបនេះជាមួយយើងខ្ញុំទៀតនៅពេលខាងមុខ ដើម្បីដោះស្រាយការទាក់ទងរវាងប្រទេសទាំងពីរ ។ យើងខ្ញុំបានបញ្ជាក់ថា រដ្ឋាភិបាលបារាំងនិងកាន់តែយល់នូវនយោបាយដូចពោលខាងលើរបស់កម្ពុជាមិនខាន ។

ការពិភាក្សាគ្នានេះក្នុងបរិយាកាសធូរស្រាលនិងមិត្តភាព ។

លោកទីប្រឹក្សារូបនេះបានបញ្ជាក់ម្តងទៀតថា ការមកជួបយើងនេះជាលើកដំបូងហើយក្រោយដែលកម្ពុជាបានរំដោះ ហើយជួបនេះដោយបានទទួលអនុញ្ញាតពីរដ្ឋាភិបាល ។

តាមទឹកមុខនិងអាកប្បកិរិយាឃើញថា បារាំងចង់ឱយមានការទាក់ទងល្អជាមួយកម្ពុជាឡើងវិញ ។

សូមជូនពត៌មាននិងសូមមតិអង្គការ ។

**ជូ**

ថ្ងៃ ៤-៣-៧៨

ទទួលថ្ងៃ ៥-៣-៧៨ ម៉ោងៈ ១៧:៣០នាទី

ចម្លងជូនៈ អ៊ុំ អ៊ុំនួន បងវ៉ាន់ បងវន មន្ទីរ ឯកសារ

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក
**ទស្សនាវដ្តី "ស្វែងរកការពិត"**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ឬតាមទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
ឬ Email: dccam@bigpond.com.kh

# កាលប្បវត្តិរបស់ហាណូយ

## (១៩៦០-១៩៧៨)

### ១៩៦០

***៣០ កញ្ញា:*** បក្សប្រជាជនបដិវត្តខ្មែរប្តូរឈ្មោះមកជា "បក្សកុម្មុយនិស្តកម្ពុជា" ។

***ខែកញ្ញា:*** សមាជលើកទីបីរបស់បក្សពលករវៀតណាម ។ របាយការណ៍នយោបាយរបស់គណៈកម្មាធិការប្រតិបត្តិមជ្ឈិម ដែលផ្ញើជូនអង្គសមាជនេះ បញ្ជាក់ថា "ទាក់ទងនឹងប្រទេសជិតខាង យើងចង់បើកនិងធ្វើឲ្យរីកចម្រើនទៅមុខនូវទំនាក់ទំនងជិតខាងល្អ ដោយឈរលើមូលដ្ឋានគោរពឯករាជ្យនិងអធិបតេយ្យភាព ព្រមទាំងមិនជ្រៀតជ្រែកគ្នាទៅវិញទៅមកចូលក្នុងកិច្ចការផ្ទៃក្នុងផងគ្នា ។ យើងស្វាគមន៍គោលនយោបាយសន្តិភាពនិងអព្យាក្រឹតភាពរបស់ព្រះរាជាណាចក្រកម្ពុជា ហើយជាមួយគ្នានេះដែរ យើងនឹងពង្រឹងទំនាក់ទំនងមិត្តភាពថែមទៀត" ។

### ១៩៦២

***២២ សីហា:*** ប្រមុខរដ្ឋកម្ពុជាសម្តេចព្រះនរោត្តម សីហនុ ស្នើឲ្យសន្និសីទ១៤ប្រទេសធានានូវឯករាជ្យភាពនិងអព្យាក្រឹតភាពរបស់ព្រះរាជាណាចក្រកម្ពុជា ។ (សំណើនេះត្រូវបានលើកឡើងជាថ្មីម្តងទៀតនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៦៤) ។ សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមប្រកាសថាបានរៀបចំខ្លួនរួចហើយក្នុងការចូលរួមសន្និសីទនេះ ហើយសន្យាថានឹងគោរពឯករាជ្យភាព សន្តិភាព និងអព្យាក្រឹតភាពរបស់ព្រះរាជាណាចក្រកម្ពុជា ។ ក៏ប៉ុន្តែសំណើរបស់កម្ពុជាត្រូវបានសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងរដ្ឋាភិបាលប្រតិកិរិយាមួយចំនួនទៀតច្រានចោល ។

### ១៩៦៤

***២០ មិថុនា និង ១៨ សីហា:*** ប្រមុខរដ្ឋកម្ពុជាបានស្នើ ង្វៀន ហ៊ៀវ ថ ប្រធានរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង ចំនួនពីរលើក ឲ្យរៀបចំកិច្ចចរចាដើម្បីដោះស្រាយបញ្ហាព្រំដែនរវាងប្រទេសទាំងពីរ ។

***តុលា និង ធ្នូ:*** ជាការឆ្លើយតបនឹងសំណើរបស់ប្រមុខរដ្ឋកម្ពុជា រណសិរ្សរំដោះជាតិវៀតណាមខាងត្បូងបានបញ្ជូនគណៈប្រតិភូមួយក្រុមទៅកាន់ទីក្រុងប៉េកាំងដើម្បីជួបប្រជុំជាមួយភាគីកម្ពុជា ។ ទោះបីជាយើងមានសុឆន្ទៈយ៉ាងណាក៏ដោយ ក៏កិច្ចចរចានេះមិនទទួលបានជោគជ័យឡើយ ដោយសារខាងភាគីកម្ពុជាលើកឡើងនូវការទាមទារមិនសមហេតុសមផល ជាអាទិ៍ដូចជា ទាមទារកោះ ហាយ ថាក និងកោះ ៩ ជូ ដែលជាផ្នែកមួយនៃទឹកដីវៀតណាមជារៀងរហូតមក (កោះទាំងពីរនេះស្ថិតនៅខាងត្បូងខ្សែប្រេវីយេ) ។

### ១៩៦៥

***មីនា:*** សន្និសីទប្រជាជាតិឥណ្ឌូចិនលើកទីមួយត្រូវបានរៀបចំឡើងនៅទីក្រុងភ្នំពេញ ។ សេចក្តីសម្រេចរបស់សន្និសីទនេះកត់សម្គាល់ជាថ្មីម្តងទៀតថា គណៈប្រតិភូរណសិរ្សមាតុភូមិវៀតណាម និងរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង សន្យាថានឹងគោរពឯករាជ្យភាព អព្យាក្រឹតភាព និងបូរណភាពទឹកដីរបស់កម្ពុជា ។

***ឧសភា:*** កម្ពុជាផ្តាច់ទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក ។

### ១៩៦៦

***សីហា:*** ឆ្លើយតបតាមសំណើរបស់ប្រមុខរដ្ឋកម្ពុជា គណៈប្រតិភូមួយក្រុមនៃរណសិរ្សរំដោះជាតិវៀតណាមខាងត្បូងដឹកនាំដោយលោក ដិន បៀវ គាម សមាជិកគណៈកម្មាធិការអចិន្ត្រៃនៃរណសិរ្សរំដោះជាតិ មកធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញ ដើម្បីបើកការចរចាជាថ្មីលើបញ្ហាព្រំដែនរវាងប្រទេសទាំងពីរ ។ កិច្ចចរចានេះត្រូវបានផ្អាកដោយសារភាគីកម្ពុជាលើកឡើងជាថ្មីនូវការទាមទារមិនសមហេតុផល ។

## ១៩៦៧

**៩ ឧសភា :** រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាអំពាវនាវដល់ប្រទេសផ្សេងៗទៀតឲ្យទទួលស្គាល់ឯករាជ្យភាព អធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេសកម្ពុជា ដូចដែលមានកំណត់នៅក្នុងផែនទីដែលប្រើនៅឆ្នាំ១៩៥៤ ។

**៣១ ឧសភា :** រណសិរ្សរំដោះជាតិប្រកាសការទទួលស្គាល់របស់ខ្លួន ហើយសន្យានឹងគោរពបូរណភាពទឹកដីរបស់កម្ពុជានៅក្នុងក្របខ័ណ្ឌព្រំប្រទល់ដែលមានស្រាប់ ។

**៨ មិថុនា :** រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមប្រកាសទទួលស្គាល់និងសន្យាគោរពឯករាជ្យភាព អធិបតេយ្យភាពនិងបូរណភាពទឹកដីរបស់កម្ពុជាតាមព្រំប្រទល់ដែលមានស្រាប់ ។

**២០ មិថុនា :** តំណាងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមប្រចាំនៅទីក្រុងភ្នំពេញ ត្រូវបានតែងតាំងឲ្យឡើងឋានៈជាស្ថានទូត ។ ឯកអគ្គរដ្ឋទូត ង្វៀន ធឿង ឡើងកាន់តំណែងនៅថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៦៧ ។

**២២ មិថុនា :** បង្កើតតំណាងរណសិរ្សរំដោះជាតិប្រចាំនៅទីក្រុងភ្នំពេញ ដឹកនាំដោយ ង្វៀន វ៉ាន់ ហៀវ ដែលជាសមាជិកគណៈកម្មាធិការមជ្ឈិមនៃរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង ។

## ១៩៦៩

**១៣ មករា :** ផ្លូវអាកាសហាណូយ-ភ្នំពេញត្រូវបានបើកសាជាថ្មី ។

**៩ ឧសភា :** តំណាងរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូងប្រចាំនៅទីក្រុងភ្នំពេញ ត្រូវបានដំឡើងឋានៈជាស្ថានទូត ។

**៣០ មិថុនា :** តាមការអញ្ជើញរបស់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា វិញ ទិន ផាត ប្រធានរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្ននៃសាធារណរដ្ឋវៀតណាមខាងត្បូងធ្វើទស្សនកិច្ចជាមិត្តភាពនៅកម្ពុជា ។ គោលបំណងនៃដំណើរទស្សនកិច្ចនេះគឺចង់ពង្រឹងយុទ្ធសាមគ្គីភាពនិងទំនាក់ទំនងរវាងប្រទេសទាំងពីរ ។

## ១៩៧០

**១១ មីនា :** ដោយសារអវត្តមានរបស់សម្តេច សីហនុ នៅក្នុងប្រទេសកម្ពុជា ស្ថានទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងរដ្ឋាភិបាលបដិវត្តបណ្តោះអាសន្នវៀតណាមប្រចាំនៅទីក្រុងភ្នំពេញ ត្រូវបានបណ្តេញចេញតាមការញុះញង់របស់ពួកសេ.អ៊ី.អា និង លន់ណុល-សិរិមតៈ ។

**១៤ មីនា :** នៅទីក្រុងភ្នំពេញ មហាក្សត្រិយានី កុសុមៈ ដែលជាព្រះមាតារបស់សម្តេច សីហនុ បានទាមទារឲ្យបញ្ឈប់រាល់សកម្មភាពប្រទូសរ៉ាយប្រឆាំងនឹងអាណិកជនវៀតណាមដែលតាំងទីលំនៅនៅក្នុងប្រទេសកម្ពុជា ព្រមទាំងអញ្ជើញលោក ចេង ហេង ប្រមុខរដ្ឋស្តីទី និងលោក លន់ ណុល នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឲ្យទទួលខុសត្រូវកិច្ចការនេះ ។

**១៦ មីនា :** សម្តេច សីហនុ ព្រះប្រមុខរដ្ឋ ផ្ញើទូរលេខមួយច្បាប់ពីទីក្រុងប៉េកាំងមកថ្វាយព្រះមហាក្សត្រិយានី កុសុមៈ ស្នើឲ្យមហាក្សត្រិយានីចាត់វិធានការក្នុងនាមព្រះមហាក្សត្រ ដើម្បីទប់ទល់ដោះស្រាយរាល់ការលំបាកដែលកើតឡើងក្នុងទំនាក់ទំនងរវាងកម្ពុជានិងវៀតណាម ។

**១៨ មីនា :** រដ្ឋប្រហារដោយសេនាប្រមុខ លន់ ណុល ។ សម្តេច សីហនុ ត្រូវបានដកចេញពីតំណែងជាប្រមុខរដ្ឋ ។ សហរដ្ឋអាមេរិកនិងសារព័ត៌មានពិភពលោកប្រកាសពីតួនាទីរបស់សេ.អ៊ី.អានៅក្នុងការធ្វើរដ្ឋប្រហារនេះ ។

**២៣ មីនា :** ព្រះរាជសារនិងសេចក្តីប្រកាសជាផ្លូវការរបស់សម្តេចព្រះ នរោត្តម សីហនុ ថ្កោលទោសរដ្ឋប្រហារ និងប្រកាសរំលាយចោលរដ្ឋាភិបាល លន់ណុល និងសភាទាំងពីរ ។ ព្រះអង្គក៏បានប្រកាសថានឹងបង្កើតរាជរដ្ឋាភិបាលថ្មីមួយទៀតដែលមានឈ្មោះថា «រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជា ។ ការតស៊ូប្រដាប់អាវុធចាប់ផ្តើមឡើងនៅទូទាំងប្រទេស ។

**២៥ មីនា :** រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមប្រកាសថ្កោលទោសរដ្ឋប្រហារថ្ងៃ១៨ ខែមីនា ឆ្នាំ១៩៧០ ហើយបញ្ជាក់ថា «ទម្រង់ការបានមកពីគោលការណ៍ដែលថាការរំដោះកម្ពុជាជាការងាររបស់ប្រជាជនខ្មែរនោះ

រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមប្រកាសគាំទ្រយ៉ាងពេញលេញចំពោះសេចក្តីប្រកាសទាំងប្រាំចំណុចនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ របស់សម្តេចព្រះ នរោត្តម សីហនុ...។ ក្នុងស្មារតីគោរពគ្នា សាមគ្គីគ្នា និងជួយគ្នាទៅវិញទៅមក ប្រជាជនវៀតណាមនឹងគាំទ្រអស់ពីចិត្តពីថ្លើមដល់កិច្ចខិតខំប្រឹងប្រែងស្របច្បាប់របស់ប្រជាជនខ្មែរ» ។

**២៦ មីនា:** តំណាងរាស្ត្របីរូបគឺ ខៀវ សំផន ហ៊ូ យន់ និង ហ៊ូ នឹម ប្រកាសគាំទ្រការអំពាវនាវរបស់សម្តេច សីហនុ ។

**ពាក់កណ្តាលខែមេសា:** អាមេរិកកាំងបញ្ជាឲ្យ ង្វៀន វ៉ាន់ធៀវ វាយលុកចូលទឹកដីតំបន់ស្វាយរៀងនៃប្រទេសកម្ពុជា ។

**២៣ មេសា:** ក្រុមប្រជាជន (ដែលជាអង្គការលាក់មុខរបស់បក្សកុម្មុយនិស្តម្ពុជា) បោះពុម្ពផ្សាយនូវសេចក្តីថ្លែងការណ៍បញ្ជាក់អំពីការតាំងចិត្តរបស់ខ្លួនដើម្បីស្វែងរកឯកភាពជាតិ និងគាំទ្រដល់សេចក្តីប្រកាសរបស់សម្តេច សីហនុ ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ។

**២៤-២៥ មេសា:** សន្និសីទកំពូលនៃប្រជាជាតិឥណ្ឌូចិន ។ សេចក្តីប្រកាសរួមរបស់សន្និសីទសង្កត់ធ្ងន់ថា «បក្ស...ទទួលស្គាល់ និងសន្យាគោរពបូរណភាពទឹកដីកម្ពុជាដែលមានព្រំប្រទល់ដូចមានសព្វថ្ងៃនេះ...» ។ ផាម វ៉ាន់ ដុង នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមប្រកាសនៅក្នុងសុន្ទរកថាថា «ប្រជាជនវៀតណាមនិងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមចូលរួមយ៉ាងសកម្មក្នុងការបំពេញកាតព្វកិច្ចពង្រឹងយុទ្ធសាមគ្គីភាពរវាងប្រទេសយើងទាំងបី ហើយជានិច្ចកាលយើងតែងតែឲ្យតម្លៃទៅលើសន្តានចិត្តរបស់មិត្តមកលើយើង ។ ចំពោះជំនាន់ក្រោយៗវិញ ទំនាក់ទំនងរវាងប្រជាជនយើងទាំងបីនឹងក្លាយជាទំនាក់ទំនងប្រកបដោយការស្រឡាញ់គ្នានិងគោរពគ្នាទៅវិញទៅមក យុទ្ធសាមគ្គីភាពនៅក្នុងចលនាតស៊ូប្រឆាំងនឹងខ្មាំងសត្រូវកិច្ចសហប្រតិបត្តិការយូរអង្វែង និងជួយគ្នាទៅវិញទៅមកក្នុងគោលបំណងកសាងប្រទេសរៀងៗខ្លួនតាមមាគ៌ានិងទេពកោសល្យរបស់ប្រជាជនផ្ទាល់» ។

**៣០ មេសា:** តាមការបញ្ជារបស់ប្រធានាធិបតីសហរដ្ឋអាមេរិក រីឆាត និចសុន កងទ័ពអាមេរិកនិងកងទ័ពរបស់ក្រុងសៃហ្គនជាច្រើនអង្គភាព បានឆ្លងកាត់ព្រំដែនពីខាងវៀតណាមខាងត្បូងមកកម្ពុជា ។

**៣ ឧសភា:** សមាជរណសិរ្សរួបរួមជាតិកម្ពុជាៈ សម្តេច សីហនុ ត្រូវបានបោះឆ្នោតជ្រើសតាំងជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ។ រាជរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជាត្រូវបានបង្កើតឡើងដោយមាន ប៉ែន នុត ធ្វើជានាយករដ្ឋមន្ត្រី ។ រាជរដ្ឋាភិបាលនេះមានពីរផ្នែក÷ ផ្នែកទីមួយបង្កើតឡើងនៅបរទេស ទទួលបន្ទុកទំនាក់ទំនងខាងក្រៅ ផ្នែកទីពីរបង្កើតឡើងនៅក្នុងប្រទេស ដឹកនាំដោយ ខៀវ សំផន ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ និងជាអគ្គមេបញ្ជាការកងទ័ពប្រជាជនរំដោះជាតិ ។

**២៥ ឧសភា:** សម្តេច នរោត្តម សីហនុ ដែលជាប្រមុខរដ្ឋកម្ពុជា និងជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា រួមព្រះរាជដំណើរជាមួយ ប៉ែន នុត នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជា យាងមកដល់ប្រទេសវៀតណាមក្នុងដំណើរទស្សនកិច្ចជាផ្លូវការមួយ ។ សេចក្តីថ្លែងការណ៍រួមវៀតណាម-កម្ពុជាត្រូវបានផ្សព្វផ្សាយជាសាធារណៈនៅទីក្រុងហាណូយ ។ សេចក្តីប្រកាសនិយាយថា «ប្រជាជនខ្មែរដឹងគុណយ៉ាងជ្រាលជ្រៅចំពោះសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមដែលបានឧបត្ថម្ភគាំទ្រពេញទំហឹងចំពោះនយោបាយឯករាជ្យភាព សន្តិភាព និងអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ចំពោះការទទួលស្គាល់ និងគោរពបូរណភាពទឹកដីក្នុងព្រំប្រទល់បច្ចុប្បន្ន និងសិទ្ធិគាំទ្រតាំងពីដំបូងចំពោះតស៊ូប្រកបដោយយុត្តិធម៌ និងជោគជ័យ ប្រឆាំងនឹងចក្រពត្តិអាមេរិកនិងខ្ញុំកញ្ជះ លន់ណុល-សិរិមតៈ» ។

**តុលា:** លន់ ណុល និងបក្ខពួក បានបង្កើតរបបគ្រប់គ្រងមួយហៅថា «សាធារណរដ្ឋខ្មែរ» ។ **(នៅមានត)**

## ពាក្យស្លោកខ្មែរក្រហម

◆ **កម្ចាត់របៀបរបបដឹកនាំ និងធ្វើការខារវាយមាយ រយីករយាក ប៉ាគណាប៉ាគណី ប្រថុយប្រថាន គ្មានស្មារតីទទួលខុសត្រូវជាដាច់ខាត។** *(ឯកសារទង់បដិវត្តន៍)*

# ហួត សម្បត្តិ

**(តចប់)** ក្នុងឆ្នាំ១៩៧៣ មតិសកលលោកបានគ្របដណ្តប់មកលើប្រទេសកម្ពុជា ក្នុងការចង់ឲ្យកម្ពុជាចរចាជាមួយរបប លន់ ណុល ដែលមានអាមេរិកជាអ្នកគាំទ្រ ។ នៅក្នុងពេលនោះ ប្រធានាធិបតីនៃប្រទេសជាមិត្តដូចជាប្រទេសម៉ូរីតានី អាល់សេរី រូម៉ានី បានបបួលសម្តេច សីហនុ ចរចាជាមួយរបប លន់ ណុល ។ ចំណែកឯ សម្តេច សីហនុ ក៏ចង់ជួបជាមួយលោក គីសស៊ីងហ្គ័រ រដ្ឋមន្ត្រីការបរទេសអាមេរិកដែរ ។ នៅពេលឃើញសភាពមិនសូវល្អយ៉ាងដូច្នេះ ហួត សម្បត្តិ បានស្នើសុំលាឈប់ពីតំណែងនៃរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយបានស្នើឲ្យប្រគល់អំណាចរដ្ឋាភិបាលទាំងស្រុងទៅឲ្យអ្នកដែលនៅក្នុងស្រុក ។


ហួត សម្បត្តិ នៅមន្ទីរ ស-២១

ក្រោយពីបានចេញពីតំបន់រំដោះក្នុងឆ្នាំ១៩៧៣ សម្តេច សីហនុ បានជួបជាមួយលោក ជូ អេនឡាយ ដើម្បីសុំឲ្យជួយនិយាយជាមួយលោក គីសស៊ីងហ្គ័រ ក្នុងរឿងបញ្ជូនព្រះមាតារបស់ទ្រង់ចេញពីប្រទេសកម្ពុជា មកកាន់ចិនប្រជាមានិត ដើម្បីព្យាបាលជំងឺមហារីក ។ លោក គីសស៊ីងហ្គ័រ ក៏យល់ព្រមតាមសំណើនេះ ហើយបានឲ្យ លន់ ណុល ដោះលែងក្រុមសីហនុនិយមដែលជាប់គុក និងអនុញ្ញាតឲ្យព្រះមាតារបស់សម្តេច សីហនុ និងអ្នកបម្រើមួយចំនួន មកកាន់ប្រទេសចិន ។

នៅឆ្នាំ១៩៧៣ មុននឹងមកកាន់តំបន់រំដោះវិញ សម្តេច សីហនុ ក៏សុំលាលែងពីតំណែងប្រមុខរដ្ឋទៀត ដោយសាររដ្ឋាភិបាលហាមមិនឲ្យទ្រង់ជួបជាមួយលោក គីសស៊ីងហ្គ័រ ។

នៅឆ្នាំ១៩៧៤ សម្តេច សីហនុ សុំលាលែងពីតំណែងម្តងទៀត ប៉ុន្តែ ហួត សម្បត្តិ ពុំបានដឹងអំពីមូលហេតុយ៉ាងណាឡើយ ។ ក្នុងកាលៈទេសៈអាក្រក់ដូច្នេះ ជូ អេនឡាយ បានមកសម្រុះសម្រួលឲ្យសម្តេច សីហនុ ឲ្យសុខចិត្តបន្តបេសកកម្មរបស់ទ្រង់រហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

នៅឆ្នាំ១៩៧៥ សម្តេច សីហនុ ចូលមកកម្ពុជាវិញ ហើយបានចេញទៅធ្វើទស្សនកិច្ចនៅប្រទេសមួយចំនួននៅអឺរ៉ុប អាស៊ី និងអាហ្វ្រិក ដោយបានប្រាប់ទៅអ្នកដឹកនាំប្រទេសទាំងនោះអំពីសភាពការណ៍ក្នុងកម្ពុជា អំពីនយោបាយដែលកម្ពុជាបានជ្រើសរើស និងអំពីការរៀបចំប្រទេស ។ ព័ត៌មានសំខាន់មួយដែលសម្តេច សីហនុ បានប្រាប់មេដឹកនាំប្រទេសទាំងនោះគឺថា "ប្រទេសកម្ពុជាគ្មានចាយប្រាក់ទេ" ។ បញ្ហានេះធ្វើឲ្យមេដឹកនាំនៃប្រទេសទាំងនោះ ចង់ដឹងថាតើកម្ពុជាធ្វើយ៉ាងណាក្នុងការដោះដូររវាងប្រជាជននិងប្រជាជន រវាងប្រជាជននិងរដ្ឋាភិបាល ។

**សកម្មភាពក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃចាប់ខ្លួន**

ហួត សម្បត្តិ ត្រឡប់ចូលស្រុក ហើយបានមកដល់ភ្នំពេញនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៥ ។ ពេលមកដល់ភ្នំពេញភ្លាម ហួត សម្បត្តិ ក៏បានស្កាត់រក ចៅ សេង, ប៉ែន ញ៉ាច, គីម ស្រ៊ុន, នូ ពេជ និង ហោ ណាំហុង ដើម្បីសាកសួរអំពីលទ្ធផលនៃការងារ ។ ប៉ុន្តែអ្នកទាំង៥បានប្រាប់ថា "បង អៀង សារី បានទទួលបេសកកម្មការទូតនិងនយោបាយទាំងអស់ ហើយបានប្រាប់ថា ដល់រៀនសូត្រចប់ត្រូវចុះទៅជនបទបង្កបង្កើនផល រៀនធ្វើពលកម្ម រួចមករៀនសូត្រសាចុះសាឡើង" ។ ក្នុងចំណោមអ្នកទាំង៦នាក់ មានអ្នកខ្លះត្រូវធ្វើការនៅការិយាល័យនៃក្រសួងការបរទេស ហើយអ្នកខ្លះក៏ត្រូវចេញទៅបំពេញបេសកកម្មការទូតបន្តទៅទៀត ។

លុះដល់ដើមឆ្នាំ១៩៧៦ ជួន ប្រាសិទ្ធិ, គាត ឈន់, ចាន់ យូរ៉ាន់, សារិន ឆាក និង អ៊ិន សុភាព ដែលជាកម្មាភិបាលនៃក្រសួងការបរទេស ក៏មកចូលរួមរៀនសូត្រហើយបានស្នាក់នៅជាមួយ ហួត សម្បត្តិ ។ ក្រោយពេលចប់វគ្គរៀនសូត្រ ក្រុមរបស់ ហួត សម្បត្តិ ដែលមានគ្នា៨នាក់ (ក្នុងនោះមាន៥នាក់ជាអ្នកទទួលបេសកកម្មប្រមូលព័ត៌មាន) ត្រូវបានអង្គការឲ្យចុះទៅ

ជនបទដើម្បីបង្កបង្កើនផលនៅភូមិតូង ស្រុកត្បូងឃ្មុំ ភូមិភាគបូព៌ា ។ រហូតដល់ខែសីហា ឆ្នាំដដែលនេះ ទើបអង្គការហៅក្រុមរបស់ ហួត សម្បត្តិ មកភ្នំពេញវិញ ហើយឲ្យទៅធ្វើពលកម្មនៅចម្ការអង្គការនៅច្រាំងចំរេះ ។ ក្រៅអំពីក្រុមដែលអង្គការហៅមកពីភូមិភាគបូព៌ា ហួត សម្បត្តិ សង្កេតឃើញមានសុទ្ធតែយុទ្ធជនយុទ្ធនារីឬអ្នកធ្វើការនៅក្នុងក្រសួងការបរទេស ដែលរួមមានទាំង នរោត្តម ភូរិស្សរ៉ា (បងមឿន) និងភរិយាឈ្មោះ ស្រីសូត្រ (បងសូត្រ) ។ នៅទីនោះ អ្នកទាំងអស់គ្នាត្រូវធ្វើពលកម្មដូចជា សង់ផ្ទះ កាប់ដីដាំដំណាំ ប្រឡេះគ្រាប់ពោតហាល ស្ងោរពោត និងចិញ្ចឹមត្រី ។ ត្រីដែលចិញ្ចឹមនៅទីនោះ អង្គការបានយកទៅលក់ឲ្យទូតបរទេសនៅភ្នំពេញបីដងក្នុងមួយអាទិត្យ ។ ហួត សម្បត្តិ បានត្អូញត្អែរពីការលំបាកក្នុងការងារពលកម្មនេះថា "ខ្ញុំបាទមានអាយុចាស់ ហើយកម្លាំងក៏ថយ ត្រូវធ្វើការងារជាមួយនឹងក្រុមប្រឡេះពោតហាល ស្ងោរពោតចិញ្ចឹមត្រី រួចកាប់ដីដាំដំណាំ..." ។ ហួត សម្បត្តិ ធ្វើការនៅសហករណ៍ច្រាំងចំរេះ រហូតដល់ថ្ងៃដែលអង្គការចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ។

## ឯកសារផ្សេងៗដែលពាក់ព័ន្ធនឹងចម្លើយសារភាពរបស់ ហួត សម្បត្តិ

ក្រៅពីឯកសារចម្លើយសារភាពរបស់ ហួត សម្បត្តិ ឃើញមានឯកសារមួយដែលអ្នកទទួលខុសត្រូវលើការសួរចម្លើយជនរងគ្រោះរូបនេះ បានធ្វើសេចក្តីរាយការណ៍សរុបអំពីផែនការរបស់សូវៀតចំពោះកម្ពុជា ។ ឯកសារនេះសរសេរថា÷

"I. វិធានការរបស់សូវៀតមុនអនុវត្តផែនការ÷ ១) សូវៀតបិទផ្លូវអាកាសដើម្បីផ្តាច់ជំនួយពីចិនមកកម្ពុជា ។ ២) តាមសមុទ្រ សូវៀតធ្វើប្លុកកូស (ការបិទគមនាគមន៍) ចាំបាញ់កប៉ាល់របស់ចិនដែលចូលមកកម្ពុជា ។ (ចម្លើយ អ៊ីស៊ូប គន្ធី ទំព័រ៣៣ បន្ទាត់ទី៤ដល់ទី៦) ។

II. កម្លាំងយោធាដែលសូវៀតត្រូវប្រើពេលវាយលុកចូលកម្ពុជា÷ ១) កម្លាំងប្រយុទ្ធគឺទ័ពខ្មែរសេរីរបស់ សឺង ង៉ុកថាញ់ និងក្រុមទាហានដែលរត់ចូលទៅសៀម វៀតណាម ក្រោយ១៧ មេសា ។ (ចម្លើយ ហួត សម្បត្តិ ទំព័រ៩ បន្ទាត់ទី១២ដល់១៧) ។ ២) ជាទិស សូវៀតយកវៀតណាម លាវ ជាកម្លាំងស្រួចប្រយុទ្ធជាមួយកម្ពុជា ។ តែសូវៀតយកខ្មែរកម្ពុជាក្រោមវាយកម្ពុជាដើម្បីដោះស្រាយទំនាស់រវាងកម្ពុជា-វៀតណាម (ចម្លើយ អ៊ីស៊ូប គន្ធី ទំព័រ២ បន្ទាត់ទី១៦ ដល់២២) ។

III. រយៈកាលអនុវត្តៈ ១) ទិសដៅរបស់អាមេរិក សូវៀត វៀតណាម ផ្តើមវាយកម្ពុជាពេលដាច់ឆ្នាំ១៩៧៦ (ចម្លើយ អ៊ីស៊ូប គន្ធី ទំព័រទី២ បន្ទាត់ទី៩ដល់ទី១០) ។

IV. ពេលផ្តើមអនុវត្តរយៈកាលទី១ៈ ១) សូវៀតប្រមូលកម្លាំងចេញពីព្រំដែនវៀតណាម លាវ សៀម សម្រុកចូលវាយកម្ពុជា (ចម្លើយ ហួត សម្បត្តិ ទំព័រ៩ បន្ទាត់ទី៨ដល់១១) ។ ២) ទ័ពដែលចេញពីវៀតណាម លាវ សៀម ត្រូវចាប់ដៃគ្នានៅក្រចេះ ដណ្តើមយកខាងឆ្វេងមេគង្គឲ្យបានជាមូលដ្ឋាន ។ យកក្រចេះ ស្ទឹងត្រែង រតនគិរី កំពង់ចាម ក្នុងរយៈកាលទី១ (ចម្លើយ ហួត សម្បត្តិ ទំព័រទី១១ បន្ទាត់ទី១០ដល់បន្ទាត់ទី១៨) ។ ៣) សូវៀតយកកម្លាំង៥០០០០នាក់វាយកម្ពុជាតាមបែបអង់ហ្គោឡា (ចម្លើយ អ៊ីស៊ូប គន្ធី ទំព័រ៣ បន្ទាត់ទី១៣ដល់បន្ទាត់ទី១៨) ។ ៤) សូវៀតបញ្ចូលរថក្រោះនិងកម្លាំងថ្មើរជើង ១០០០០នាក់ចូលមកតាមពោធិចិនតុង រួចវាយឲ្យខ្ទេចក្នុងរយៈពេលមួយយប់ (ចម្លើយ អ៊ីស៊ូប គន្ធី ទំព័រ១៣ បន្ទាត់ទី១៣ដល់១៨) ។ ៥) សូវៀតយកទ័ព៣២០០០០នាក់វាយតាមសមុទ្រ ។ ពេលវាយ វៀតណាមបើកផ្លូវទន្លេឲ្យសូវៀតដឹកជញ្ជូនទ័ពនិងសម្ភារចូលមកកម្ពុជា (ចម្លើយ អ៊ីស៊ូប គន្ធី ទំព័រ១៤ បន្ទាត់ទី៧ដល់១០) ។

V. ពេលឈ្នះ ១) ឈ្នះភ្លាម ចាត់តាំងរដ្ឋាភិបាលមួយលើភូមិភាគដែលគេដណ្តើមបាន (ចម្លើយ ហួត សម្បត្តិ ទំព័រ១១ បន្ទាត់ទី២០ដល់២៤) ។ ២) ក្រោយឈ្នះភ្លាម ចាត់រដ្ឋាភិបាលមួយតាមបែបអង់ហ្គោឡា (ចម្លើយ អ៊ីស៊ូប គន្ធី ទំព័រ៣ បន្ទាត់ទី១០ដល់១២) ។ ៣) រយៈកាលទីពីរគឺបានវាយរំដោះទូទាំងប្រទេសតែម្តង (ចម្លើយ ហួត សម្បត្តិ) ។

VI. ប្រភពផែនការៈ ១) ប្រភពផែនការគឺចេញពីសហរដ្ឋអាមេរិក សូវៀត វៀតណាម ។ តែសហរដ្ឋអាមេរិកជំរុញឲ្យសូវៀតចេញមុខ វាជាជំនួយពីក្រោយ (ចម្លើយ ហួត សម្បត្តិ ទំព័រ១៤ បន្ទាត់ទី១៣ដល់១៨) ។ ២) ផែនការឈ្លានពានរបស់សូវៀត សហរដ្ឋអាមេរិក វៀតណាម បានរៀបចំកាលពី១០-

៧៥ (ខែតុលា ឆ្នាំ១៩៧៥)។ (ចម្លើយ អ៊ីស៊ូប គន្ធី ទំព័រចុងបញ្ចប់)»។

ក្នុងចម្លើយសារភាពរបស់ ហ៊ួត សម្បត្តិ ជនដែលពាក់ព័ន្ធនឹងសកម្មភាពក្បត់រួមមាន១៩នាក់ ក្នុងនោះមាន ចៅ សេង, ប៉ែន ញ៉ាច, គីម ស្រ៊ុន, នូ ពេជ្រ, ហោ ណាំហុង, ជួន អេន, គាត ឈន់, សារិន ឆាក, ឌិក សាគុណ, ចែម ស្នួន, ប៉ែន ស្មំផង, គា ឡាំងហាក់, កែ មាស, ជួង សំអុល, ថាច់ សួង, សារ៉ាត, ភូរិស្សរ៉ា, ស្រី សូត្រ និង ចាន់ យូរ៉ាន់។

## ភាពស្មោះត្រង់របស់ជនរងគ្រោះចំពោះអង្គការ

ហ៊ួត សម្បត្តិ បានសម្តែងភាពស្មោះត្រង់ក្នុងចម្លើយសារភាពរបស់ខ្លួនចំពោះអង្គការថា «...ខាងក្រោមនេះជាសេចក្តីរាយការណ៍របស់ខ្ញុំបាទធ្វើដោយស្មោះត្រង់ជាទីបំផុត...ខ្ញុំមិនដែលបានទទួលលុយកាក់ឬធ្វើសេចក្តីរាយការណ៍អ្វីទៅឲ្យពួកចក្រពត្តិអាមេរិកទេ ជាពិសេសពួកសេ.អ៊ី.អា។ ខ្ញុំបាទគ្មានប្រាក់ផ្ទាល់ខ្លួននៅបរទេសទេ ផ្ទះក៏គ្មានដែរ អង្គការអាចនឹងធ្វើការស៊ើបសួរអង្កេតបានដោយងាយ...។ កាលដែលខ្ញុំធ្វើការនៅអង្គការសហប្រជាជាតិ ខ្ញុំបានប្រឆាំងយ៉ាងខ្លាំងក្លាចំពោះអាចក្រពត្តិអាមេរិក បានជួយការពារប្រទេសជាមិត្តមិនចូលជាសមាជិកអង្គការសហប្រជាជាតិ ដូចជា ចិនប្រជាមានិត កូរ៉េ វៀតណាម បានបកអាក្រាតយ៉ាងខ្លាំងអាចក្រពត្តិអាមេរិក...»។

ហ៊ួត សម្បត្តិ បានសម្តែងពីបំណងរបស់ខ្លួនដែលចូលមកក្នុងប្រទេស និងអង្វរករសុំការគ្រាប្រណីពីបក្ស៖ «ខ្ញុំគ្មានគោលបំណងអាក្រក់ទេដែលចូលមកមាតុភូមិជាទីស្នេហារបស់ខ្ញុំបាទ ខិតខំរួមចំណែកជាមួយអ្នកស្នេហាជាតិនិងអ្នកបដិវត្តដើម្បីចូលមករួមចំណែកក្នុងប្រទេស កសាងនិងការពារប្រទេសតាមគោលនយោបាយដ៏ត្រឹមត្រូវរបស់អង្គការបដិវត្តន៍ដ៏មហាអស្ចារ្យរបស់យើង...សូមអង្គការមេត្តាអនុគ្រោះទុកឲ្យខ្ញុំបាទរស់នៅតទៅទៀតដើម្បីបម្រើអង្គការបដិវត្តន៍ឲ្យអស់ពីចិត្តពីថ្លើម...។ បើសិនណាអង្គការបដិវត្តន៍មិនអនុគ្រោះខ្ញុំបាទទេ បាទសូមស្នើមិត្តប្រធានមេត្តារក្សាកូនប្រពន្ធខ្ញុំបាទផង ពីព្រោះខ្ញុំបាទមិនបានក្បត់ជាតិទេ ហើយមិត្តក៏ធ្លាប់ស្គាល់ប្រពន្ធកូនខ្ញុំបាទដែរ...»។

ហ៊ួត សម្បត្តិ ត្រូវអង្គការចាប់ខ្លួននៅ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយត្រូវកម្ទេចចោលនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំដដែលនេះ បន្ទាប់ពីបានសួរចម្លើយនៅក្នុងមន្ទីរ ស-២១ ចំនួន១២លើក។ ក្នុងអំឡុងពេលជាប់នៅក្នុងមន្ទីរ ស-២១ ហ៊ួត សម្បត្តិ មានជំងឺ ស្គមរីងរៃនិងរាកមួលយ៉ាងធ្ងន់ធ្ងរ។

ការវិលត្រឡប់របស់ ហ៊ួត សម្បត្តិ មកស្រុកកំណើតមិនត្រឹមតែជាការខកចិត្តតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំខ្លួនឯងមករកសេចក្តីស្លាប់ទៀតផង។

**ជួង សុភារិទ្ធ**

# ហ៊ូ នឹម



ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការនិងព័ត៌មាននៃរបបកម្ពុជាប្រជាធិបតេយ្យ។ នៅឆ្នាំ១៩៦២ ហ៊ូ នឹម ត្រូវបានបោះឆ្នោតជ្រើសតាំងជាសមាជិកសភាជាតិ។ ហ៊ូ នឹម បញ្ចប់សញ្ញាប័ត្របណ្ឌិតផ្នែកគ្រប់គ្រងសាធារណៈ នៅសាកលវិទ្យាល័យភ្នំពេញនៅឆ្នាំ១៩៦៥។

ហ៊ូ នឹម ជាអ្នកនាំពាក្យខាងកំណែទម្រង់ផ្នែករដ្ឋបាលនិងអប់រំ ធ្វើការជាមួយ ខៀវ សំផន និង ហ៊ូ យន់។ អ្នកទាំងបីដែលជាសមាជិកសភាជាតិ បានឆ្លៀតពេលបង្រៀនសិស្សក្រីក្រនៅវិទ្យាល័យចំនួនពីរ។ សិស្សជាច្រើនបានចូលប្រឡូកយ៉ាងសកម្មក្នុងការបាចខិត្តប័ណ្ណរបស់រណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងភ្នំពេញក្នុងអំឡុងពេលសង្គ្រាមចាប់ផ្តើមដំបូង។

## ពាក្យស្លោកខ្មែរក្រហម

◆ **រៀនសូត្រថែបំប៉ន លើកតំកើងនៃចរិតអង្គការចាត់តាំង ចរិតវិន័យដោយសកម្ម និងចរិតបដិវត្តន៍ដោយសកម្ម តាមស្មារតីម៉ាក្សលេនីន ដើម្បីផ្ចាញ់ផ្ចាលនូវសិទ្ធិសេរីភាពបក្ខជនមិនសកម្មសតិអារម្មណ៍គ្មានអង្គការ គ្មានវិន័យ។**

(សៀវភៅលេខ ០១៨៖ គណហ)

# ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍

## ការធ្វើផែនទីវាលពិឃាតនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥-២០០០

(តពីលេខមុន)

| ល.រ | ល.រទីតាំង | ឈ្មោះទីតាំង | ទិន្នន័យរណ្តៅនិងជនរងគ្រោះ តាមជាក់ស្តែង | | ទិន្នន័យរណ្តៅនិងជនរងគ្រោះ តាមរបាយការណ៍ | | របាយការណ៍ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|
| | | | ប៉ាន់ស្មានរណ្តៅ | ប៉ាន់ស្មានជនរងគ្រោះ | ប៉ាន់ស្មានរណ្តៅ | ប៉ាន់ស្មានជនរងគ្រោះ | |
| ៥៨ | ១៤០៨០៣ | វត្តស្វា | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៥៩ | ១៤០៨០៤ | វត្តកញ្ជួន | ៣៤ | ៥០០០ | ២៦ | ជាង៥០០០ | ១៩៩៥/៩៦ |
| ៦០ | ១៤០៩០៣ | ព្រៃអណ្តូង | ជាង១០០ | គ្មាន | ជាង១០០ | គ្មាន | ១៩៩៥/៩៦ |
| ៦១ | ១៤១០០១ | ទួលក្រាំងស្វាយ | ៤១ | ៥០០០ | ៤១ | គ្មាន | ១៩៩៥/៩៦ |
| ៦២ | ១៤១០០២ | ទួលក្រាំងស្វាយ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៦៣ | ១៤១០០៣ | ទួលគ្រៀមគរ | ២៧០ | ៣០០០-៥០០០ | ២៧០ | ជាង៥០០០ | ១៩៩៥/៩៦ |
| ៦៤ | ១៤១០០៤ | វត្តចាស់ | ១ | អដ្ឋិធាតុ៣០០០ | គ្មាន | ៣០០០ | ១៩៩៥/៩៦ |
| ៦៥ | ១៥០១០៩ | បឹងបត់កណ្តាល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៦៦ | ១៥០១១០ | ព្រៃភាគ | ៣០០-៤០០ | ១៥០០០ | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៦៧ | ១៥០១១១ | ដូនអាម | ២ | ៩៥០ | ២ | ៩៥០ | ១៩៩៥/៩៦ |
| ៦៨ | ១៥០២០២ | ក្បាលឈើពុក | ១ | ៨០០ | ១ | ជាង៨០០ | ១៩៩៥/៩៦ |
| ៦៩ | ១៥០២០៣ | ទួលតាប៉ែវ | ៣០ | ៣០០០ | គ្មាន | ៣០០-៥០០ | ១៩៩៥/៩៦ |
| ៧០ | ១៥០៤០៧ | វត្តកណ្តាល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៧១ | ១៥០៤០៨ | វត្តកណ្តាល | ៣០០ | ៩០០ | ៣ | ៩០០ | ១៩៩៥/៩៦ |
| ៧២ | ១៥០៥០៤ | វត្តកោះជុំ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៧៣ | ១៥០៥០៥ | វត្តកោះជុំ | ១០០ | ១៣០០ | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៧៤ | ១៧១០០១ | វត្តអដ្ឋិការាម | ២ | គ្មាន | យ៉ាងតិច៨ | ៨០០០ | ១៩៩៥/៩៦ |
| ៧៥ | ១៧១០០២ | វិទ្យាល័យសៀមរាប | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៧៦ | ១៧១០០៣ | ត្រពាំងសេះ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៧៧ | ១៧១០០៤ | គុកសៀមរាប | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៧៨ | ១៧១០០៥ | វត្តធម្មយុត្តិ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៧៩ | ១៨០១០១ | អូគ្រាវ | ២៥០ | ១០០០ | គ្មាន | គ្មាន | ១៩៩៥/៩៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨០ | ១៨០២០១ | តាកែ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៨១ | ១៨០២០២ | តាកែ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៨២ | ១៨០២០៣ | ចម្ការម្រេច | ជាង២០០ | ១៥០០ | ប្រហែល២០០ | ប្រហែល១២០ | ១៩៩៥/៩៦ |
| ៨៣ | ១៨០២០៤ | វត្តទួល | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៨៤ | ១៨០២០៥ | វាលស្បូវ | ជាង៥០ | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៨៥ | ១៨០២០៦ | ទួលចម្ការកៅស៊ូ | ៣០ | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៨៦ | ១៨០២០៧ | កោះខ្សង | ៧ | ជាង១០០ | ២ | គ្មាន | ១៩៩៥/៩៦ |
| ៨៧ | ១៨០២០៨ | តាសេក | ៣ | គ្មាន | រណ្តៅខ្លះៗ | គ្មាន | ១៩៩៥/៩៦ |
| ៨៨ | ១៨០២០៩ | តាសេក | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៨៩ | ២០០១០១ | ទប់ខ្សាច់ | ៤៣៩ | ១៨១៣ | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៩០ | ២០០២០១ | តាណា | ៥ | ២១៤ | ៥ | ច្រើនពាន់ | ១៩៩៥/៩៦ |
| ៩១ | ២០០២០២ | តាណា | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៩២ | ២០០២០៣ | វត្តឫស្សីសាញ់ | ៥ | ៣១៩ | ៣ | អដ្ឋិធាតុ១០០០ | ១៩៩៥/៩៦ |
| ៩៣ | ២០០២០៤ | វត្តឫស្សីសាញ់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៩៤ | ២០០៥០១ | ធ្លក | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ៩៥ | ២០០៥០២ | ធ្លក | ៤១ | ច្រើនពាន់ | ៤១ | ១០០០០-១៥០០០ | ១៩៩៥/៩៦ |
| ៩៦ | ២០០៥០៣ | វត្តស្វាយផ្អែម | ១៤ | ១៦៨ | ២ | ៤៤ | ១៩៩៥/៩៦ |
| ៩៧ | ២០០៥០៤ | វត្តចាស់ | គ្មាន | គ្មាន | ៩ | ១០១ | ១៩៩៥/៩៦ |
| ៩៨ | ២០០៥០៥ | (សារមន្ទីរ)បឹងរ៉ៃ | ២៨ | ២០០០០-៣០០០០ | ២៨ | ៣៣០ | ១៩៩៥/៩៦ |
| ៩៩ | ២០០៧០១ | វត្តគីរីរំដួល | គ្មាន | គ្មាន | រណ្តៅសាកសពរួម | គ្មាន | ១៩៩៥/៩៦ |
| ១០០ | ២១០៦០១ | ទួលស្វាយ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ១០១ | ២១១០០១ | ភ្នំសន្ទុង | ១៦ | គ្មាន | លើសពី១ | គ្មាន | ១៩៩៥/៩៦ |
| ១០២ | ២១១០០២ | វត្តព្រៃផ្គាវ | គ្មាន | ៥០០(?) | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ១០៣ | ២១១០០៣ | វត្តជើងចាប | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ១០៤ | ២១០៦០២ | វត្តពោធិមាសអណ្តែត | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៥/៩៦ |
| ១០៥ | ២១០៩០១ | វត្តក្រាំងតាចាន់ | ២១ | ១០០៤២ | គ្មាន | គ្មាន | ១៩៩៥/៩៦ |

**(នៅមានត)**

តួលេខដែលចុះផ្សាយនៅក្នុងលេខនេះ សម្រាប់ខេត្តព្រៃវែង ពោធិសាត់ សៀមរាប ក្រុងព្រះសីហនុ ស្វាយរៀង និងខេត្តតាកែវ ។

◆ ចំពោះពត៌មានដែលដាក់ថា "គ្មាន" មានន័យថាពុំមានសាក្សីឬតួលេខ ប៉ុន្តែវត្តមានទីតាំងបានមកពីប្រភពផ្សេង ។

◆ ចំពោះពត៌មានដាក់ស្តែងនិងពត៌មានតាមរបាយការណ៍ មានន័យខុសគ្នាត្រង់ថា ពត៌មានដាក់ស្តែងគឺបានមកពីសាក្សីដែលបញ្ជាក់ប្រាប់នៅទីតាំងកើតហេតុ ។ ពត៌មានតាមរបាយការណ៍ មានន័យថា សាក្សីផ្សេងទៀតដែលប្រាប់តួលេខអំពីទីតាំងដដែល ។

**(តពីលេខមុន)** ក្រោយពេលកត់ត្រាកាលបរិច្ឆេទរួចហើយ បុគ្គលិកធ្វើការនៅមន្ទីរ ស-២១ និងអ្នកទោសមានឋានៈតូចតាច បានដាក់ឈ្មោះអ្នកដែលធានាខ្លួនឲ្យចូលបម្រើការងារ[បដិវត្តន៍]។ ជាទូទៅ អ្នកធានាច្រើនតែជាអ្នកធ្វើការនៅតាមភូមិ ឬជាកម្មាភិបាលយុទ្ធជន។

សំណួរបន្ទាប់មកទៀតគឺទុកចន្លោះឲ្យសរសេរអំពី“មូលហេតុចូលបដិវត្តន៍”។ នៅក្នុងចម្លើយសារភាព ចំណុចនេះតែងតែត្រូវភ្លេចបំពេញ។ ប៉ុន្តែផ្ទុយទៅវិញ បន្ទាប់ពីពេល“ចូលបដិវត្តន៍” បន្តិចក្រោយមក អ្នកទោសភាគច្រើនសារភាពថាបានចូលបម្រើសេ.អ៊ី.អា ឬអង្គការបរទេសផ្សេងទៀត។ ប៉ុន្តែមិនគួរឲ្យជឿសោះថា ពិធីបញ្ចូលសេ.អ៊ី.អាដែលអ្នកទោសបានរៀបរាប់ប្រាប់ មានលក្ខណៈដូចគ្នានឹងប្រការផ្សេងៗដែលចែងនៅក្នុងលក្ខន្តិកៈបក្ស ក្នុងការចូលបម្រើបក្សកុម្មុយនិស្តកម្ពុជា។ អ្នកទោសនៅចាំថា ធ្លាប់បានធ្វើសច្ចាប្រណិធាន និងគោរពទង់ជាតិ នៅចំពោះមុខអ្នកធានារបស់ខ្លួន។ ដោយសារមានការបង្ខំឲ្យសារភាពថា បានចូលបម្រើអ្វីដែលខ្លួនមិនដែលធ្លាប់ឮទាល់តែសោះនោះ អ្នកទោសបានត្រឹមតែនិយាយប្រាប់អំពីជំហានការងារនយោបាយមួយមុខតែប៉ុណ្ណោះ ដែលមានអ្នកទោសមួយចំនួន (ឬអ្នកសួរចម្លើយ) ធ្លាប់បានធ្វើកន្លងមក។



**សម្លេងពីមន្ទីរ ស-២១**
**ខគ្គទី៤: ការបង្កើតសំណួរសម្រាប់ធម្លាក់កំហុស**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

អ្នកទោសមួយចំនួនដែលមានវ័យចំណាស់ៗបន្តិច បាននិយាយថា សេ.អ៊ី.អា គឺជាអង្គការរបស់អាមេរិក។ អ្នកទោសទាំងនោះបានអះអាងថាខ្លួនធ្លាប់បានជ្រើសរើសឲ្យចូលបម្រើអង្គការនេះដោយជនជាតិអាមេរិកាំងផ្ទាល់ ហើយថាធ្លាប់បានទទួលប្រាក់ខែជាប្រាក់ដុល្លារច្រើនៗទៀតផង។ ការអះអាងផ្សេងៗទៀតក៏មានលក្ខណៈដូចគ្នានេះដែរ។ ជាក់ស្តែង ឈ្មោះ ផៃ ឌី ដែលត្រូវបានចាប់ខ្លួននៅភូមិភាគឧត្តរនៅខែមិថុនា ឆ្នាំ១៩៧៦ បានពិពណ៌នាត្រួសៗអំពីប័ណ្ណសម្គាល់ខ្លួន។ ផៃ ឌី និយាយថា គាត់បានទទួលប័ណ្ណនេះកាលពីក្នុងសម័យ លន់ ណុល ដែលមានចុះហត្ថលេខាដោយ“ប្រធានសេ.អ៊ី.អា»ប្រចាំនៅទីក្រុងភ្នំពេញ ឈ្មោះ ចន ដេវីន។ អ្នកទោសម្នាក់ទៀតនិយាយថា ខ្លួនធ្លាប់ត្រូវបានជ្រើសរើសដោយជនជាតិអាមេរិកាំងម្នាក់ឈ្មោះ “កេនណេឌី” នៅទសវត្សរ៍ឆ្នាំ១៩៦០ ហើយបានសារភាពថា គ្រូបង្រៀនរបស់ខ្លួនមួយរូបក្នុងចំណោមគ្រូបង្រៀនដទៃទៀតនៅក្នុងវិទ្យាល័យ ពោលគឺ អៀង ធីរិទ្ធ (ដែលក្លាយជាប្រពន្ធរបស់ អៀង សារី តាំងពីឆ្នាំ១៩៥២) ក៏ជាភ្នាក់ងារសេ.អ៊ី.អាដែរ។ ការចោទប្រកាន់ដ៏ចម្លែកនេះធ្វើឲ្យ ឌុច ដែលកំពុងតែអាន បានចារសម្គាល់នៅគែមចម្លើយនោះថា “តើ អៀង ធីរិទ្ធ ជាប្រពន្ធរបស់អ្នកណា? តើឯងមានភស្តុតាងអ្វីមកបញ្ជាក់?»។

អ្នកទោសម្នាក់ទៀតដែលគ្រាន់តែដឹងថា“សេ.អ៊ី.អា”មានន័យផ្ទុយពីកម្ពុជាប្រជាធិបតេយ្យនោះ បាននិយាយថា ពាក្យកាត់របស់ សេ.អ៊ី.អា មានន័យថា “មានហូបគ្រប់គ្រាន់”។ អ្នកផ្សេងទៀតអះអាងថា អ្នកជ្រើសរើសឲ្យចូលសេ.អ៊ី.អាបាននិយាយប្រាប់ថា “នៅជាមួយសេ.អ៊ី.អានឹងមានស្រី ស្រា ល្ខោន ផ្សារផ្សា ផ្ទះថ្ម និងម៉ូតូជិះ» ឬថា “ក្រោយពីចូលសេ.អ៊ី.អា នឹងអាចដើរហើរដោយសេរី [ពីព្រោះ] គ្មានវិន័យអ្វីទេ”។ និយមន័យដែលបក្សកុម្មុយនិស្តអាចទទួលយកបាន គឺចេញពីមាត់របស់ ពេញ សុភាព ត្រូវជាកូនស្រីរបស់ សុខ ធួក (ហៅ វន វេត) ជាកម្មាភិបាលជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា។ សុភាព ត្រូវបានចាប់ខ្លួនជាមួយឪពុកនៅឆ្នាំ១៩៧៨។ សុភាព បានរំឭកដល់សម្តីម្តាយដែលនិយាយប្រាប់ខ្លួនថា «សេ.អ៊ី.អាគឺជាអ្នកដែលបង្កប់ស៊ីរូង

ផ្ទៃក្នុងបក្ស» ។

ស៊ីវ ហេឌ័រ មានប្រសាសន៍ថា «នៅក្នុងចម្លើយសារភាពនៅមន្ទីរស-២១ ពាក្យដូចជា សេ.អ៊ី.អា និង កា.ហ្សេ.បេ... ជាទូទៅមានន័យថា «ខ្មាំង» ។ ប្រសិនបើអ្នកឯងនិយាយថា អ្នកណាម្នាក់ជាសេ.អ៊ី.អា ពុំមែនអ្នកឯងចង់និយាយថា ម្នាក់នោះជាសមាជិករបស់អង្គការសេ.អ៊ី.អាឡើយ ប៉ុន្តែគឺអ្នកឯងចង់និយាយថាម្នាក់នោះជាខ្មាំងទៅវិញ» ។ ស្រដៀងគ្នានេះដែរ នៅក្នុងបដិវត្តន៍វប្បធម៌នៅប្រទេសចិន វាមិនសំខាន់ត្រង់ថា ខ្មាំងត្រូវហៅថាយ៉ាងម៉េចនោះទេ ឲ្យតែអ្នកនោះត្រូវបានសង្គមប្រកាសមិនទទួលស្គាល់និងថ្កោលទោសយ៉ាងស័ក្តិសិទ្ធិទៅវាជាការគ្រប់គ្រាន់ទៅហើយ ។ ឯកសារកាលពីជំនាន់នោះសរសេរថា «ដើម្បីចោទនរណាម្នាក់ ត្រូវយកចំណុចទាំងអស់នេះមកប្រើ÷ ស្តាំនិយមជ្រុល ឆ្វេងនិយមជ្រុល ប្រឆាំងបដិវត្តន៍ សមាសភាពមិនល្អ ភ្នាក់ងារសូវៀត ភ្នាក់ងារអាមេរិក ភ្នាក់ងារយេ.អ៊ុម.ធី ជាដើម ។ល ។» ក្នុងលក្ខណៈប្រហាក់ប្រហែលគ្នានេះដែរ លីន វ៉ៃ បានទាញហេតុផលថា «វិធានការនានាក្នុងការចោទប្រកាន់បុគ្គល» គឺជាផ្នែកមួយនៃនយោបាយរបស់ចិននៅក្នុងបដិវត្តន៍វប្បធម៌ដែលនាំឲ្យមានអំពើឃោរឃៅជាទ្រង់ទ្រាយធំ ។ ការយល់ស៊ីជម្រៅរបស់ លីន វ៉ៃ អាចស្របនឹងករណីរបស់កម្ពុជាប្រជាធិបតេយ្យ ដែលក្នុងរបបនេះ អ្នកណាក៏ដោយឲ្យតែត្រូវចោទថាជា «ខ្មាំង» គឺត្រូវបាននាំយកមកមន្ទីរ ស-២១ ឬត្រូវសម្លាប់នៅនឹងកន្លែងតែម្តង ដោយគ្មានបញ្ជាក់ឲ្យដឹងពីដំណើរដើមទងអ្វីទាំងអស់ ។

នៅក្នុងការភ្ជាប់អ្នកដែលត្រូវចោទប្រកាន់ទៅនឹងភ្នាក់ងារស៊ើបការណ៍សម្ងាត់បរទេសនានា អ្នកសួរចម្លើយនៅមន្ទីរស-២១ បានធ្វើតាមគន្លងវិធានការផ្សេងៗដែលធ្លាប់អនុវត្តនៅសហភាពសូវៀតកាលពីទសវត្សរ៍ឆ្នាំ១៩៣០ដែរ ។ កាលនោះ អ្នកទោសត្រូវបានចោទប្រកាន់ថាធ្វើការឲ្យភ្នាក់ងារស៊ើបការណ៍សម្ងាត់បរទេសក្នុងគោលបំណងផ្តួលរំលំរបបដឹកនាំដោយស្តាលីន ។ ពលរដ្ឋសូវៀតដែលមានភក្តីភាព មិនអាចត្រូវបានគិតថានឹងប្រឆាំងរបបនេះទេ ប៉ុន្តែអ្នកដែលហ៊ានប្រឆាំងត្រូវបានចាត់ទុកថា «មិនមែនជាប្រជាជនសូវៀតទេ» ។ នៅប្រទេសកម្ពុជាអ្នកដែលត្រូវបានចោទថាក្បត់នឹងបដិវត្តន៍ក៏ត្រូវបានគិតថា «មិនមែនជាខ្មែរ»ដែរ ។ សុន្ទរកថារបស់សមមិត្ត ប៉ុល ពត ដែលថ្លែងកាលពីខែធ្នូ ឆ្នាំ១៩៧៧ បញ្ជាក់ថា «យើងបាន[កម្ចាត់]ខ្សែបង្កប់អន្តរជាតិហើយ ។ ខ្សែធំៗទាំងបីនោះគឺ សេ.អ៊ី.អារបស់អាមេរិក កា.ហ្សេ.បេរបស់សូវៀត និងខ្សែវៀតណាមលេបទឹកដី ។

នៅឆ្នាំ១៩៩៧ ប៉ុល ពត បានប្រាប់ទៅអ្នកកាសែតឈ្មោះណេត ថេយ័រ ថា «ភ្នាក់ងារវៀតណាម» ជាអ្នកទទួលខុសត្រូវចំពោះការស្លាប់ភាគច្រើនស្ទើរតែទាំងអស់ដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រៅពីយួនតើមានអ្នកណា បើបក្សយើងមានបំណងបរិសុទ្ធជាជនជាតិខ្មែរពិតៗ មានចិត្តស្មោះត្រង់ ហើយបក្សមានគំនិតផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រនោះ ។

វគ្គបន្តមកទៀតដែលនិយាយអំពីប្រវត្តិរូប មានសំណួរជាច្រើនដែលសួររក «ចំណុចខ្លាំង» និង «ចំណុចខ្សោយ» ។ នៅក្នុងចម្លើយសារភាព «ចំណុចខ្លាំង» មិនឃើញមានទេ ប៉ុន្តែ«ចំណុចខ្សោយ» ត្រូវបានកត់ចូលក្នុង «ប្រវត្តិសកម្មភាពក្បត់» ។ «ប្រវត្តិសកម្មភាពក្បត់នោះមិនត្រឹមតែកត់ចូលនូវសកម្មភាពរបស់អ្នកទោសតែប៉ុណ្ណោះទេ តែថែមទាំងរៀបរាប់ការណ៍អំពីការសន្ទនាទៀតផងដែលក្នុងនោះមានត្អូញត្អែរអំពីជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ភាគច្រើននៃការត្អូញត្អែរនេះបង្ហាញអំពីការរិះគន់ចំពោះកម្ពុជាប្រជាធិបតេយ្យ របស់អ្នកដែលបានរស់រានមានជីវិតពីរបបនោះ ។ ការរិះគន់ទាំងនោះរៀបរាប់អំពីជាតិមួយដែលប្រជាជនត្រូវញាំញីដោយភាពក្រីក្រ ស្លៀកពាក់ខោអាវរហែករយ៉ែ គ្មានអាហារគ្រប់គ្រាន់ ធ្វើការធ្ងន់នៅក្រោមការឃ្លាំមើលនិងការគំរាមកំហែងជាប់ជាប្រចាំ គ្មានការទុកចិត្តគ្នារស់នៅក្រោមវិន័យតឹងរ៉ឹងហួសប្រមាណ គ្មានសិទ្ធិសេរីភាពដើរហើរ ។

អ្វីដែលអ្នកទោសនឹកឃើញខ្លាំងជាងគេ ប្រហែលជា «សុភមង្គល» ហើយមើលទៅ ។ សុភមង្គលជាស្ថានភាពមួយពិបាកយល់និងពិបាកស្មាន ដែលកើតឡើងនៅក្នុងជីវិតគ្រួសារដូចជាមានការហូបចុកគ្រប់គ្រាន់ និងសេរីភាពក្នុងការដើរហើរទៅកន្លែងណាមួយដែលខ្លួនពេញចិត្តជាដើម ។ ការនឹកអាឡោះ

អាល័យនេះមានផលប៉ះពាល់ដល់សតិអារម្មណ៍របស់អ្នកធ្វើការនៅក្នុងគុកដែរ ។ នៅពេលដែលអ្នកទោសម្នាក់ឈ្មោះ យស់ ធឿន តូញត្អែរថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ "យើងរស់នៅដូចសត្វជាប់ទ្រុង" ហើយ ហ៊ុយ សាវ៉ន ប្រៀបធៀបបដិវត្តន៍ទៅនឹង "រស់នៅក្នុងគុក" អ្នកធ្វើការនៅក្នុងគុកដែលកត់ត្រាការចោទប្រកាន់ ប្រាកដជាបាត់មាត់ដូចត្រូវគេចុកអ៊ីចឹង ។ ការនិយាយរបៀបនេះបានលេចឡើងក្រោយមកទៀតនៅក្នុងចម្លើយសារភាពរបស់អ្នកធ្វើការនៅក្នុងគុកផ្ទាល់តែម្តង ។

អ្នកទោសភាគច្រើនជាយុទ្ធជនវ័យក្មេងដែលស្គាល់ពិភពលោកយើងនេះតិចតួចបំផុត ។ ជាក់ស្តែង នៅគ្រប់ឯកសារចម្លើយសារភាពដែលខ្ញុំបានជួបប្រទះ មិនឃើញមាននិយាយអំពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ដូចជាការបិទទ្វារសាលានិងសារព័ត៌មាន ការដកហូតអំណាចរបស់អ្នកមាននិងអ្នកចេះដឹង ការលុបបំបាត់មិនឲ្យមានតុលាការនិងការបោះឆ្នោត ឬការជម្លៀសប្រជាជនទីក្រុងដោយបង្ខំផងទេ ។ ចម្លើយសារភាពបីដែលខ្ញុំបានអាន មាននិយាយតូញត្អែរអំពីការគាបសង្កត់ទៅលើសាសនា ប៉ុន្តែមានបង្ហាញការសោកស្តាយចំពោះការបាត់បង់ពិធីបុណ្យប្រពៃណីផ្សេងៗ ជាជាងបាត់បង់ឱវាទរបស់ព្រះពុទ្ធ ។ អ្នកដែលសោកស្តាយចំពោះការបាត់បង់យសស័ក្តិ មុខមាត់ និងកិត្តិយស មិនសោកស្តាយចំពោះការបាត់បង់ ឬការអាម៉ាស់មុខរបស់អ្នកមានបុណ្យស័ក្តិខ្ពង់ខ្ពស់ ឬការបំផ្លាញកេរ្តិ៍ឈ្មោះ ។ ប៉ុន្តែផ្ទុយទៅវិញអ្នកទោសដែលសោកស្តាយចំពោះការបាត់បង់សិទ្ធិ បានសារភាពថាខ្លួនចង់បានសិទ្ធិនេះសម្រាប់ខ្លួនឯងផ្ទាល់ដែរ ។

អ្នកទោសក៏បានតូញត្អែរជាញឹកញយអំពីវិន័យតឹងតែងនៅក្នុងជីវិតបដិវត្តនេះ ។ អ្នកទោសនិយាយថា រស់នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ខ្លួនមិនអាច"ដើរទៅណាមកណាតាមចិត្ត" "ដើរលេងជាមួយគ្រួសារនិងមិត្តភក្តិ" បានទេ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកទោសត្រូវធ្វើការដោយមានការបង្ខំពីមុខពីក្រោយ ។ ណុប នួន អតីតអ្នកសួរចម្លើយបាននិយាយថា "អង្គការបញ្ជាយើងវិវត់ដូចជាគោក្របីអ៊ីចឹង" ហើយ គីម ជឿង រំពុកទាំងជូរចត់ថា "យើងរស់នៅក្រោមការដឹកនាំរបស់គេ ។ អ្នកឯងត្រូវសុំការអនុញ្ញាតធ្វើនេះធ្វើនោះ ...នៅអំឡុងពេលសង្គ្រាម (១៩៧០-៧៥) យើងធ្វើទ័ពក៏ជួបការលំបាកដែរ ។ នៅក្នុងសមរភូមិប្រយុទ្ធស្លាប់រស់ យើងមិនដែលគិតរឿងលំបាកអ្វីទេ ពីព្រោះនៅទីបញ្ចប់យើងចង់បានសេរីភាពនិងភាពសប្បាយរីករាយ ។ ប៉ុន្តែជាលទ្ធផល នៅពេលសង្គ្រាមចប់ អ្វីៗគ្រប់យ៉ាងនៅតែបន្តពិបាករហូតគ្មានពេលស្រាកស្រាន្តដដែល" ។

អ្នកទោសជាច្រើន ច្រើននឹកដល់ពេលដែលខ្លួនធ្លាប់មានសេរីភាពក្នុងការសម្រេចអ្វីដែលខ្លួនត្រូវធ្វើបន្ទាប់ទៅទៀត ។ នៅខណៈដែលដឹងខ្លួនថា"អស់សេរីភាព" នៅក្នុងកិច្ចប្រជុំនយោបាយ ហើយនិងត្រូវបានភ្ជាប់ទំនាក់ទំនងអំពីសកម្មភាពអាក្រក់របស់ខ្លួនជាមួយអាមេរិកនោះ អ្នកទោសភាគច្រើនបានរំពុកឡើងវិញដោយពេញចិត្តនូវសេរីភាពផ្ទាល់ខ្លួនដែលធ្លាប់បានទទួលមុនពេលមានសង្គ្រាមស៊ីវិល ។ ព្រំ យ៉ុន បានរៀបរាប់ជំហរ "ប្រឆាំងបដិវត្តន៍"ដូចតទៅនេះ÷ "ខ្ញុំចង់ហូបអីក៏បាន ចង់ធ្វើអ្វីក៏ធ្វើទៅ ចង់ដើរទៅណាក៏ដើរទៅ" ។ អ្នកទោសម្នាក់ទៀតនិយាយថា "កាលពីសង្គមចាស់គ្មានការសម្ងាត់អ្វីឡើយ បើអ្នកឯងមានលុយ អ្នកឯងសប្បាយហើយ" ។ អ្នកទោសទីបីសារភាពថាមាន"កំហុស" ក្នុងការ"បំផុសឲ្យប្រជាជនស្រលាញ់សុភមង្គលដែលធ្លាប់មានកាលពីមុន" ។

អ្នកទោសក៏នឹកអាល័យដល់ការរស់នៅសុខដុមរម្យនាជាមួយសាច់ញាតិបងប្អូននិងមិត្តភក្តិដែរ ។ មានអ្នកខ្លះស្តាយមិនបានលេងល្បែង រាំវង់ មើលល្ខោន ភាពយន្ត លេងស្រី ផឹកស្រា ដូចកាលពីមុន ដែលជាអំពើមួយត្រូវហាមប្រាមនិងកាត់បន្ថយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការសោកស្តាយទាំងនេះកើតឡើងជាញឹកញយនៅក្នុងចម្លើយសារភាពរបស់អ្នកទោសវ័យក្មេងដែលនិយាយថា ខ្លួននិយាយអ្វីដែលខ្លួនគិតថាអ្នកសួរចម្លើយចង់ស្តាប់ ។ មើលទៅប្រហែលជាមិនពិតទេដែលថា ភាគច្រើននៃអ្នកទោសវ័យក្មេងធ្លាប់បានរីករាយនឹងពេលវេលាកាលពីមុន មានលុយ ឬពេលសប្បាយក្លាយជាអ្នកលេងល្បែង អ្នកផឹកស៊ីស្រីញីអូនបង ពីព្រោះអំពើទាំងអស់នេះគ្រាន់តែជាការស្រមៃរបស់អ្នកទោសតែប៉ុណ្ណោះ ។ អ្នកទោស

ប្រហែលជាស្ទានដល់នូវកម្រិត «ទោស» ដែលបណ្តាលមកពីអំពើដូចរៀបរាប់នេះ ។ នៅពេលឲ្យសរសេរសកម្មភាព«ប្រឆាំងនឹងបដិវត្តន៍» អ្នកទោសបេះតែប្រឌិតរឿងផ្សេងៗ ដូចជាធ្លាប់បានរួមភេទ និយាយលេងសើច លេងបៀ និងផឹកស្រាជាដើម ។ អ្នកទោសភេទស្រីត្រូវបានលួងឲ្យឆ្លើយថាធ្លាប់មានទំនាក់ទំនងនឹងរឿងនេះជាច្រើនដង ។ អ្នកទោសភេទប្រុសត្រូវឈរពេញៗមួយយប់ ។

ជាទូទៅ អ្នកទោសជាច្រើនបានសម្តែងនូវការអាឡោះអាល័យចំពោះជីវិតរបស់ខ្លួនមុនសម័យបដិវត្តន៍ ។ ការត្អូញត្អែររបៀបនេះលេចឡើងជារឿយៗ ហើយដូចៗគ្នានៅក្នុងឯកសារនានា សរសេរឡើងតាមខែនីមួយៗផ្សេងគ្នា ។ វាហាក់ដូចជាច្បាប់ដើមដែលមើលទៅមានលក្ខណៈសមរម្យជាចម្លើយសារភាពត្រូវបានអ្នកសួរចម្លើយឬអ្នកធ្វើការខាងឯកសារស្រង់ចេញជាអត្ថបទដោយមិនខ្វល់ពីអ្វីដែលអ្នកទោសបានធ្វើឬនិយាយឡើយ ។ វាអាចជាការពិតដែលថា ចម្លើយសារភាពរបស់អ្នកទោសដែលមានឋានៈតូចតាចជាច្រើននាក់ ត្រូវបានអ្នកធ្វើការខាងឯកសារស្រាក់បញ្ចូលគ្នាដោយមិនចាំបាច់សួរចម្លើយច្រើនឡើយ នៅពេលដែលទម្រង់ទូទៅនៃ «កំហុស» និងអ្វីដែលបង្កើតបានជាការត្អូញត្អែរដែលអាចទទួលយកបាន ចេញជារូបរាងច្បាស់ហើយនោះ ។ ជាក់ស្តែង អតីតអ្នកសួរចម្លើយឈ្មោះ ឈឹម ឈុន បានសារភាពនៅក្នុងចម្លើយរបស់ខ្លួនថា «បានត្រឹមតែសរសេរដំណើររឿង(របស់អ្នកទោស)ណាដែលងាយសរសេរប៉ុណ្ណោះ ។ ប្រសិនបើដំណើររឿងស្មុគស្មាញច្រើនពេក ហើយពិបាកសរសេរ ខ្ញុំគ្រវាត់វាចោល» ។

ទោះជាមានទង្វើបែបនេះយ៉ាងណាក៏ដោយ ក៏ចម្លើយសារភាពដែលបញ្ជាក់ពីកង្វះខាតចំពោះបដិវត្តន៍ តែងតែមានលក្ខណៈស្មោះត្រង់ខុសពីធម្មតាដែរ ។ ឧទាហរណ៍ជាក់ស្តែង នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ ឈិន ជាប អតីតទាហាននៅក្នុងកងពលធំ១០៣ បានរំឭកនូវកិច្ចសន្ទនាជាមួយសមមិត្តរបស់គាត់ម្នាក់÷ «ឈុន នៅកងពល៣១០ ធ្វើឲ្យខ្ញុំមើលឃើញថាបដិវត្តន៍ខ្មោងផឹតទាំងអស់ ។ ឈុន និយាយថា ធ្វើបដិវត្តន៍សព្វថ្ងៃនេះពិបាកណាស់ ហើយច្របូកច្របល់ទៀតផង ទាំងការស្លៀកពាក់ ទាំងការហូបចុក មិនដែលបានគ្រប់គ្រាន់ម្តងណាទេ ។ ឈុន និយាយទៀតថា លំបាកនៅពេលមានសង្គ្រាមវាគ្រប់គ្រាន់ទៅហើយ ប៉ុន្តែនៅពេលសង្គ្រាមចប់រឹតតែពិបាកលើសមុនទៅទៀត ។ គ្មានពេលសម្រាកទេ ។ បើធ្វើការប្រៀបធៀបទៅឃើញថា ពួកវាប្រើយើងដូចគោក្របីអ៊ីចឹង ប៉ុន្តែមិនឲ្យស៊ីស្មៅទេ ។ ហើយមិនតែប៉ុណ្ណោះសោត អ្នកឯងមិនអាចរស់នៅកន្លែងដែលអ្នកឯងចង់រស់ទេ គ្មានសេរីភាពទាំងអស់ បើគ្មានការអនុញ្ញាតទេ សូម្បីតែដើរមួយជំហានក៏អ្នកឯងដើរមិនបានផង ។ សព្វថ្ងៃនេះ យើងរស់នៅគ្មានសប្បាយទេ ។ គ្មានការលេងសើច ...ប៉ុន្តែផ្ទុយមកវិញ បើយើងក្រឡេកមើលសង្គមចាស់វិញ កាលនោះឪពុកម្តាយយើងធ្វើការមែន តែមិនយ៉ាប់ណាស់ណាទេ ហើយគាត់មិនដែលខ្វះអាហារហូបចុកឡើយ គឺរស់នៅដោយសប្បាយ មានឯករាជ្យ និងដោយស្រួលទៀតផង ។ បើយើងចង់ធ្វើអីធ្វើទៅ គ្មានអ្នកណាឃាត់អ្នកណាឃាំងទេ បើចង់ចាយវាយក៏បាន ព្រោះយើងមានលុយ ៗ»

មុននេះមួយខែ ឌិត គង់ ដែលធ្វើទាហានដូច ឈុន ដែរ បានរំឭកឡើងវិញថា «កាលពីខែកុម្ភៈ ឆ្នាំ១៩៧៦ ស៊ុង បានប្រាប់ខ្ញុំថា បើសិនជាអ្នកឯងធ្វើបដិវត្តន៍សង្គមនិយម ហូបមិនឆ្ងាញ់ទេ ហើយអ្នកឯងធ្វើការក៏ឥតមានពេលសម្រាកដែរ ពោលគឺធ្វើរហូតទាល់តែដួលនៅនឹងកន្លែង ។ អ្នកឯងធ្វើការទាំងយប់ទាំងថ្ងៃគ្មានពេលសម្រាកសូម្បីតែបន្តិចក៏គ្មានផង អ្នកឯងគ្មានសិទ្ធិសេរីភាពទាល់តែសោះ ។ ធ្វើបដិវត្តន៍គឺហូបបបរទាំងព្រឹកទាំងថ្ងៃ ហើយការហូបចុកនោះក៏មិនគ្រប់គ្រាន់ទៀត ។ ទៅណាមកណាត្រូវមានសំបុត្រអនុញ្ញាត ។ ចេញចូលត្រូវមានវិន័យត្រឹមត្រូវ ។ នៅពេលដែលអ្នកឯងធ្វើបដិវត្តន៍សង្គមនិយមគ្មានប្រាក់ខែ គ្មានបុណ្យសក្តិ គ្មានស្រី គ្មានស្រា គ្មានល្បែង គ្មានឡានជិះទេ ។ អ្នកឯងត្រូវដើររហូត ទៅណាក៏ដើរដែរ» ។

**(នៅមានត)**

◆ **ដឹកនាំធ្វើការងារល្អ គឺភ្ជាប់សភាពការណ៍ជាប់និងច្បាស់ វិភាគសភាពការណ៍ជាប់និងច្បាស់ ហើយមានវិធានការត្រូវច្បាស់ល្អ។**

*(សៀវភៅលេខ ០៧៦ៈ កណបហ)*

# កុមារស្មាគស្មំ បដិវត្តន៍បរាជ័យ

“មានតែកុមារទេទើបអាចបម្រើបដិវត្តន៍ កម្ទាត់ខ្មាំងប្រតិកិរិយាបាន ព្រោះកុមារនៅក្មេងខ្ចី ធ្វើអ្វីស្តាប់បញ្ជា ស្មោះត្រង់ ហើយនិងសកម្មប្រយុទ្ធ” ។ គំនិតនេះត្រូវបាន សមមិត្តនារី អៀង ធីរិទ្ធ រដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌និងសង្គមកិច្ច ឡើងមានមតិយល់ស្របនិងបញ្ជាក់បន្ថែមតាមសំណូមពររបស់ សមមិត្តលេខា ប៉ុល ពត ក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីនាថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៦ ។ នៅពេលដាក់គោលការណ៍នេះចេញ អង្គប្រជុំក៏បានទទួលស្គាល់នូវអសមត្ថភាពរបស់កុមារ ប៉ុន្តែបានចាត់ទុកថាជាបញ្ហាបណ្តោះអាសន្ន ។ ក្រោយមកពុំមានវិធានការគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហានេះឡើយ ដែលវាជាហេតុមួយនាំឲ្យបដិវត្តន៍ទទួលបរាជ័យ ។ ចំណែកឯកុមារវិញត្រូវរងទុក្ខទោសរហូតមកដល់បច្ចុប្បន្ន ។ ខ្ញុំនឹងលើកយកដំណើរជីវិតកុមារីពេទ្យម្នាក់មកបង្ហាញជាឧទាហរណ៍ដូចខាងក្រោមនេះ ÷

សារិន រស់នៅខេត្តតាកែវ មិនចេះអក្សរច្បាស់លាស់ ដោយសារតែគាត់បានចូលរៀនអក្សរចំនួន២ម៉ោងប៉ុណ្ណោះក្នុងមួយថ្ងៃ ក្នុងរយៈពេលប្រហែល ១ឆ្នាំ ។ ក្រោយមកគាត់បានរៀនបច្ចេកទេសពេទ្យបណ្តើរ ធ្វើជាកម្មាភិបាលពេទ្យនៅមន្ទីរពេទ្យ៦មករាបណ្តើរ (មន្ទីរពេទ្យធំនៅទីក្រុងភ្នំពេញបច្ចុប្បន្ន) ។ សារិន រៀនតែនៅក្នុងរយៈពេល៣ខែ ដើម្បីមើលថ្នាំនិងចាក់ថ្នាំ (ដោយធ្វើការចាក់ទៅលើខ្ទើយនិងដើមចេកជាការរៀនសូត្រ) ។ សារិន រៀនមើលថ្នាំតាមការចំណាំទៅលើរូបរាងនៃថ្នាំ ។ វិធីនេះអាចឲ្យគាត់ដឹងត្រឹមថា តើថ្នាំមួយណាចាក់ត្រគាក ហើយថ្នាំមួយណាចាក់សរសៃ ។ សារិន មិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាមនុស្សថ្មីដើម្បីកសាងសង្គមថ្មី បដិវត្តន៍ថ្មី តាមគោលនយោបាយរបស់ខ្មែរក្រហមនៅឡើយទេ ។ សមមិត្តនារី អៀង ធីរិទ្ធ ក៏បានទទួលស្គាល់ដែរថា កម្មាភិបាលពេទ្យមើលថ្នាំច្រឡំ ព្រោះមិនចេះមើលអក្សរ ។ ចំណែក រៀល សន ដែលជាប្រធានពេទ្យស្រុកត្រាំកក់ ខេត្តតាកែវក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ធ្លាប់បានជួបប្រទះដោយផ្ទាល់នូវកម្មាភិបាលពេទ្យរបស់គាត់ ដែលបានចាក់ថ្នាំឲ្យអ្នកជំងឺខុស បណ្តាលឲ្យមានគ្រោះថ្នាក់រហូតដល់ស្លាប់ (ដែលជាមូលហេតុមកពីការមិនចេះអក្សរ) ។



ជ័យ សារិន

មុនពេលដែលរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩ សារិន ព្រមទាំងអ្នកជំងឺមួយចំនួនបានភៀសខ្លួនតាមរថភ្លើង

ឆ្ពោះទៅខេត្តបាត់ដំបង ។ សារិន ត្រូវបានជ្រើសរើសឲ្យធ្វើជាពេទ្យក្នុងជួរកងទ័ព ។ គាត់បានគេចខ្លួន ប៉ុន្តែត្រូវចាប់បានមកវិញនៅខេត្តពោធិសាត់ ហើយត្រូវបញ្ជូនឲ្យទៅជីក "ប្រឡាយជ័យជំនះ" ។ សារិន បានរត់រួចពីការជីកប្រឡាយនៅខេត្តពោធិសាត់ដោយដក់ជាប់នូវទិដ្ឋភាពសម្លាប់មនុស្សដែលគាត់បានឃើញនៅទីនោះ ។ គាត់រំឭកថា "ខ្ញុំចាំមិនភ្លេចទេ រឿងដែលខ្ញុំរត់ចេញពីការដ្ឋានជីកប្រឡាយ ជួនកាលខ្ញុំយល់សប្តិឃើញគេដេញបាញ់ខ្ញុំទៀតផង" ។

ជីវិតជាកុមាររបស់ សារិន ក៏មិនខុសពីជីវិតរបស់កុមារដទៃដែលត្រូវបានជ្រើសរើសឲ្យបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។ កុមារទាំងអស់ត្រូវបានចាត់ទុកជាកូនរបស់អង្គការ ហើយមានតែអង្គការមួយគត់ដែលមានគុណបំណាច់ចំពោះកុមារ ។ កុមារលែងជាកូនរបស់ឪពុកម្តាយទៀតហើយ ។ ដើម្បីបង្ហាញនូវលក្ខណៈឯកភាពនិងការរាប់អានស្មើគ្នាចំពោះគ្រប់មនុស្សទាំងអស់ ប្រធានកងកុមារបង្រៀនកុមារឲ្យហៅគ្នាថា "មិត្ត" សូម្បីតែឪពុកម្តាយខ្លួនឯងក៏ សារិន ហៅ"មិត្ត"ដែរ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏មនោសញ្ចេតនាពីធម្មជាតិរវាងឪពុកម្តាយនិងកូនមិនអាចកាត់ផ្តាច់បានឡើយ ។ សារិន តែងតែរត់មកផ្ទះដើម្បីជួបឪពុកម្តាយ ប៉ុន្តែដោយសារការភ័យខ្លាចចំពោះការធ្វើទណ្ឌកម្ម ទើប សារិន រាងចាលនិងកាត់ចិត្តលែងនឹកនាដល់ឪពុកម្តាយទៀត ។

នៅក្នុងរបបខ្មែរក្រហម សារិន មិនហ៊ានរាប់អានបងបង្កើតដែលធ្វើការជាមួយគ្នាទេ ព្រោះបារម្ភថាប្រសិនបើបងរបស់គាត់បានប្រព្រឹត្តកំហុសអ្វីមួយនោះ ទោសកំហុសនោះនឹងត្រូវរាលដាលដល់ខ្លួនគាត់ដែរ ។ រហូតមកដល់ពេលនេះទើប សារិន យល់ថា បងប្អូននិងគ្រួសារគឺសំខាន់ណាស់សម្រាប់ជីវិតមនុស្សគ្រប់រូប ។ គាត់មានប្រសាសន៍ថា "តែហួសពេលហើយ បងរបស់ខ្ញុំបាត់ខ្លួនមិនឃើញវិលត្រឡប់មកវិញទេ" ។ បច្ចុប្បន្ននេះ សារិន មានអាយុ៣៧ឆ្នាំ ជាកសិករនៅភូមិត្រពាំងធំ ខាងជើង ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ។

**គីម កែវកន្និដ្ឋា**

# ហ៊ូ យន់



ហ៊ូ យន់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហករណ៍ និងកែទម្រង់ជនបទនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅឆ្នាំ១៩៥៥ ហ៊ូ យន់ ទទួលបានសញ្ញាប័ត្របណ្ឌិតសេដ្ឋកិច្ចមកពីសាកលវិទ្យាល័យប៉ារីស ។ នៅឆ្នាំ១៩៥៨ ហ៊ូ យន់ ត្រូវបានជ្រើសតាំងជាតំណាងរាស្ត្រខេត្តកំពង់ចាម ហើយបានចូលរួមឈរឈ្មោះបោះឆ្នោតជាបន្តបន្ទាប់មុនពេលឃ្លាតឆ្ងាយពីទីក្រុងភ្នំពេញនិងនយោបាយសភាជាតិ ។

ចំពោះបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនវិញ ហ៊ូ យន់ ត្រូវបានចាត់ទុកជាមនុស្សដែលហ៊ាននិយាយរិះគន់ចំៗ និងមានចរិតឆេវឆាវជាង ខៀវ សំផន ហើយជាអ្នកប្រកាន់ខ្ជាប់លទ្ធិម៉ាក្សចាស់គំរិល ។

## ពន្យល់ពាក្យរបស់ខ្មែរក្រហម

- **វឌ្ឍនភាព** : ការចំរើនឡើងជាលំដាប់ ។
- **ឧនាភិវឌ្ឍនភាព** : ភាពមិនចំរើន មិនលូតលាស់ ។
- **វណ្ណៈ** : ពួក ថ្នាក់ពួក ។
- **ប្រត្យក្សពិសោធន៍** : ការពិសោធន៍ជាក់ស្តែង ការពិសោធន៍ឃើញច្បាស់និងភ្នែក ។
- **និន្នាការ** : អាការដែលទ្រេតទៅទៅឬដែលលំអៀងទៅម្ខាង ។
- **អានានិគមនិយម** : លទ្ធិដែលនិយមយកប្រទេសតូចមកដាក់ជាចំណុះរបស់ខ្លួន ។
- **សកម្មភាព** : ដំណើរការមានកិច្ចការប្រព្រឹត្តទៅជានិច្ច ។
- **វិប្បដិសារៈ** : សេចក្តីក្តៅក្រហាយឬនឹកស្តាយក្រោយ ។
- **វីរជន** : អ្នកខ្លាំងពូកែ មានឈ្មោះល្បីល្បាញក្នុងការបំរើប្រទេស ។

(សៀវភៅ "បទរៀនសូត្រ" របស់សមមិត្ត អ៊ីវ ប៊ុនឈឿន)

# ជុំវិញការលាលែងរបស់ សម្តេច សីហនុ

## *ទស្សនៈខ្មែរក្រហមចំពោះមូលហេតុនិងលទ្ធផលនៃការលាលែងរបស់សម្តេច សីហនុ*

នៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ កម្ពុជាប្រជាធិបតេយ្យបានរៀបចំប្រជុំគណៈអចិន្ត្រៃយ៍រណសិរ្ស ដោយមានការចូលរួមពីសំណាក់សមមិត្តលេខា (ប៉ុល ពត) សមមិត្តអនុលេខា (នួន ជា) សមមិត្ត វ៉ន (វ៉ន វ៉េត) សមមិត្ត ខៀវ (សុន សេន) សមមិត្ត ហែម (ខៀវ សំផន) សមមិត្ត ឌឿន សមមិត្ត ទុំ និងសមមិត្ត ទូច ។ កិច្ចប្រជុំផ្តោតសំខាន់ទៅលើរបៀបវារៈតែមួយគត់ គឺ «សីហនុ លាឈប់ពីតំណែង» ។

នៅក្នុងកំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍រណសិរ្ស ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ បញ្ជាក់ថា សមមិត្ត ហែម (ខៀវ សំផន) បានរាយការណ៍ជូនអចិន្ត្រៃយ៍អំពីការលាឈប់របស់សម្តេច សីហនុ។ សម្តេច សីហនុ បានផ្ញើសំបុត្រជាភាសាបារាំងជូនអង្គការពីរច្បាប់ ។ ១ច្បាប់ស្នើសុំលាឈប់ ហើយបញ្ជាក់ពីមូលហេតុសំខាន់ៗដែលនាំឲ្យសម្តេចលាឈប់ ពិសេសសម្តេចចង់សង្កត់លើបញ្ហារោគផ្សេងៗរបស់សម្តេចដែលពុំអនុញ្ញាតឲ្យសម្តេចបន្តទៅទៀតបាន ។ រីឯ១ច្បាប់ទៀតជាសេចក្តីរាយការណ៍ចំពោះ «ប្រជាជនកម្ពុជាប្រជាធិបតេយ្យថាសម្តេចលាឈប់មុនថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦» ។

កំណត់ហេតុបានកត់សម្គាល់ការត្អូញត្អែររបស់សម្តេច សីហនុ ថា «ពេលជួបទូតម៉ូរីតានីនិងទូតសេណេហ្កាល់ សីហនុក៏បានប្រាប់ថាគាត់លាឈប់ដាច់ខាតដែរ ។ ដល់ជួបគណៈប្រតិភូសេដ្ឋកិច្ចពាណិជ្ជកម្មចិន គាត់ត្អូញអំពីជំងឺគាត់...» ។ សម្តេច សីហនុ ផ្ទាល់ព្រះអង្គ ក៏បានថ្លែងទៅកាន់អ្នកដែលស្រលាញ់គោរពព្រះអង្គនៅទីក្រុងបែលក្រាដ មុនពេលទ្រង់សម្រេចព្រះទ័យយាងចូលមកកម្ពុជាវិញថា «រដ្ឋាភិបាលប្រទេសខ្ញុំបានសុំឲ្យខ្ញុំបំពេញបេសកកម្មមួយនៅអង្គការសហប្រជាជាតិ និងនៅតាមបណ្តាប្រទេសជាមិត្តជាង១០ទៀត ។ បេសកកម្មនេះត្រូវបញ្ចប់នៅថ្ងៃនេះ ។ ខ្ញុំនឹងមិនបំពេញបេសកកម្មផ្សេងទៀតដើម្បីបម្រើផលប្រយោជន៍របបថ្មីឡើយ ។ ខ្ញុំមានបំណងសុំលាលែងពីមុខតំណែង ។ ប៉ុន្តែ ខ្ញុំបានចាត់ទុកខ្លួនឯងថាជាទាហានម្នាក់ដែលកំពុងចង់ធ្វើខ្លួនឲ្យគេបញ្ចេញពីកំណែនទ័ព ដូច្នេះខ្ញុំត្រូវតែត្រឡប់ចូល“បន្ទាយ” ដើម្បីដូរសម្លៀកបំពាក់ស៊ីវិលចេញមកវិញ» ។

តាមមតិរបស់អង្គការ មូលហេតុដែលនាំសម្តេច សីហនុ លាឈប់មានពីរយ៉ាងគឺៈ ១) មូលហេតុវែងឆ្ងាយនិង ២) មូលហេតុចំពោះមុខ ។ អង្គការឲ្យហេតុផលថា ចំពោះមូលហេតុវែងឆ្ងាយ គឺទំនាស់វណ្ណៈជាមូលដ្ឋានរវាងបដិវត្តន៍និងសម្តេចព្រមទាំងគ្រួសារ ។ «គាត់នៅជាមួយយើងមិនបាន ។ កន្លងមកគាត់រស់នៅជាយុទ្ធវិធីទេ ។ ដោយយើងដំណើរការជាយុទ្ធវិធីទៅ គាត់ចេះតែនៅបណ្តើរៗ ។ សីហនុ មិនមែនលាឈប់តែម្តងទេ ។ គាត់លាឈប់តាំងពីឆ្នាំ១៩៧១មក» ។

«មតិអង្គការ»បន្តទៀតថា មូលហេតុចំពោះមុខគឺទំនាស់ជាយុទ្ធវិធី វាបន្ថែមពីលើទំនាស់ជាមូលដ្ឋាន ។ ហេតុផលលាលែងរបស់សម្តេច សីហនុ ត្រូវបានអង្គការលើកជាឧទាហរណ៍បញ្ជាក់ច្បាស់ថា «ដូចជាយើងឲ្យទូតចេញទៅក្រៅដោយពុំសួរគាត់ ។ គឺជារឿងតូចតាចទេ តែគាត់ស្មានថាប្រហែលយើងលែងត្រូវការគាត់ហើយ ។ ដូច្នោះ ទំនាស់ក៏ចង់បានតំណែងតទៅទៀតដែរ» ។

ខ្មែរក្រហមហាក់ទាញយកផលប្រយោជន៍ពីសម្តេច សីហនុ សម្រាប់បញ្ហាក្រៅប្រទេស ។ ប៉ុន្តែសម្រាប់កិច្ចការក្នុងប្រទេស ពិសេសការដឹកនាំ ខ្មែរក្រហមមិនត្រូវការទ្រង់ឡើយ ។ ដូចដែលសៀវភៅកំណត់ហេតុរបស់ខ្មែរក្រហមបានគូសបញ្ជាក់ថា «តស៊ូប្រជាជាតិ តស៊ូប្រជាធិបតេយ្យ ដើម្បីឈានចូលសង្គមនិយម ចំពោះសម្តេច សីហនុ គឺយើងឲ្យនៅដដែល តែត្រូវបក្សយើងដឹកនាំ និងដើម្បីឲ្យគាត់ទប់ទល់នូវសត្យានុម័តដែលបុកពីខាងក្រៅ ហើយដាច់ខាតមិនឲ្យបុគ្គលនេះក្តាប់រដ្ឋអំណាចទេ» ។ ដូច្នេះ នៅក្នុងក្រសែភ្នែករបស់ខ្មែរក្រហម សម្តេច សីហនុ មិនមែនជាធាតុផ្សំដ៏សំខាន់របស់ក្បាលម៉ាស៊ីនខ្លួនទេ ។ «ក្រោយរដ្ឋប្រហារ

ចលនាបដិវត្តន៍យើងវិវត្តដោយលោតផ្លោះដោយកត្តាអត្តនោមតិរបស់យើងក៏គ្រប់គ្រាន់ កត្តា សីហនុ បន្ថែមទៀត ហើយសកលលោកជួយឧបត្ថម្ភទៀត ត្រូវរកនិងរក្សាសភាពវិវត្តន៍យ៉ាងនេះតទៅទៀត» ។ សម្តេច សីហនុ បានសារភាពថា ក្នុងរយៈពេលដែលព្រះអង្គកាន់មុខតំណែងក្រុមប្រឹក្សារដ្ឋមន្ត្រី ឬប្រមុខរដ្ឋខ្មែរក្រហម ព្រះអង្គបានធ្វើអធិបតីភាពពេញលេញក្នុងការប្រជុំក្រុមប្រឹក្សារដ្ឋមន្ត្រីតែ២ដងប៉ុណ្ណោះ ។ ការប្រជុំទី១បានប្រព្រឹត្តទៅនៅខែកញ្ញា ឆ្នាំ១៩៧៥ ដែលកាលនោះ ខៀវ សំផន, សុន សេន, ហ៊ូ នឹម, កុយ ធួន, តូច ភឿន បានធ្វើ«សេចក្តីរាយការណ៍» ថ្វាយព្រះអង្គម្នាក់ម្តងៗ ស្តីពីលទ្ធផលនិងស្នាដៃផ្សេងៗដែលទទួលបានតាមក្រសួងរៀងៗខ្លួនក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ដំណើរយាងនិវត្តន៍របស់ព្រះអង្គមកកាន់ប្រទេសកម្ពុជាវិញនៅខែកញ្ញា ក្នុងឆ្នាំដដែល ។

មតិអង្គការរៀបរាប់ពីជីវិត បរិយាកាសជុំវិញ និងជម្រើសរបស់សម្តេច សីហនុ ថា «សម្តេចអត់ការងារធ្វើ អផ្សុក ហើយបរិយាកាសនៅជុំវិញ ពិសេសប្រពន្ធយំជាប់ ជំរុញឲ្យគាត់ទ្រាំមិនបាន ។ បើនៅតទៅទៀតក៏មិនយូរ យ៉ាងច្រើន១ឆ្នាំឬ ២ឆ្នាំ ។ បើគង់តែទៅដាដដែល ទៅមុនឲ្យហើយទៅល្អជាង» ។ សម្តេច សីហនុ ក៏មានព្រះបន្ទូលត្អូញត្អែរស្រដៀងគ្នានេះដែរថា «ខ្ញុំគ្មានកិច្ចការណាមួយដែលត្រូវធ្វើសម្រាប់ប្រទេសខ្ញុំឬអតីតប្រជារាស្ត្រខ្ញុំឡើយ ។ ដោយត្រូវគេដាក់ឲ្យស្ថិតនៅក្នុងសភាពជាមនុស្សគ្មានការងារធ្វើដូច ភូរិស្ស៉ា ដែលអួតថាជារដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ខ្មោចនោះ ខ្ញុំបានសាកល្បងរំសាយទុក្ខកង្វល់ដោយអានអត្ថបទផ្សេងៗដែលរៀបរាប់ពីម្ហូបឆ្ងាញ់ៗនៅប្រទេសបារាំង... ខ្ញុំនឹកស្រមៃដល់ប្រទេសបារាំងដើម្បីព្យាយាមបំភ្លេចកម្ពុជាដ៏អភ័ព្វរបស់ខ្ញុំ» ។

កិច្ចប្រជុំគណៈអចិន្ត្រៃយ៍សម្តែងនូវមោទកភាពថា ប្រជាជនកម្ពុជាទាំងមូល កម្មាភិបាល និងកងទ័ពទាំងអស់ បានដកដង្ហើមធំចុងក្រោយរបស់ខ្លួនផុតហើយ រីឯដំណោះស្រាយការចាត់តាំងក្នុងអង្គការរដ្ឋយើងបានស្រួល ហើយគ្មានពាក់ព័ន្ធអ្វីទៀតទេ ។ ចំពោះកិច្ចការបរទេសដែលខ្មែរក្រហមយល់ថា សម្តេច សីហនុ ជាកត្តាចម្បងនោះ ក៏ត្រូវអង្គការមានសុទិដ្ឋិនិយមថានឹងគ្មានបញ្ហាដែរក្រោយពេលសម្តេច សីហនុ សុំលាលែង ។ «ការងារបរទេសយើងក៏នឹងល្អជាងមុន ព្រោះយើងធ្វើខ្លួនយើង យើងយកជំហរខ្លួនយើង ព្រោះអត់ សីហនុ យើងជ្រះស្រឡះ» ។




ទាក់ទងនឹងបច្ច័យអវិជ្ជមាននៃការលាលែងរបស់សម្តេច សីហនុ មតិអង្គការបានលើកឡើងថា «ម្យ៉ាងវៀតណាមវាយយើងថាយើងឆ្កែង ។ សីហនុ ជួយយើង ម៉េចចោល សីហនុ ។ វាប្រាប់បដិវត្តន៍ផ្សេងៗលើកល្អពីខ្លួនវា បន្តុះបង្អាប់យើង» ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី «បញ្ហានេះជាបញ្ហាបណ្តោះអាសន្នទេ ។ ឲ្យតែយើងនៅជិតស្និទ្ធនឹងគេទៅ អត់ចោទអីទេ» ។

ទោះជាក្នុងដំណាក់កាលនេះខ្មែរក្រហមលែងត្រូវការសម្តេច សីហនុ ក៏ដោយចុះ ក៏ខ្មែរក្រហមទទួលស្គាល់ពីស្នាព្រះហស្តសមត្ថភាព និងគុណូបការៈរបស់សម្តេចចំពោះជាតិដែរ ។ «គោលជំហរយើងទាំងអស់គ្នា ទាំងរដ្ឋាភិបាល គឺនៅតែថាគាត់មានសគុណលើប្រទេស ពិសេសនៅលើឆាកអន្តរជាតិ ។ គាត់មានសគុណលើជាតិដែលមហាសន្និបាតបានសម្រេចហើយ ។ យើងគោរពសមូហភាពណាស់ បើថាម៉េចគឺអ៊ីចឹងហើយ តែសុំឲ្យគាត់នៅជាមួយប្រជាជនទៀត ។ ប្រជាជនតម្កល់ទុកសគុណគាត់តទៅទៀត យើងមានអំណរសាទរណាស់ ហើយខំឲ្យអស់លទ្ធភាពអនុវត្តនូវសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតជាតិពិសេសរបស់យើង» ។

នៅក្នុងទិសដៅទីពីរដែលជាប្រការទប់ទល់នឹងការមិនព្រមលាលែងរបស់សម្តេចនោះ អង្គការបានលើកឡើងថា «យើងនឹងប្រជុំគណៈរដ្ឋមន្ត្រីដើម្បីសម្រេច» ។ បើតាមសេចក្តីរាយការណ៍

របស់សមមិត្ត ហែម សម្តេច សីហនុ ហាក់ដូចជាមិនក្រោញនឿលដូចដែលគណៈប្រជុំអចិន្ត្រៃយ៍បានគិតនោះទេ ។ នៅក្នុង "មតិរបស់អង្គការក្នុងអង្គប្រជុំយប់ថ្ងៃទី១៣" សមមិត្ត ហែម បញ្ជាក់ច្បាស់ថា "គាត់សម្រេចសុំលាលែងពីតំណែងដាច់ខាត" ។ សមមិត្ត ហែម បន្ថែមទៀតថា សម្តេច សីហនុ ទទូចហើយទទូចទៀតថា "សូមអង្គការអាណិតឲ្យខ្ញុំឲ្យផង ។ ឲ្យខ្ញុំសំពះ លូនក៏បានដែរ ឲ្យតែបានឈប់" ។

សមមិត្តលេខាចាត់ទុកការលាលែងនេះជាបញ្ហាធំៈ "ទុកឲ្យអង្គការមជ្ឈិមយើងជាអ្នកអារកាត់ចុះ" ។ ទន្ទឹមនឹងពេលគ្នានេះដែរ សមមិត្តលេខាបានព្រាងជាគោលគំនិតដែលអង្គការអចិន្ត្រៃយ៍ទាំងមូលយល់ស្របដែរ ។ គំនិតសំខាន់ៗមានដូចជាមិនឲ្យសម្តេច សីហនុ ចេញទៅក្រៅប្រទេស ប្រជុំគណៈរដ្ឋមន្ត្រីរាយការណ៍ជូនគណៈរដ្ឋមន្ត្រីដើម្បីសម្រេច រួចហើយទៅជួប សីហនុ ទៀត ដោយមាន ប៉ែន នុត ចូលរួមដែរ និងវាយខ្សែលួស"ឲ្យកូនគាត់មកភ្នាម ដោយបញ្ជាក់ថាឲ្យមករួមចូលឆ្នាំនិងបុណ្យឯករាជ្យ ។ យើងចង់ដោះស្រាយបញ្ហានេះឲ្យបានស្អាត ។ យើងត្រូវដោះស្រាយយ៉ាងនេះទើបចំណេញបដិវត្តន៍" ។

"មតិអង្គការ"បន្ថែមថា ទោះជាសម្តេច សីហនុ មានទំនាស់ជាមួយនឹង"យើង"ក្តី ប៉ុន្តែសម្តេចបានចូលរួមជាមួយនឹង"យើង"ដែរ ។ ដោយហេតុនេះហើយ បានជាបក្សសម្រេចឲ្យសម្តេចធ្វើជាគណៈប្រធានរដ្ឋទៀត ។ មតិអង្គការបាននិយាយចាក់បណ្តោយថា "តែគាត់មិនព្រម ។ ដូច្នោះគាត់នៅបានបុមិនបានជារឿងរបស់គាត់" ។




ប៉ុន្តែកំណត់ហេតុប្រជុំអចិន្ត្រៃយ៍អះអាងដោយគ្មានមូលដ្ឋានច្បាស់លាស់ថា "យើងចាត់ទុកគាត់ជាឥស្សរជនមួយរូប ។ យើងមិនកាប់សម្លាប់គាត់ទេ ។ តែចំពោះប្រជាជាតិនិងប្រជាជន គាត់ក៏មានទោសធ្ងន់ក្នុងឋានៈជាអ្នកកាប់សម្លាប់ប្រជាជន" ហើយទាញសេចក្តីសន្និដ្ឋានថា "ការសម្រេចរបស់យើងសមហេតុសមផលគ្រប់យ៉ាង ។ យើងនៅតែថែរក្សាគាត់ ។ តែបើគាត់នៅតែរើបម្រះ យើងត្រូវបញ្ចប់" ។

"មតិអង្គការ" ក្នុងអង្គប្រជុំយប់ថ្ងៃទី១៣ (ខែមីនា) បានប្រើពាក្យធ្ងន់ៗថា ទិសវិវត្តរបស់បដិវត្តន៍គឺត្រូវបញ្ចប់សក្តិភូមិយ៉ាងដូច្នេះឯង ។ ក្រឡាអុកវាចេញមកដល់ត្រឹមហ្នឹងហើយ ។ របបសក្តិភូមិទាំងមូលត្រូវបដិវត្តន៍កម្ទេចនិងគាស់រំលើងជាស្ថាពរ ។ អង្គការនៅបានបន្ថយពាក្យថា "ស្តេចដែលមានមកពីរពាន់ឆ្នាំហើយ ទីបំផុតត្រូវស្អាត" ហើយថា "យើងគ្មានផ្លូវអីចេញក្រៅពីនេះទេ" ។ ទាក់ទងនឹងប្រតិកម្មដែលអាចកើតមានចំពោះវិធានការរបស់អង្គការ មានការនិយាយបង្ការទុកជាមុនថា "ប្រតិកម្មច្បាស់ជាមានខ្លះ តែយើងត្រូវតែដើរតាមផ្លូវបដិវត្តន៍ចំណេញ" ហើយថា ចាប់ពីថ្ងៃនេះទៅលែងឲ្យសម្តេច (សីហនុ) ជួបទូតបរទេស ហើយពន្យល់គេដោយលេសសមរម្យ ។

**សួ ប៊ុនស៊ូ**

## ពាក្យស្លោកខ្មែរក្រហម

### អំពីការកសាងសង្គមនិយម

◆ សមរភូមិកសិកម្ម ឧស្សាហកម្ម សិប្បកម្ម ប្តេជ្ញាវាយសំរុកសំរេចផែនការ១០០% និងអោយលើសថែមទៀត ។

◆ សមរភូមិកំពង់ផែ ឃ្លាំង ដឹកជញ្ជូនជើងទឹក ជើងគោក ផ្លូវដែក និងពាណិជ្ជកម្ម ប្តេជ្ញាវាយសំរុកសំរេចផែនការ ១០០% និងអោយលើសថែមទៀត ។

◆ សមរភូមិ សង្គមកិច្ច សុខាភិបាល សិក្សា ឃោសនាអប់រំ ប្តេជ្ញាវាយសំរុកសំរេចផែនការ១០០%និងអោយលើសថែមទៀត ។

◆ សមរភូមិស្រែអំបិល នេសាទ ប្តេជ្ញាវាយសំរុកផែនការ ១០០%និងលើស ។

◆ សមរភូមិចំការកៅស៊ូ កប្បាស ក្រចៅ អំពៅ និងដំណាំយុទ្ធសាស្ត្រផ្សេងៗទៀត វាយសំរុកសំរេចផែនការ១០០% និងអោយលើសថែមទៀត ។

(សៀវភៅកំណត់ហេតុ លេខ២០៧/៦)

# តម្លៃនៃភស្តុតាង

*(តពីលេខមុន)*

### ក) បញ្ហាភស្តុតាងជាក់ស្តែងមួយចំនួន

នៅក្នុងវគ្គកន្លងមកនេះ ខ្ញុំបានពិភាក្សាលក្ខណៈសំខាន់ក្នុងការយកឯកសារមកធ្វើជាភស្តុតាង គឺនិយាយពីឯកសារដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ប៉ុន្តែដើម្បីប្រើប្រាស់ឯកសារទាំងនេះឲ្យមានប្រសិទ្ធភាពនៅក្នុងសាលាក្តីឬតុលាការខក្រិដ្ឋកម្មពិសេសណាមួយបាន ការកាត់ក្តីនឹងត្រូវតែសង្កត់ធ្ងន់ទៅលើចំណុចមួយចំនួននៃបញ្ហាភស្តុតាងជាក់ស្តែង ។ ក្នុងខណៈដែលវិធាននៃភស្តុតាងដែលនឹងត្រូវយកមកប្រើនៅក្នុងតុលាការខ្មែរក្រហមដែលនឹងអាចកើតឡើងមិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយនោះ មានជំហានមួយចំនួនដែលការកាត់ក្តីប្រាកដជានឹងជួបប្រទះដោយមិនគិតពីវិធានដែលអនុម័តដោយតុលាការដែលទទួលខុសត្រូវ ។ វគ្គនេះពិភាក្សាជាសង្ខេបទៅលើការពិចារណាលើចំណុចខ្លះៗដូចខាងក្រោម÷

#### ១) ការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ

ដើម្បីយកមកប្រើជាភស្តុតាងប្រឆាំងនឹងអតីតកម្មាភិ-បាលនៃបក្សកុម្មុយនិស្តកម្ពុជា ដំបូងត្រូវតែមានការពិនិត្យឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាយ៉ាងហ្មត់ចត់ឡើងវិញជាទូទៅជាផ្នែកមួយនៃការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ ។ ដោយសារមជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារជាង៣សែនទំព័រ ដំណើរការស៊ើបអង្កេតនឹងចាំបាច់ត្រូវមានកម្រិតផ្តោតទៅលើជំពូកឯកសារណាមួយក្នុងចំណោមឯកសារទាំងអស់ ។ នាយកនិងបុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងចាត់ចែងការងាររបស់ខ្លួនតាមរបៀបមួយដែលជាការជួយជ្រោមជ្រែងដ៏ល្អបំផុតដល់រាល់អ្នកស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌដោយធានាថា អ្នកស៊ើបអង្កេតនឹងបានពិនិត្យហ្មត់ចត់និងជ្រើសរើសយកភស្តុតាងទាំងឡាយណាដែលមានការពាក់ព័ន្ធនិងមានធាតុនាំផ្លូវយ៉ាងសំខាន់ ។

#### ២) ភាពដើមដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់

មុនពេលដាក់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាភស្តុតាង ដំណើរការពិនិត្យឯកសារឲ្យបានត្រឹមត្រូវតាមច្បាប់ជាការចាំបាច់ណាស់ដែរ ។ ឯកសារដើមរបស់បក្សកុម្មុយនិស្តកម្ពុជាមានចំណាស់ជាង២០ឆ្នាំទៅហើយ ហើយជាការច្បាស់ណាស់ថា តុលាការនឹងតម្រូវឲ្យមានការកាត់សេចក្តីដើម្បីបង្ហាញឲ្យឃើញថា ភស្តុតាងឯកសារពិតជាត្រឹមត្រូវពិតប្រាកដក្នុងលក្ខណៈដើម ហើយមិនរលួយខូច ។ ឯកសារដែលត្រូវយកមកបង្ហាញគឺតម្រូវឲ្យមានទាំងការធ្វើកោសល្យវិច័យនិងខ្សែសង្វាក់នៃការថែរក្សាឯកសារផង ។ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងជួយការកាត់សេចក្តី នៅក្នុងដំណើរការធ្វើឲ្យមានលក្ខណៈដើមត្រឹមត្រូវតាមច្បាប់ តាមវិធីដែលធ្វើទៅបាននិងបង្ហាញថាភស្តុតាងឯកសារមិនខូច មិនក្លែងក្លាយអ្វីឡើយ ពោលគឺនៅរក្សាធាតុដើមទាំងអស់ ។

#### ៣) ការមើលថែទាំឯកសារយ៉ាងពិសេស

ឯកសារភស្តុតាងដែលមានតម្លៃ ត្រូវតែបានថែទាំនិងរក្សាទុកសម្រាប់យកទៅប្រើប្រាស់នៅក្នុងតុលាការ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានបទពិសោធន៍ខាងតម្កល់ទុកនិងដោះស្រាយជួសជុលឯកសារដែលកំពុងតែមានការពុកផុយ ។ ក៏ប៉ុន្តែមជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនជាស្ថាប័នច្បាប់ ដូច្នេះគឺមិនដឹងអំពីដំណើរការដែលតុលាការធ្វើឡើងសម្រាប់ថែនិងរក្សាឯកសារក្នុងលក្ខណៈពិសេសទេ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងជំរុញឲ្យមានដំណើរការរបៀបនេះតាមតែអាចធ្វើទៅបាន និងបានខិតខំស្វែងរកគំរូបង្ហាញផ្លូវមកពីតុលាការខក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី ដើម្បីជាជំនួយដ៏មានសារសំខាន់បំផុត ។

#### ៤) ការគ្រប់គ្រងពត៌មាន

ដោយមានឯកសារយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលមាន

តម្លៃភ័ស្តុតាងដ៏សំខាន់ តុលាការដែលទទួលខុសត្រូវអាចអនុវត្តតាមប្រព័ន្ធទំនើបដូចគ្នាក្នុងការចាត់ចែងគ្រប់គ្រងព័ត៌មាន ។ ប្រព័ន្ធគ្រប់គ្រងនេះនឹងមានលក្ខណៈសមរម្យក្នុងការបញ្ចូលជាលេខដើម្បីរកឯកសារ ។ មជ្ឈមណ្ឌលឯកសារបានពិគ្រោះជាមួយតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី ហើយនឹងរិះរកគ្រប់មធ្យោបាយក្នុងការសម្រួលឲ្យមានការស្វែងរកឯកសារនិងប្រភពផ្សេងៗទៀតឲ្យមានប្រសិទ្ធភាពនិងច្បាស់លាស់ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏នឹងផ្តល់ការកាត់សេចក្តីដោយមានការពន្យល់បញ្ជាក់យ៉ាងលម្អិតនូវប្រព័ន្ធស្វែងរកព័ត៌មាន និងការហ្វឹកហាត់ដែលមានការចាំបាច់ ។

### ៩) បទបញ្ញាក្នុងការចូលប្រើប្រាស់ឯកសារ

នៅពេលដែលតុលាការហៀបនឹងកើតឡើង មជ្ឈមណ្ឌលឯកសារកម្ពុជានឹងត្រូវថែរក្សាសភាពដើមនៃឯកសាររបស់ខ្លួនយ៉ាងប្រុងប្រយ័ត្ន ។ ដើម្បីថែរក្សាបាន មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវតែអនុវត្តនយោបាយឲ្យបានហ្មត់ចត់ដែលកម្រិតចំពោះការប្រើប្រាស់ ឯកសារទាំងនេះពីសំណាក់សាធារណជន និងស្ថាប័ននានា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបាននិងកំពុងធ្វើការជាមួយនឹងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី ហើយរៀបចំបង្កើតនយោបាយដែលឆ្លើយតបទៅនឹងតម្រូវការរបស់តុលាការដែលទទួលខុសត្រូវឬសាលាជម្រះក្តី និងថែរក្សាសភាពដើមរបស់ឯកសារនិងឯកសារភ័ស្តុតាងផ្សេងៗទៀត ។

## ឃ) ការបញ្ជាក់ពីសាក្សី

ភ័ស្តុតាងឯកសារអាចបង្កើតជាមូលដ្ឋានគ្រឹះសំខាន់សម្រាប់កាត់សេចក្តីអតីតមន្ត្រីរបស់បក្សកុម្មុយនិស្តកម្ពុជា ប៉ុន្តែនៅក្នុងតុលាការឬអង្គជំនុំជម្រះក្តីឧក្រិដ្ឋកម្ម គ្មានអ្វីសម្រាប់ជំនួសអំណាចសំណួរតតគ្រោងទុក និងឲ្យមានចម្លើយឬតម្លៃបញ្ជាក់ពិតប្រាកដពីសំណាក់សាក្សីដែលឃើញផ្ទាល់ភ្នែកទេ ។ របបកម្ពុជាប្រជាធិបតេយ្យបានបន្សល់ទុកនូវសាក្សីសំខាន់ៗរាប់ពាន់នាក់ (ទោះជាមិនមានរាប់លាននាក់ក៏ដោយ) ដែលឃើញសកម្មភាពឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់របស់កម្ពុជាប្រជាធិបតេយ្យ ។ ឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់នូវគំរូរាប់មិនអស់ឈានទៅរកសាក្សី ហើយអាចក្លាយជាចំណុចចាប់ផ្តើមសម្រាប់ការសម្រេចធ្វើកិច្ចសម្ភាសន៍ជាមួយសាក្សីទាំងនោះ ។ កសិណសាក្សីរបៀបនេះនឹងមានសារសំខាន់ទាំងចំពោះសក្តិកម្មខ្លួនឯង និងជាផ្លូវសម្រាប់បញ្ជាក់ភ័ស្តុតាងឯកសារផ្សេងៗទៀតយ៉ាងច្រើនសន្ធឹកសន្ធាប់ ប្រឆាំងនឹងអតីតមន្ត្រីខ្មែរក្រហមដែលនឹងត្រូវយកមកកាត់សេចក្តី ។

ការពិភាក្សាយ៉ាងល្អិតល្អន់ទៅលើកសិណសាក្សីរបស់សាក្សីសំខាន់ៗ គឺហួសពីវិសាលភាពរបស់របាយការណ៍ផ្នែកច្បាប់ទៅទៀត ។ ទោះជាយ៉ាងណាក៏ដោយ កសិណសាក្សីដែលនៅរស់ដល់សព្វថ្ងៃ អាចផ្តល់ការគាំទ្រយ៉ាងសំខាន់ចំពោះឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយសមនឹងទទួលការពិភាក្សាខ្លះនៅក្នុងរបាយការណ៍ផ្នែកច្បាប់ ។ ផ្នែកលម្អិតតូចៗនៅខាងក្រោមនេះនឹងផ្តល់ជាយោបល់ខ្លះទៅលើប្រភេទព័ត៌មានដែលសាក្សីអាចផ្តល់ ដែលនឹងមានសារប្រយោជន៍ក្នុងការបញ្ជាក់ឯកសារ និងផ្តល់ជាភ័ស្តុតាងមានប្រយោជន៍ចំពោះការកាត់សេចក្តី ។ នៅពេលចាប់ផ្តើមធ្វើកិច្ចសម្ភាសន៍ជាមួយសាក្សីសំខាន់ៗ ព្រះរាជអាជ្ញានឹងចាំបាច់ត្រូវកំណត់ថាតើសាក្សីណាខ្លះមានសមត្ថភាពនិងមានឆន្ទៈចង់ផ្តល់កសិណដ៏សំខាន់បំផុត ។

### ១) កសិណដែលជាការប៉ីងប្រាផ្ទា

គោលដៅទូទៅនៃកសិណរបស់សាក្សីគឺផ្តល់នូវភ័ស្តុតាង (និងគាំទ្រដល់ភ័ស្តុតាងឯកសារ) ថា មន្ត្រីនៃបក្សកុម្មុយនិស្តកម្ពុជាមានការទទួលខុសត្រូវលើការបញ្ជាឲ្យមានការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មនានាជាក់លាក់ ។ ដូចនេះ កសិណរបស់សាក្សីនឹងមានប្រយោជន៍បំផុត ប្រសិនបើកសិណនេះរួមបញ្ចូលប្រភេទព័ត៌មានដូចតទៅនេះ÷ ក) អត្តសញ្ញាណនិងតួនាទីនៅក្នុងបក្សកុម្មុយនិស្តកម្ពុជា (ប្រសិនបើមាន) និងកន្លែងរស់នៅរបស់សាក្សីនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ខ) អំពើឧក្រិដ្ឋកម្មជាក់លាក់ដែលត្រូវដាក់ទណ្ឌកម្ម ដែលត្រូវបានប្រព្រឹត្តឡើងដោយសមាជិកនៃបក្សកុម្មុយនិស្តកម្ពុជា ។ គ) អត្តសញ្ញាណនិងតួនាទីរបស់ជនដែលដល់នៅក្នុងបក្សកុម្មុយនិស្តកម្ពុជា ។ ឃ) ព័ត៌មានស្តីអំពីខ្សែសង្វាក់នៃការបញ្ជាពីភូមិ ស្រុក និងតំបន់ ។ និង ង) ការរៀបរាប់អំពីឧក្រិដ្ឋកម្មដែលមានទ្រង់ទ្រាយធំនិងចរិតជាប្រព័ន្ធ

ដែលត្រូវបានប្រព្រឹត្តឡើងដោយសមាជិកនៃបក្សកុម្មុយនិស្តកម្ពុជា ។

ដើម្បីបំភ្លឺបញ្ជាក់អំពីគំនិតនេះ ខ្ញុំសូមបង្ហាញជូននូវឧទាហរណ៍ខាងក្រោមនេះ បង្ហាញពីភាពផ្ទុយគ្នារវាងកសិណដីមានសារសំខាន់ឬមានទម្ងន់និងកសិណដែលមានតម្លៃភ័ស្តុតាងបន្ទាប់បន្សំ÷

*កសិណដែលមានទម្ងន់ៈ*

*«...នៅក្នុងភូមិ ក របស់ស្រុក ខ សង្កាត់ គ តំបន់ ឃ ខ្ញុំបានឃើញកម្មាភិបាលរបស់បក្សកុម្មុយនិស្តកម្ពុជាប្រព្រឹត្តអំពើឧក្រិដ្ឋកម្មជាច្រើន ។ ឧទាហរណ៍នៅដើមខែមីនា ឆ្នាំ១៩៧៦ មានបុរសពីរនាក់ឈ្មោះ សុខ និង សៅ ដែលជាយុទ្ធជននៅក្នុងកងកម្លាំងយោធាស្រុក វរសេនាតូច១០០ បានមកដល់ភូមិខ្ញុំ ហើយបានបាញ់ប្រហារមកលើមិត្តរបស់ខ្ញុំឈ្មោះ ធឿន និង នាន ដោយសារមិត្តទាំងពីរនាក់របស់ខ្ញុំបាននិយាយរឿងនយោបាយរិះគន់អង្គការ...។ សុខ និង សៅ គឺជាផ្នែកមួយនៃអង្គភាពដែលបញ្ជាដោយឈ្មោះ សែម ដែលខ្ញុំបានឃើញចេញបញ្ជាជាច្រើនលើកមកហើយ ។ ឈ្មោះ សែម គឺជាអ្នកបញ្ជាយោធាស្រុក...» ។*

*កសិណដែលមិនសូវមានទម្ងន់ៈ*

*«នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំរស់នៅក្នុងភូមិមួយនៅខេត្តបាត់ដំបង ។ ខ្ញុំបានឃើញប្រជាជនជាច្រើននាក់ត្រូវបានខ្មែរក្រហមនាំយកទៅបាត់ៗ ។ ខ្ញុំមិនដឹងថាមានអ្វីកើតឡើងចំពោះអ្នកភូមិទាំងនោះទេ ។ អ្នកដទៃផ្សេងទៀតត្រូវបានសម្លាប់ចោល ។ បងប្រុសនិងឪពុករបស់ខ្ញុំត្រូវបានបញ្ជូនទៅកាន់ជំរំ» ។*

ឯកសាររាយការណ៍ផ្ទាល់មាត់ទីពីរនេះមានលក្ខណៈជាការនិយាយជាសាច់រឿង ដែលការកាត់សេចក្តីនឹងទទួលបានពីសាក្សីសំខាន់ៗជាច្រើននាក់ ។ ការអះអាងនេះអាចត្រូវបានយកមកប្រើជាភ័ស្តុតាងប្រយោលបង្ហាញថាមានអំពើឃោរឃៅកើតឡើងជាទ្រង់ទ្រាយធំ តែមិនអាចបង្ហាញអំពីរចនាសម្ព័ន្ធនៃការបញ្ជាបទល្មើសជាក់លាក់នានាដែលត្រូវបានប្រព្រឹត្តឡើងនិងពត៌មានសំខាន់ៗដទៃទៀតឡើយ ។

## ២) ការធ្វើកិច្ចសម្ភាសន៍ជាមួយនឹងសាក្សីសំខាន់ៗ

នៅក្នុងកិច្ចសម្ភាសន៍ សាក្សីសំខាន់ៗមានលក្ខណៈសមរម្យក្នុងការផ្តល់ចម្លើយដែលមិនសូវមានការទាក់ទង ពីព្រោះសាក្សីទាំងនោះមិនដឹងអំពីប្រភេទពត៌មានជាក់លាក់ដែលមានប្រយោជន៍នៅក្នុងដំណើរការកាត់សេចក្តី ។ ឧទាហរណ៍ វាកម្រនឹងកើតឡើងចំពោះសាក្សីសំខាន់ៗណាស់ដែលថា ការផ្តល់ពត៌មានជាក់លាក់ចំពោះសាលាជម្រះក្តីឬតុលាការ ស្តីអំពីខ្សែសង្វាក់បញ្ជារបស់ភូមិ ឃុំ នឹងមានន័យស្មើ (ឬលើស) នឹងការនិយាយប្រាប់អំពីការបាត់ខ្លួនរបស់អ្នកដែលខ្លួនស្គាល់ ។ ដោយសារមូលហេតុនេះ យកល្អគួរតែធ្វើកិច្ចសម្ភាសន៍ដែលមានរចនាសម្ព័ន្ធដែលបង្ហាញដល់សាក្សីឲ្យនិយាយអំពីពត៌មានដែលមានសារសំខាន់បំផុត ។ តាមពិត ការអនុញ្ញាតឲ្យអ្នកដែលផ្តល់កិច្ចសម្ភាសន៍ប្រាប់អំពីរឿងរ៉ាវផ្ទាល់ខ្លួន គឺមិនមែនជាការប៉ះពាល់ដល់ភ័ស្តុតាងទេ ប៉ុន្តែជួនកាលការនិយាយលម្អិតផ្នែកច្បាប់អាចកប់បាត់ឬត្រូវបានបំភ្លេចនៅក្នុងពេលនិយាយរៀបរាប់វែងឆ្ងាយនោះ ។

ផ្លូវសំខាន់ចាំបាច់ដែលនាំឲ្យមានកិច្ចសម្ភាសន៍ល្អ គឺការធ្វើឲ្យមានតុល្យភាពរវាងការបើកចំហហើយនិងវិធីគ្រប់គ្រងមួយចំនួន ។ សាក្សីសំខាន់ហាក់ដូចជាចង់និយាយចេញនូវអ្វីដែលមិនទាន់សួរទៅទៀត ប្រសិនបើសំណួរនិងការស្នង់មតិខាងក្រៅដែលមានភាពស្មោះត្រង់ធ្វើឲ្យមានការចាប់អារម្មណ៍ និងកសាងនូវភាពជឿទុកចិត្តពិតនោះ ។ ជួនកាល សាក្សីសំខាន់ៗចាំបាច់ត្រូវស្ទុះងាកមកនិយាយអំពីរឿងដែលកើតឡើងពីយូរយារណាស់ហើយទៅវិញ ។ ក៏ប៉ុន្តែ កិច្ចសម្ភាសន៍នឹងត្រូវទទួលការឲ្យយោបល់ដើម្បីផ្តល់ជាសេចក្តីណែនាំដ៏ល្អិតល្អន់ចំពោះសាក្សីដោយព្យាយាមធ្វើឲ្យសាក្សីផ្តោតសំខាន់តែទៅលើពត៌មានភ័ស្តុតាងដែលមានសារប្រយោជន៍ទាំងអស់ ។ នៅខាងក្រោមនេះ ខ្ញុំបានផ្តល់នូវការពិភាក្សាសង្ខេបទៅលើប្រភេទផ្សេងៗនៃពត៌មាន ដែលនឹងសម្របឲ្យមានកសិណដ៏មានសារប្រយោជន៍បំផុត ។

### ក) កន្លែងរស់នៅ

ធាតុសំខាន់ដំបូងបង្អស់នៃកសិណដ៏មានសារសំខាន់គឺទាក់ទងនឹងអត្តសញ្ញាណរបស់សាក្សីសំខាន់ៗ ។ ពត៌មានសំខាន់ៗ

មានដូចជា÷ ១) តើសាក្សីនេះរស់នៅទីណានៅក្នុងចន្លោះខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩? ២) ភូមិភាគ តំបន់ ស្រុក និងឃុំ នៃបក្សកុម្មុយនិស្តកម្ពុជា ដែលជាទីតាំងភូមិរបស់សាក្សីរស់នៅ ៣) តើសាក្សីមានរស់នៅកន្លែងណាផ្សេងពីភូមិនេះទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? ៤) តើសាក្សីរស់នៅតែមួយកន្លែងនោះប្អូយ៉ាងណា? ៥) ប្រសិនបើមិនបានរស់នៅទេ ហេតុអ្វីបានជាគាត់ទៅទីនោះ ។ ប្រសិនបើសាក្សីសំខាន់ម្នាក់នេះត្រូវបានបង្ខំឲ្យទៅភូមិឬសហករណ៍ដែលគាត់ធ្លាប់រស់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ បើដឹងក៏មានសារប្រយោជន៍ដែរ ។ ៦) អ្នកណាដែលបង្ខំគាត់ទៅទីនោះ ៧) តើគាត់ត្រូវបានប្រាប់យ៉ាងដូចម្តេចខ្លះ (ប្រសិនបើមាន) នៅក្នុងពេលជម្លៀសជូរទីលំនៅនេះ ។

### ខ) តួនាទី

ពត៌មានសំខាន់ទីពីរគឺទាក់ទងនឹងតួនាទីរបស់សាក្សីសំខាន់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ កសិណដែលមានប្រយោជន៍រួមមាន÷ ១) តើសាក្សីធ្វើការដែរឬទេនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ២) (ប្រសិនបើធ្វើការ) តើមានមុខងារអ្វី ។ ប្រសិនបើសាក្សីធ្វើការឲ្យបក្សកុម្មុយនិស្តកម្ពុជានៅពេលណាមួយនៅក្នុងសម័យនោះ ជាការសំខាន់ណាស់ក្នុងការដឹងអំពី÷ ១) តួនាទីពិតប្រាកដរបស់គាត់ ២) អ្នកនៅត្រួតពីលើគាត់ចំពោះរាល់កិច្ចការនីមួយៗ ៣) អ្នកត្រួតពីលើអ្នកទាំងនេះ ប្រសិនបើស្គាល់ និង ៤) តើបទបញ្ជាត្រូវបានផ្តល់និងទទួលយ៉ាងដូចម្តេចនៅក្នុងសាខានៃបក្សកុម្មុយនិស្តកម្ពុជា ។

### គ) អំពើឧក្រិដ្ឋកម្ម

ជាក់ស្តែង កសិណដែលមានសារប្រយោជន៍បំផុតគឺរួមមានពត៌មានស្តីអំពីបទល្មើសព្រហ្មទណ្ឌដែលត្រូវបានប្រព្រឹត្តឡើងឬសង្កេតឃើញដោយសាក្សីសំខាន់នេះ ។ ប្រសិនបើសាក្សីរូបនេះធ្លាប់បានធ្វើទារុណកម្មឬសម្លាប់ជនណាម្នាក់ បង្ខំឲ្យធ្វើពលកម្ម ចាប់ដាក់គុកដោយគ្មានការជម្រះក្តី យកក្មេងដោយបង្ខំចេញពីគ្រួសារ ឬធ្វើទុក្ខបុកម្នេញជនណាម្នាក់តាមរបៀបផ្សេងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ នោះកសិណដ៏សំខាន់រួមមាន÷ ១) ការរៀបរាប់អំពីសកម្មភាពចប់ចុងចប់ដើម ២) ហេតុអ្វីបានជាប្រព្រឹត្តអំពើទាំងនេះ ។ ប្រសិនបើសាក្សីរូបនេះទទួលបញ្ជាពីអ្នកផ្សេង ការកាត់សេចក្តីក៏ចាំបាច់ដឹងអំពី÷ ១) អ្នកណាជាអ្នកបញ្ជាឲ្យប្រព្រឹត្តអំពើទាំងនេះ ២) តើមានអ្នកណានៅក្នុងខ្សែសង្វាក់បញ្ជាពីលើបំផុតចេញបញ្ជាដែរឬទេ ។ ប្រសិនបើគ្មានការចេញបញ្ជាទេ ត្រូវដឹង÷ ១) ថាតើអ្នកនៅពីលើសាក្សី (និងអ្នកនៅពីលើអ្នកទាំងនោះទៀត) បានដឹងអំពីសកម្មភាពទាំងនេះទេ ២) តើអ្នកនៅពីលើសាក្សីនេះមានបានផ្តន្ទាទោសសាក្សីរូបនេះដែរឬទេ ។

ជាធម្មតា សាក្សីសំខាន់ក៏អាចមានពត៌មានមានប្រយោជន៍ស្តីអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងដោយមនុស្សផ្សេងទៀត ។ ប្រសិនបើសាក្សីរូបនេះធ្លាប់បានឃើញសមាជិកណាម្នាក់នៃបក្សកុម្មុយនិស្តកម្ពុជា ធ្វើទារុណកម្ម ឬសម្លាប់អ្នកណាម្នាក់ បង្ខំឲ្យធ្វើពលកម្ម ចាប់ដាក់គុកដោយគ្មានការជម្រះក្តី យកកុមារពីគ្រួសារ ឬធ្វើទុក្ខបុកម្នេញអ្នកនោះតាមវិធីផ្សេងណាមួយនោះ ការកាត់សេចក្តីគួរតែសម្រេចអំពី÷ ១) សារជាតិពិតនៃអំពើទាំងនេះ ២) តើអំពើទាំងនេះកើតឡើងនៅពេលណានិងកន្លែងណាជាក់លាក់ពិតប្រាកដ ៣) អត្តសញ្ញាណរបស់សមាជិកនៃបក្សកុម្មុយនិស្តកម្ពុជាដែលមានការពាក់ព័ន្ធ និង ៤) តួនាទីរបស់សមាជិកបក្សកុម្មុយនិស្តកម្ពុជាដែលមានការពាក់ព័ន្ធ ។ ក្នុងករណីដែលជនដៃដល់ធ្វើការពន្យល់ចំពោះអំពើទាំងអស់ដែលខ្លួនបានប្រព្រឹត្តនេះ កសិណគួរតែមាន÷ ១) អ្វីដែលជនដៃដល់បាននិយាយ ២) ថាតើជនដៃដល់មានបានទទួលបញ្ជាឲ្យប្រព្រឹត្តអំពើទាំងនេះដែរឬទេ ៣) តើសាក្សីបានពត៌មានតាមវិធីណា ។ ជាការសំខាន់ដែរក្នុងការកំណត់ថាតើសាក្សីសំខាន់ដឹងអំពីអត្តសញ្ញាណរបស់អ្នកនៅពីលើជនដៃដល់ ហើយថាតើជនដៃដល់ត្រូវបានដាក់ទណ្ឌកម្មឬស្តីបន្ទោសតាមវិធីផ្សេងៗដែរឬទេ ។ ហើយប្រភពពត៌មានសាក្សីគួរតែបញ្ជាក់ឲ្យដឹង ។ **(នៅមានត)**

**ចន ឆរធីរអារី**

**អត្ថន័យនៃពាក្យខ្មែរក្រហម**

◆ ***ខ្លួនឧបត្ថម្ភខ្លួន:*** *ផ្អែកលើកម្លាំងប្រជាជនឯងជាសំខាន់ ។*

*(ទង់បដិវត្តន៍ លេខពិសេស ខែធ្នូ-មករា ឆ្នាំ១៩៧៥-៧៦)*

# តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍

**សេចក្តីផ្តើម**

នៅពាក់កណ្តាលសតវត្សរ៍ទី២០នេះ មានការរីកចម្រើនផ្នែកសិទ្ធិមនុស្សក្នុងល្បឿនមួយដែលមិនធ្លាប់មានពីមុន ។ ចាប់ផ្តើមរាប់ពីប្រទេសហៃទីដល់អតីតយូហ្គោស្លាវី និងចាប់ពីប្រទេសយូហ្គោស្លាវីដល់រ៉្វាន់ដា តម្លៃមនុស្សកំពុងតែចាក់ទម្លុះរដ្ឋដែលមានរនាំងរឹងដូចថ្ម និងកំពុងតែពុះពារក្នុងការបង្កើតជាមូលដ្ឋានគ្រឹះរបស់ខ្លួន ។ ហ៊ីត្លែរគឺជាជនទី១ដែលបានបញ្ចេញមូលហេតុនៃចំណាត់វិធានការក្នុងការជ្រៀតចូលក្នុងអធិបតេយ្យរបស់រដ្ឋ ។ អំពើឃោរឃៅនៅក្នុងសង្គ្រាមលោកលើកទី២ បានធ្វើឲ្យមានកំហឹងពុះកញ្ជ្រោលឡើងនៅក្នុងបុកលោកខាងលិចដែលយល់ថាការសម្លាប់ឲ្យផុតពូជទៅលើជនជាតិជ្វីហ្វគឺជាការវាយប្រហារដោយចំហទៅលើភាពថ្លៃថ្នូររបស់មនុស្សជាតិទូទៅ ។ កំហឹងខាងផ្លូវចិត្តនេះបានផុសចេញយ៉ាងច្បាស់ក្រឡែតនៅឯតុលាការជម្រះក្តីនៅនូរិមប៊ឺក ដែលជាសន្ទុះបង្កើតឲ្យមានចលនាសិទ្ធិមនុស្សជាលក្ខណៈអន្តរជាតិ ។ ជាលើកទី១ហើយនៅក្នុងប្រវត្តិសាស្ត្រដែលរដ្ឋនិងបុគ្គលត្រូវបានដាក់ឲ្យទទួលខុសត្រូវជាអន្តរជាតិចំពោះបទព្រហ្មទណ្ឌដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងទឹកដីរបស់ខ្លួននិងមានលក្ខណៈជាប្រព័ន្ធនិងទ្រង់ទ្រាយធំ ។ ការចាប់ខ្លួនឧត្តមសេនីយ៍ ពីណូចេ ជាឯកគោភាគីរបស់ប្រទេសអេស្ប៉ាញបញ្ជាក់ច្បាស់នូវឧទាហរណ៍មួយដែលទាក់ទងនឹងការដែលថាតើភាពមិនទាន់ដាច់ស្រេចមានច្រើនដល់កម្រិតណាទៅលើវប្បធម៌សិទ្ធិមនុស្សចាប់តាំងពីមានការចាប់កំណើតនៃវប្បធម៌នេះ ។

ទោះបីជាមានការរីកចម្រើនយ៉ាងខ្លាំងនៅក្នុងអន្តរជាតូបនីយកម្មនៃសិទ្ធិមនុស្សនិងបទដ្ឋានដាច់ខាតយ៉ាងណាក៏ដោយ ក៏ទាំងអស់នេះគឺមិនទាន់ល្អត្រឹមត្រូវនៅឡើយទេ ។ ការផ្លាស់ប្តូរពីពិភពលោកមួយដែលមាននិន្នាការផ្សេងគ្នាពីរ ទៅពិភពលោកមួយដែលមាននិន្នាការខុសគ្នាច្រើន បានពន្លត់សង្គ្រាមត្រជាក់ក៏ប៉ុន្តែបែរជាបានបណ្តាលឲ្យមានការកើនឡើងនូវ“ចំណុចក្តៅ”យ៉ាងច្រើននៅជុំវិញពិភពលោកទៅវិញ ។ ពិភពលោកទំនើបស្គាល់ពួកហ៊ីត្លែរជាច្រើននាក់ ព្រមទាំងវាលពិឃាតប្រជាជននិងទីតាំងជាច្រើនដែលស្តែងចេញពីភាពស្រពេចស្រពិលតាមរយៈ“ការបោសសម្អាត”ជាតិជាតិពន្ធជនជាតិនិងសាសនា ដែលបណ្តាលឲ្យមានការកម្ទេចចោលនូវប្រជាជនមួយភាគធំ ។ ក៏ប៉ុន្តែ ដោយសារបណ្តារដ្ឋមួយចំនួននៅតែបន្តដើរតួយ៉ាងសំខាន់នៅក្នុងប្រព័ន្ធអន្តរជាតិ ជនដៃដល់ដែលបានប្រព្រឹត្តអំពើយង់ឃ្នងទាំងអស់នេះហាក់នៅដើរហើរដោយសេរីនៅក្រោមរបាំងខាងក្រៅនៃតម្លៃរបស់រដ្ឋទាំងនោះ ។

ស្នាដៃនិពន្ធមួយក្រោមចំណងជើងថា “តម្លៃនៃពេលវេលា: ពន្លឺស្រាង៧នៃសតវត្សរ៍ទី២១” បានពញ្ញាក់ស្មារតីសហគមន៍អន្តរជាតិឲ្យប្រុងប្រៀបឈានទៅសម្រេចគោលការណ៍ដែលផ្សព្វផ្សាយកាលពីពាក់កណ្តាលសតវត្សរ៍កន្លងទៅ នៅក្នុងគោលការណ៍នូរិមប៊ឺក និងអនុសញ្ញាមួយចំនួនទៀតរបស់អង្គការសហប្រជាជាតិ ។ ស្នាដៃសិក្សាស្រាវជ្រាវនេះអះអាងនូវហេតុផលក្នុងការឈានទៅសម្រេចគោលការណ៍នានា ដើម្បីបង្កើតឲ្យមានតុលាការអន្តរជាតិអចិន្ត្រៃយ៍មួយក្នុងគោលបំណងកាត់ទោសឧក្រិដ្ឋជនដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ផ្នែកដំបូងនៃអត្ថបទស្រាវជ្រាវនេះបានបញ្ជាក់ច្បាស់ពីមូលហេតុនាំឲ្យមានតុលាការដែលមានចរិតបែបនេះ ។ អត្ថបទនេះទាញហេតុផលថា ការបង្កើតតុលាការនេះគឺជាការចាំបាច់ផ្តល់នូវចំណាប់អារម្មណ៍ទៅលើតម្លៃដែលប្រកាសនៅក្នុងគោលការណ៍នូរិមប៊ឺក និងអនុសញ្ញាមួយចំនួនទៀតរបស់អង្គការសហប្រជាជាតិ ព្រមទាំងជំរុញវប្បធម៌សិទ្ធិមនុស្សឲ្យមានការរីកចម្រើនទៅមុខទៀត ។

ផ្នែកទី២នៃសំណេររិះគន់ចំពោះភាពឆ្លើយតបនៃប្រព័ន្ធអន្តរជាតិនាពេលបច្ចុប្បន្ន ក្នុងការចាត់វិធានការដោះស្រាយ

ជាមួយនឹងជនដៃដល់ដែលបានប្រព្រឹត្តអំពើដ៏គួរឲ្យស្អប់ខ្ពើមទាំងនេះ ។ ការឆ្លើយតបចំនួន៣ជាដំបូងបង្ហាញឲ្យឃើញនៅក្នុងគំនិតអធិបតេយ្យភាពរបស់រដ្ឋ ។ ការឆ្លើយតបទី១មិនត្រូវបានអនុវត្ត ។ ប៉ុន្តែការឆ្លើយតបទី២យល់ស្របគ្នាទាំងស្រុងនឹងរដ្ឋាភិបាលនៃជាតិមួយ ក្នុងការអនុវត្តកិច្ចការផ្ទៃក្នុងរបស់ខ្លួន ។ ការឲ្យយោបល់ផ្សេងៗគ្នាទាំងនេះបានផ្តល់អំណាចទៅឲ្យរដ្ឋាភិបាលជាតិ ដើម្បីបង្កើត"តុលាការចម្រុះ"ក្រោមដែនសមត្ថកិច្ចរបស់ខ្លួន រួមជាមួយអ្នកច្បាប់អន្តរជាតិដែលដើរតួនាទីយ៉ាងសំខាន់ ។ ប្រទេសអាហ្វ្រិកខាងត្បូងបានយកការឆ្លើយតបទី៣មកធ្វើជាឧទាហរណ៍បញ្ជាក់អំពីការបង្កើតគណៈកម្មការស្វែងរកការពិត ។ ការឆ្លើយតបទាំង២ចុងក្រោយបានឲ្យអាទិភាពទៅលើតម្លៃមនុស្សលើសពីតម្លៃរបស់រដ្ឋ ម្យ៉ាងតាមរយៈការចាត់វិធានការឯកតោភាគីនិងម្យ៉ាងទៀតតាមរយៈអន្តរាគមន៍របស់អន្តរជាតិ ។ ការប៉ុនប៉ងរបស់ប្រទេសអេស្ប៉ាញក្នុងការកាត់ទោសឧត្តមសេនីយ៍ពីណូចេ បញ្ជាក់មាននៅក្នុងជម្រើសទី៤ ។ ចំណែកឯជម្រើសទី៥គឺការបង្កើតតុលាការព្រហ្មទណ្ឌពិសេសនៅប្រទេសយូហ្គោស្លាវីនិងរ៉្វាន់ដា ។

ផ្នែកទី៣នៃអត្ថបទសិក្សាស្រាវជ្រាវនេះបានធ្វើការស្ទាបស្ទង់មតិទៅលើសំណើសុំឲ្យមានការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងច្បាប់ដែលអនុម័តនៅទីក្រុងរ៉ូមដែលបច្ចុប្បន្នកំពុងតែត្រូវបានពិភាក្សា ។ តាមរយៈការវាយតម្លៃអត្ថបទនេះបានទាញសេចក្តីសន្និដ្ឋានថា ប្រព័ន្ធតុលាការសព្វថ្ងៃមិនបានផ្តល់នូវដំណោះស្រាយគ្រប់គ្រាន់ឬបានផ្តល់នូវដំណោះស្រាយមានលក្ខណៈលម្អៀងចំពោះព្រហ្មទណ្ឌឃោរឃៅក្រោមច្បាប់អន្តរជាតិ ។ ហេតុដូច្នេះមានតែតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ ហើយមានលក្ខណៈប្រហាក់ប្រហែលនឹងតុលាការដែលបានប្រមើលមើលនៅក្នុងច្បាប់ដែលអនុម័តនៅទីក្រុងរ៉ូមក៏ប៉ុន្តែ (ដោយមានការសើរើ) កែតម្រូវឡើងវិញខ្លះដើម្បីឲ្យត្រូវគ្នាគ្រប់ផ្នែក មិនអត្តនោម័តិ ព្រមទាំងបន្ថយការរើសអើងក្នុងការផ្តល់យុត្តិធម៌ ។

## ១) ហេតុអ្វីបានយើងចាំបាច់ឲ្យមានតុលាការព្រហ្មទណ្ឌអន្តរជាតិ?

និក្ខេបបទសិក្សាស្រាវជ្រាវនេះស្នើឲ្យមានការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិមួយតាមដំណោះស្រាយដែលទទួលបានការពេញចិត្ត ។ ទី១ ហេតុអ្វីបានជាគួរតែមានតុលាការព្រហ្មទណ្ឌអន្តរជាតិ? ទី២ ហេតុអ្វីបានជាតុលាការព្រហ្មទណ្ឌគួរតែមានចរិតជាអន្តរជាតិ? ។ ថ្មីៗនេះ សហគមន៍អន្តរជាតិខ្វះយន្តការអចិន្ត្រៃយ៍ក្នុងការឆ្លើយតបទៅនឹងព្រហ្មទណ្ឌទាំងឡាយក្រោមច្បាប់អន្តរជាតិ ។ ដែនសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងត្រូវកំណត់ដោយព្រហ្មទណ្ឌ ដែលការប្រព្រឹត្តនោះនឹងអាចការពារអព្ភន្តរញ្ញាណរបស់សហគមន៍អន្តរជាតិ ជាពិសេសអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ការរំលោភបំពានដោយកម្រោលទាំងនេះគួរតែជំរុញឲ្យសហគមន៍អន្តរជាតិដាក់ទណ្ឌកម្មប្រឆាំងទើបសមរម្យ ។ ដើម្បីកុំឲ្យអំពើអាក្រក់បែបនេះងើបឡើងរួចនិងអស់សកម្មភាពគឺត្រូវវាយប្រហារទៅលើអ្នកដែលមានចិត្តជាមនុស្សដូចយើងរាល់គ្នាដែរ ។ ការបំពារបំពានទាំងនេះគឺជាការរំលោភទៅលើភាពថ្លៃថ្នូររបស់មនុស្សជាតិ ។ ដូច្នេះការចាប់ខ្លួននិងការនាំខ្លួនជនដៃដល់មកកាត់ទោសចំពោះមុខតុលាការ ធ្វើឲ្យមានការសម្តែងនូវកំហឹងនិងការស្អប់ខ្ពើមរបស់មនុស្សជាតិទូទៅ ។ មានតែការបញ្ចេញ"ការស្អប់ខ្ពើម"របស់យើងឲ្យបានសមរម្យនិងលែងទទួលស្គាល់នូវអំពើនេះទេ ទើបយើងអាចស្តារបាននូវសណ្តាប់ធ្នាប់នៅក្នុងប្រព័ន្ធ"តុលាការព្រហ្មទណ្ឌអន្តរជាតិ"និងខ្លួនយើងផ្ទាល់ ។

ការដាក់ទណ្ឌកម្មតាមទស្សនវិជ្ជា គឺដើម្បីរកយុត្តិធម៌មួយ ។ យុត្តិធម៌ទាមទារឲ្យមានសំណង ។ ដើម្បីបែងចែករវាងអ្នកគេចវេះនិងអ្នកចេញមុខទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋ យុត្តិធម៌តម្រូវឲ្យជនដៃដល់ទាំងនោះទទួលខុសត្រូវទៅតាមអំពើរបស់ខ្លួន ។ ទី១ ការផ្តន្ទាទោសទាមទារឲ្យមានការនិយាយរឿងពិតនិងការទទួលខុសត្រូវរបស់ជនដៃដល់ ។ ទោះបីជាជនដៃដល់រត់គេចពីការចាប់ខ្លួនក៏ដោយ ក៏ដីកាចាប់ខ្លួនធ្វើឲ្យជនដៃដល់មានស្លាកស្នាមទុយ៌ស ហើយចាត់ទុកអ្នកទាំងនោះជាជនរស់នៅក្រៅសង្គម ។ តម្លៃនៃការធ្វើឲ្យមានស្លាកស្នាមទុយ៌សនិងការអាម៉ាស់មុខទោះបីជាវាមិនមានជារូបរាងអាចប៉ះពាល់បានក៏ដោយ ប៉ុន្តែមិនត្រូវមើលស្រាលឡើយ ។ ទី២ សហគមន៍នឹងត្រូវស្តាបនា

ឡើងវិញជាមិនខាននៅពេលណាដែលយុត្តិធម៌ត្រូវបានកំណត់ច្បាស់ ។ ទី៣ នៅពេលដែលយុត្តិធម៌ចេញជារូបរាង សិទ្ធិរបស់ជនរងគ្រោះនឹងត្រូវបានសងវិញដោយសមស្របក្នុងនាមជាពលរដ្ឋស្របច្បាប់ ។ បុគ្គលម្នាក់មានស្វ័យភាព មានន័យថាបុគ្គលនោះជា "មនុស្សស្របច្បាប់" ពោលគឺជាអ្នកមានសិទ្ធិនិងកាតព្វកិច្ចជាផ្លូវការ ។ ជាពិសេសដំណើរការព្រហ្មទណ្ឌនាំឲ្យមានការទទួលស្គាល់តាមផ្លូវច្បាប់ថា យុត្តិធម៌មិនមែនជាឯកសិទ្ធិទេ តែជាសិទ្ធិដែលប្រជាពលរដ្ឋគ្រប់រូបត្រូវតែទទួលបាន ។ ចំណុចចុងក្រោយគឺការគោរពត្រូវបានផ្តល់ដល់ជនរងគ្រោះ ល្គឹកណាសហគមន៍ចាត់វិធានការជាក់ស្តែងជួសមុខឲ្យជនរងគ្រោះ និងតំណាងឲ្យការចងចាំរបស់ជនរងគ្រោះ ។ ហេតុដូចនេះ អង្គជំនុំជម្រះស្របច្បាប់មួយនឹងបញ្ចប់រាល់ការទទួលខុសត្រូវជាបុគ្គលនិងជាសមូហភាព នៅក្នុងគោលគំនិតមួយថា អ្វីដែលគួរតែធ្វើពិតជាត្រូវធ្វើបានមែន ។ ការបញ្ចប់ការទទួលខុសត្រូវនេះទៀតសោត ក៏នឹងផ្តល់នូវលក្ខខណ្ឌដែលត្រូវតែបំពេញជាមុនសម្រាប់ឲ្យមានការលូតលាស់និងរីកចម្រើនពិតៗ ។

ជ្រុងយុត្តិធម៌មួយទៀតផ្តល់ហេតុផលថាការដាក់ទណ្ឌកម្មនឹងចូលរួមកម្ចាមិនឲ្យមានអំពើរារាំងមិនឲ្យព្រហ្មទណ្ឌកើតឡើងនាពេលអនាគត ។ បុព្វកថានៃច្បាប់រ៉ូមបានបញ្ជាក់ជំហរខ្លីៗ ហើយច្បាស់ៗ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិ"ជាអ្នកកំណត់បញ្ចប់ការរួចទោសចំពោះជនដៃដល់ដែលបានប្រព្រឹត្តព្រហ្មទណ្ឌ និងចូលរួមទប់ស្កាត់មិនឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មសាជាថ្មី..." ។

ទឡ្ហីករណ៍នេះបញ្ជាក់ច្បាស់ថា អ្នកបំពានច្បាប់សំខាន់ៗត្រូវតែបានកំណត់ឲ្យបានច្បាស់លាស់ ។ ការមិនបានដឹងនូវសេចក្តីប្រកាស និងការមិនបានដាក់ទណ្ឌកម្មដល់ជនដៃដល់គឺជាគ្រោះថ្នាក់ផ្នែកសីលធម៌ ហើយជាផលវិបាក វានឹងនាំដល់ការមិនគោរពប្រតិបត្តិច្បាប់ដោយផ្អែកតាមហេតុការណ៍ពិតនៃការសម្លាប់មនុស្សតាមអំពើចិត្តនិងរួចទោសរហូត ។

រួមសេចក្តីមក ការរំលោភបំពានទៅលើភាពថ្លៃថ្នូររបស់មនុស្សជាតិធ្វើឲ្យយើងមានកាតព្វកិច្ចនិងមានគំនិតចង់បានយុត្តិធម៌ ព្រមទាំងជំរុញយើងឲ្យចាត់ការក្នុងរឿងនេះទៀតផង ។

ភាពចាំបាច់ខាងសីលធម៌ក្នុងការប្តឹងតុលាការ គឺដូចគ្នាទៅនឹងកាតព្វកិច្ចច្បាប់ដែរ ដែលបានចាក់ឫសនៅក្នុងប្រវត្តិសាស្ត្រ ។ ហេតុផលទីពីរដែលជាការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺបង្ហាញបានឥតខ្ចោះនូវយុត្តាធិការផ្លូវច្បាប់និងផ្លូវប្រវត្តិសាស្ត្រ ។ ប្រព័ន្ធច្បាប់ណាមួយក៏ដោយ ទោះជាប្រព័ន្ធច្បាប់ក្នុងស្រុកឬអន្តរជាតិ គឺត្រូវផ្អែកលើគោលវិធាននៃច្បាប់ ។ នៅពេលដែលគោលគំនិតនេះដំណើរការចេញជារូបរាងជាក់ស្តែងហើយនោះវាពិតជាមានន័យ ។ ថ្មីៗនេះយើងមានគោលគំនិតច្រើនណាស់ ។ ក៏ប៉ុន្តែ យើងនៅតែចង់បានគំនិតទាំងនេះចេញជាការអនុវត្តជាក់ស្តែង ។

តុលាការនូរិមប៊ឺកគឺជាគំរូច្បាប់ទីមួយដែលបកស្រាយគោលការណ៍ឲ្យចេញជារូបភាពជាក់ស្តែង ។ តុលាការនេះមិនត្រឹមតែទទួលបានជោគជ័យក្នុងការផ្សព្វផ្សាយគោលការណ៍នានាទេ តែថែមទាំងទទួលបានជោគជ័យក្នុងការបង្កើតក្របខ័ណ្ឌជាមូលដ្ឋានសម្រាប់វិនិច្ឆ័យឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៀតផង ។ ក្រោយពីមានតុលាការនៅនូរិមប៊ឺកមក អនុសញ្ញាជាច្រើនរបស់អង្គការសហប្រជាជាតិក៏ផ្តល់ជាផលយ៉ាងឆាប់រហ័សក្នុងការរៀបចំចងក្រងគោលការណ៍នៃបទដ្ឋានជាច់ខាត ។ អនុសញ្ញាអង្គការសហប្រជាជាតិដែលគួរឲ្យកត់សម្គាល់ជាងគេបំផុត ទាក់ទងនឹងប្រធានបទអំពើប្រល័យពូជសាសន៍ដែលចែងថាៈ "បុគ្គលទាំងឡាយណាដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើប្រល័យពូជសាសន៍...នឹងត្រូវនាំមកជំនុំជម្រះក្តីដោយតុលាការរបស់រដ្ឋនៅក្នុងដែនដីដែលអំពើនោះបានកើតឡើង ឬដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ដោយផ្អែកទៅតាមរដ្ឋធម្មនុញ្ញនៃរដ្ឋរៀងៗខ្លួន" ។

ចាប់តាំងពីពេលនោះមក ពិភពលោកបានមើលឃើញការព្យាយាមរបស់សហគមន៍អន្តរជាតិក្នុងការធ្វើឲ្យគោលការណ៍ទាំងនេះមានប្រសិទ្ធិភាព និងក្នុងការចាប់ខ្លួនឧក្រិដ្ឋជនក្រោមច្បាប់អន្តរជាតិ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងទាំងនេះមានលក្ខណៈមិនទៀងទាត់និងមិនគ្រប់គ្រាន់ទេ ដោយសារតែគ្មានស្ថាប័នអចិន្ត្រៃយ៍ដែលមានសមត្ថកិច្ចធ្វើកិច្ចការនេះ ។ ចង់និយាយថា ច្បាប់អន្តរជាតិមិនបានឆ្លើយតបឲ្យបានជាទីពេញចិត្តចំពោះការរំលោភដ៏ធ្ងន់ធ្ងរទៅលើបទដ្ឋាននានា ពីព្រោះគ្មានការបង្កើតស្ថាប័ននីតិបញ្ញត្តិនិង

រដ្ឋបាលសម្រាប់រយៈពេលយូរអង្វែង ។

ការអភិវឌ្ឍនិងការលើកកម្ពស់វប្បធម៌សិទ្ធិមនុស្ស ព្រមទាំងការគ្រប់គ្រងបែបប្រជាធិបតេយ្យ គឺជាហេតុផលទីបីឲ្យមានការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍មួយ ។ ដោយផ្អែកទៅលើគោលការណ៍ការវិនិច្ឆ័យទៅលើរឿងក្ដីនឹងបង្កើតបានជាកម្រងសិក្សាស្រាវជ្រាវដ៏សម្បូរបែបសម្រាប់ឲ្យមានអាហារូបករណ៍លើប្រធានបទសិទ្ធិមនុស្ស បង្កើតវេទិកាពិភាក្សានិងជំរុញឲ្យមានការយល់ដឹងកាន់តែច្បាស់អំពីបញ្ហាយុត្តិធម៌ ។ បើតាមគំនិតទស្សនវិជ្ជាវិញ ការបង្កើតតុលាការដែលមានចរិតបែបនេះ នឹងបង្កើនថែមទៀតទៅលើសមិទ្ធិផលនៃវប្បធម៌សិទ្ធិមនុស្សដើម្បីពង្រឹងវិធាននៃច្បាប់ ជាពិសេសគឺការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ។ ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យនឹងធានាបាននូវភាពស្មើគ្នាក្នុងការពេញចិត្តនិងការអនុវត្តជាក់ស្ដែងរបស់ប្រជាពលរដ្ឋ ។ ក៏ប៉ុន្តែ ពេលណាច្បាប់ផ្ដន្ទាទោសបទល្មើសតូចតាច ឬទោសទូទៅ តែបែរជាឲ្យឃាតករធំៗដើរហើរដោយសេរីនិងយ៉ាងរំភើយនៅមុខប្រជាពលរដ្ឋ នោះសន្តិភាពនិងស្ថិរភាពប្រជាធិបតេយ្យច្បាស់ជាត្រូវបានបំផ្លាញ ហើយច្បាប់នឹងពិតជាក្លាយទៅជាអសារបង់មិនខានឡើយ ។ «សម្រាប់មិត្តរបស់ខ្ញុំគ្មានបញ្ហា គេចង់បានអ្វីក៏បាន ។ តែចំពោះសត្រូវរបស់ខ្ញុំវិញ ច្បាប់គឺច្បាប់» ។ គួរឲ្យសោកស្ដាយណាស់ដែលមានករណីនេះកើតឡើងជាញឹកញយ ។ ប៉ុន្តែការទាក់ទាញឲ្យមានការគាំទ្រចំពោះការកែទម្រង់តាមផ្លូវនេះពិតជាមិនអាចទៅរួចទេ ។ ដូច្នេះជាការច្បាស់ណាស់ថាការខកខានមិនបានផ្ដន្ទាទោស គឺជាការបោះបង់ចោលនូវអំណាចតាមបែបប្រជាធិបតេយ្យ ។

សរុបមក សហគមន៍អន្តរជាតិមានកាតព្វកិច្ចផ្នែកសីលធម៌ កាតព្វកិច្ចច្បាប់ និងឱកាសក្នុងការបន្ថែមទៅលើវប្បធម៌សិទ្ធិមនុស្ស និងពង្រឹងវិធាននៃច្បាប់សកលក្នុងការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ ។

## ២) តើប្រព័ន្ធសព្វថ្ងៃនេះមានអ្វីខុសឆ្គងខ្លះ?

រហូតមកដល់ពេលបច្ចុប្បន្ននេះ ការឆ្លើយតបរបស់សហគមន៍អន្តរជាតិទៅនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនទាន់មានគ្រប់គ្រាន់មានលក្ខណៈរើសអើង និង(ឬ) មានលក្ខណៈតាមតែចិត្តនឹកឃើញ ។

ការឆ្លើយតបមួយគឺថាគ្មានបានធ្វើអ្វីទាំងអស់ ។ អ្នកគាំទ្រភាពអសកម្មជាដំបូងឲ្យហេតុផលថាដោយសារបញ្ហាអធិបតេយ្យភាព ។ តើហេតុផលនេះចេញពីការព្រួយបារម្ភពិតៗនៃតម្លៃបូរណភាពរបស់រដ្ឋដល់កម្រិតណាទៅ ។ ភាពលម្អៀងនៅតែជាបញ្ហាចោទនៅឡើយ ។ ទី២ អ្នកទាំងនោះយល់ថាសន្តិភាពនិងការអភិវឌ្ឍតម្រូវឲ្យ«ដឹកកប់អតីតកាល»ចោលទើបបាន ។ ឧទាហរណ៍រដ្ឋាភិបាលកម្ពុជាបានទាញហេតុផលនិងផ្ដោតការយកចិត្តទុកដាក់យ៉ាងសំខាន់លើចំណុចមួយថា «ការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងអស់នឹងអាចនាំឲ្យមានចលនាតស៊ូបះបោរសាជាថ្មីមិនខាន» ។ ក៏ប៉ុន្តែសន្តិភាពនិងការជំនុំជម្រះទោសមិនមែនអាចដើរស្របគ្នានោះទេ ហើយក៏មិនមែនមានសន្តិភាពត្រូវតែអត់ការជំនុំជម្រះដាច់ខាតនោះដែរ ។

កត្តាមួយទៀតដែលជាឧបសគ្គដល់ការចាត់វិធានការនេះ គឺការខ្វះឬបាត់បង់ភស្តុតាងឯណោះទេ ។ មានហេតុផលពីរយ៉ាងដែលទាក់ទងទៅនឹងបញ្ហាភស្តុតាងនេះ ។ ទី១ មានការខ្វះខាតភស្តុតាងដើម្បីធ្វើការចោទប្រកាន់ដោយសារការរំលោភបំពានទាំងនោះនិងក្បាលម៉ាស៊ីនដឹកនាំនៃអង្គការនេះមានភាពសម្ងាត់ពេក មិនអាចអ្នកណាដឹងបាន ។ ទី២ ភស្តុតាងមានការបាត់បង់ជាបន្តបន្ទាប់ដោយសារពេលវេលាចេះតែកន្លងទៅ ។ បញ្ហានេះគឺបណ្ដាលមកពីសភាពការណ៍កម្ពុជានាពេលបច្ចុប្បន្ន ហើយអំពើឃោរឃៅក្នុងករណីជាច្រើនមិនបានបន្សល់ទុកនូវភស្តុតាងឡើយ ។

***(នៅមានត)***

**សេង ធារី**

## ពាក្យស្លោកខ្មែរក្រហម

- **ការប្រៀបធៀបកំហឹងមិនមែនប្រៀបធៀបកម្លាំងសឹក និងសេដ្ឋកិច្ចទេ គឺប្រៀបធៀបដោយកម្លាំងមនុស្សនិងស្មារតី គឺគេត្រូវការមនុស្សសំរេចដឹកនាំសេដ្ឋកិច្ចនិងដឹកនាំកម្លាំងសឹក។** *(សៀវភៅកំណត់ហេតុរបស់សមមិត្ត ញ៉ុក សារុន)*

# សុពលភាពច្បាប់នៃ

## សំបុត្រចំហរបស់ ខៀវ សំផន ជូនបងប្អូនរួមជាតិទាំងអស់

ភ័ស្តុតាងផ្ទាល់ដ៏មានសារសំខាន់មួយសម្រាប់តុលាការ ត្រូវបានបង្ហាញដោយមេដឹកនាំខ្មែរក្រហមខ្លួនឯង ។ តើនឹងអាចមានភ័ស្តុតាងរបៀបនេះទៀតដែរឬទេនៅពេលខាងមុខ សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា?

សំបុត្រចំហធ្វើនៅប៉ៃលិន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០០១ ដោយ ខៀវ សំផន អាចបង្ហាញជាភ័ស្តុតាងផ្ទាល់តាមផ្លូវច្បាប់បានក្នុងច្រើនករណី ។ ខ្ញុំសូមលើក៣ករណីមកបង្ហាញជូនដូចខាងក្រោម÷

**ករណីទី១:** ខៀវ សំផន បានទទួលស្គាល់ខ្លួនឯងថាមានតួនាទីជា“ប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ” ។ ការទទួលស្គាល់របៀបនេះនឹងត្រូវបានតុលាការចាត់ទុកថាជាភ័ស្តុតាងផ្ទាល់ ដោយយល់ថានេះជាសម្តីផ្ទាល់របស់សាមីខ្លួន ដោយគ្មានការបង្ខិតបង្ខំ ។ បន្ថែមពីលើនេះទៀត ការទទួលស្គាល់របស់ ខៀវ សំផន នឹងធ្វើឲ្យឯកសារមួយចំនួនមានតម្លៃគ្រប់គ្រាន់ខាងផ្លូវច្បាប់ ។ ឯកសារមួយស្តីអំពី “សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន” ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលក្នុងសេចក្តីសម្រេចនោះ ខៀវ សំផន ហៅ សមមិត្ត ហែម ត្រូវបានតែងតាំងជា “គណៈប្រធានរដ្ឋ” ។ ការទាញហេតុផលរបៀបដូចគ្នានេះ អាចនឹងត្រូវបានធ្វើយ៉ាងល្អឥតខ្ចោះតាមរយៈការស្រាក់ភ្ជាប់គ្នាចំពោះអ្វីដែល ខៀវ សំផន បានប្រកាសប្រាប់ដោយខ្លួនឯង ទៅនឹងឯកសារជាច្រើនដែលមានស្រាប់ ។ ចំណុចមួយទៀតដែល ខៀវ សំផន បានសរសេរថាខ្លួនមិនដែលបានធ្វើប្រធានមន្ទីរ៨៧០ ហើយគ្រាន់តែជាសមាជិកសាមញ្ញមួយរូបនៃមន្ទីរនេះ ក៏អាចមានតម្លៃគ្រប់គ្រាន់ក្នុងការទាញហេតុផលថា ពិតជាមានមន្ទីរ៨៧០នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមែន ។ មានឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ដែលត្រូវបានបញ្ជូនទៅឲ្យមន្ទីរ៨៧០ ឬត្រូវបានបញ្ជូនពីមន្ទីរនេះទៅកន្លែងផ្សេងៗទៀតវិញ ទាក់ទិនទៅនឹងបញ្ហាស្ទើរតែគ្រប់យ៉ាងក្នុងរបបខ្មែរក្រហម ។

**ករណីទី២:** ខៀវ សំផន បានទទួលស្គាល់ដោយខ្លួនឯងយ៉ាងពេញទំហឹងថា ខ្លួនជាសមាជិកមជ្ឈិមត្រៀមនៅក្នុងឆ្នាំ១៩៧១ ហើយពេញសិទ្ធិនៅពាក់កណ្តាលឆ្នាំ១៩៧៦ ។ នេះជាភ័ស្តុតាងផ្ទាល់ដ៏សំខាន់មួយទៀតសម្រាប់តុលាការបង្ហាញថាពិតជាមានគណៈកម្មាធិការមជ្ឈិមនិងគណៈកម្មាធិការអចិន្ត្រៃយ៍ នៃបក្សកុម្មុយនិស្តកម្ពុជារបស់របបកម្ពុជាប្រជាធិបតេយ្យ ។ គណៈកម្មាធិការទាំងពីរនេះហើយដែលបានចេញសេចក្តីសម្រេចជាគោលនយោបាយផ្សេងៗ និងអនុវត្តគោលនយោបាយទាំងនោះដែលនាំទៅដល់ការសម្លាប់យ៉ាងរង្គាលនៅក្នុងរបបគ្រប់គ្រងរវាងឆ្នាំ១៩៧៥-៧៩ ។

**ករណីទី៣:** ខៀវ សំផន បាននិយាយថា ខ្លួនមិនដឹងរឿងរ៉ាវសម្លាប់រង្គាលទេ ក៏ប៉ុន្តែបែរជាបានដឹងរឿងរ៉ាវនៃការចាប់ចងនិងអំពើឃោរឃៅនៅក្នុងខេត្តព្រះវិហារនៅក្នុងរវាងពាក់កណ្តាលឆ្នាំ១៩៧៨ ។ ហេតុអ្វីបានជា ខៀវ សំផន លើកយកតែករណីក្នុងខេត្តព្រះវិហារយ៉ាងដូច្នេះ? ឯកសារ “កំណត់ហេតុនៃអង្គប្រជុំការងារមូលដ្ឋាន” ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ដែលចូលរួមប្រជុំដោយ ខៀវ សំផន ហៅ សមមិត្ត ហែម បាននិយាយដល់បញ្ហា “សភាពការណ៍នៅឧត្តរ ១០៦ និង ១០៣” (លេខចុងក្រោយ១០៣គឺជាលេខតំបន់១០៣ សម្រាប់លេខតំបន់ព្រះវិហារ ក្នុងខេត្តព្រះវិហារ) ។ ខៀវ សំផន ដែលជាអតីតប្រធានគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ បានប្រកាសជាចំហថា “ការសម្លាប់យ៉ាងឃោរឃៅព្រៃផ្សៃស្តាប់ទៅគួរឲ្យព្រឺក្បាល” ។ ដើម្បីឲ្យកាន់តែមានការជឿជាក់ខ្ពស់ជាងនេះថែមទៀត ខ្ញុំសូមជម្រាបថា មានរណ្តៅសាកសពដែលបន្សល់ទុកដោយកម្ពុជាប្រជាធិបតេយ្យដែល ខៀវ សំផន

ទទួលស្គាល់ថា“ជារដ្ឋមួយពេញលក្ខណៈច្បាប់” មានដល់ទៅចំនួន១៨ ៩៧៥ រណ្តៅ នៅទូទាំងប្រទេសកម្ពុជាដ៏តូចមួយ ។ ចំនួនរណ្តៅទាំងអស់ខាងលើត្រូវបានស្រាវជ្រាវតាមលក្ខណៈវិទ្យាសាស្ត្រ ហើយបានចងក្រងជាប្រវត្តិសាស្ត្រអស់រយៈពេល ៥ឆ្នាំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ផ្អែកលើសំបុត្រចំហឃើញថា អំពើសម្លាប់រង្គាលត្រូវបាន ខៀវ សំផន ជឿជាក់ថាមានកើតឡើងពិតប្រាកដ ហើយភាពជាមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏ត្រូវបាន ខៀវ សំផន ទទួលស្គាល់ដោយខ្លួនឯងយ៉ាងជាក់ច្បាស់ ។ ទាំងអស់នេះឆ្លើយតបបានយ៉ាងល្អឥតខ្ចោះទៅនឹងមាត្រាទី១នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ ព្រះករុណា ព្រះបាទសម្តេច នរោត្តម សីហនុ បានឡាយព្រហស្តលេខាលើច្បាប់នេះនៅថ្ងៃសុក្រទី ១០ ខែសីហា ឆ្នាំ២០០១ ។ គ្មានច្បាប់ណាមួយដែលនឹងអនុញ្ញាតឲ្យរួចពីការចោទប្រកាន់ទោសចំពោះបទឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរដែលជនល្មើសបានប្រព្រឹត្តឡើងដោយភាពឆោតល្ងង់នោះទេ ។

**ម៉ាន់ថាន់ ពៅដារ៉ា**

# ប្រវត្តិរូបសង្ខេបរបស់ ខៀវ សំផន

ខៀវ សំផន មានឈ្មោះបដិវត្តន៍ថា សមមិត្ត ហែម ឈ្មោះហៅក្រៅៈ តាឈុន ឬ តាហុង កើតនៅឆ្នាំ១៩២៩ ត្រូវនឹងឆ្នាំម្សាញ់ នៅស្រុកកោះសូទិន ខេត្តកំពង់ចាម តំបន់២២ ភូមិភាគបូព៌ា ។ ខៀវ សំផន ជាកូនខ្មែរកាត់ចិនបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតផ្នែកសេដ្ឋកិច្ចនយោបាយ នៅទីក្រុងប៉ារីស ក្នុងឆ្នាំ១៩៥៩ ។

ក្រោយពេលត្រឡប់មកប្រទេសកម្ពុជាវិញ ខៀវ សំផន ធ្វើគ្រូបង្រៀនភាសាបារាំង រហូតដល់ឆ្នាំ១៩៥៤ទើបបើកកាសែតមួយនៅភ្នំពេញ ឈ្មោះថា “អុបសែរវ៉ាទ័រ” ។ ចាប់ពីឆ្នាំ ១៩៥០ ដល់ឆ្នាំ១៩៦០ ខៀវ សំផន ធ្វើជារដ្ឋមន្ត្រីរបស់រាជការសម្តេច ព្រះនរោត្តម សីហនុ។ ឆ្នាំ១៩៦៦ ខៀវ សំផន ជាប់ឆ្នោតជាតំណាងរាស្ត្រប្រចាំមណ្ឌលខេត្តកណ្តាល ។ ពាក់កណ្តាលឆ្នាំ១៩៦០ ខៀវ សំផន ប្រកាសឲ្យមានការតស៊ូមួយដើម្បីរំដោះយកទឹកដីកម្ពុជាក្រោមមកវិញ ។ នៅខែសីហា ឆ្នាំដដែលនេះ ខៀវ សំផន ក៏ត្រូវចាប់ខ្លួនពីបទចោទប្រកាន់ថាជា “ខ្មែរក្រហម” ។

ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៦៧ ខៀវ សំផន រត់ចូលព្រៃជាមួយ ហ៊ូ យន់ និង ហ៊ូ នឹម បន្ទាប់ពីមានដីកាចាប់ខ្លួនគាត់ ។

ខែកក្កដា ឆ្នាំ១៩៧១ ខៀវ សំផន ជាប្រធានអង្គប្រជុំរយៈពេល២សប្តាហ៍ ដែលរៀបចំនៅទីស្នាក់ការរបស់ ប៉ុល ពត នៅភូមិភាគឧត្តរ ។ របៀបវារៈនៃអង្គប្រជុំនេះគឺ “តើគួរអនុញ្ញាតឲ្យសម្តេច សីហនុ ចូលរួមក្នុងចលនាតស៊ូដែរឬទេ?” ។ ឆ្នាំ១៩៧៤ ខៀវ សំផន បានគាំទ្រឲ្យមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៥ ខៀវ សំផន បានចូលរួមក្នុង“អង្គប្រជុំគណៈអចិន្ត្រៃយ៍” ស្តីអំពី“ការបែងចែកការងារ” ហើយនៅក្នុងអង្គប្រជុំនេះ ខៀវ សំផន ត្រូវបានចាត់តាំងឲ្យទទួលផ្នែករណសិរ្សនិងរាជរដ្ឋាភិបាលពាណិជ្ជកម្មខាងបញ្ជីនិងតម្លៃ ។ ថ្ងៃទី៨ ខែមីនា ឆ្នាំ១៩៧៦ ខៀវ សំផន បានចូលរួមក្នុង“អង្គប្រជុំការងារមូលដ្ឋាន” ស្តីអំពី “បញ្ហាបោះឆ្នោតថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ និងសភាពការណ៍នៅឧត្តរ ១០៦និង១០៣” ។

ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ នៅក្នុងសេចក្តីសម្រេចរបស់ “គណៈកម្មាធិការមជ្ឈិម” ខៀវ សំផន ត្រូវបានជ្រើសតាំងឲ្យធ្វើជាប្រធានគណៈប្រធានរដ្ឋ ។ ពាក់កណ្តាលឆ្នាំ១៩៧៦ ខៀវ សំផន ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជា ។

យោងតាមសម្តីរបស់ អៀង សារី នៅដើមឆ្នាំ១៩៧៧ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានមន្ទីរ៨៧០ ដែលជាមន្ទីររបស់មជ្ឈិម ជំនួសកន្លែងរបស់សមមិត្ត ឌឿន ។

**ហ៊ុយ វណ្ណៈ**

# ជនកុម្មុយនិស្ត ខ្មែរក្រហម និង វៀតណាមៈ

## ប្រវត្តិទំនាក់ទំនងរវាងខ្មែរក្រហមនិងវៀតណាម

**(តចប់)** នៅទន្ទឹមពេលនេះដែរ ទស្សនាវដ្តីទង់ក្រហមដែលជាស្ថាប័នពត៌មានផ្លូវការរបស់សម្ព័ន្ធយុវជនកុម្មុយនិស្តកម្ពុជាបានចុះផ្សាយអត្ថបទមួយបញ្ជាក់ថា "បក្សកុម្មុយនិស្តកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥១" កាលនោះមានការជួយជ្រោមជ្រែងពីសំណាក់បក្សពលករវៀតណាម ។ ការនិយាយបែបនេះវាផ្ទុយនឹងសេចក្តីបង្គាប់របស់ ប៉ុល ពត ដែលអះអាងថាបក្សកុម្មុយនិស្តកម្ពុជាលេចរូបរាងឡើងនៅក្នុងឆ្នាំ១៩៦០ ហើយមិនបានទទួលជំនួយពីបក្សពលករវៀតណាមទេ ។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៦ ផ្លូវហោះហើរជាប្រចាំមួយរវាងទីក្រុងហាណូយនិងវៀងច័ន្ទក៏ត្រូវបានបង្កើតឡើង ។ ផលិតផលជ័រកៅស៊ូស្រស់ត្រូវបានដឹកទៅលក់ឲ្យប្រទេសសិង្ហបុរីក្នុងគោលបំណងដើម្បីទទួលជំនួយមនុស្សធម៌និងថ្នាំពេទ្យពីអង្គការសហប្រជាជាតិនិងក្រុមហ៊ុនអាមេរិកាំងមួយចំនួន ។ ព្រឹត្តិការណ៍ទាំងនេះបង្ហាញឲ្យឃើញការចុះខ្សោយនៃក្រុមប្រឆាំង ឲ្យឃើញការផ្លាស់ប្តូរមាគ៌ានយោបាយនិងឥរិយាបថរបស់រដ្ឋអំណាចកម្ពុជាចំពោះប្រទេសវៀតណាមនិងបក្សពលករវៀតណាម ។

ការប្រែប្រួលបែបនេះនៅក្នុងទីក្រុងភ្នំពេញ បានលើកទឹកចិត្តដល់ថ្នាក់ដឹកនាំវៀតណាមដែលឲ្យយោបល់ដល់មិត្តសូវៀតរបស់ខ្លួនថា "សភាពការណ៍នៅកម្ពុជាមិនមានលក្ខណៈច្បាស់លាស់ទេ ប៉ុន្តែធ្វើការជាមួយ នួន ជា ងាយស្រួលជាងធ្វើការជាមួយ ប៉ុល ពត និង អៀង សារី" ។ មិត្តសូវៀតក៏បញ្ជូនសញ្ញាសំខាន់មួយដល់ថ្នាក់ដឹកនាំថ្មីរបស់ខ្មែរ÷ នៅកិច្ចប្រជុំពេញអង្គនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តសូវៀតកាលពីខែតុលា ឆ្នាំ១៩៧៦ ប្រឺសនីវ បានប្រកាសមួយរំពេចថា "ផ្លូវឆ្ពោះទៅរកការអភិវឌ្ឍត្រូវបានបើកចំហនៅក្នុងចំណោមប្រទេសផ្សេងទៀតមុនកម្ពុជាប្រជាធិបតេយ្យ" ។ ក៏ប៉ុន្តែ ក្តីសង្ឃឹមថានឹងមានស្ថិរភាពឬការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងប្រទេសកម្ពុជា បន្តិចក្រោយមកក៏ក្លាយជាស្រអាប់ដោយសារតែទីក្រុងហាណូយមិនធ្វើការប៉ុនប៉ងសំខាន់ៗក្នុងការគាំទ្រដល់គូបដិបក្ខរបស់ ប៉ុល ពត ។ វាពិបាកណាស់ក្នុងការរកឲ្យឃើញពីមូលហេតុដែលនាំឲ្យមានស្ថានការណ៍នេះកើតឡើង ។ តើវាកើតឡើងដោយសារវៀតណាមគិតថាមិនអាចមានការផ្លាស់ប្តូរ ឬក៏វៀតណាមមិនហ៊ានធ្វើការសម្របសម្រួល"ប្រជាជនរបស់ខ្លួន"នៅទីក្រុងភ្នំពេញ ឬមួយក៏វៀតណាមមិនដឹងច្បាស់លាស់ថាតើត្រូវជួយដោយរបៀបណា ឬក៏វៀតណាមគ្មានលទ្ធភាពផ្តល់ជំនួយ? រាល់ការប៉ុនប៉ងដក ប៉ុល ពត ចេញពីអំណាច ត្រូវបញ្ចប់សម្រាប់ទីក្រុងហាណូយ÷ អ្នកប្រឆាំងនឹង"បងទី១" រាប់ពាន់នាក់ត្រូវបានចាប់ដាក់គុកនិងសម្លាប់ចោល ហើយឥឡូវនេះក្រោយពីអ្នកឈ្នះបានឡើងកាន់អំណាចសាជាថ្មី ក៏អនុវត្តនយោបាយប្រឆាំងនឹងវៀតណាមយ៉ាងចំហ ។

ល្បែង"ឆ្មានិងកណ្តុរ"រវាង ប៉ុល ពត និងទីក្រុងហាណូយបានបញ្ចប់ទៅក្រោយពីឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសវៀតណាម ហ៊័ង វ៉ាន់ ឡឺយ មកធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញនៅខែកុម្ភៈ ឆ្នាំ១៩៧៧ ។ ប៉ុល ពត បានបដិសេធសំណើចូលរួមប្រជុំកំពូលរវាងថ្នាក់ដឹកនាំកម្ពុជា-វៀតណាម ។ ក្រោយពីទទួលបរាជ័យនៃដំណើរទស្សនកិច្ចនេះមក ចុងក្រោយទីក្រុងហាណូយជឿជាក់ថាខ្លួនមិនអាចឈានដល់កិច្ចព្រមព្រៀងជាមួយថ្នាក់ដឹកនាំកម្ពុជាបានទេ ។ ក្តីសង្ឃឹមដែលថា នួន ជា អាចផ្លាស់ប្តូរសភាពការណ៍សម្រាប់បម្រើផលប្រយោជន៍ខាងវៀតណាមត្រូវរលាយអស់ ។ នៅក្នុងជំនួបរវាងឯកអគ្គរដ្ឋទូតសូវៀតនិងឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ហ៊័ង ប៊ិក សឺន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ តំណាងខាងវៀតណាមនិយាយថា "នៅអំឡុងពេលមានសង្គ្រាមជាមួយសហរដ្ឋអាមេរិក ជំហររបស់ នួន ជា ចំពោះវៀតណាមគឺមានលក្ខណៈវិជ្ជមាន ហើយឥឡូវនេះ នៅក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយថ្នាក់ដឹកនាំវៀតណាម នួន ជា មានក្តី

អាណិតចំពោះវៀតណាមខ្លះដែរ ប៉ុន្តែដោយសារសភាពការណ៍កម្ពុជាបច្ចុប្បន្នបានធ្វើឲ្យបុគ្គលទាំងនេះមិនអាចធ្វើទៅកើត» ។

ការសម្រេចចិត្តរបស់វៀតណាមក្នុងការប្រកាន់យកជំហរទំនាក់ទំនងកាន់តែតឹងរ៉ឹងជាមួយកម្ពុជាប្រជាធិបតេយ្យ គឺដោយសារសង្គ្រាមព្រំដែនឥតឈប់ឈរដែលផ្តើមឡើងដោយខ្មែរក្រហមនៅនិទាឃរដូវនៃឆ្នាំ១៩៧៧ ព្រមជាមួយការលេចចេញនូវបុគ្គលិកយោធាចិនដែលផ្តល់ការហ្វឹកហ្វឺននិងបំពាក់អាវុធដល់កងកម្លាំងខ្មែរក្រហម សង់ផ្លូវនិងមូលដ្ឋានយោធា ។ នៅក្នុងចំណោមមូលដ្ឋានទាំងនោះ មានមូលដ្ឋានទ័ពអាកាសមួយនៅក្នុងខេត្តកំពង់ឆ្នាំងដែលសម្រួលឲ្យយន្តហោះយោធាចូលទៅដល់រដ្ឋធានីវៀតណាមខាងត្បូង (ហូជីមិញ/សៃហ្គន) ក្នុងរយៈពេលតែកន្លះម៉ោងប៉ុណ្ណោះ ។ សភាពការណ៍បានវិវឌ្ឍទៅដល់លក្ខណៈមួយដែលថា វៀតណាមត្រូវតែគិតអំពីការគំរាមកំហែងដល់សន្តិសុខជាតិជាជាងគិតអំពីសហព័ន្ធឥណ្ឌូចិន ។ កាលៈទេសៈថ្មីនេះតម្រូវឲ្យមានដំណោះស្រាយថ្មី ។ ទាក់ទងនឹងបញ្ហានេះ ព័ត៌មានខាងក្រោមដែលឯកអគ្គរដ្ឋទូតស៊ុយអែតទទួលបានពីសហការីហុងគ្រីនៅក្នុងប្រទេសវៀតណាម ធ្វើឲ្យមានការចាប់អារម្មណ៍ខ្លាំងបំផុត ។ «ដូចព័ត៌មានដែលអ្នកកាសែតហុងគ្រីទទួលបានដូច្នេះដែរគឺថានៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៧ គណៈកម្មាធិការប្រធានផ្នែកនយោបាយនិងប្រតិបត្តិនៃបក្សកុម្មុយនិស្តវៀតណាមបានបើកសម័យប្រជុំវិសាមញ្ញនៅទីក្រុងសៃហ្គន ក្រោមអធិបតីភាពរបស់ឡេ យន់ ក្នុងគោលបំណងពិភាក្សាអំពីពេលវេលាចុះផ្សាយព័ត៌មានស្តីអំពីការឈ្លានពានរបស់កម្លាំងប្រតិកិរិយាកម្ពុជា» ។ ពាក្យថា «កម្លាំងប្រតិកិរិយាកម្ពុជា» បង្ហាញឲ្យឃើញច្បាស់ពីការផ្លាស់ប្តូរនយោបាយវៀតណាម ។ ទីក្រុងហាណូយមានផែនការប្រតិបត្តិការថ្មីដើម្បីទប់ទល់នឹងសភាពការណ៍នៅកម្ពុជា ។

ចំណុចមួយនៃផែនការនេះគឺការផ្លាស់ប្តូរយុទ្ធសាស្ត្រធ្វើសង្គ្រាមនៅតាមព្រំដែន ។ ចុងឆ្នាំ១៩៧៧ កងទ័ពវៀតណាមគ្រាន់តែការពារប៉ុណ្ណោះ ប៉ុន្តែឥឡូវនេះវៀតណាមវាយប្រហារចូលទឹកដីកម្ពុជាដោយផ្ទាល់ ដែលធ្វើឲ្យខ្មែរក្រហមភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ នៅខែធ្នូ-មករា ឆ្នាំ១៩៧៧-៧៨ កងទ័ព


យុាំង វ៉ាន់គៀត

វៀតណាមបានកម្ទេចអង្គភាពរបស់កម្ពុជាប្រជាធិបតេយ្យ ហើយដេញតាមចាប់យុទ្ធជនខ្មែរក្រហម ។ ក្រោយពេលវាយប្រហារហើយ វៀតណាមមិនចូលមកកាន់កាប់ទេ ប៉ុន្តែបានដកកងទ័ពចេញយ៉ាងលឿន ។ អ្នកឆ្លើយឆ្លងព័ត៌មានរបស់ហុងគ្រី ហ្គាតានដីវ ត្រូវបានរាយការណ៍ថា «កងទ័ពវៀតណាមបានពង្រាយ៣៥គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ប៉ុន្តែមិនអាចកាន់កាប់ទឹកដីកម្ពុជាទាំងស្រុងតាមផ្លូវនយោបាយទេ» ។ ការវាយលុកប្រកបដោយជោគជ័យនេះធ្វើឲ្យហាណូយមានលទ្ធភាពធ្វើការវាយតម្លៃយ៉ាងពិស្តារទៅលើសភាពការណ៍នៅកម្ពុជានិងឥរិយាបថរបស់ប្រជាជនវៀតណាមភាគច្រើន ។ នៅពេលដែលកងទ័ពវៀតណាមលុកចូលក្នុងទឹកដីកម្ពុជា ប្រជាជនមូលដ្ឋានបាន «ឃើញមុខវៀតណាមយ៉ាងច្បាស់» ដូចដែលអគ្គទូតជាន់ខ្ពស់វៀតណាមបានជម្រាបដល់ឯកអគ្គរដ្ឋទូតយ៉ាងដូច្នេះដែរ» ។ មិនតែប៉ុណ្ណោះ នៅពេលដែលកងទ័ពវៀតណាមដកចេញពីទឹកដីកម្ពុជា មានមនុស្សរាប់ពាន់នាក់ភៀសខ្លួនតាមពីក្រោយកងទ័ពទាំងនោះសំដៅទៅប្រទេសវៀតណាមដែរ ។



កងទ័ពខ្មែរក្រហម

នៅពេលនោះ ទីក្រុងហាណូយគិតតែទៅលើផ្លូវពីរយ៉ាងតែប៉ុណ្ណោះក្នុងការដោះស្រាយបញ្ហាកម្ពុជា ។ យោងតាមសម្តីរបស់ វុ ហ៊ីង ប្រធាននាយកដ្ឋានកុងស៊ុលនៃក្រសួងការបរទេសវៀតណាមបានឲ្យដឹងថា «ជម្រើសទីមួយគឺជ័យជម្នះសម្រាប់កម្លាំង «ពង្រីកខ្លួន» នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយជម្រើសទីពីរបង្ខំឲ្យ ប៉ុល ពត ចរចានៅក្នុងស្ថានភាពចុះដុនដាប» ។

ដូចយើងឃើញស្រាប់ហើយ ទីក្រុងហាណូយថែមទាំងបានប្រុងប្រៀបធ្វើរដ្ឋប្រហារនិងយកជ័យជម្នះតាមរយៈ«កម្លាំងពង្រីកខ្លួន» ព្រមទាំងធ្វើឲ្យ ប៉ុល ពត ចុះចាញ់និងទទួលយកនូវលក្ខខណ្ឌផ្សេងៗពីវៀតណាម ។ ក៏ប៉ុន្តែថ្នាក់ដឹកនាំវៀតណាមគិតខុស ។ ការប៉ុនប៉ងផ្តួលរំលំ ប៉ុល ពត តាមរយៈការធ្វើកុប្បកម្មពីសំណាក់កម្លាំងយោធាភូមិភាគបូព៌ានោះ បានបញ្ចប់ដោយទទួលមហន្តរាយយ៉ាងធ្ងន់ធ្ងរចំពោះការងើបបះបោរប្រឆាំងនឹង ប៉ុល ពត នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ ។ ដូចនេះជម្រើសទីមួយអាចត្រូវដកចេញ ។ ផែនការទីពីរក៏ហាក់មិនមានភាពជាក់លាក់អ្វីដែរ ដោយសារតែជំនួយចិនមកឲ្យខ្មែរក្រហមកើនឡើងខ្លាំងពេកនៅឆ្នាំ១៩៧៨ ហើយជំនួយនេះបានកាត់បន្ថយការលំបាកមួយចំនួនដែលរបបកម្ពុជាប្រជាធិបតេយ្យកំពុងតែជួបប្រទះ ។

ថ្នាក់ដឹកនាំវៀតណាមទំនងជាមិនបានប្រកាន់យកផែនការទាំងពីរឈុតដូចដែល វុ ហ៊ីង ណែនាំចំពោះឯកអគ្គរដ្ឋទូតសូវៀតទេមើលទៅ ។ ថ្នាក់ដឹកនាំវៀតណាមមានជម្រើសទីបីមួយទៀត÷ ការផ្តួលរំលំរបប ប៉ុល ពត ដោយការវាយលុកជាទ្រង់ទ្រាយធំ និងដាក់ការគ្រប់គ្រងថ្មីនៅទីក្រុងភ្នំពេញដោយទីក្រុងហាណូយ ។ ហេតុដូចនេះហើយបានជានៅពាក់កណ្តាលខែកុម្ភៈ ឆ្នាំ១៩៧៨ ថ្នាក់ដឹកនាំបក្សវៀតណាម ឡេ យន់ និង ឡេ ឌឹក ថ បានជួបជំបូងជាមួយក្រុមកុម្មុយនិស្តខ្មែរមួយក្រុមតូចដែលនៅសេសសល់នៅក្នុងប្រទេសវៀតណាមដែលបង្កើតជាក្រុមសាជាថ្មីនៅឆ្នាំ១៩៥៤ (ភាគច្រើននៃសមាជិកនៅក្នុងក្រុមនេះបានវិលត្រឡប់មកកម្ពុជានៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ហើយក្រោយមកត្រូវបានសម្លាប់ចោលនៅក្នុងការបង្ក្រាបផ្សេងៗ)

និងជួបជាមួយអតីតខ្មែរក្រហមដែលស្វែងរកសិទ្ធិជ្រកកោន នៅក្នុងប្រទេសវៀតណាមដើម្បីរស់ឲ្យផុតពីការបង្ក្រាបរបស់ ប៉ុល ពត ។ គោលបំណងនៃជំនួបនេះគឺដើម្បីបង្កើតឡើងនូវ ចលនាប្រឆាំង ប៉ុល ពត និងបង្កើតក្បាលម៉ាស៊ីនដឹកនាំ នយោបាយ ។ក្បាលម៉ាស៊ីននយោបាយនេះរួមមាន វរសេនីយ៍ត្រី ប៉ែន សុវណ្ណ ជាជនជាតិខ្មែរដែលរស់នៅវៀតណាមជាង២៥ឆ្នាំ និងអតីតខ្មែរក្រហម ហ៊ុន សែន ដែលទើបតែរត់ភៀសខ្លួនចូល ទឹកដីវៀតណាមនៅខែមិថុនា ឆ្នាំ១៩៧៧ ។ នៅពេលនោះ “ខ្សែសង្វាក់ជំរំសម្ងាត់”សម្រាប់កេណ្ឌនិងហ្វឹកហាត់កងទ័ពស្ថិតនៅ ក្នុងទឹកដីវៀតណាមខាងត្បូង ។ អតីតមូលដ្ឋានយោធាអាមេរិកាំង នៅ សួន ឡុក និង ឡុង ប៊ូវ គឺជាមូលដ្ឋានធំបង្អស់ ។ នៅខែមេសា ឆ្នាំ១៩៧៨ កងពលតូចទី១របស់កងទ័ពប្រឆាំងនឹង ប៉ុល ពត ត្រូវបានបង្កើតឡើងស្ងាត់ៗ ។ ក្រោយមកទៀត មានកងពល តូចផ្សេងៗថ្នាក់ត្រឹមកម្រិតវរសេនាតូចចុះ ត្រូវបានបង្កើតឡើង ជាបន្តបន្ទាប់នៅក្នុងទឹកដីវៀតណាម ។

ការផ្តល់នូវមូលដ្ឋានការទូតសម្រាប់ប្រតិបត្តិការផ្តួលរំលំ ប៉ុល ពត ត្រូវបានចាត់ទុកថាមានសារប្រយោជន៍បំផុត ។ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ គណៈកម្មាធិការប្រធានផ្នែក នយោបាយនិងប្រតិបត្តិនៃគណៈកម្មាធិការមជ្ឈិមបក្សពលករ វៀតណាមដែលដឹកនាំដោយ ឡេ យន់ បានសម្រេចចិត្តធ្វើ ដំណើរទៅកាន់ទីក្រុងម៉ូស្គូ ។ អគ្គទូតសូវៀតបានរាយការណ៍ កាលពីខែមិថុនា ឆ្នាំ១៩៧៨ ថា “ដំណើរមកកាន់ម៉ូស្គូរបស់ ថ្នាក់ដឹកនាំវៀតណាម គួរតែលាក់ការណ៍ឲ្យបានល្អ ។ ឡេ ឌុង ទិន អនុប្រធានទទួលបន្ទុកបុគ្គលិករួម នឹងអមដំណើរ ឡេ យន់” ។

ដោយមានការធានាថានឹងមានកិច្ចគាំទ្រជាផ្លូវការ និង ក្រោយពីការបញ្ចប់សន្ធិសញ្ញាទំនាក់ទំនងមិត្តភាពនិងកិច្ចសហ ប្រតិបត្តិការរវាងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀតនិង សាធារណរដ្ឋសង្គមនិយមវៀតណាមរួចមក វៀតណាមបាន ចាប់ផ្តើមនិយាយដោយច្បាស់ៗថា “រដូវប្រាំងខាងមុខនេះអាច យកមកប្រើសម្រាប់វាយលុកជាទ្រង់ទ្រាយធំទៅលើរបបភ្នំពេញ” ។ រឿងដែលគួរឲ្យចាប់អារម្មណ៍គឺថា វៀតណាមបានបញ្ជាក់ប្រាប់ តំណាងសូវៀតដែលមានការព្រួយបារម្ភអំពីប្រតិកម្មរបស់ចិន ចំពោះការវាយលុកដែលនឹងកើតឡើងខាងមុខថា “ចិននឹងមិន មានពេលបញ្ជូនអគ្គភាពកងទ័ពក្នុងទ្រង់ទ្រាយធំមកភ្នំពេញដើម្បី សង្គ្រោះរបបកម្ពុជាប្រជាធិបតេយ្យបានទេ” ។

និយាយជាទូទៅ នៅមុនថ្ងៃចូលវាយលុក វៀតណាមបាន និយាយដោយត្រង់ៗនិងច្បាស់ៗទៅកាន់សម្ព័ន្ធមិត្តសូវៀត អំពី អ្វីដែលខ្លួនបានដឹងពីសភាពការណ៍នៅក្នុងជួរថ្នាក់ដឹកនាំខ្មែរ ។ នៅខែតុលា ឆ្នាំ១៩៧៨ យោងតាមសម្តីរបស់មន្ត្រីបក្សជាន់ខ្ពស់ វៀតណាម“ទទួលបន្ទុកបញ្ហាកម្ពុជា” ម្នាក់ បានឲ្យដឹងថា ទីក្រុង ហាណូយនៅតែជឿជាក់ថា “មានឥស្សរជនបក្សសំខាន់ៗពីររូប នៅទីក្រុងភ្នំពេញដែលស្របគំនិតជាមួយវៀតណាម គឺ នួន ជា និងអតីតលេខាបក្សទីមួយភូមិភាគបូព៌ា សោ ភឹម” ។ អគ្គទូត សូវៀតបាននិយាយថា “មិត្តដឹងហើយថា នួន ជា ប្រឆាំងនឹង របប ប៉ុល ពត ។ នួន ជា ត្រូវគ្នាជាមួយបក្សកុម្មុយនិស្ត វៀតណាមណាស់ ប៉ុន្តែដោយខ្លាចមានការវាយប្រហារមកលើខ្លួន នួន ជា មិនអាចសម្តែងចេញបានទេ” ។ ដោយព្យាយាមសង្គ្រោះ នួន ជា ពីការវាយប្រហារនេះ វៀតណាមបានទាក់ទងជាមួយ នួន ជា កាន់តែខ្លាំង ។ គេមិនដឹងពីវាសនារបស់ សោ ភឹម ទេ តែជឿជាក់ថា សោ ភឹម បានរត់ភៀសនិងលាក់ខ្លួននៅ ក្នុងព្រៃបាត់ទៅហើយ ។ យោងតាមគំនិតរបស់គណៈកម្មាធិការ មជ្ឈិមនៃបក្សកុម្មុយនិស្តវៀតណាម សមាជិកគណៈកម្មាធិការ ប្រធានផ្នែកនយោបាយនិងប្រតិបត្តិនៃគណៈកម្មាធិការមជ្ឈិម បក្សកុម្មុយនិស្តកម្ពុជា នួន ជា និង សោ ភឹម ត្រូវបានស្គាល់ សុះសាយថាជាឥស្សរជននយោបាយនៅក្នុងប្រទេសកម្ពុជា ដែល“នៅក្នុងកាលៈទេសៈអំណោយផលនឹងអាចក្លាយជាមេ ដឹកនាំកងទ័ពបដិវត្តន៍នៅក្នុងប្រទេសប្រកបដោយសមានចិត្ត” ។

ពិតណាស់ ប្រសិនបើ សោ ភឹម និង នួន ជា បានចូលរួម ជាមួយកងកម្លាំងដើម្បីដឹកនាំការតស៊ូនេះ ម៉្លេះសមការបណ្តេញ ប៉ុល ពត ចេញពីភ្នំពេញ និងផ្លាស់ជំនួសដោយកងកម្លាំងដែល គាំទ្រវៀតណាម នឹងបានសម្រេចបាត់ទៅហើយតាមរយៈការ ប្រយុទ្ធនិងបំផ្លិចបំផ្លាញដ៏សាហាវនៅឆ្នាំ១៩៧៩នោះ ។ មេដឹក នាំទាំងពីរនាក់នេះជាអ្នកគ្រប់គ្រងយោធានិងក្បាលម៉ាស៊ីនដឹកនាំ បក្សមួយចំណែកធំ ហើយអាចយកតំបន់សំខាន់ៗមួយចំនួន

នៅក្នុងប្រទេសដាក់ក្រោមការគ្រប់គ្រងរបស់ខ្លួន ។ ក៏ប៉ុន្តែ វៀតណាមសង្ឃឹមថា ឥស្សរជនទាំងពីររូបនេះដែលអាចដឹកនាំការបះបោរប្រឆាំងនឹង ប៉ុល ពត នោះ មិនមានមូលដ្ឋានច្បាស់លាស់ទេ ។ ជាក់ស្តែងគឺថាៈ សោ ភឹម បានស្លាប់នៅក្នុងការបះបោរក្នុងខែមិថុនា ឆ្នាំ១៩៧៨ ចំណែកឯ នួន ជា វិញ ដូចដឹងស្រាប់ហើយ គាត់បែរជាក្លាយទៅជាអ្នកដើរតាមក្រោយ ប៉ុល ពត យ៉ាងដាច់ខាតទៅវិញ ។ នួន ជា មិនបានងាកមកខាងវៀតណាមឡើយ ។ ជាងនេះទៅទៀត រហូតមកដល់សព្វថ្ងៃនេះ សភាពការណ៍នៅជុំវិញ នួន ជា ក៏នៅតែមិនច្បាស់ដែរ ។ វាពិបាកណាស់ក្នុងការយល់អំពីមូលហេតុដែលថា រហូតមកដល់ចុងឆ្នាំ ១៩៧៨ទៅហើយ ទីក្រុងហាណូយនៅតែមានជំនឿថា នួន ជា គឺជាមនុស្សរបស់ខ្លួន ទោះបីជាបទពិសោធន៍បង្ហាញឲ្យឃើញការពិតផ្ទុយយ៉ាងណាក៏ដោយ ។ តើទីក្រុងហាណូយមិនដឹងថា នួន ជា នៅខាង ប៉ុល ពត រហូតដែរឬទេ? ដឹងពីការទាមទាររបស់ នួន ជា ថា “ជនជាតិភាគតិចវៀតណាមមិនត្រូវអនុញ្ញាតឲ្យរស់នៅលើទឹកដីកម្ពុជាដែរឬទេ? ដឹងពីភាពឃោរឃៅរបស់ នួន ជា ឬទេ? និងមានដឹងថា ក្នុងការប្រៀបធៀបជាមួយ នួន ជា ប្រជាជនចាត់ទុក ប៉ុល ពត ថាមានចិត្តល្អឬទេ? ។ អាចនិយាយបានពីរយ៉ាង ទីមួយថា នួន ជា បោកប្រាស់វៀតណាមដោយខំពន្យល់ហេតុផលពីភាពឃោរឃៅរបស់ខ្លួននិងសកម្មភាពប្រឆាំងនឹងវៀតណាម ដោយការបង្ខិតបង្ខំដែល នួន ជា ជាអ្នកធ្វើដោយផ្ទាល់ដៃ ។ ទីពីរ វៀតណាមពុំដោយខ្លួនឯងដោយមិនជឿថា ដើងចាស់កុម្មុយនិស្តដែលធ្លាប់ធ្វើការយ៉ាងជិតស្និទ្ធជាមួយពួកខ្លួននៅក្នុងបក្សកុម្មុយនិស្តឥណ្ឌូចិនតែមួយ និងជាអ្នកដែលដាច់ខាតចំពោះទីក្រុងហាណូយ អាចក្បត់វៀតណាមខ្លួនឯងវិញដូច្នេះសោះ ។ បានសេចក្តីថា វៀតណាមមិនត្រឹមតែចាញ់បោក នួន ជា ទេ ប៉ុន្តែថែមទាំងចាញ់បោកជនកុម្មុយនិស្តដើងចាស់មួយចំនួនទៀតនៅក្នុងបក្សកុម្មុយនិស្តឥណ្ឌូចិនដូចជា តាម៉ុក និង សោ ភឹម យ៉ាងជូរចត់ទៀតផង ។

ទាក់ទងនឹងបញ្ហានេះ ទីក្រុងហាណូយដែលរៀបចំការវាយលុកនិងបង្កើតរដ្ឋអំណាចកម្ពុជាថ្មីមួយ ត្រូវបង្ខំចិត្តពឹងពាក់បុគ្គលតូចតាចមកពីថ្នាក់កណ្តាលនៃចលនាខ្មែរក្រហម មានជាអាទិ៍ដូចជា ហេង សំរិន, ជា ស៊ីម និង ហ៊ុន សែន ផ្សំជាមួយតួឯកនយោបាយដែលគួរឲ្យទុកចិត្តពីររូបទៀតដែលរស់នៅវៀតណាមជាច្រើនឆ្នាំមកហើយ គឺ ប៉ែន សុវណ្ណ និង កែវ ចិន្តា ។ ក្រុមទាំងពីរនេះបង្កើតបានជាបង្អែកដ៏រឹងមាំនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាដែលត្រូវបានបង្កើតឡើងនៅខែធ្នូ ឆ្នាំ១៩៧៨ និងបក្សប្រជាជនបដិវត្តកម្ពុជាដែលបង្កើតសាជាថ្មីក្នុងរយៈពេលបន្តិចក្រោយមកនៅដើមខែមករា ឆ្នាំ១៩៧៩ ។ ក្នុងករណីនេះ អតីតខ្មែរក្រហមបានគ្រប់គ្រងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលគណៈកម្មាធិការមជ្ឈិមដឹកនាំដោយ ហេង សំរិន ហើយនិងខ្មែរមួយចំនួនទៀតដែលរស់នៅលើទឹកដីវៀតណាមអស់ពេលយ៉ាងយូរ ទទួលមុខតំណែងសំខាន់ៗនៅក្នុងជួរបក្សប្រជាជនបដិវត្តកម្ពុជា ចំណែកឯ ប៉ែន សុវណ្ណ ត្រូវដាក់ឲ្យធ្វើជាប្រធានគណៈកម្មការកសាងបក្ស ដែលក្រោយមកក្លាយជាគណៈកម្មាធិការមជ្ឈិមនៃបក្សប្រជាជនបដិវត្តកម្ពុជា ។

ដូចយើងឃើញស្រាប់ហើយ ទីក្រុងហាណូយបានរៀនពីកំហុសដែលបានធ្វើជាមួយ ប៉ុល ពត និងខ្មែរក្រហម ហើយបានសម្រេចចិត្ត “លែងដាក់ស៊ុតទាំងអស់ទៅក្នុងល្អីតែមួយទៀតហើយ” ។

ការកាន់កាប់ទីក្រុងភ្នំពេញដោយកងទ័ពវៀតណាមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ និងការប្រកាសបង្កើតសាធារណរដ្ឋប្រជាមានិតកម្ពុជា មានន័យថា ខ្មែរក្រហមលែងជាអង្គការចាត់តាំងនយោបាយនៅក្នុងប្រទេសកម្ពុជាទៀតហើយ ។ ខ្មែរក្រហមដែលនៅសេសសល់ បានលាក់ខ្លួននៅតាមព្រំប្រទល់ជាប់ទឹកដីថៃ ដើម្បីបន្តធ្វើសង្គ្រាមឈ្លបអូសបន្លាយទៅមុខទៀត ។ ប៉ុន្តែខ្មែរក្រហមមិនអាចស្តារអំណាចនិងឥទ្ធិពលរបស់ខ្លួនដែលមានកាលពីមុនមកបានទេ ។ អំណាចនយោបាយនៅក្នុងប្រទេសកម្ពុជាត្រូវបានប្រែក្លាយទៅជាបក្សប្រជាជនបដិវត្តកម្ពុជាដែលបង្កើតឡើងសាជាថ្មីដោយវៀតណាម ។ ចំពោះប្រវត្តិទំនាក់ទំនងរវាងអង្គការចាត់តាំងនៃបក្សប្រជាជនបដិវត្តកម្ពុជាជាមួយបក្សកុម្មុយនិស្តវៀតណាម និងឥរិយាបថរបស់ថ្នាក់ដឹកនាំវៀតណាមចំពោះ ហ៊ុន សែន ដែលក្រោយមកក្លាយជានាយករដ្ឋមន្ត្រីនៅឆ្នាំ១៩៩៥ ហើយដែលត្រូវបានហៅថា “បុរសពោរពេញទៅដោយសេចក្តីក្លាហាន” នោះ គឺជាប្រធានបទមួយផ្សេងទៀតដែលត្រូវលើកយកមកពិភាក្សា ។

**មិត្រ មូសយ៉ាកូវ**



ថូម៉ាស់ ហាម៉ាប៊ឺក

# ◆ ការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ: តើកិច្ចព្រមព្រៀងទៅលើការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម កើតឡើងដោយរបៀបណា?





**(តពីលេខមុន)** បញ្ហាដែលពិសេសនិងពិបាកបំផុតគឺការបង្កើតដែនយុត្តាធិការសម្រាប់បុគ្គល សម្រាប់តុលាការពិសេសនេះ ថាតើបុគ្គលមួយណាដែលនឹងត្រូវចោទប្រកាន់ ។ ក្រុមអ្នកជំនាញការបានប្រើគំនិតមួយថា មានតែ“ជនដែលទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋដ៏ធ្ងន់ធ្ងរបំផុត” តែប៉ុណ្ណោះ ដែលនឹងត្រូវយកមកកាត់សេចក្ដី ។ គំនិតនេះក៏ត្រូវបានលើកយកមកនិយាយនៅក្នុងសេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិនិងគណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្ស ។ ដូចនេះ មានតម្រូវការមួយក្នុងការស្វែងរករូបមន្តផ្លូវច្បាប់មួយដែលកំណត់ចំនួនការកាត់សេចក្ដីដោយគ្មានផ្ដល់ការលើកលែងទោស ចំពោះអ្នកនៅក្រៅក្រុមដែលបានកំណត់ដើម្បីយកមកកាត់ទោសនេះ ។ ក្រុមអ្នកជំនាញការបានទាញសេចក្ដីសន្និដ្ឋានថា បញ្ហានេះត្រូវតែបានដោះស្រាយក្នុងលក្ខណៈជា“នយោបាយរបស់ព្រះរាជអាជ្ញា” ។

នៅក្នុងដំណាក់កាលនេះ ជាការច្បាស់ណាស់ថា មានបញ្ហាពីរដែលអាចពិបាកយ៉ាងខ្លាំង ពោលគឺៈ ទីមួយ វិធីសាស្ត្រក្នុងការជ្រើសតាំងចៅក្រមនិងព្រះរាជអាជ្ញា ។ ទីពីរ ចំនួនជនបរទេសនិងជនជាតិខ្មែរក្នុងចំណោមចៅក្រមនិងព្រះរាជអាជ្ញា ។ សម្ដេចនាយករដ្ឋមន្ត្រីបានសួរថា តើលោកអគ្គលេខាអង្គការសហប្រជាជាតិអាចជ្រើសតាំងជនបរទេសដែរឬទេ ហើយខ្ញុំដឹងថាសម្ដេចបានពិភាក្សាជាផ្លូវការ ហើយស្ដីអំពីលទ្ធភាពក្នុងការចូលរួមស្មើគ្នា គឺ៥០-៥០ ។

ប៉ុន្តែចំពោះដំណោះស្រាយក្នុងការជ្រើសតាំងនេះមានការប្រថុយគ្រោះថ្នាក់មួយដែលថា ការជ្រើសរើសចៅក្រមនិងព្រះរាជអាជ្ញាកម្ពុជានឹងអាចចូលជាបញ្ហាពាក់ព័ន្ធនយោបាយ ។ មិនតែប៉ុណ្ណោះ ជាការសំខាន់ណាស់ក្នុងការចៀសវាងការយល់ឃើញថាចៅក្រមនិងព្រះរាជអាជ្ញាមាន“ថ្នាក់”ពីរផ្សេងគ្នា ។ មានការទាញហេតុផលដ៏មានទម្ងន់ ទាមទារឲ្យមានយន្តការជ្រើសតាំងមួយសម្រាប់ជ្រើសតាំងអ្នកទាំងនេះ ។ និយាយម្យ៉ាងវិញទៀត ការជ្រើសរើសគួរតែមានការយល់ព្រមពីសំណាក់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ឬដោយយន្តការមិនលម្អៀងដែលលោកនឹងអាចបង្កើតសម្រាប់គោលដៅនេះ ។ ដំណើរការដែលសហគមន៍អន្តរជាតិអាចបដិសេធការជ្រើសតាំងជនជាតិកម្ពុជា នឹងបង្កើនភាពទុកចិត្តកាន់តែខ្ពស់ចំពោះការបង្កើតតុលាការនៅក្នុងប្រទេសកម្ពុជា ។

នៅទន្ទឹមពេលនេះដែរ ជាការសំខាន់ណាស់ថា អង្គភាពនៅក្នុងប្រទេសកម្ពុជាដែលមានការពាក់ព័ន្ធនៅក្នុងដំណើរការនេះអាចជារចនាសម្ព័ន្ធតុលាការ គឺមិនមែនរដ្ឋាភិបាលទេ ។ ជម្រើសជាក់ស្ដែងបំផុតនោះគឺឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលផ្អែកតាមរដ្ឋធម្មនុញ្ញ ។ ក្រៅពីកិច្ចការផ្សេងទៀត ស្ថាប័ននេះទទួលខុសត្រូវចាត់តាំងអង្គចៅក្រមនិងព្រះរាជអាជ្ញា ។

ជាការច្បាស់ដែរថាការពិភាក្សាទៅលើចំនួនចៅក្រមនិងព្រះរាជអាជ្ញាខ្មែរនិងបរទេសអាចទទួលផលប៉ះពាល់ពីសំណាក់វិធានក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ។ ខ្ញុំបានសរសេរនៅក្នុងអនុស្សរណៈផ្ទៃក្នុងមួយច្បាប់ថា “មានព្រះរាជអាជ្ញាឬចៅក្រមអន្តរជាតិភាគច្រើនអាចមានសុវត្ថិភាពជាង ។ ភាគីកម្ពុជាប្រហែលជាមានការលំបាកក្នុងការទទួលយក (នេះជាមូលហេតុដែលថា ចំណុចស្ដី

អំពីវិធាននៃការសម្រេចចិត្តអាចមានប្រយោជន៍) ។ ចំណុចសំខាន់គឺថា ជនជាតិកម្ពុជាទោះជាត្រូវបានជ្រើសតាំងមកពីខាងក្រៅក៏ដោយ មិនអាចមានលទ្ធភាពយកឈ្នះលើជនបរទេសតាមរយៈសំឡេងឆ្នោតឡើយ ។ នេះជាចំណុចដ៏មានឥទ្ធិពលមួយ ពោលគឺការដឹងខ្លួនដែលថាចៅក្រមកម្ពុជាខ្លួនឯងផ្ទាល់មិនអាចធ្វើសេចក្តីសម្រេចតែម្នាក់ឯងបាន នឹងកាត់បន្ថយគ្រោះថ្នាក់នៃការគាបសង្កត់" ។

ភារកិច្ចពិភាក្សាផ្ទៃក្នុងក៏ត្រូវបានជួយជ្រោមជ្រែងដែរតាមរយៈទស្សនាទានរបស់គណៈកម្មការមេធាវីសម្រាប់សិទ្ធិមនុស្សដែលបានសង្កត់ធ្ងន់អំពីសារសំខាន់នៃការបញ្ជាក់នៅក្នុងច្បាប់ដែលកំពុងតែជំរុញនូវសិទ្ធិក្នុងការការពារខ្លួននិងបណ្តឹងឧទ្ធរណ៍ ហើយថាសាក្សីនានានឹងត្រូវបានធានាសន្តិសុខនិងការពារដែលជាចំណុចមិនទាន់ត្រូវបានក្តោបឲ្យបានហ្មត់ចត់នៅក្នុងសេចក្តីព្រាងមុនដំបូងរបស់អគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ។

នៅក្នុងខណៈដែលការិយាល័យទទួលបន្ទុកកិច្ចការច្បាប់កំពុងតែធ្វើការលើបញ្ហានេះ មានការចាំបាច់មួយក្នុងការសម្រេចចិត្តទៅលើក្រុមអ្នកជំនាញការឲ្យមកធ្វើការនៅភ្នំពេញ ។ ខ្ញុំមានយោបល់មួយចំនួន ប៉ុន្តែបែរទៅជាថាការិយាល័យទទួលបន្ទុកកិច្ចការច្បាប់មានការចាប់អារម្មណ៍ក្នុងការធ្វើកិច្ចការនេះដោយផ្ទាល់ ។ ខ្ញុំបានស្វាគមន៍ការចូលរួមនេះ ប៉ុន្តែការឃើតយ៉ាវនេះគួរតែត្រូវបានលើកមកពន្យល់នៅទីក្រុងភ្នំពេញ ។ ជាការសំខាន់ណាស់ថា ក្នុងដំណាក់កាលនេះ អង្គការសហប្រជាជាតិបានធ្វើការយ៉ាងលឿន និងមានការតាំងចិត្តទៀតផង ។ ក្តីសង្ឃឹមរបស់ខ្ញុំគឺថា ក្រុមអ្នកជំនាញការច្បាប់នឹងទៅប្រទេសកម្ពុជានៅចុងខែមិថុនា តែដោយមានការវិវត្តនៃព្រឹត្តការណ៍និងដោយមានការសន្យាផ្សេងៗ ក្រុមនេះមិនបានមកក្នុងខែនេះទេ គឺរហូតដល់ចុងខែសីហាឯណោះ ។

នៅក្នុងពេលទន្ទឹមគ្នានេះដែរ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិត្រូវបានរាយការណ៍សង្ខេបជូន ។ គម្រោងទូទៅនៃសំណើរបស់លោកអគ្គលេខាធិការ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដោយរដ្ឋាភិបាលកម្ពុជា ជាពិសេសអំពីការឲ្យយោបល់របស់អង្គការសហប្រជាជាតិដែលថាភាគច្រើននៃចៅក្រមគួរតែជាអន្តរជាតិ ។

### ***បេសកកម្មរបស់ ហ្សាកលីន និងការពិភាក្សាតទៅទៀត***

បេសកកម្មមួយដែលដឹកនាំដោយជំនួយការលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការច្បាប់ ឈ្មោះលោក ហ្សាកលីន បានធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញចាប់ពីថ្ងៃទី២៥ ដល់ថ្ងៃទី៣១ ខែសីហា ។ ក្រុមការងារមួយដឹកនាំដោយទេសរដ្ឋមន្ត្រីជាន់ខ្ពស់ សុខ អាន ត្រូវបានតែងតាំងដោយរដ្ឋាភិបាលកម្ពុជា ដើម្បីមកជួបជំនុំជាមួយក្រុមអ្នកជំនាញការរបស់អង្គការសហប្រជាជាតិ ។ ក្រុមការងារនេះបានប្រគល់ជូននូវសេចក្តីព្រាងច្បាប់មួយសម្រាប់ជម្រុញឲ្យមានការតាក់តែងច្បាប់ ។ គណៈប្រតិភូអង្គការសហប្រជាជាតិបានឆ្លើយតបវិញនៅក្នុងអំឡុងទស្សនកិច្ចនេះដែរ ដោយប្រគល់ជូននូវសេចក្តីព្រាងច្បាប់មួយផ្សេងទៀត ។ សេចក្តីព្រាងច្បាប់ទាំងពីរនេះមានភាពខុសប្លែកពីគ្នាច្រើនណាស់ ។

សេចក្តីព្រាងច្បាប់ទាំងពីរនេះខុសគ្នាលើសារជាតិនៃដែនយុត្តាធិការដែលមានសមត្ថកិច្ច និងចំណុចដែលថាតើវាជាផ្នែកមួយនៃប្រព័ន្ធតុលាការដែលមានស្រាប់ (សេចក្តីព្រាងច្បាប់កម្ពុជា) ឬជាតុលាការពិសេសមួយបង្កើតឡើងជាពិសេសដើម្បីកាត់សេចក្តីជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សក្នុងអំឡុងរបបខ្មែរក្រហម (សេចក្តីព្រាងច្បាប់របស់អង្គការសហប្រជាជាតិ) ។ សេចក្តីព្រាងច្បាប់របស់រដ្ឋាភិបាលកម្ពុជាស្នើថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកជ្រើសតាំងចៅក្រមនិងព្រះរាជអាជ្ញាទាំងអស់ ហើយភាគតិចនៃអ្នកទាំងនោះគឺជាជនបរទេសដែលត្រូវបានជ្រើសតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ សេចក្តីព្រាងច្បាប់របស់អង្គការសហប្រជាជាតិស្នើថា ចៅក្រមនិងព្រះរាជអាជ្ញាទាំងអស់នឹងត្រូវជ្រើសតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

សេចក្តីព្រាងច្បាប់កម្ពុជាបង្ហាញពីប្រព័ន្ធច្បាប់ដែលមានស្រាប់ជាមួយនឹងតុលាការក្រុងភ្នំពេញ សាលាឧទ្ធរណ៍ និងតុលាការកំពូល ។ នៅក្នុងសេចក្តីព្រាងច្បាប់របស់អង្គការសហប្រជាជាតិ តុលាការនេះមានការិយាល័យពីរៈ សាលាដំបូង និងសាលាឧទ្ធរណ៍

រួមទាំងអយ្យការនិងការិយាល័យក្រឡាបញ្ជី ។

គណៈប្រតិភូរបស់អង្គការសហប្រជាជាតិបានសង្ខេបនូវខ្លឹមសារសំខាន់ៗរបស់ខ្លួនដូចខាងក្រោមនេះ÷

«បើចង់ឲ្យការជំនុំជម្រះទោសមេដឹកនាំខ្មែរក្រហមមានយុត្តិធម៌ គ្មានភាពលម្អៀង និងនីតិវិធីត្រឹមត្រូវតាមគំរូបទដ្ឋាន អន្តរជាតិ (ហើយទទួលបាននូវការគាំទ្រនិងភាពស្របច្បាប់)ពីសំណាក់សហគមន៍អន្តរជាតិ ជាការសំខាន់ណាស់ថា សមាសភាពអន្តរជាតិនៅក្នុងតុលាការនេះត្រូវតែមាំទាំ ហើយត្រូវតែមានប្រសិទ្ធភាពតាមដែនការអន្តរជាតិនិងជាតិ ។ បញ្ហានេះមិនអាចសម្រេចទៅបានដោយគ្រាន់តែបន្ថែមនូវចំនួនចៅក្រមបរទេសចូលក្នុងសមាសភាពប្រព័ន្ធតុលាការដែលមានស្រាប់ ហើយមានជនជាតិកម្ពុជានិងមិនមែនជនជាតិកម្ពុជាចូលធ្វើជាចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិកក្រឡាបញ្ជី ទើបអាចសម្រេចកិច្ចការនេះបាន» ។

កិច្ចពិភាក្សាគ្នានេះបានបញ្ចប់ទៅដោយមានការសន្យាពីសំណាក់ភាគីកម្ពុជា ក្នុងការពិនិត្យសាឡើងវិញទៅលើសេចក្តីព្រាងច្បាប់របស់ខ្លួនតាមការឲ្យយោបល់ពីអង្គការសហប្រជាជាតិ ។ ក្រុមការងាររបស់អង្គការសហប្រជាជាតិយល់ថា សេចក្តីព្រាងច្បាប់ដែលត្រូវបានពិនិត្យពិច័យសាឡើងវិញនោះ នឹងត្រូវបានចេញផ្សាយមុនឬនៅក្នុងអំឡុងពេលដំណើរទស្សនកិច្ចរបស់សម្តេច ហ៊ុន សែន ទៅកាន់ទីក្រុងញូវយ៉ក នៅខែកញ្ញា ។

នៅក្នុងកិច្ចជួបប្រជុំជាមួយនឹងលោកអគ្គលេខាធិការអង្គការសហប្រជាជាតិនៅថ្ងៃទី១៦ ខែកញ្ញា សម្តេច ហ៊ុន សែន បានដាក់ជូននូវកំណត់អនុស្សរណៈស្នារតីមួយច្បាប់ដែលមានជម្រើសបីយ៉ាងសម្រាប់ការចូលរួមរបស់អង្គការសហប្រជាជាតិ ។ ចំណុចទីមួយគឺថា អង្គការសហប្រជាជាតិត្រូវផ្តល់ក្រុមជំនាញការច្បាប់ដើម្បីរួមគ្នាជាមួយនឹងមេធាវីកម្ពុជានិងមេធាវីមកពីប្រទេសផ្សេងៗជួយធ្វើសេចក្តីព្រាងច្បាប់ចាំបាច់នានា និងផ្តល់ចៅក្រមព្រមទាំងព្រះរាជអាជ្ញាឲ្យមកចូលរួមនៅក្នុងដំណើរការជំនុំជម្រះក្តីនៅតុលាការកម្ពុជាដែលមានស្រាប់ ។ ជម្រើសទីពីរគឺអង្គការសហប្រជាជាតិត្រូវផ្តល់ក្រុមជំនាញការច្បាប់ដែលមិនមានការចូលរួមដោយផ្ទាល់នៅក្នុងដំណើរការជំនុំជម្រះក្តីឡើយ រីឯជម្រើសទីបីគឺ អង្គការសហប្រជាជាតិត្រូវបញ្ចប់ការចូលរួមរបស់ខ្លួននៅត្រង់ដំណាក់កាលនេះ ។

ជម្រើសទាំងបីនេះក៏ត្រូវបានលើកយកមកពិភាក្សាដែរនៅក្នុងកិច្ចប្រជុំនៅទីក្រុងញូវយ៉ករវាងលោក ហេន ខូរែល និង រ៉ាល្ហ្សាកលីន មកពីការិយាល័យទទួលបន្ទុកកិច្ចការច្បាប់ និងឯកឧត្តម សុខ អាន មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលកម្ពុជា ។ មន្ត្រីអង្គការសហប្រជាជាតិមិនបានរើសយកនូវចំណុចណាមួយឡើយ នៅក្នុងពេលកំពុងពិភាក្សាទៅលើសំណើសេចក្តីព្រាងច្បាប់ ។ មកដល់ដំណាក់កាលនេះមានការសន្មតថា «ជម្រើសទី១»គួរតែត្រូវយកមកអនុវត្តសាកល្បង ។ ប្រសិនបើជម្រើសនេះមិនអាចទៅរួចទេ អង្គការសហប្រជាជាតិនឹងត្រូវបញ្ចប់នូវការចូលរួមរបស់ខ្លួន («ជម្រើសទី៣») ។ លេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិកំពុងតែរង់ចាំការឆ្លើយតបពីសំណាក់រដ្ឋាភិបាលទៅលើសេចក្តីព្រាងច្បាប់ដែលគណៈប្រតិភូដឹកនាំដោយលោក ហ្សាកលីន បន្សល់ទុកនៅទីក្រុងភ្នំពេញ ។ ឯកឧត្តម សុខ អាន មានប្រសាសន៍ថា សេចក្តីព្រាងច្បាប់នឹងត្រូវបញ្ជូនទៅកាន់អង្គការសហប្រជាជាតិនៅក្នុងអំឡុងមួយឬពីរសប្តាហ៍ ។

នៅក្នុងពេលស្នាក់នៅទីក្រុងញូវយ៉ក គណៈប្រតិភូក៏បានជួបប្រជុំជាមួយតំណាងនានាមកពីក្រសួងការបរទេសសហរដ្ឋអាមេរិក ក្រោយពីពេលនោះហាក់ដូចជាមានការយោគយល់គ្នាកាន់តែច្បាស់រវាងរដ្ឋាភិបាលទាំងពីរទៅលើបញ្ហានេះ ។

## ខែតុលា ឆ្នាំ១៩៩៩

នៅពេលដែលខ្ញុំមកដល់កម្ពុជានៅខែតុលា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទើបតែបានផ្សាយជាសាធារណៈនៅក្នុងព្រឹត្តប័ត្រប្រចាំខែ អំពីការកត់សម្គាល់របស់ព្រះអង្គចំពោះការទាញហេតុផលដែលលើកឡើងដោយសម្តេច ហ៊ុន សែន ដែលថាសំណើរបស់អង្គការសហប្រជាជាតិដែលដាក់ជូនលោកដោយក្រុមបេសកកម្មដឹកនាំដោយលោក ហ្សាកលីន គឺជាការគំរាមកំហែង

ដល់“អធិបតេយ្យភាពជាតិ” ។ សម្តេចព្រះ នរោត្តម សីហនុ បានសរសេរថា “ប្រទេសផ្សេងៗទៀតដែលមានអធិបតេយ្យភាព បាននិងកំពុងតែបន្តទទួលយកនូវតុលាការអន្តរជាតិមួយដែលទទួលបន្ទុកវិនិច្ឆ័យក្តីពលរដ្ឋរបស់ខ្លួន ដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ នេះមិនមែនជាការរំលោភទៅលើអធិបតេយ្យភាពរបស់ប្រទេសដែលមានការចាប់អារម្មណ៍ក្នុងរឿងនេះឡើយ” ។ ទ្រង់មានព្រះរាជបន្ទូលនៅក្នុងការជួបប្រជុំជាមួយយើងថា នេះជាសិទ្ធិអធិបតេយ្យភាពរបស់យើងក្នុងការអញ្ជើញអង្គការសហប្រជាជាតិ ។ ការសុំជំនួយមិនមែនមានន័យថាបោះបង់អធិតេយ្យភាពទេ ។ ព្រះមហាក្សត្រមានព្រះរាជបន្ទូលថា ជំនួយរបស់អង្គការសហប្រជាជាតិជាការចាំបាច់ណាស់ ហើយព្រះអង្គនឹងគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់យើងដើម្បីនាំយកមេដឹកនាំខ្មែរក្រហមមកកាន់តុលាការដើម្បីវិនិច្ឆ័យទោសតាមច្បាប់ ។

កម្មវិធីមួយទៀតគឺការជួបប្រជុំជាមួយសម្តេច ហ៊ុន សែន ។ សំឡេងនៃការពិភាក្សានេះមិនមានន័យស្ងាបនាសោះ ។ សម្តេចមានប្រសាសន៍នៅពេលចាប់ផ្តើមពិភាក្សាដំបូងថា សម្តេចមិនស្រួលខ្លួននិងមានជំងឺផ្តាសាយ ។ សម្តេចមានប្រសាសន៍ថា ឥឡូវខ្ញុំចង់បញ្ចប់ការពិភាក្សាត្រឹមតែប៉ុណ្ណេះ ហើយចាប់ផ្តើមមានការអនុវត្តជាក់ស្តែងតែម្តង ។ “យើងមិនអាចទ្រាំចាំទៀតទេ ។ យើងត្រូវរំខានច្រើនពេកហើយដោយសារបញ្ហានេះ” ។

ផ្ទៃរឿងរបស់សម្តេច ហ៊ុន សែន គឺ“អធិបតេយ្យភាព” ។ សម្តេចមានប្រសាសន៍ថា សម្តេចមិនបានសុំឲ្យមានដាក់បញ្ហានេះជារបៀបវារៈសំខាន់របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឬមហាសន្និបាតអង្គការសហប្រជាជាតិទេ ។ ធ្វើរបៀបនេះនឹងបង្កើតបញ្ហាចំពោះសមាជិកអចិន្ត្រៃយ៍ទាំងប្រាំដូចជាប្រទេសចិនជាដើម ហើយរដ្ឋាភិបាលមិនចង់ធ្វើរបៀបនេះទេ ។ សម្តេចមានប្រសាសន៍ទៀតថា លេខាធិការដ្ឋានបានផ្តល់ព័ត៌មានមកក្រុមប្រឹក្សាសន្តិសុខអំពីបញ្ហានេះ ។ សម្តេចមានចំណាប់អារម្មណ៍ថា វាជាការរំលោភមួយដែលសូម្បីតែសម្តេចក៏មិនត្រូវបានជម្រាបអំពីបញ្ហានេះជាមុនផង ។

ដូចជាពេលមុនៗដែរថា កិច្ចពិភាក្សាហាក់ដូចជាមានបញ្ហាពីរ ៖ ទីមួយខាងវោហារសាស្ត្រនិងទីពីរការពិតជាក់ស្តែង ។ ខាងក្រោមនេះជាប្រសាសន៍របស់សម្តេច ហ៊ុន សែន (យោងតាមកំណត់ហេតុរបស់យើង)÷

*“នេះមិនមែនសម្រាប់កម្ពុជាឆ្លើយតបទៅលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទេ ប៉ុន្តែឲ្យគាត់ឆ្លើយទៅនឹងជម្រើសបីយ៉ាងដែលលើកឡើងនៅក្នុងអនុស្សរណៈជំនួយស្មារតី” ។*

*“កម្ពុជាចង់មានឱកាសធ្វើម្ចាស់លើខ្លួនឯង ។ អ្នកឯងអាចចូលរួម ប៉ុន្តែកុំចង់ធ្វើម្ចាស់លើបញ្ហានេះឲ្យសោះ” ។*

*“ទុកឲ្យយើងធ្វើតុលាការ រួចហើយមើលថាតើវាត្រូវតាមគំរូអន្តរជាតិដែរឬអត់ ។ វានឹងត្រូវបានរៀបចំធ្វើមិនឲ្យខុសនឹងគំរូអន្តរជាតិឡើយ ។ ទុកឲ្យយើងធ្វើចុះ” ។*

*“យើងចង់សុំលុយសម្រាប់ធ្វើតុលាការឲ្យបានច្រើនដូចនៅតុលាការរ៉្វាន់ដានិងយូហ្គោស្លាវី ។ យើងមានលុយមែន លុយនេះនឹងយកមកប្រើប្រាស់សម្រាប់ធ្វើផ្លូវ សាលា គុក” ។*

*“នៅក្នុងសុន្ទរកថារបស់ខ្ញុំឯមហាសន្និបាតអង្គការសហប្រជាជាតិ ខ្ញុំបាននិយាយអំពីភាពចាំបាច់ក្នុងការពិនិត្យឡើងវិញនូវឥរិយាបថរបស់មន្ត្រីអង្គការសហប្រជាជាតិមួយចំនួន នៅក្នុងការដោះស្រាយបញ្ហាជាមួយរដ្ឋដែលជាសមាជិក ឧទាហរណ៍ការទាមទារថាចៅក្រមកម្ពុជាត្រូវតែឆ្លងកាត់ការត្រួតពិនិត្យពីសំណាក់លោកអគ្គលេខាធិការ ។ តើឯណាទៅអធិបតេយ្យភាពនោះ? តើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបង្កើតឡើងដើម្បីអ្វី? គ្រាន់តែជាទីងមោងប៉ុណ្ណោះទេឬ? ខ្ញុំគ្រាន់តែចង់មានចំណាប់អារម្មណ៍របស់ខ្ញុំចំពោះបញ្ហាមន្ត្រីអង្គការសហប្រជាជាតិដែលជួយលោកអគ្គលេខាធិការតែប៉ុណ្ណោះ” ។*

*“ការងាររបស់ខ្ញុំឥឡូវនេះបានចប់សព្វគ្រប់ហើយ ព្រោះអនុស្សរណៈជំនួយស្មារតីត្រូវបានប្រគល់ជូនរួចហើយ ។ ខ្ញុំចាំតែការឆ្លើយតបតែប៉ុណ្ណោះ ។ នៅក្នុងអំឡុងកិច្ចប្រជុំរវាងឯកឧត្តម សុខ អាន ជាមួយនឹងលោក ហេន ខូរែល លោក ខូរែល សួរថា*

តើកម្ពុជាត្រូវការជម្រើសមួយណា? យើងយល់បានថា ប្រសិនបើកម្ពុជានិយាយថាចង់បានជម្រើសទីបី ពេលនោះកម្ពុជានឹងនិយាយថា កម្ពុជាមិនចង់ឲ្យមានអង្គការសហប្រជាជាតិទេ ។ ប៉ុន្តែប្រសិនបើកម្ពុជានិយាយថាចង់បានជម្រើសទីមួយ នោះកម្ពុជានឹងនិយាយថា កម្ពុជាចង់ឲ្យមានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិយ៉ាងពេញលេញ ។ ឯកឧត្ដម សុខ អាន បានឆ្លើយតបវិញថា វាអាស្រ័យលើលោកអគ្គលេខាធិការទេដែលជាអ្នកឆ្លើយតប ។ បើខ្ញុំជាអង្គការសហប្រជាជាតិវិញនោះ ខ្ញុំនឹងឲ្យកម្ពុជាចាត់ការបញ្ហានេះដោយខ្លួនឯងហើយ" ។

"ប្រសិនបើគេ (ក្រុមជំនាញការរបស់អង្គការសហប្រជាជាតិ) ទទួលបន្ទុកជ្រើសតាំងនិងជ្រើសរើសចៅក្រមភាគច្រើន... គេមិនមែនជាអ្នកចូលរួមទេ ។ ខ្ញុំមិនចង់ឲ្យមានស្ដ្រីជាជនបរទេសមកស្លៀកសម្លៀកបំពាក់ខ្មែរទេ ។ ខ្ញុំចង់ឲ្យស្ដ្រីខ្មែរស្លៀកពាក់ជាខ្មែរ ហើយឲ្យបរទេសមកជួយតុបតែងមុខទៅបានហើយ" ។

"ប្រសិនបើអង្គការសហប្រជាជាតិចង់មានចៅក្រមច្រើនជាង ឬធ្វើការជ្រើសរើសចៅក្រមដោយខ្លួនឯងនោះ អង្គការសហប្រជាជាតិនឹងគ្រប់គ្រងដំណើរការទាំងអស់ទៅហើយ ។ ចំពោះកម្ពុជាគឺជាគ្រោះថ្នាក់មួយនៃការស្ថិតនៅក្រោមអាណាព្យាបាលរបស់អង្គការសហប្រជាជាតិជារៀងរហូត ។ យើងអាចរំលាយបញ្ហាខ្មែរក្រហមបាន ដូចនេះយើងពិតជាអាចរៀបចំតុលាការបានហើយ ។ បើគ្មានការកាត់ទោសខ្មែរក្រហម នឹងមានន័យថាគ្មានតម្លៃអ្វីទៀតហើយ ។ ខ្ញុំបានលះបង់ពេលវេលាចំនួន៣០ឆ្នាំក្នុងការវាយខ្មែរក្រហម ។ ខ្ញុំចង់ឲ្យគេជ្រើសរើសខ្ញុំឲ្យទទួលរង្វាន់ណូបែលចំពោះស្នាដៃនេះ" ។

នៅក្នុងកិច្ចប្រជុំមួយដែលមានភាពច្បាស់លាស់ សម្ដេច ហ៊ុន សែន មានប្រសាសន៍ថា ឥឡូវនេះសហរដ្ឋអាមេរិកបានដើរតួជាអ្នកសម្របសម្រួលទាក់ទងនឹងជម្រើសទីមួយក្នុងជម្រើសទាំងបីដែលរដ្ឋាភិបាលបានដាក់ជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ គំរូនៃ"ចំនួនលើសលប់"គឺជាជម្រើសដ៏ល្អបំផុតដែលកម្ពុជាទទួលយកបាន ។

សម្ដេចមានប្រសាសន៍ថា ផ្លូវដែលអង្គការសហប្រជាជាតិត្រូវជ្រើសរើសដើម្បីចូលរួមក្នុងដំណើរការនេះ គឺផ្ដល់យោបល់ទៅលើសេចក្ដីព្រាងច្បាប់ ។ អ្នកជំនាញការបានជួបជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក លោក ដេវីដ សេហ៊្វ័រ ។ អ្នកជំនាញការរុស្ស៊ីមួយរូបនិងបារាំងមួយរូប ឥឡូវនេះត្រូវបានសន្និមទុកថានឹងមកជួយរដ្ឋាភិបាលកម្ពុជានៅក្នុងកិច្ចការធ្វើសេចក្ដីព្រាងច្បាប់នេះ ។ សម្ដេចមានប្រសាសន៍ថា អ្នកជំនាញការបានអញ្ជើញអតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌របស់សហរដ្ឋអាមេរិកឈ្មោះលោក រ៉េមស៊ី ក្លាក ឲ្យមកជួយធ្វើការ ។

សេចក្ដីព្រាងច្បាប់ថ្មីនេះនឹងចប់សព្វគ្រប់ឆាប់ៗនេះ ។ ក្រុមការងារខាងរដ្ឋាភិបាលដែលដឹកនាំដោយឯកឧត្ដម សុខ អាន កំពុងតែធ្វើកិច្ចការនេះ រួចហើយនឹងបញ្ជូនទៅឲ្យក្រុមជំនាញការច្បាប់របស់អង្គការសហប្រជាជាតិ ។ ខាងរដ្ឋាភិបាលចង់បានសេចក្ដីសង្កេតឬយោបល់ពីអង្គការសហប្រជាជាតិឲ្យបានឆាប់បំផុត រួចហើយនឹងដាក់ជូនគណៈរដ្ឋមន្ត្រី ។ សេចក្ដីសម្រេចចុងក្រោយនឹងធ្លាក់ដល់ដៃរដ្ឋសភាជាតិនិងព្រឹទ្ធសភា ។ សម្ដេច ហ៊ុន សែន ចង់ឲ្យមានការរៀបចំឲ្យបានចប់សព្វគ្រប់ និងចាប់ផ្ដើមដំណើរការជំនុំជម្រះក្ដីនៅត្រីមាសទីមួយឆ្នាំ២០០០ ។

នៅក្នុងដំណាក់កាលដំបូង ខ្ញុំបាននិយាយថានឹងគ្មានការចូលរួមពីសំណាក់អង្គការសហប្រជាជាតិទេនៅក្នុងដំណើរការកាត់សេចក្ដីមេដឹកនាំខ្មែរក្រហម បើលោកអគ្គលេខាធិការអង្គការសហប្រជាជាតិមិនត្រូវបានទាញហេតុផលមកពន្យល់ឲ្យបានច្បាស់លាស់ថាសំណើនេះនឹងធានាឲ្យមានយុត្តិធម៌ ភាពគ្មានលម្អៀង និងនីតិវិធីត្រឹមត្រូវតាមបទដ្ឋានអន្តរជាតិទេនោះ និងមានការធានាថានឹងមិនមានការជ្រៀតជ្រែកផ្នែកនយោបាយ ហើយដំណើរការទាំងមូលនឹងឯករាជ្យពិតប្រាកដ ។

នៅក្នុងការងារនេះ ខ្ញុំក៏បានពិគ្រោះជាមួយនឹងតំណាងមកពីអង្គការក្រៅរដ្ឋាភិបាលកម្ពុជាមួយចំនួនដែរ ។ គំនិតសង្ខេបៗរបស់ក្រុមទាំងនេះត្រូវបានផ្ដុំផ្គុំជាសេចក្ដីថ្លែងការណ៍មួយដែលចុះហត្ថលេខាដោយសមាគមមេធាវី គម្រោងអ្នកការពារក្ដីកម្ពុជា

និងជំនួយផ្នែកច្បាប់កម្ពុជា នាថ្ងៃទី២២ ខែតុលា ។ ក្រុមអ្នកតំណាងរបស់អង្គការក្រៅរដ្ឋាភិបាលបានស្នើជាយោបល់ថា មេធាវីទាំងអស់និងប្រធានព្រះរាជអាជ្ញាបរទេសគួរតែត្រូវបានជ្រើសតាំងដោយអង្គការសហប្រជាជាតិ ហើយថាបុគ្គលមិនមែនជាជនជាតិកម្ពុជាក៏អាចចូលរួមជាអ្នកស៊ើបអង្កេតនៅក្នុងដំណើរការកាត់សេចក្តីនេះដែរ ។

ដើម្បីធ្វើឲ្យប្រាកដថាមានការការពារឯករាជ្យពេញលេញរបស់តុលាការនេះ ក្រុមអង្គការក្រៅរដ្ឋាភិបាលបានស្នើថា ប្រធានការិយាល័យរដ្ឋបាលបរទេសគួរតែត្រូវបានជ្រើសតាំងដោយអង្គការសហប្រជាជាតិ ហើយមានថវិកាស្វ័យតមួយដែលគ្រប់គ្រងដោយប្រធានរដ្ឋបាលនេះ ។ ក្រុមនេះនៅគូសបញ្ជាក់ទៀតថា សន្តិសុខសម្រាប់មន្ត្រីតុលាការព្រមទាំងសាក្សីត្រូវតែបានការពារត្រឹមត្រូវនៅក្នុងអំឡុងនិងក្រោយពីការជំនុំជម្រះក្តីត្រូវបានបញ្ចប់ ។

## ជំនួយការរបស់សហរដ្ឋអាមេរិកនិងការស្រាយបំភ្លឺរបស់រដ្ឋាភិបាលកម្ពុជា

ឯកអគ្គរដ្ឋទូតថ្មីរបស់សហរដ្ឋអាមេរិកប្រចាំនៅទីក្រុងភ្នំពេញលោក ខេន វៀដឺមែន បានធ្វើអន្តរាគមន៍នៅដើមខែតុលានៅក្នុងដំណើរការនេះ ។ លោកបានព្យាយាមបំបែកភាពទាល់ច្រករវាងជំហររបស់អង្គការសហប្រជាជាតិនិងជំហររដ្ឋាភិបាល ហើយបានផ្តោតសំខាន់ទៅលើភាពខុសគ្នាទាក់ទង«ភាគី»ណាមួយនឹងគួរទទួលចំនួនចៅក្រមច្រើនជាង ។ ក្រុមបេសកកម្មរបស់លោកហ្សាកលីន បានទទូចថា សហគមន៍អន្តរជាតិត្រូវតែមានចំនួនច្រើនជាងដើម្បីធានាឲ្យមានភាពតាមគំរូបទដ្ឋានអន្តរជាតិ ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទាមទារឲ្យខាងកម្ពុជាមានចំនួនច្រើនជាងដោយទាញហេតុផលអំពីអធិបតេយ្យភាព ។

ការឲ្យយោបល់លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកគឺថា កម្ពុជាគួរតែមានចៅក្រមអន្តរជាតិមិនអាចត្រូវបានទាត់ចោលយ៉ាងហោចណាស់មានមួយរូបនៅពីក្រោយសេចក្តីសម្រេចនេះដើម្បីបញ្ជាក់ពីសុពលភាព ។ នេះហៅថា «មតិភាគច្រើនលើសលប់» ។

តំណាងរដ្ឋាភិបាលសហរដ្ឋអាមេរិកក៏បានពិភាក្សាដែរថា តើការកាត់ក្តីនេះនឹងរៀបចំឡើងជាពិសេស ឬបញ្ចូលគ្នាជាមួយប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ក្នុងប្រទេសកម្ពុជា ។ សំណើរបស់តំណាងទាំងនេះគឺថា អង្គជំនុំជម្រះពិសេស ឬ«សវនាការ» គួរតែត្រូវបានបង្កើតឡើងនៅក្នុងតុលាការដែលមានស្រាប់ ដែលជារូបមន្តមួយក្រោយមកត្រូវបាននិយាយប្រាប់ខ្ញុំថា «មានផលប្រយោជន៍ពិសេស» ។ គំនិតនេះបានជំរុញឲ្យមានការពិភាក្សាមួយទៅលើការប្រើពាក្យថ្មី (ដែលអាចជាការនាំឲ្យមានភាពមិនច្បាស់លាស់ថែមទៀត) ។

យោបល់មួយទៀតរបស់លោកឯកអគ្គរដ្ឋអាមេរិកគឺថា ដែនសមត្ថកិច្ចសម្រាប់បុគ្គលគួរតែកំណត់ឲ្យមានចំពោះតែបុគ្គលមួយចំនួនតូចបានហើយ ប៉ុន្តែ អៀង សារី ក៏ត្រូវតែបញ្ចូលនៅក្នុងក្រុមនេះដែរ ។

ចុងបញ្ចប់លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកបានស្នើសុំឲ្យអង្គការសហប្រជាជាតិត្រួតពិនិត្យមើលការខុសត្រូវដំណើរការនេះដើម្បីធានាឲ្យមានលក្ខណៈត្រឹមត្រូវតាមបទដ្ឋានអន្តរជាតិ ។ បើមិនមានចំណុចទាំងអស់នេះទេ សហគមន៍អន្តរជាតិនឹងដកខ្លួនចេញ(រួមទាំងថវិកាផង) ។ ការស្នើនេះហាក់ដូចជាមានលក្ខណៈពិសេសដែរ គឺមានការពិភាក្សាពីការចូលរួមកាន់តែច្រើនរបស់អង្គការសហប្រជាជាតិ ប៉ុន្តែខ្លឹមសារដែលចង់និយាយប្រហែលថាអ្នកដើរតួអន្តរជាតិសំខាន់ៗរួមទាំងសហរដ្ឋអាមេរិកផងនឹងដើរតាមអង្គការសហប្រជាជាតិដែរឬទេ ចំពោះការបន្តចូលរួមនៅក្នុងដំណើរការនេះ ។

ទោះបីជាអន្តរាគមន៍របស់សហរដ្ឋអាមេរិកនៅលើផ្នែកខ្លះមានប្រយោជន៍ក៏ពិតមែនតែបើមានកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលផ្សេងទៀតនោះ នឹងរឹតតែមានប្រយោជន៍ជាងនេះទៅទៀត ។ ខ្ញុំមិនត្រូវបានពិគ្រោះជាមួយឡើយ លើគំនិតផ្តួចផ្តើមរបស់លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ហើយខាងភាគីអង្គការសហប្រជាជាតិក៏អត់ដែរ ។ ការខ្វះចន្លោះ

នេះត្រូវបានដោះស្រាយរួចហើយនៅពាក់កណ្តាលខែតុលា ជាពេលតែមួយដែលខ្ញុំទៅជួបលោកឯកអគ្គរដ្ឋទូត ដាវីដ សេហ្ស៊័រ នៅទីក្រុងភ្នំពេញ ។

លោក សេហ្ស៊័រ បានជួបឯកឧត្តម សុខ អាន ប្រធានក្រុមការងាររបស់រដ្ឋាភិបាលកម្ពុជា ស្តីពីបញ្ហាខ្មែរក្រហម (ដែលបានជួបជាមួយគណៈប្រតិភូដឹកនាំដោយលោក ហ្សាកលីន នៅខែសីហាកន្លងទៅ) ។ លោក សេហ្ស៊័រ និយាយថា រដ្ឋាភិបាលសហរដ្ឋអាមេរិកមិនចង់ជំនួសអង្គការសហប្រជាជាតិនៅក្នុងកិច្ចចរចានេះទេ ប៉ុន្តែចង់ជួយឲ្យដំណើរការនេះដើរទៅមុខ ។ ជំហររដ្ឋាភិបាលសហរដ្ឋអាមេរិកគឺមិនគាំទ្របុច្ចូលរួមក្នុងដំណើរជំនុំជម្រះក្តីទាំងឡាយណាដែលមិនត្រូវបានយល់ព្រមពីសំណាក់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិឡើយ ។ រដ្ឋាភិបាលសហរដ្ឋអាមេរិកមិនចង់ចូលធ្វើអន្តរាគមន៍ឲ្យមាន “ជម្រើស” ខុសពីជំហររបស់អង្គការសហប្រជាជាតិទេ ។ អង្គទូតរបស់បារាំងមួយរូបបានប្រាប់ខ្ញុំដូចគ្នានេះដែរអំពីជំហររបស់រដ្ឋាភិបាលលោកនិងឯកអគ្គរដ្ឋទូតប្រទេសរុស្ស៊ី ។

ចំណាប់អារម្មណ៍របស់លោក សេហ្ស៊័រ គឺថា ឥឡូវនេះភាសាជាការសំខាន់ណាស់សម្រាប់រដ្ឋាភិបាលៈ រដ្ឋាភិបាលមិនពេញចិត្តពាក្យថាតុលាការ “ចម្រុះ” ហើយចង់ដកខ្លួនឲ្យឆ្ងាយពីពាក្យថា “តុលាការអន្តរជាតិ” ។ ចំពោះតុលាការខ្លួនឯងគឺចង់ប្រើពាក្យជាភាសាបារាំងថា “audience extraordinaire” ប្រែជាភាសាអង់គ្លេសថា “extraordinary session” ដែលមានន័យថា អង្គជំនុំជម្រះវិសាមញ្ញ ។

ការជួបប្រជុំរបស់ខ្ញុំជាមួយនឹងបុគ្គលសំខាន់ៗមួយចំនួន ដូចជាសម្តេច ជា ស៊ីម សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ឯកឧត្តម ស ខេង និងឯកឧត្តម សុខ អាន ហាក់បញ្ជាក់អំពីចំណាប់អារម្មណ៍ថា អ្នកធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗមានអារម្មណ៍ថាពាក្យថ្មីនេះគឺជាផ្នែកមួយនៃដំណោះស្រាយទុកមុខមាត់ចំពោះ“អធិបតេយ្យភាព” ។

ហើយក៏ជាការច្បាស់ដែរថា តំណាងរបស់រដ្ឋាភិបាលកម្ពុជាបានគិតកាន់តែឆ្ងាយទៅលើទិដ្ឋភាពជាក់ស្តែង ។ នៅក្នុងបទដ្ឋានច្បាប់ដែលនឹងត្រូវយកមកប្រើប្រាស់ តំណាងទាំងនេះចង់ប្រើពាក្យ “Politicide” ឬក៏ “Autogenocide” ។ នេះជាការច្បាស់ណាស់ថាតំណាងទាំងនេះចង់ប្រើពាក្យពិសេសបញ្ជាក់ពីបទពិសោធន៍របស់កម្ពុជាឲ្យមានការទទួលស្គាល់ និងធ្វើការប្រៀបធៀបជាមួយនឹងពាក្យ “apartheid” ដែលប្រើនៅប្រទេសអាហ្វ្រិកខាងត្បូង ។

តំណាងរដ្ឋាភិបាលរៀបចំទទួលយកនូវគំនិតមតិភាគច្រើនលើសលប់នេះហើយ ប៉ុន្តែទទូចថាសូមឲ្យភាគច្រើនជាជនជាតិកម្ពុជា ។ តំណាងទាំងនោះស្នើថា សុំឲ្យមានចៅក្រមប្រាំរូបនៅសាលាដំបូង ប្រាំពីររូបនៅសាលាឧទ្ធរណ៍ និងប្រាំបួនរូបនៅតុលាការកំពូល ។ ជនជាតិកម្ពុជាក្នុងចំណោមបុគ្គលទាំងនេះ នឹងត្រូវជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលជាស្ថាប័នច្បាប់កំពូលមានអំណាចក្នុងការជ្រើសតាំងចៅក្រម (ដោយសារស្ថាប័ននេះមានសមាជិកភាពលើសលប់មកពីគណបក្សប្រជាជនកម្ពុជាមានមនុស្សជាច្រើនរួមទាំងព្រះមហាក្សត្រផង មានចម្ងល់អំពីភាពលម្អៀងផ្នែកនយោបាយ) ។ ក្រៅពីក្រុមចៅក្រមដែលមានស្រាប់ ហាក់ដូចជាគ្មានការបើកចំហឲ្យមានលទ្ធភាពក្នុងការជ្រើសតាំងចៅក្រមមកពីខាងក្រៅទេ ។ ប៉ុន្តែឯកឧត្តម សុខ អាន បានយល់ព្រមលើកម្រូវការឲ្យមានភាពជឿជាក់គ្នាទៅវិញទៅមកក្នុងដំណើរការជ្រើសតាំងនេះ ។

ចំពោះបញ្ហាព្រះរាជអាជ្ញាវិញ រដ្ឋាភិបាលកម្ពុជាកំពុងតែពិចារណាអំពីគំរូមួយដែលមានព្រះរាជអាជ្ញាកម្ពុជាមួយរូបនិងអន្តរជាតិមួយរូប ហើយប្រហែលជាមានចៅក្រមស៊ើបអង្កេតពីររូបធ្វើការតាមប្រព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ ។ មានចំណុចមួយកើតឡើងគឺថា រដ្ឋាភិបាលគិតថា ព្រះរាជអាជ្ញាទាំងពីររូបនេះនឹងត្រូវចុះហត្ថលេខាទៅលើដីកាចោទប្រកាន់ទាំងអស់គ្នា ។

**(នៅមានត)**

# អង្គការសហប្រជាជាតិខ្វះឆន្ទៈក្នុងការប្រយុទ្ធនឹងអំពើប្រល័យពូជសាសន៍

បត្យាប័ននិងការកាត់ទោស ស្លូបូដាន់ មីឡូសីវីក ធ្វើឲ្យមានការស្ងើចសរសើរយ៉ាងខ្លាំងនៅទូទាំងពិភពលោក ។ អ្នកខ្វះរហូតដល់និយាយថា សករាជថ្មីនៃការទទួលខុសត្រូវចំពោះមុខច្បាប់ ចាប់ផ្តើមលេចពន្លឺព្រឹមៗនៅលើពិភពលោកយើងហើយ ។ តើធ្វើដូចម្តេចនឹងអាចនិយាយថាវាជាការពិតបាន បើយើងមិនទាន់ក្រឡេកមើលទៅព្រឹត្តិការណ៍កាលពីទសវត្សរ៍កន្លងទៅផងនោះ? នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ អង្គការសហប្រជាជាតិនិងមេដឹកនាំពិភពលោកបានបញ្ចេញនូវភាពស្ទាក់ស្ទើរក្នុងការបញ្ឈប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍កើតឡើងនៅក្នុងសង្គ្រាមស៊ីវិលនៅទូទាំងពិភពលោក ។ ការឆ្លើយតបរបស់អង្គការសហប្រជាជាតិ ធ្វើឡើងពីភាពខ្វះឆន្ទៈនិងប្រសិទ្ធភាពក្នុងករណីប្រទេសកម្ពុជា និងអតីតប្រទេសយូហ្គោ-ស្លាវី ទៅភាពគួរឲ្យអាម៉ាស់បំផុតគឺនៅប្រទេសរវ៉ាន់ដា



ទីម័រខាងកើត និងប្រទេសសេរ៉ាឡេអូន ។ អង្គការសហប្រជាជាតិ និងអ្នកគាំទ្រសិទ្ធមនុស្សជាច្រើន បានបង្វែរកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនពីការការពារឧក្រិដ្ឋកម្មសង្គ្រាមទៅជាការដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មសង្គ្រាម ឬយុត្តិធម៌ក្រោយពីមានសោកនាដកម្ម ជាជាងប្រឈមមុខដោះស្រាយអង្គហេតុ «មិនឲ្យកើតឡើងសាជាថ្មី» ។ តើនៅពេលណាទើបច្បាប់អន្តរជាតិអាចផ្តល់យុត្តិធម៌សម្រាប់មនុស្សទាំងអស់គ្នា? តើអ្វីទៅជាដែនកំណត់នៃយុត្តិធម៌ក្រោយសោកនាដកម្មសំខាន់ជាងគេបំផុត? តើពេលណាទើបការជម្រះក្តីស្រុះស្រួលគ្នាក្នុងការបកអាក្រាតរាល់កន្ទុះវិធានការដាក់ស្តែងកន្លងទៅ?

ប្រទេសកម្ពុជាគឺជាប្រទេសតូចមួយមានសារប្រយោជន៍មួយបង្ហាញពីទំនាក់ទំនងរវាងប្រជាជាតិដែលគ្មានអំណាចទាល់តែសោះ និងច្បាប់អន្តរជាតិក្នុងអំឡុងសតវត្សរ៍ទី២០ ។ នៅរវាងឆ្នាំ១៩៧៥-៧៩ យ៉ាងហោចណាស់មានមនុស្សចំនួន១លាននាក់ត្រូវបាត់បង់ជីវិតដោយសារការសាកល្បងលទ្ធិកុម្មុយនិស្តយុគសម័យថ្មរំលីងរបស់អង្គការខ្មែរក្រហម ។ ក្រោយពីវៀតណាមផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យនេះទៅ តើអង្គការសហប្រជាជាតិឬសហរដ្ឋអាមេរិកបានគាំទ្រដល់កិច្ចប្រឹងប្រែងក្នុងការនាំថ្នាក់ដឹកនាំខ្មែរក្រហមយកមកកាត់ទោសចំពោះមុខតុលាការដែរឬទេ? ចម្លើយគឺ «ទេ» ។ នៅឆ្នាំ១៩៧៩ រដ្ឋាភិបាល ជីមី ខាធ័រ បានបោះឆ្នោតគាំទ្ររបបប្រល័យពូជសាសន៍ឲ្យបន្តកាន់កាប់អាសនៈកម្ពុជាប្រចាំនៅមហាសន្និបាតអង្គការសហប្រជាជាតិ ។ ទោះបីជាអង្គការសហប្រជាជាតិបានបញ្ជូនកងទ័ពចំនួន២ម៉ឺននាក់ ព្រមទាំងទីប្រឹក្សា៥ពាន់នាក់មកកាន់ប្រទេសកម្ពុជាយ៉ាងណាក៏ដោយ



ក៏គ្មានការលើកឡើងអំពីឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ដែរ ។ នៅទីបញ្ចប់ ខ្មែរក្រហមមិនត្រឹមតែមិនត្រូវបានបំផ្លាញចោលដោយហេតុផលនៃការព្រួយបារម្ភរឿង«យុត្តិធម៌ពិភពលោក»ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការលើកលែងទោសដល់ អៀង សារី និងខ្មែរក្រហមដែលចុះចូលមួយចំនួនទៀតនៅឆ្នាំ១៩៩៦ ។

ក្រោយពីមានការចរចាតឹងសរសៃកអស់រយៈពេលជាង៣ឆ្នាំជាមួយអង្គការសហប្រជាជាតិមក សម្តេច ហ៊ុន សែន បានប្រកាសថ្មីៗនេះថា ប្រជាជាតិរបស់សម្តេចនឹងរៀបចំដំណើរការជម្រះក្តីឧក្រិដ្ឋកម្មសង្គ្រាមដែលកើតឡើងនៅក្នុងប្រទេសខ្លួនដោយគ្មានកិច្ចគាំទ្រពីសំណាក់អង្គការសហប្រជាជាតិ ។

ប្រជាជាតិទីម័រខាងកើតក៏បានសន្យាថានឹងមានការរៀបចំបង្កើតតុលាការឧក្រិដ្ឋកម្មសង្រ្គាមអង្គការសហប្រជាជាតិដែរ ក្រោយពីការបោះឆ្នោតឆ្នាំ១៩៩៩រួចហើយ ។ ទោះបីជាសេចក្តីសម្រេចចិត្តក្នុងការបញ្ចប់ការកាន់កាប់អស់រយៈពេល២៤ឆ្នាំរបស់ប្រទេសឥណ្ឌូនេស៊ីបានទទួលជ័យជម្នះដោយការបោះឆ្នោតក៏ដោយ ប៉ុន្តែនៅពេលដែលពួកជីវពលគាំទ្រប្រទេសឥណ្ឌូនេស៊ីធ្វើសង្រ្គាមប្រឆាំងនឹងជនស៊ីវិល អង្គការសហប្រជាជាតិបែរជារត់ចេញទៅវិញ ។ ការឆ្លើយតបផ្នែកយោធាដែលដឹកនាំដោយប្រទេសអូស្ត្រាលីបានកើតមានឡើងក្រោយពីសំណង់អគារ៧០ភាគរយត្រូវបានកម្ទេច ជនស៊ីវិលចំនួន១ពាន់នាក់ត្រូវបានសម្លាប់ និង២សែននាក់ទៀតត្រូវបានជម្លៀសទៅកាន់ជំរំប្រមូលផ្តុំនៅទីម័រខាងលិច ។

ទោះជាមានការគំរាមកំហែងថានឹងមានតុលាការឧក្រិដ្ឋកម្មសង្រ្គាមរបស់អង្គការសហប្រជាជាតិក៏ដោយ ក៏រដ្ឋាភិបាលឥណ្ឌូនេស៊ីយល់ព្រមឲ្យកាត់ទោសជនសង្ស័យពីបទឧក្រិដ្ឋកម្មសង្រ្គាមរបស់ខ្លួនដែរ ។ ក្រោយពីមេដឹកនាំជីវពលមួយរូបត្រូវបានកាត់ទោសឲ្យជាប់ឃុំនៅក្នុងផ្ទះមន្ត្រីអង្គការសហប្រជាជាតិមួយរូបបានកត់សម្គាល់ថា «សាលក្រមទាំងនេះគឺជាការចំអកឡកឡឺយដល់ការទទូចរបស់សហគមន៍អន្តរជាតិដែលចង់បានយុត្តិធម៌នៅក្នុងករណីដ៏គួរឲ្យរន្ធត់នេះ» ។ គំរូច្បាប់បណ្តោះអាសន្នទាំងពីរនេះកើនឡើងកាន់តែជាក់ស្តែងទៅទៀតនៅប្រទេសសេរ៉ាឡេអូន ។


គ្រឹន វ៉ាន់ថាញ់

កិច្ចព្រមព្រៀង *Lome Accords* ដែលចរចាដោយ ចេស៊ី ជែកសុន ជួសមុខរដ្ឋាភិបាលលោកប្រធានាធិបតី ប៊ីល គ្លីនតុន បានបង្ខំទៅលើមេដឹកនាំសេរ៉ាឡេអូន អាម៉េដ តេចាន កាបោស ដែលជាប់ឆ្នោតកាលពីខែកក្កដា ឆ្នាំ១៩៩៩ ។ ហ្វូឌី សានកូស មេដឹកនាំក្រុមឧទ្ទាមដែលមានឈ្មោះថា រណសិរ្សរួបរួមបដិវត្តន៍ មិនត្រឹមតែត្រូវបានដោះលែងពីការឃុំឃាំងទេ ប៉ុន្តែថែមទាំងផ្តល់នូវការលើកលែងទោសប្រកបដោយភាពស្រពេចស្រពិល និងត្រូវបានដាក់ឈ្មោះថា អនុប្រធានាធិបតី និង ស្នងការធនធានពេជ្រទៀត ។ ជនរងគ្រោះនៃរណសិរ្សរួបរួមបដិវត្តន៍ឈ្មោះ វីកតូរីយ៉ា កាហ្ស៊ូ ត្រូវទាល់គំនិតនៅពេលមានសេចក្តីសម្រេចចិត្តរបស់លោកខាងលិចដែលលើកតម្កើងឃាតករសម្លាប់កូនរបស់គាត់ ។ «ខ្ញុំឃើញពួកវាសម្លាប់កូនទាំងអស់របស់ខ្ញុំព្រមទាំងចៅរបស់ខ្ញុំដែលមានអាយុ២ឆ្នាំផង ។ ខ្ញុំរកកន្លែងប្តឹងមិនបានទេ ។ ខ្ញុំមិនបានទទួលយុត្តិធម៌ឡើយ» ។ នៅក្នុងអំឡុងពេលប៉ុន្មានខែនៃការចុះហត្ថលេខាលើកតិកាសញ្ញារណសិរ្សរួបរួមបដិវត្តន៍ក៏ចេះតែបន្តកាប់សម្លាប់និងធ្វើបាបជនស៊ីវិល ហើយថែមទាំងបានចាប់ពង្រត់កងទ័ពអង្គការសហប្រជាជាតិរាប់រយនាក់ទៀតផង ។


អ្នកទោសនៅមន្ទីរ ស-២១

នៅទីបញ្ចប់កងទ័ពអង្គការសហប្រជាជាតិ១ពាន់នាក់ត្រូវការកម្លាំងកុម្ម៉ង់ដូអង់គ្លេសនិងទាហានស៊ីឈ្នួលអាមេរិកខាងត្បូងបន្ថែម ដើម្បីបណ្តេញរណសិរ្សរួបរួមបដិវត្តន៍ឲ្យចូលទៅក្នុងព្រៃវិញ ។ មេបញ្ជាការកងកម្លាំងយោធារបស់អង្គការសហប្រជាជាតិបានលាលែងពីតំណែងជាមួយនឹងកម្លាំងថែរក្សាសន្តិភាពជនជាតិឥណ្ឌា ។ គាត់បានចោទសហការីរបស់ខ្លួនម្នាក់ជាជនជាតិនីហ្សេរីយ៉ា ថាបានផ្តល់ជំនួយនិងជំរុញឲ្យរណសិរ្សនេះប្រព្រឹត្តអំពើអាក្រក់ ។ នៅពេលដែល សានខូស ត្រូវចាប់ខ្លួនដោយជនស៊ីវិលកាលពីឆ្នាំកន្លងទៅ អង្គការសហប្រជាជាតិសន្យាថានឹងរៀបចំឲ្យមានតុលាការឧក្រិដ្ឋកម្មសង្គ្រាមមួយសម្រាប់ប្រទេសសេរ៉ាឡេអូន ។ មកដល់ថ្ងៃនេះ ការពិភាក្សាត្រូវគាំងដំណើរស្ទួក ។ តើតុលាការជម្រះទោសអន្តរជាតិដែលមានលក្ខណៈឥតខ្ចោះនៅប្រទេសសេរ៉ាឡេអូន អាចលុបលាងនូវបរាជ័យកាលពីពេលមុនៗបានដែរឬទេ? តើអ្វីទៅជាដែនកំណត់

នៃយុត្តិធម៌ក្រោយសោកនាដកម្ម?

អង្គការសហប្រជាជាតិបានចំណាយថវិការាប់លានដុល្លារ សម្រាប់កាត់ទោសបុគ្គល៩រូបនៅប្រទេសតង់ហ្សានី ហើយមនុស្សជិត១សែននាក់ត្រូវឃុំនៅក្នុងគុកនៃប្រទេសរ៉្វាន់ដានៅឡើយ ។ តើការផ្តន្ទាទោសទៅលើជនទាំងនេះបានធ្វើឲ្យមនុស្ស៨សែននាក់ដែលត្រូវបានកាប់សម្លាប់កាលពីឆ្នាំ១៩៩៤រស់ឡើងវិញ ឬបានបញ្ចប់នូវសង្គ្រាមស៊ីវិលដែលកំពុងតែឆាបឆេះប្រទេសកុងហ្គោដែរឬទេ? ។ ការជម្រះក្តីមិនអាចលុបលាងកន្ទុះវិធានការដ៏គួរឲ្យអាម៉ាស់ចំពោះអំពើប្រល័យពូជសាសន៍ដែលអាចការពារជាមុនបានទេ ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ឧក្រិដ្ឋកម្មសង្គ្រាម សិទ្ធិមនុស្ស និងយុត្តិធម៌ក្រោយសោកនាដកម្ម បានក្លាយទៅជាខស្សោហកម្មដែលពោរពេញទៅដោយតារាដែលតែងតាំងដោយខ្លួនឯង ដើងសារជំនួញ (អ្នកគួកដេ) អំណាច និងអ្នកគាំទ្រឧបត្ថម្ភ ។ ជាងនេះទៅទៀត គំនិតដែលថាប្រព័ន្ធច្បាប់អន្តរជាតិដែលយកលំនាំតាមតុលាការនៅនូរិមប៊ឺក នឹងចាប់ផ្តើមចាក់ឫសឆាប់ៗនេះហើយ ។ ប៉ុន្តែនៅចុងបញ្ចប់នៃសតវត្សរ៍ប្រកបដោយការបង្ហូរឈាមដែលមិនពិពណ៌នាបាននៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ "សហគមន៍អន្តរជាតិ"ស្អីគេនោះ



អ្នកទោសនៅមន្ទីរ ស-២១



អ្នកទោសនៅមន្ទីរ ស-២១

កាន់តែធ្វើព្រងើយកន្តើយចំពោះអំពើគួរឲ្យព្រឺព្រួចដែលសមាជិកគ្មានអំណាចទាល់តែសោះនិងសមាជិកមិនសូវសំខាន់ផ្នែកនយោបាយទទួលរង ។ តើមានអ្វីផ្លាស់ប្តូរដែរឬទេ ក្រៅពីការភូតកុហកដែលបាននិយាយមកកាន់ខ្លួនយើង? ប្រសិនបើបត្យាប័នរបស់ ស្លូបូដាន់ មីឡូសីវិក និងការជម្រះក្តី ពិតជាដើមទំព័រសករាជនៃច្បាប់អន្តរជាតិមែននោះ ចូរពន្យល់ដល់ វីកតូរីយ៉ា កាហ្ស៊ូ នៃប្រទេសសេរ៉ាឡេអូនផងចុះ ។ កាហ្ស៊ូ និយាយថា "ពិភពលោករកយុត្តិធម៌នៅកូសូវ៉ូ ។ តើយើងស្ថិតនៅពិភពផ្សេងពីកូសូវ៉ូឬ? តើកូនរបស់ខ្ញុំមានតម្លៃទាបជាងកូនក្មេងនៅកូសូវ៉ូឬ?" ។ **ភីតធ័រ ម៉ាឃ្សៀ**

# អគ្គលេខាធិការទាំង៧រូបនៃអង្គការសហប្រជាជាតិ

១) លោក ទ្រីវ៉េ លី (Trygve Lie) មកពីប្រទេសណ័រវេស កាន់តំណែងចាប់តាំងពីខែកុម្ភៈ ឆ្នាំ១៩៤៦ (លាឈប់ពីតំណែង) នៅខែវិច្ឆិកា ឆ្នាំ១៩៥២ ។

២) លោក ដាក ហាមម៉ាស ចូល (Dag Hammarsk Jold) មកពីប្រទេសស៊ុយអែដ កាន់តំណែងចាប់តាំងពីខែមេសា ឆ្នាំ១៩៥៣ (ហើយស្លាប់ដោយការធ្លាក់យន្តហោះនៅតំបន់អាហ្វ្រិក) នៅខែកញ្ញា ឆ្នាំ១៩៦១ ។

៣) លោក អ៊ូ ថាន់ (U Thant) មកពីប្រទេសភូមា កាន់តំណែងចាប់ពីខែវិច្ឆិកា ឆ្នាំ១៩៦២ ដល់ខែធ្នូ ឆ្នាំ១៩៧១ ។

៤) លោក ឃឺត វ៉ដហែម (Kurt Waldheim) មកពីប្រទេសអូទ្រីស កាន់តំណែងចាប់ពីខែមករា ឆ្នាំ១៩៧២ ដល់ខែធ្នូ ឆ្នាំ១៩៨១ ។

៥) លោក ហ្សាវីយេ ប៉េរ៉េ ឌឺ គូអេឡា (Javier Perez de Cuellar) មកពីប្រទេសប៉េរូ កាន់តំណែងចាប់ពីខែមករា ឆ្នាំ១៩៨២ ដល់ខែធ្នូ ឆ្នាំ១៩៩១ ។

៦) លោក ប៊ូត្រូស ប៊ូត្រូស ហ្គាលី (Boutros Boutros Ghali) មកពីប្រទេសអេហ្ស៊ីប កាន់តំណែងចាប់ពីខែមករា ឆ្នាំ១៩៩២ ដល់ខែធ្នូ ឆ្នាំ១៩៩៦ ។

៧) លោក កូហ្វី អាណាន់ (Kofi Annan) ជនជាតិហ្គាណា កាន់តំណែងពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៧ រហូតដល់បច្ចុប្បន្ន ។

# ខែបុណ្យភ្ជុំ ខ្ញុំយំក្នុងគុក

"ខ្ញុំស្រក់ទឹកភ្នែកនៅពេលដែលគេយកខ្នោះមកដាក់ខ្ញុំ ។ ខ្ញុំនឹកខ្លោចចិត្តខ្លួនឯងដែលវេទនាពន់ពេក ដេកផ្ទាល់នឹងដីដូចសត្វធាតុ នៅលើខ្លួនប្រាណកើតមានសុទ្ធតែចៃ នៅលើក្បាលមានសុទ្ធតែកមរមាស់... រដូវបុណ្យភ្ជុំ ខ្ញុំអើតតាមបង្អួចឃើញមនុស្សម្នាយកចង្ហាន់ទៅវត្ត ចំណែកឯខ្ញុំវិញ យំនៅក្នុងគុក" ។ នេះគឺជាសម្តីរៀបរាប់នូវទុក្ខលំបាកវេទនារបស់ ឈឹម សំអុល ជាអតីតអ្នកទោសខ្មែរក្រហមនៅតំបន់បូព៌ាពីឆ្នាំ១៩៧៤ រហូតដល់ឆ្នាំ១៩៧៥ ។


ឈឹម សំអុល

ឈឹម សំអុល អាយុ៤៥ឆ្នាំ បច្ចុប្បន្នជាកសិករមួយរូបរស់នៅភូមិតាដោ ឃុំសារិកាកែវ ស្រុកស្អាង ខេត្តកណ្តាល បានរំឭកឡើងវិញនូវរឿងរ៉ាវអតីតកាលដែលគាត់បានជួបប្រទះកាលពី២៥ឆ្នាំមុនថា៖ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេច សីហនុ នៅឆ្នាំ១៩៧០ ខ្ញុំត្រូវទាហាន លន់ ណុល ដែលចុះពីភ្នំពេញមកជ្រើសរើសឲ្យធ្វើជាកងស្វ័យត្រាណដើម្បីការពារសន្តិសុខភូមិ ។ នៅយប់មួយក្នុងដើមឆ្នាំ១៩៧៤ កងទ័ពរំដោះរបស់ខ្មែរក្រហមបានឡើងមកវាតត្បាតភូមិស្រុករបស់ខ្ញុំ ហើយបានចាប់ខ្លួនខ្ញុំនិងអ្នកស្រុកចំនួន៣០នាក់ ដោយចោទប្រកាន់ថា"ជាប់និន្នាការ"បម្រើឲ្យរបបចាស់ (របបសាធារណរដ្ឋខ្មែរ ដឹកនាំដោយលោកសេនាប្រមុខ លន់ ណុល) ។ ម៉ោងប្រហែល១០យប់ មានឈ្លបមិនស្គាល់មុខ២ឬ៣នាក់មកហៅខ្ញុំថា "អាអុលៗ អ្នែងចុះពីលើផ្ទះភ្លាម!" ។ ខ្ញុំដឹងថាបើចុះពិតជាមានបញ្ហាហើយ ដូច្នេះខ្ញុំមិនចុះទេ ។ ពេលដែលខ្ញុំមិនព្រមចុះពីលើផ្ទះ ឈ្លបទាំងនោះបានយកចំពុះទុងចាក់ពីក្រោមផ្ទះ "ប្រាកៗ" រួចបាញ់សំដៅមកខ្ញុំចំនួន៣គ្រាប់ ។ ដោយពួកវាស្រែកហៅសន្ធាប់ខ្លាំងពេក និងខ្លាចពួកវាបាញ់ត្រូវ ខ្ញុំក៏លើកដៃឡើងលើហើយចុះមកក្រោមផ្ទះ ។ គ្រាន់តែចុះមកដល់ដីភ្លាម ពួកវាបានចាប់កន្ត្រាក់យកនាឡិកាពីដៃ រួចចងស្ពាយសេកបណ្តើរខ្ញុំចេញទៅ ។

នៅពេលដែលពួកខ្មែរក្រហមបណ្តើរខ្ញុំនិងមនុស្សដទៃទៀតមកដល់ក្រោយភូមិ ស្រាប់តែមានគ្រាប់ផ្លោងកាណុង៦បាញ់ចេញពីជ្រោយចង្វារ ។ ទាហាន លន់ ណុល បាញ់ផ្លោងសន្ធាប់ពេក ពួកទាហានខ្មែរក្រហមក៏បានរត់ចោលពួកខ្ញុំ ។ ចំណែកឯខ្ញុំនិងមនុស្សទាំងអស់ភ័យខ្លាំងពេកក៏កន្ត្រាក់ដាច់ខ្សែចំណងពីដៃ ហើយនាំគ្នាទៅក្រាបពួននៅតាមរណ្តៅគ្រាប់ ។ ក្រោយពេលស្គររកាំភ្លើងស្ងប់ស្ងាត់ទៅវិញ ពួកខ្មែរក្រហមបានមកភ្ញាក់មនុស្សទាំងអស់ឲ្យងើបឡើង រួចចងស្ពាយសេកបណ្តើរទៅមុខទៀតរហូតដល់មាត់ស្ទឹងមួយ រួចហើយក៏ចាប់ផ្តើមឆែកឆេរកលុយ ។ ទាហានខ្មែរក្រហមទាំងនោះបាននិយាយថា៖ "អ្នកណាមានលុយកាក់សម្ភារអីត្រូវដកហូតទាំងអស់ចាំដល់ថ្ងៃណាកសាងខ្លួនបាន អង្គការនឹងឲ្យវិញ" ។ ឆែកឆេររួចហើយ ពួកខ្មែរក្រហមក៏បណ្តើរមនុស្សទាំងអស់កាត់តាមមាត់ស្ទឹងទៅមុខទៀត ។ កំពុងតែដើរស្រាប់តែមានយន្តហោះមកពីភ្នំពេញដេញបាញ់មួយសាទៀត ប៉ុន្តែបាញ់សំដៅតែពួកខ្មែរក្រហមតែប៉ុណ្ណោះ ។ ប៉ុន្មាននាទីក្រោយមក យន្តហោះក៏

ត្រឡប់ទៅវិញ ។ ទាហានខ្មែរក្រហមក៏បណ្តើរមនុស្សទាំងអស់មកដាក់នៅមន្ទីរអប់រំព្រៃក្នុងស្រុកល្វាឯម ។ ខ្ញុំបានជាប់ឃុំឃាំងនៅមន្ទីរអប់រំព្រៃនេះចំនួនពីរសប្តាហ៍ ។ នៅពេលដែលពួកខ្មែរក្រហមបណ្តើរ ខ្ញុំមិនមានការភិតភ័យឡើយ ប៉ុន្តែនៅពេលដែលពួកខ្មែរក្រហមយកខ្នោះមកដាក់ជើងរើលែងរួច «ទើបខ្ញុំស្រក់ទឹកភ្នែក» ។

និយាយដល់ត្រឹមនេះ សំអុល ដកដង្ហើមធំ សម្លឹងមើលកដៃ រួចបន្តទៀតថាៈ «នៅទីនោះវេទនាណាស់ ហូបបាយនឹងស្លឹកជ្រូក ប្រើស្លាបព្រាសំបកគ្រំ ។ រយៈពេល២សប្តាហ៍ដែលខ្ញុំជាប់ឃុំឃាំងនៅមន្ទីរអប់រំព្រៃនេះ សន្តិសុខមន្ទីរអប់រំបានហៅខ្ញុំទៅធ្វើប្រវត្តិរូបចំនួន៣ដង ។ សន្តិសុខម្នាក់បានគោះតុសម្លុតខ្ញុំថាៈ "ពួកអែងហ្នឹងសុទ្ធតែធ្វើស៊ីយ៉ាណាទាំងអស់!" ។ ដោយសារតែពួកខ្មែរក្រហមកំហឹងខ្លាំងពេក ខ្ញុំក៏សារភាពតាមត្រង់ ។ កាលណោះមិនថាខ្ញុំឬអ្នកទោសដទៃទៀតឡើយ ពួកសន្តិសុខហៅមកធ្វើប្រវត្តិរូបម្នាក់ម្តងៗគ្រប់គ្នា ។ ក្នុងពេលធ្វើប្រវត្តិរូបទាំងបីលើក ខ្ញុំបានឆ្លើយកុហកថា"ខ្ញុំគ្មានបងប្អូនទេ" ។ អ្នកទោសមុនៗធ្លាប់ខ្សឹបប្រាប់ខ្ញុំថាៈ បើកាលណាឆ្លើយតាមត្រង់ ពួកខ្មែរក្រហមនឹងមកស្រាវជ្រាវតាមខ្សែយកបងប្អូនទៅទៀត ។ ក្រៅពីការធ្វើប្រវត្តិរូប ពួកសន្តិសុខខ្មែរក្រហមបានឲ្យអ្នកទោសទាំងអស់ចេញទៅធ្វើស្រែ កាប់អុស រែកដី និងរែកទឹក ។ អ្នកទោសធ្វើការមួយថ្ងៃៗគ្មានពេលសម្រាក ហើយឲ្យហូបចុកមិនគ្រប់គ្រាន់ ។

រយៈពេល១ឆ្នាំដែលជាប់ឃុំឃាំង ខ្មែរក្រហមបានបញ្ជូនសំអុល ទៅដាក់នៅមន្ទីរអប់រំពកន្លែងផ្សេងៗគ្នា ។ សំអុលបានមានប្រសាសន៍បញ្ជាក់អំពីការផ្លាស់ប្តូរកន្លែងឃុំឃាំងថាៈ «បន្ទាប់ពីជាប់ឃុំឃាំងនៅមន្ទីរអប់រំព្រៃរយៈពេល២សប្តាហ៍ ខ្មែរក្រហមបានបញ្ជូនអ្នកទោសចំនួន១៥នាក់ រួមទាំងរូបខ្ញុំផងមកដាក់នៅមន្ទីរអប់រំស្នាយពលក្នុងស្រុកពារាំង ខេត្តព្រៃវែង ចំនួន១ថ្ងៃ ដើម្បីបញ្ជូនបន្តទៅមន្ទីរអប់រំព្រៃក្រឡាញ់ ។ អ្នកទោសទាំងអស់ដែលបញ្ជូនពីមន្ទីរអប់រំព្រៃទៅកាន់មន្ទីរអប់រំស្នាយពលពុំមានដាក់ខ្នោះឡើយ គឺខ្មែរក្រហមចងអ្នកទោសនឹងខ្សែអំបោះដោយដាក់បញ្ញត្តិថា "បើអ្នកណាម្នាក់ធ្វើឲ្យដាច់ខ្សែចំណង នឹងបាញ់ចោលភ្លាម!" ។ ប៉ុន្តែសំណាងដែរ ដោយសន្តិសុខគ្រាន់តែដាក់បញ្ញត្តិតែពុំបានអនុវត្ត ព្រោះនៅពេលដើរប្រសិនបើអ្នកណាម្នាក់ដើរលឿនបន្តិច អ្នកនៅបន្ទាប់ត្រូវតែកេះប្រាប់គ្នាថា "កុំដើរលឿនពេក ដាច់ឥឡូវហើយ!" ។ នៅពេលណាខ្សែដាច់ម្តងៗ អ្នកទោសស្រែកទាំងស្ងន់ស្ងោៈ "ជួយៗ! ជួយចងគ្នាវិញ!" ។ ពេលដែលឃើញអ្នកទោសចងចំណងគ្នាឡើងវិញ ពួកខ្មែរក្រហមនាំគ្នាសើចសប្បាយ ។ ដើរមកដល់ភូមិមួយដែលមានប្រជាជនប្រមាណ១០គ្រួសារ ស្ថិតនៅក្នុងស្រុកពារាំង ខេត្តព្រៃវែង ស្រាប់តែប្រជាជននៅក្នុងភូមិប្រដាប់ដោយដំបង កាំបិត ពូថៅ ខ្វះកាន់ចប មកចោមរោមបម្រុងវាយអ្នកទោស ដោយនិយាយទៅកាន់ក្រុមសន្តិសុខថា "មិត្ត! សុំជូរមាន់! ពួកហ្នឹងពួកចក្រពត្តិ! សុំជូរមាន់!" ។ អ្នកទោសទាំងអស់ភ័យញ័រគ្រប់ៗគ្នា ព្រោះខ្លាចប្រជាជនសម្លាប់ ប៉ុន្តែបានសន្តិបាលហាមឃាត់ក៏ស្ងាត់ទៅវិញ ។ ខ្មែរក្រហមបានបណ្តើរអ្នកទោសទាំងអស់ទៅមុខទៀតអស់រយៈពេល៣ថ្ងៃទើបទៅដល់មន្ទីរអប់រំស្នាយពល ។ តាមពិត ចម្ងាយផ្លូវពីមន្ទីរអប់រំព្រៃទៅកាន់មន្ទីរអប់រំស្នាយពលចំណាយពេលតែ១ថ្ងៃប៉ុណ្ណោះ ។ លុះពេលយប់ងងឹត សន្តិសុខបានបណ្តើរអ្នកទោសចាកចេញពីមន្ទីរអប់រំស្នាយពលឆ្ពោះទៅមន្ទីរអប់រំព្រៃក្រឡាញ់ ដែលជាមន្ទីរឃុំឃាំងចុងក្រោយសម្រាប់ខ្ញុំ» ។

សំអុល ជាប់ឃុំឃាំងនៅមន្ទីរអប់រំព្រៃក្រឡាញ់អស់រយៈពេលជិត១ឆ្នាំ រហូតដល់ថ្ងៃ ១៧ មេសា ១៩៧៥ ដែលកងទ័ពខ្មែរក្រហមវាយដណ្តើមបានក្រុងភ្នំពេញ ទើបខ្មែរក្រហមដោះលែងរូបគាត់និងអ្នកទោស៥នាក់ទៀតឲ្យចេញពីមន្ទីរឃុំឃាំងមកធ្វើស្រែចម្ការក្នុងរបបមួយដែលគាត់ឲ្យឈ្មោះថា "គុកឥតជញ្ជាំង" ។

សំអុល បានរំឭកនូវរឿងរ៉ាវទាំងឡាយដែលគាត់ធ្លាប់ជួបប្រទះរយៈពេលជិត១ឆ្នាំនៃការជាប់ឃុំឃាំងនៅមន្ទីរអប់រំព្រៃក្រឡាញ់ថា «កាលដែលខ្ញុំជាប់ឃុំឃាំងនៅមន្ទីរអប់រំព្រៃបាន១សប្តាហ៍ ប្រធានមន្ទីរសន្តិសុខបានហៅអ្នកទោសទាំងអស់មកប្រជុំថាៈ "យើងឡើងទៅលើទៀត ទៅនៅជាមួយប្រជាជន" ។ ខ្ញុំអរណាស់នៅពេលដែលឮថាបានមករស់នៅជាមួយប្រជាជន

ប៉ុន្តែតាមការពិតយកអ្នកទោសមកដាក់នៅមន្ទីរអប់រំព្រែកក្រឡាញ់សោះ ។ មកដល់ទីនេះ ប្រធានសន្តិសុខបាននិយាយថា «យើងមកនេះគឺមកហាត់ពត់លត់ដំ ខំកសាងខ្លួនចាប់ពីថ្ងៃនេះតទៅ» ។ ខ្ញុំចេះតែគិតនៅក្នុងចិត្ត «លត់ដំកសាងខ្លួនរបៀបម៉េច?» ។ ការលត់ដំនៅទីនេះលំបាកវេទនាខ្លាំងណាស់ គឺពួកខ្មែរក្រហមលត់ដំអ្នកទោសតាំងពីដេក តាំងពីដើរ តាំងពីការហូបចុកសព្វបែបយ៉ាង «ដំនោះដំ ដំទាល់តែសល់តែស្បែកហើយនិងឆ្អឹង» ។ ខ្មែរក្រហមបានយកសាលារៀនធ្វើជាមន្ទីរឃុំឃាំង ។ នៅទីនោះមានអ្នកទោសទាំងចាស់ទាំងថ្មីប្រមាណជិត៣០នាក់ ។ ក្នុង១បន្ទប់មានអ្នកទោស៥នាក់ ។ ចំណែកឯរបបហូបចុកក្នុង១ថ្ងៃ២ពេលសម្រាប់ពេលព្រឹកគឺនៅម៉ោង១១ និងពេលល្ងាចនៅម៉ោង៥ ។ ក្នុងមួយពេលៗ អ្នកទោសម្នាក់ៗទទួលបានបបរ១វែក និងសម្លម្ជូរក្តាម១ចានសម្រាប់អ្នកទោស៥នាក់ ។ ក្នុងសម្លមួយចានគឺមានក្តាមមួយចំហៀងនិងបន្លែដើមបន្ទាដំបងយក្ស៥ចំណិត ហើយទឹកសម្លវិញ ដួសបានតែម្នាក់មួយស្លាបព្រាប៉ុណ្ណោះ ។ បបរ១វែកនោះគ្មានចានដាក់ទេ ពីព្រោះ «ចានសម្រាប់ដាក់សម្ល ឯបបរដាក់ក្នុងស្លុកស្លឹកត្នោត» ។ រាល់ពេលដែលចុងភៅដួសបបរដាក់ក្នុងស្លុករួចហើយ ទាំងគេទាំងខ្ញុំត្រូវលើកស្លុកឡើងហុតបបរសិន បើមិនធ្វើដូច្នេះទេបបរដែលមានសុទ្ធតែទឹកនឹងហូរអស់ ។ «ហុតទឹកបបររួចសឹមគិតពីសម្លជាក្រោយ» ។

ព្រឹកព្រលឹមឡើង អនុប្រធានសន្តិសុខបានបែងចែកអ្នកទោសឲ្យធ្វើការទៅតាមផ្នែក អ្នកខ្លះទៅស្ទូង ខ្លះទៅដកសំណាប និងខ្លះទៀតទៅរែកទឹក ។ ប្រធានសន្តិសុខបានហាមប្រាមដល់អ្នកទោសទាំងអស់មិនឲ្យទាក់ទងជាមួយប្រជាជនឡើយ ។ នៅពេលដែលជួបនឹងប្រជាជន មិនត្រូវនិយាយប្រាប់ប្រជាជនពីភាពលំបាកវេទនារបស់ខ្លួនទេ ព្រោះថាទាំងអស់នេះគឺជារឿង «លាក់ការណ៍របស់អង្គការ» ។ អ្វីដែលនឹងត្រូវនិយាយប្រាប់ប្រជាជនគឺ «ហូបចុកគ្រប់គ្រាន់ សុខសប្បាយធម្មតា» ។ ថ្ងៃមួយនៅក្នុងរដូវភ្ជុំបិណ្ឌ ខ្ញុំបានទៅរែកទឹកពីអណ្តូងនៅក្នុងវត្តមួយ ។ ទើបតែទម្លាក់ធុងទៅដល់ក្នុងអណ្តូងស្រាប់តែមានព្រះសង្ឃមួយអង្គនិមន្តមកសួរខ្ញុំថា «ញោមមានអីពីសាទេរាល់ថ្ងៃហ្នឹង?» ។ ខ្ញុំក៏និយាយតាមត្រង់ថា «ករុណាអត់មានអីហូបទេលោកតាបបរ១វែក» ។ ដោយសេចក្តីអាណិត លោកសង្ឃបានយកនំអន្សមជ្រូក៣ឲ្យមកខ្ញុំៈ «ញោមឯងហូបឲ្យស្រួលបួល កុំឲ្យគេឃើញ» ។ ខ្ញុំឃើញនំអន្សមជ្រូកធំៗដូចឃើញមាសពេជ្រ អរណាស់នឹកថា «អញបានមួយពេលនេះគ្រប់ហើយ!» ។ នំមួយដាក់ថ្នក់ នំមួយមួរដាក់ចង្កេះខោ នំមួយកាន់ហូប ។ ទើបតែហែកនំហៀបនឹងដាក់មាត់ ស្រាប់តែមានសន្តិសុខខ្មែរក្រហមម្នាក់មិនដឹងមកពីណា ស្រែកសម្លុតខ្ញុំ «អ្ហែងលួចនំគេស៊ី!» រួចសន្តិសុខនោះវាយខ្ញុំ៤ស្ញ័យកាំភ្លើង ខ្ញុំក៏ដួលផ្កាប់មុខទៅនឹងមាត់អណ្តូង ហើយសន្តិសុខនោះក៏យកនំទៅបាត់ ។ ចំពោះប្រជាជនវិញគឺចង់ឲ្យអ្នកទោសបានហូប ប៉ុន្តែនៅពេលដែលខ្មែរក្រហមឃើញ មិនត្រឹមតែមិនឲ្យយើងហូបទេ ថែមទាំងស្តីបន្ទោសប្រជាជនថែមទៀតៈ «បើមិត្តឯងចង់ឲ្យវាស៊ី មិត្តឯងឲ្យខ្ញុំមុន» ។

កាន់តែនៅចាំមិនភ្លេចទៀតគឺថ្ងៃមួយនោះខ្ញុំបានជួបនឹងបងប្រុសរបស់ខ្ញុំក្នុងពេលដែលសន្តិសុខបណ្តើរខ្ញុំនិងអ្នកទោសដទៃទៀតទៅស្ទូងស្រូវ ។ ពេលបានឃើញបង ខ្ញុំបានស្រែកសួរ «បង! មកពីណា?» ។ ក្រោយពីបងប្រុសខ្ញុំដើរផុតទៅ ខ្មែរក្រហមម្នាក់បានសួរខ្ញុំថា «អ្ហែងសួរអាណាមិញ?» ។ ខ្ញុំតបវិញថា «ខ្ញុំសួរបងខ្ញុំ!» ។ ដាំង១១! ខ្មែរក្រហមរូបនោះបានវាយខ្ញុំ៣ស្ញ័យកាំភ្លើង ហើយព្រមានថា «ថ្ងៃក្រោយកុំណា! បើអ្ហែងចង់សួរវា សួរអញមុនសិន» ។ សន្តិសុខខ្មែរក្រហមនៅកន្លែងនោះសុទ្ធតែក្មេងៗ ដែលមានអាយុពី១៦ទៅ១៧ឆ្នាំតែប៉ុណ្ណោះ ប៉ុន្តែអ្នកទោសគ្មានកម្លាំងនឹងតទល់ឡើយ ។ ដូចជារូបខ្ញុំនេះជាដើម ឲ្យតែចេញទៅវាលហើយមានខ្យល់បក់ខ្លាំង


ហ៊ុយ វណ្ណៈ នៅខេត្តមណ្ឌលគិរី

បន្តិច បើដើរមិនប្រយ័ត្នទឹងដួលភ្លាម ។

អ្នកទោសទាំងអស់ដែលជាប់នៅក្នុងមន្ទីរឃុំព្រែកក្រឡាញ់ មានរាងសនាមិនខុសគ្នាប៉ុន្មានឡើយ គ្រាន់តែយូរនិងឆាប់ប៉ុណ្ណោះ ហើយម្នាក់ៗគិតតែពីបញ្ហា"ស្លាប់ហើយនិងរស់" ។ អ្នកទោសមួយចំនួនបានស្លាប់បាត់បង់ជីវិតដោយសារតែ"ជំងឺហើម" ដែលបណ្តាលមកពី"កង្វះចំណីអាហារ" និងមួយចំនួនទៀតស្លាប់ដោយសារតែ"ចង់លួចរត់" ។

សំអុល អះអាងបញ្ជាក់ទៅលើមូលហេតុនៃការស្លាប់បាត់បង់ជីវិតរបស់អ្នកទោសទាំងពីរករណីខាងលើថា "អ្នកទោសមួយចំនួនគ្មានកម្លាំងនឹងចេញទៅធ្វើការ ដោយសារតែការផ្តល់អាហារមិនគ្រប់គ្រាន់...ដេកយូរទៅកើតមានជំងឺហើមហូរទឹករងៃ ។ យប់មួយនោះអ្នកទោស៥នាក់បាននាំគ្នាគាស់ទ្វារគុកលួចរត់ ។ ចៃដន្យអី មេកងបានដឹងរឿងនេះក៏ទៅរាយការណ៍ប្រាប់ប្រធានសន្តិសុខ ។ ព្រលឹមឡើង ប្រធានសន្តិសុខហៅអ្នកទោសទាំងអស់មកប្រជុំ ហើយសួរថា "មើល! អាណាខ្លះចង់លួចរត់យប់មិញ?" ។ អ្នកទោសទាំងអស់បាននាំគ្នាឆ្លើយថា "អត់ដឹងទេ" ។ ប្រធានសន្តិសុខសម្តុតថា "យើស! ពួកអ្នែងសុទ្ធតែត្រូវដើងគ្នា ពួកអ្នែងចង់រត់?" ។ ប៉ុន្តែអ្វីៗគ្រប់យ៉ាងប្រធានសន្តិសុខបានដឹងទាំងអស់ ព្រោះថាមេកងដែលបានដឹងរឿងនេះគឺជាអ្នកទោសដែលប្រធានសន្តិសុខចាត់តាំងឲ្យឃ្លាំមើលនិងរាយការណ៍អំពីសកម្មភាពរបស់អ្នកទោស ។ នៅពេលថ្ងៃ មិនដឹងថាមេកងរូបនេះទៅធ្វើការនៅកន្លែងណាឡើយ ប៉ុន្តែពេលយប់មកដេកនៅក្នុងគុកជាមួយអ្នកទោសដែរ ។ បញ្ចប់ការប្រជុំ ប្រធានសន្តិសុខបានបញ្ជាឲ្យក្រុមសន្តិសុខចាប់អ្នកទោសទាំង៥នាក់ចងស្លាបសេក ហើយយកក្រណាត់ខ្មៅចងមុខ រួចបណ្តើរចេញទៅខាងក្រោយគុកប៉ែកខាងត្បូង ។ ចំណែកឯអ្នកទោសដទៃទៀតដែលមិនមានជាប់ពាក់ព័ន្ធ ត្រូវត្រឡប់ចូលក្នុងគុកវិញ ។ ប្រធានសន្តិសុខបានមកបិទទ្វារគុកហើយដាក់បញ្ញត្តិថា "បើឮសូរគ្រាប់កាំភ្លើង មានអ្នកណាម្នាក់ជ្រួលច្របល់ នឹងបាញ់ចោល" ។ មួយស្របក់ក្រោយមក ខ្ញុំឮប្រធានសន្តិសុខរាប់ "១! ២! ៣!" ស្នូរកាំភ្លើងប្រាវ ។ មិនឮសម្លេងអ្នកទោសស្រែកអ្វីបន្តិចសោះ ពេលក្រឡេកទៅខាងមុខស្រាប់តែឃើញសម្លៀកបំពាក់របស់សាកសពអ្នកទោសទាំង៥នាក់ហាលនៅលើរបង ។

គួរឲ្យអាណោចអាធ័មជាងនេះទៀត បន្ទាប់ពីខ្ញុំបានមកជាប់ឃុំឃាំងនៅព្រែកក្រឡាញ់អស់រយៈពេល៣ខែ ខ្ញុំបានឃើញខ្មែរក្រហមអារ-កអ្នកទោស៣នាក់នឹងផាងគ្នោតនៅចំពោះមុខខ្ញុំនិងអ្នកទោសដទៃទៀត ។ ខ្មែរក្រហមមួយក្រុមបានទៅចាប់អ្នកទោសទាំង៣នាក់ដែលត្រូវជាមិត្តរបស់ខ្ញុំ ពីមន្ទីរអប់រំព្រែករៃបញ្ជូនមកសម្លាប់នៅមន្ទីរអប់រំព្រែកក្រឡាញ់ ដោយដឹងថាអ្នកទោសទាំងបីនាក់នេះលួចរត់ចេញពីគុក" ។

សំអុល បានបញ្ជាក់ថាៈ "ការសម្លាប់អ្នកទោសប្រព្រឹត្តខុសនឹងវិន័យរបៀបនេះ គឺជាវិធីព្រមានមួយដើម្បីកុំឲ្យអ្នកទោសផ្សេងទៀតយកតម្រាប់តាម" ។

សំអុល បានមានប្រសាសន៍ចុងក្រោយថាៈ "ដរាបណាខ្ញុំនៅរស់រានមានជីវិត ដរាបនោះខ្ញុំនៅតែនឹកឃើញជានិច្ចអំពីទារុណកម្មទាំងឡាយដែលពួកខ្មែរក្រហមបានប្រព្រឹត្តមកលើរូបខ្ញុំ ។ ខ្ញុំឆ្ងល់ថាអ្នកទាំងនោះចេះនិយាយភាសាខ្មែរដូចខ្ញុំដែរ ប៉ុន្តែហេតុអ្វីបានគេសម្លាប់ខ្មែរដូចគ្នា? ជារៀងរាល់រដូវបុណ្យភ្ជុំម្តងៗ ខ្ញុំតែងតែនឹកឃើញដល់ខែបុណ្យភ្ជុំកាលពី២៥ឆ្នាំមុន ដែល"ខ្ញុំឃុំក្នុងគុក" ។

**ហ៊ុយ វណ្ណៈ**

## ពាក្យស្លោកខ្មែរក្រហម

### អំពីការលើកតម្កើងជីវភាពប្រជាជន

◆ អនុវត្តអោយបានដាច់ខាតរបបស្បៀងអាហារដែលបក្សកំណត់ពីដើមដល់ចុងឆ្នាំ ។

◆ កម្មាភិបាលល្អនិងគណៈកម្មាធិការល្អគឺស៊ុះស្វាញដោះស្រាយនិងលើកស្ទួយជីវភាពមហាជនបានល្អគ្រប់ផ្នែកនិងគ្រប់ពេលវេលា ដោយគោលជំហរទទួលខុសត្រូវនិងច្នៃប្រឌិតគំនិតផ្តើមខ្ពស់ ។

◆ វាយសំរុកថែបំប៉នជីវភាពប្រជាជនអោយបានល្អនិងកើនចំរើនឡើងឆាប់រហ័សជានិច្ច ទៅព្រមនិងការបំពាក់បំប៉នជាមូលដ្ឋានខាងនយោបាយ ។

*(សៀវភៅកំណត់ហេតុលេខ ០៧៦)*

# បុណ្យភ្ជុំៈ សូមឧទ្ទិសដល់វិញ្ញាណក្ខន្ធជីតានិងឪពុកមារបស់ខ្ញុំ


គីម កែវកន្និដ្ឋា

កាលនៅពីក្មេងម្តាយរបស់ខ្ញុំបាននិយាយប្រាប់ខ្ញុំថា គាត់មានឪពុកមាម្នាក់ឈ្មោះ ចិន សេង ដែលត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោល ដោយសារគាត់ជាទាហានពាក់សក្តិ៥ក្នុងរបបសាធារណរដ្ឋខ្មែរ ។ ចិន សេង គឺជាជីតារបស់ខ្ញុំ ។ ម្តាយមីងខ្ញុំម្នាក់ឈ្មោះ ចិន ស្រីទូច ដែលជាកូនរបស់លោកតា ចិន សេង ហើយក៏ជាអ្នកដែលបានរស់នៅជាមួយលោកតារហូតដល់ពេលដែលលោកតាត្រូវបានខ្មែរក្រហមយកទៅសម្លាប់ក្រោមរូបភាពហៅទៅ "រៀនសូត្រ" បាននិយាយថា លោកតាខ្ញុំគឺជាទាហានដ៏អង់អាចម្នាក់ ។ នៅពេលដែលលោកតាខ្ញុំមានវ័យចំណាស់ គាត់បានទទួលតួនាទីជាមេបញ្ជាការហ្វឹកហ្វឺនយោធានៅខេត្តតាកែវ ។ ក្នុងខណៈដែលទីក្រុងភ្នំពេញទទួលរងនូវការវាយលុកយ៉ាងខ្លាំងពីសំណាក់យោធាខ្មែរក្រហមនៅដើមឆ្នាំ១៩៧៥ លោកតាខ្ញុំបានទទួលបញ្ជាមកការពារខ្សែក្រវាត់ទីក្រុងភ្នំពេញ ។ គាត់បានមកភ្នំពេញដោយទុកចោលកូនប្រុសម្នាក់ឈ្មោះ ចិន ស៊ីឌិន ឲ្យរស់នៅខេត្តតាកែវតែម្នាក់ឯង ដោយមូលហេតុថា កូនប្រុសនោះជាប់រវល់សិក្សានិងត្រូវមើលថែទាំផ្ទះសម្បែងផង ។ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ លោកតានិងក្រុមគ្រួសារត្រូវបានយោធាខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ធ្វើដំណើរដោយដើងមកដល់ក្រែក ខេត្តកំពង់ចាម ។ លោកតាក៏បានសុំអង្គការខ្មែរក្រហមរស់នៅទីនោះ ។ គាត់បានប្តូរឈ្មោះរបស់គាត់ ហើយបានប្រាប់អ្នកស្រុកថាគាត់មានមុខរបរជាអ្នកលក់ធ្យូង ។ លោកតាមានកូនចិញ្ចឹមម្នាក់ដែលលោកតាបាននាំទៅជាមួយដែរនៅក្នុងពេលជម្លៀស ។

លោកតាខ្ញុំរស់នៅក្នុងខេត្តកំពង់ចាមរហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៦ ទើបត្រូវប្រធានភូមិហៅទៅរៀនសូត្រជាមួយអ្នកភូមិ២នាក់ទៀត ។ កន្លងប្រហែល១អាទិត្យក្រោយមក មានក្មេងឃ្វាលគោម្នាក់មកប្រាប់លោកយាយខ្ញុំថាឃើញសាកសពមនុស្សប្រុស៣នាក់នៅក្នុងព្រៃជ្រៅ ។ ថ្វីដ្បិតតែមានការសង្ស័យថាក្នុងចំណោមសាកសពទាំងបីនាក់នោះមានលោកតាខ្ញុំម្នាក់ដែរ យ៉ាងណាក៏ដោយ ក៏គ្មាននរណាម្នាក់ហ៊ានទៅមើលសាកសពទាំងបីនោះឡើយ ។ ចាប់តាំងពីពេលនោះមក លោកតារបស់ខ្ញុំក៏បាត់ដំណឹងសូន្យឈឹងរហូតមកដល់សព្វថ្ងៃនេះ ។

ចំណែកលោកពូ ចិន ស៊ីឌិន ក្រោយថ្ងៃ១៧មេសា គាត់ត្រូវជម្លៀសមករស់នៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ។ ម្តាយមីងរបស់លោកពូ ចិន ស៊ីឌិន ឈ្មោះ ហ៊ាង ដែលរស់នៅក្នុងខេត្តតាកែវ បាននិយាយថា ពូ ស៊ីឌិន ត្រូវបានអង្គការចាប់ខ្លួននៅឆ្នាំ១៩៧៨ ដោយគ្មាននរណាម្នាក់ដឹងសោះថាមកពីមូលហេតុអ្វីនិងបានទទួលវាសនាយ៉ាងណានៅពេលក្រោយមក ។ លោកពូខ្ញុំក៏បាត់ដំណឹងរហូតតាំងពីពេលនោះមកដែរ ។

ខ្ញុំជាអ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្នុងពេលអានឯកសារខ្មែរក្រហមដែលបន្សល់ទុកនៅគុកក្រាំងតាចាន់ ខេត្តតាកែវ ខ្ញុំបានប្រទះនូវចម្លើយសារភាពរបស់ឪពុកមាខ្ញុំ ។ វាជារឿងមួយគួរឲ្យតក់ស្លុតនិងសង្វេគណាស់ ។ ចម្លើយសារភាពដែលសរសេរថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៧៨ លោកពូ ស៊ីឌិន បានប្រាប់ឈ្មោះនិងតួនាទីរបស់លោកតាខ្ញុំ ។ ដោយសារតែលោកតារបស់ខ្ញុំស្លាប់មុនពេលចាប់ខ្លួនលោកពូ ស៊ីឌិន ទើបចម្លើយសារភាពមិនមានផលប៉ះពាល់ដល់ការចាប់ខ្លួនលោកតារបស់ខ្ញុំទេ ។ ប៉ុន្តែ ប្រសិនបើលោកតានៅមានជីវិតរស់នៅឡើយក្រោយពេលចាប់ខ្លួលោកពូរបស់ខ្ញុំនោះ ចម្លើយសារភាពនេះពិតជាផ្តល់លទ្ធភាពឲ្យអង្គការចាប់ខ្លួនលោកតាក្រោមគោលនយោបាយបោសសម្អាតខ្សែរយៈខ្លាំងផ្ទៃក្នុងក្រោមទ្រឹស្តី "ជីកស្មៅត្រូវជីកទាំងឫស" ដើម្បីប្រែក្លាយសង្គមខ្មែរឲ្យទៅជាសង្គមមួយដែលបរិសុទ្ធមួយរយភាគរយ ។ លោកពូ ស៊ីឌិន ដែលត្រូវបានបង្ខំឲ្យឆ្លើយសារភាពរួចហើយនោះ

ក៏ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោល ។ សាច់ញាតិរបស់ខ្ញុំដែលនៅរស់ដល់សព្វថ្ងៃ ប្រហែលជានឹងមានវិប្បដិសារីប្រសិនបើចម្លើយសារភាពរបស់លោកពូខ្ញុំបានធ្វើឲ្យជីតារបស់ខ្ញុំបាត់បង់ជីវិត ។


លោកតា ចិន សេង ទសវត្សរ៍ឆ្នាំ១៩៦០

ក្នុងចម្លើយសារភាព លោកពូ ចិន ស៊ីឌិន បានសរសេរថា គាត់បានដឹកនាំសកម្មភាពក្បត់អង្គការ ដោយបំផ្លាញសម្ភារ ដូចជា ចប បង្គី កាំបិត ពូថៅ ដែលមានមនុស្ស ៦នាក់ទៀតចូលរួម ហើយគាត់តែងតែបន់ស្រន់ឲ្យបដិវត្តន៍ខ្មែរក្រហមដួលរលំ ដើម្បីប្រែក្លាយរបបសមូហភាពទៅជារបបឯកជនវិញ ។ មិនតែប៉ុណ្ណោះ លោកពូខ្ញុំថែមទាំងនិយាយទៀតថា គាត់គឺជាទាហានពាក់សក្តិ២ក្នុងរបបសាធារណរដ្ឋខ្មែរ ។

គុកក្រាំងតាចាន់មានទីតាំងស្ថិតនៅក្នុងភូមិត្រពាំងលៀន ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ ។ ក្នុងបរិវេណគុកក្រាំងតាចាន់ មានរណ្តៅសាកសពរួមចំនួន២១ ដែលផ្ទុកអ្នកស្លាប់ប្រមាណ ១០០៨២នាក់ ។ កម្មាភិបាលខ្មែរក្រហមសួរចម្លើយតែងតែធ្វើទារុណកម្មឬប្រើមធ្យោបាយបោកប្រាស់ផ្សេងៗចំពោះអ្នកទោស ដែលខ្មែរក្រហមហៅថា «វិធីក្តៅ» ដើម្បីទទួលបាននូវចម្លើយសារភាពដែលខ្លួនបានដៅទុកជាមុនថាជាការពិត ។

នៅពេលអានចម្លើយសារភាពរបស់ឪពុកមាខ្ញុំនេះ ខ្ញុំតែងសួរខ្លួនឯងថាតើនៅក្នុងគុក គាត់បានជួបប្រទះរឿងអ្វីខ្លះ? អ្នកសួរចម្លើយបានប្រើទារុណកម្មកម្រិតណា ឬមធ្យោបាយបោកប្រាស់បែបណា ដែលធ្វើឲ្យគាត់សរសេរចម្លើយសារភាពនេះឡើង? តើគាត់រងការឈឺចាប់បែបណា?

តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានប្រជាជនខ្មែរ ប៉ុន្មាននាក់ទៀតដែលបានឆ្លើយសារភាពនូវមុខតំណែងរបស់សមាជិកគ្រួសារ ដោយសារការធ្វើទារុណកម្មដ៏ឃោរឃៅ និងឧបាយកលបោកប្រាស់របស់កម្មាភិបាលសួរចម្លើយ? ចម្លើយសារភាពទាំងនេះហើយដែលជាមូលហេតុបណ្តាលឲ្យមានមនុស្សជាច្រើនត្រូវស្លាប់ដោយអយុត្តិធម៌ ។

ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ក្រុមគ្រួសារនាងខ្ញុំមានជំនឿថា ព្រលឹងអ្នកដែលបានចែកឋានទៅទាំងឡាយ នឹងមកកាន់ទីវត្តអារាមដើម្បីទទួលនូវចំណីអាហារដែលសាច់ញាតិបងប្អូនកូនចៅផ្តល់ឲ្យតាមរយៈការយកទៅប្រគេនព្រះសង្ឃ ។ ជាង២០ឆ្នាំកន្លងទៅនេះ ព្រលឹងជនរងគ្រោះដែលបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានមកវិលវល់នៅទីវត្តអារាមមិនមែនគ្រាន់តែដើម្បីទទួលចំណីអាហារតែប៉ុណ្ណោះឡើយ គឺទាមទារនូវយុត្តិធម៌មួយបន្ថែមទៀត ។

វិញ្ញាណក្ខន្ធរបស់ជនរងគ្រោះទាំងឡាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពិតជាមិនអាចទៅកាន់សុគតិភពបានឡើយ ដរាបណាយុត្តិធម៌មួយមិនទាន់ត្រូវបានផ្តល់ឲ្យ ។ លោកតានិងលោកពូរបស់ខ្ញុំជាជនរងគ្រោះនៃរបបខ្មែរក្រហម ។ ខ្ញុំសូមឧទ្ទិសវិញ្ញាណក្ខន្ធគាត់ទាំងពីរឲ្យបានទៅកាន់សុគតិភព ។ **គឹម កែវកន្និដ្ឋា**

**ឯកសារក្រាំងតាចាន់ លេខ D ១៦៨**



# ដំណឹងស្វែងរកក្មួយ

នាងខ្ញុំឈ្មោះ អាំ លន់ អាយុ៧០ឆ្នាំ សព្វថ្ងៃរស់នៅភូមិតាលាវ៍ ឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ។

**សូមគោរពចូលមក**

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលស្វែងរកការពិតជាទីគោរព

សូមលោកនាយកមេត្តាជួយស្រាវជ្រាវរកឈ្មោះរបស់ក្មួយនាងខ្ញុំដោយក្តីអនុគ្រោះ គឺឈ្មោះ សា សុន ហៅ សំណាង (ឈ្មោះហៅក្នុងគ្រួសារហៅថា គង់) ។

សា សុន ហៅ គង់ ហៅ សំណាង បានកើតនៅភូមិតាលាវ៍ ឃុំស្វាយរៀង ស្រុកស្វាយរៀង (បច្ចុប្បន្នឃុំស្វាយតឿ ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង) ។ សា សុន កើតនៅឆ្នាំរការ បើគិតមកដល់ដល់សព្វថ្ងៃនេះមានអាយុ៥៧ឆ្នាំហើយ ។ មានឪពុកឈ្មោះ សា សន ធ្លាប់ធ្វើទាហានសម័យសង្គមរាស្ត្រនិយម និងមានទីលំនៅនៅស្រុកអាចម៍រមាស ខេត្តកំពង់ឆ្នាំង តាំងពីសម័យនោះរហូតមកដល់ថ្ងៃបាត់ខ្លួនទាំងក្រុមគ្រួសារនាសម័យកម្ពុជាប្រជាធិបតេយ្យ ។ មានម្តាយឈ្មោះ អាំ សុខ មុខរបរមេផ្ទះ ។ នៅក្នុងអំឡុងទសវត្សរ៍ទី៦០ សា សុន បានទៅសិក្សានៅប្រទេសបារាំងមានរយៈពេល៤ឆ្នាំ (តែមិនដឹងជំនាញ) ។

លុះដើមឆ្នាំទសវត្សរ៍ទី៧០ សា សុន បានចូលមកក្នុងស្រុកខ្មែរវិញ ។ ដល់ឆ្នាំ១៩៧៣(?) សា សុន ត្រូវបានទៅរៀននៅស្រុកបារាំងជាថ្មី ។ ប៉ុន្តែការសិក្សាលើកនេះបានប្រហែល៣-៤ខែត្រូវបានរដ្ឋាភិបាលបារាំងដេញឲ្យមកស្រុកខ្មែរវិញ (នាងខ្ញុំមិនដឹងមូលហេតុ) ។ បន្ទាប់មក សា សុន ត្រូវបានបង្រៀននៅក្នុងសាលាមួយកន្លែងក្នុងក្រុងភ្នំពេញ (នាងខ្ញុំមិនស្គាល់សាលា) ។ ការបង្រៀននេះបាន២-៣ខែ សា សុន ត្រូវបានចាប់ខ្លួនដោយរដ្ឋាភិបាល លន់ ណុល ពីបទពាក់ព័ន្ធឃាតកម្មលើរូបលោក កែវ សង់គឹម និង ថាច់ ជា ។ ក្រោយមកទៀត សា សុន ត្រូវបានជាប់គុកនៅព្រៃស (សម័យ លន់ ណុល) ។ ក្រោយថ្ងៃរំដោះ ឆ្នាំ១៩៧៥ សា សុន ត្រូវបានអង្គការខ្មែរក្រហមឲ្យទៅកាន់កាប់នៅតំបន់ព្រែកពោធិ៍ ត្រើយខាងកើតជ្រោយចង្វារ ។ លុះឆ្នាំ១៩៧៨(?) សា សុន ត្រូវបានអង្គការហៅចូលមកក្រុងភ្នំពេញទាំងគ្រួសារ ហើយបាត់ដំណឹងសូន្យសុងរហូតមកដល់សព្វថ្ងៃនេះ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូមលោកនាយកមេត្តាស្រាវជ្រាវនិងផ្តល់ជូនពត៌មានឲ្យបានដឹងដល់ញាតិមិត្តរបស់ជនរងគ្រោះខាងលើនេះផង ។ សូមលោកនាយកទទួលនូវសេចក្តីគោរពអំពីនាងខ្ញុំ ។ ទូរស័ព្ទ(១០៦) ៨៥៩ ៣៥៨ ។

# លិខិតថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ យុន កុលភាវតី សព្វថ្ងៃរស់នៅខេត្តស្វាយរៀង ។ សូមមានសេចក្តីអំណរគុណដល់លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកការពិត និងអស់លោក-លោកស្រីជាសហការី ដែលលោកបានខិតខំស្រាវជ្រាវរកឃើញអត្តសញ្ញាណរបស់លោកឪពុកនាងខ្ញុំដែលអង្គការខ្មែរក្រហមបានចាប់យកមកសម្លាប់នៅគុកទួលស្លែង (ស-២១) ។

ជាមួយសេចក្តីថ្លែងអំណរគុណនេះ នាងខ្ញុំសូមជូនពរដល់លោកនាយកផងដែរថា នៅលេខខាងមុខនេះក្នុងទស្សនាវដ្តីរបស់លោក សូមលោកនាយកមេត្តាចុះផ្សាយនូវរូបថតនិងកំណត់ហេតុសួរចម្លើយរបស់លោកឪពុកនាងខ្ញុំដែលបានបង្កើតឡើងដោយភ្នាក់ងាររបស់ ស-២១ ឲ្យនាងខ្ញុំបានឃើញនិងបានដឹងផង ។ នាងខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា លោកនាយកនឹងបំពេញតាមសំណូមពរដល់រូបនាងខ្ញុំក៏ដូចពលរដ្ឋខ្មែរយើងទូទៅដែលចង់ដឹងការពិត ។ សូមលោកនិងសហការីទាំងអស់ជួបនូវសេចក្តីសុខនិងប្រកបដោយសុវត្ថិភាពគ្រប់ទិវារាត្រី ។ សូមអរគុណ ។




ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់នៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 21, September 2001.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; Canadian International Development Agency (CIDA) through the Civil Society Fund; the Royal Danish Government and the Royal Netherlands Government, *The Hague*.